ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 22-May-2013, 14:53
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៣**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី១៧៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី *(Ms.Faiza ZOUAKRI)*

លោក ស៊ីម៉ុន មេសិនប៊ឺជ

*(Mr.Simon MEISENBERG)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ត់

លោក ឃីត រេយ៍ន័រ *(Mr. RAYNOR Keith)*

លោក ថារីក អាប់ឌុលឡាក់

*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ(*Mr.Victor KOPPE*)

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ូនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ុច សុវណ្ណារី

លោក សំ សុគង់

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធារី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ហ្វីលីព ស្បួត (TCE-65) | អង់គ្លេស |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅអ្នកជំនាញ៖ លោក ហ្វីលីព សុរ្ត** (TCE-65)

សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ....................ទំព័រ ១
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី....................ទំព័រ ២៩
សួរដោយលោក គង់ សំអុន ផ្តើមពី ....................ទំព័រ ៨៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:២៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ លោក ឌុច ផារី ឡើងរាយការណ៍ អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុង កិច្ចដំណើរសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការថ្ងៃនេះគ្រប់ភាគីទាំងអស់នេះនៃរឿងក្ដីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដោយមូលហេតុបញ្ហាសុខភាពរបស់គាត់។ រីឯអ្នកជំនាញលោក ហ្វីលីព ស្ហត មានវត្តមាននៅក្នុងបន្ទប់សវនាការ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោក ផារី។ ជាបន្តអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញរូបនេះ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម សូមគោរពសហការី អស់លោក លោកស្រីទាំងអស់។ ហើយសូមគោរពលោកអ្នកជំនាញ។ ខ្ញុំនឹងសួរលោកក្នុងរយៈពេលមួយម៉ោងកន្លះទៀត។ តាមពិតខ្ញុំត្រូវការមួយថ្ងៃកន្លះ ប៉ុន្តែខ្ញុំមិនអាចមានពេលច្រើនលើកនោះទេ។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំនឹងចូលទៅដល់ប្រធានបទដែលខ្ញុំបានសួរលោកកាលពីម្សិលមិញ។ នេះជាប្រធានបទមួយសំខាន់។ ដោយសារថាវាពាក់ព័ន្ធទៅនឹងផ្នែកទី១នៃសវនាការនេះ គឺការសម្លាប់មន្ត្រី លន់ នល់ និងទាហាន លន់ នល់។ លោកអ្នកជំនាញ ខ្ញុំសូមរំឭកឡើងវិញអំពីសក្ខីកម្មកាលពីម្សិលមិញ និងពីម្សិល

ម៉ៅ។ លោកបានផ្តល់សក្ខីកម្មអំពីគោលនយោបាយនៅក្នុងរបបបក្សកុម្មុយនីស្តកម្ពុជានៅឆ្នាំ១៩៧៥ -- មុនឆ្នាំ១៩៧៥ ពាក់ព័ន្ធនឹងការសម្លាប់មន្ត្រីរបបលន់ នល់។ មិនមានភស្តុតាងផ្ទាល់បង្ហាញអំពីបញ្ហានេះទេ ហើយក៏មិនមានឯកសារណាមួយដែលបង្ហាញអំពីអ្វីដែលលោកហៅថា វាជាការសម្លាប់ជាប្រព័ន្ធ។ ឧបទ្ទវហេតុដែលកើតឡើងជាប្រព័ន្ធនោះ។

តើខ្ញុំអាចនិយាយបានទេថា ភស្តុតាងជាក់លាក់មួយចំនួន ឬសំខាន់បំផុតនោះគឺថាវាបានមកពីសាក្សីដែលបានផ្តល់សក្ខីកម្មដែលបាននិយាយថា ពួកគេបានឃើញព្រឹត្តិការណ៍ទាំងនោះ តែមិនបានមកពីកម្មាភិបាលខ្មែរក្រហមដែលបានចូលរួមសម្លាប់ដោយផ្ទាល់នោះទេ។ តើលោកអាចបកស្រាយចំណុចនេះបានទេ?

[០៩:០៥:៥៥]

**ឆ៖** ជាទូទៅ គឺថាវាជាការពិតហើយ។ វាមានភស្តុតាងពីទាហានខ្មែរក្រហម ឬកម្មាភិបាលខ្មែរក្រមដែលពាក់ព័ន្ធក្នុងបញ្ហានេះដែរ។

**ស៖** តើខ្ញុំអាចស្វែងរកភស្តុតាងណាមួយបានទេនៅក្នុងសៀវភៅរបស់លោកនោះ?

**ឆ៖** លោកអាច -- ភី ភួន គឺថាជាប្រភពសាក្សីដែលអាចឆ្លើយទៅបាន។ គាត់ចូលរួមនៅក្នុងរតនគិរី១៩៦៨ ដែលបាននិយាយថា "វាជាគោលនយោបាយប្រឆាំងចំពោះខ្មាំង"។ ហើយគេយល់ជាទូទៅដូចគាត់អ៊ីចឹង។ ចំណុចមួយដែលខ្ញុំចង់បញ្ជាក់ជូនលោកនោះគឺ យើង -- លោកលើកឡើងយ៉ាងច្រើនអំពីអវត្តមាននៃឯកសារភស្តុតាង ប៉ុន្តែបើយើងនិយាយអំពីស្មារតីនយោបាយ កាលណាលោកនិយាយអំពីខ្សែបន្ទាត់នយោបាយ គឺថាត្រូវតែកំណត់ឲ្យច្បាស់រវាងខ្មាំងហើយនិងយើង។ គោលនយោបាយកម្ទេចខ្មាំងគឺជាគោលនយោបាយនិយាយការប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់រៀងរាល់ពេល។ ទី១ គឺថាត្រូវតែៗកាត់ផ្តាច់បេះដូងរបស់យើងចូលរួមជាមួយនឹងបក្ស។ នេះគេយល់ៗជាទូទៅ គឺថាអ៊ីចឹងឯងមិនមែនជាកុម្មុយនីស្តសូវៀត មិនមែនជាកុម្មុយនីស្តចិន ដែលថាពាក្យពេចន៍ជាលាយលក្ខណ៍អក្សរវាមានសារសំខាន់នោះទេ។ វាជាកុម្មុយនីស្តខ្មែរ គឺថាកុម្មុយនីស្តខ្មែរនេះ ជាទូទៅគឺគោលនយោបាយ ឬអ្វីៗនោះ គេបញ្ជូនតែទៅតាមមាត់តែប៉ុណ្ណោះ។ ដូច្នេះ វាមិនដូចបក្សកម្មុយនីស្តចិននោះទេ។

[០៩:០៨:១០]

**ស៖** លោក ហ្វីលីព ស្សត នេះជាការពិតហើយ ជាគោលនយោបាយដែលបានបញ្ជូនដោយផ្ទាល់មាត់ ឬក៏ត្រូវបានគេយល់ថាវាត្រូវធ្វើអ៊ីចឹង។ ខ្ញុំសូមសួរលោកដូចតទៅ ខ្ញុំថា -- ខ្ញុំយល់ឃើញថា

សហព្រះរាជអាជ្ញាបានសួរលោកហើយអំពីៗការផ្សព្វផ្សាយតាមប្រព័ន្ធវិទ្យុផ្សាយសំឡេង។ ដែលពេលនោះ គេអំពាវនាវឲ្យសម្លាប់មហាក្បត់ទាំងប្រាំពីរនាក់។ ការផ្សព្វផ្សាយនេះ គឺច្បាប់លាស់ហើយ ចំពោះមនុស្សប្រាំពីរនាក់នោះ។ ប្រហែលជាមានបន្ថែមទៅលើលើសពីមនុស្សប្រាំពីរនាក់នេះទៀត។ បើសិនណាជាមានការបញ្ជាគោលនយោបាយនោះទៅតាមផ្ទាល់មាត់បែបនេះ ខ្ញុំមិនយល់ថាតើកម្មាភិបាលថ្នាក់ទាប ឬថ្នាក់កណ្តាលហ្នឹង អាចនឹងមានភាពច្របូកច្របល់ច្រំឡំ ថាតើត្រូវធ្វើយ៉ាងម៉េចជាមួយមន្ត្រីរដ្ឋកាល លន់ នល់ និងជាមួយទាហាន លន់ នល់។ ពីព្រោះទី១ និយាយថាត្រូវតែសម្លាប់តែពួកមហាក្បត់ប្រាំពីរនាក់ទេ។ វាអាចន័យនេះគឺថាមិនច្បាស់លាស់ អាចហេតុដូច្នេះអ្នកដទៃទៀតថាមិនត្រូវប៉ះពាល់នោះទេ។ សំណួររបស់ខ្ញុំសួរថា តើលោកដែលបានសាកសួរអតីតកម្មាភិបាលខ្មែរក្រហមអំពីការច្រឡំ ឬភាពច្របូកច្របល់អំពីគោលនយោបាយនេះ។ ទី១ សេចក្តីថ្លែងការណ៍ជាសាធារណៈដែលផ្តោតតែចំពោះពួកមហាក្បត់ទាំងប្រាំពីរនាក់ ប៉ុន្តែម្យ៉ាងវិញទៀត គឺថាសារនេះវាអាចថានឹងអាចឲ្យគេធ្វើលើសពីនេះតទៅទៀត។ តើលោកយល់អំពីសំណួរខ្ញុំទេ?

[០៩:១០:០៥]

**ឆះ** យើងនិយាយអំពីសារទៅកាន់មនុស្សពីរប្រភេទ។ ទាហានខ្មែរក្រហមមិនស្តាប់វិទ្យុផ្សាយសំឡេងរបស់រណសិរ្សរួបរួមជាតិនោះទេ។ គេស្តាប់មេគេផ្ទាល់ ស្តាប់មេបញ្ជាការគេផ្ទាល់។ ខ្លឹមសារដែលលោកនិយាយយោងនេះគឺសម្រាប់ប្រជាជននៅក្នុងទីក្រុងភ្នំពេញ។ ដូចបានពិភាក្សាពីខាងដើមមកហើយគឺថាវាមានមុខពីរ។ ទី១ គឺសម្លាប់ពួកមហាក្បត់ទាំងប្រាំពីរ ប៉ុន្តែក្នុងនោះដើម្បីឲ្យអ្នកដទៃទៀតចូលរួមជាមួយនឹងបដិវត្តន៍បើសិនណាជាអ្នកឯងមកចូលរួមជាមួយបដិវត្តន៍ភ្លាមៗ*(ឮមិនច្បាស់)* សារហ្នឹង និយាយថាអ៊ីចឹង។ នោះអ្នកទាំងអស់គ្នាគឺថាបដិវត្តន៍នឹងស្វាគមន៍ ប៉ុន្តែន័យមួយទៀតថាបើមិនចូលរួមភ្លាមៗនោះទេគឺថាអ្នកឯងអាចស្ថិតនៅក្នុងចំណាត់ថ្នាក់នៃប្រភេទមហាក្បត់ទាំងប្រាំពីរនាក់នេះហើយ។ នេះពួកនរកនៅតាមទីជនបទគេអាចយល់ថាដូច្នេះឯង។ បើលោកមើលខ្លឹមសារនេះយ៉ាងហ្នឹងខ្លឹមសារនេះបញ្ជាក់អត្ថន័យថាដូច្នេះ។ ហ្នឹងនៅក្នុងចំណោមខ្មែរក្រហមខ្លួនឯងផ្ទាល់តែម្តង។ នេះគឺអ្វីដែលប្រព័ន្ធនេះវាប្រតិបត្តិការបែបហ្នឹង ត្រូវតែលោក់ការណ៍សម្ងាត់ មានសារសម្រាប់ខ្លួនយើង ដែលយើងត្រូវយល់ពីចំណុចនេះ។

**សះ** ខ្ញុំជឿថាវាមានការស្មានៗដែលថា កម្មាភិបាលខ្មែរក្រហម កម្មាភិបាលថ្នាក់ទាប ថ្នាក់កណ្តាលមិនស្តាប់វិទ្យុរណសិរ្សរួបរួមជាតិកម្ពុជានោះទេ។ ប៉ុន្តែមធ្យោបាយមួយទៀតនោះគឺថា សារនេះ

គឺចង់និយាយថាកម្មាភិបាលទាំងនោះមិនមានឱកាសសម្លាប់អ្នកប្រាំពីរនេះទេ។ ហើយមួយទៀតគឺសារនេះសំដៅថា បើចូលរួមជាមួយបដិវត្តន៍ទាន់ពេលវេលាស្វាគមន៍ បើមិនទាន់គឺ -- ដោយសារដែលយើងមាន, បាទ សារទី១គឺថាសម្លាត់ – សារទី១គឺប្រកាសចំហតែម្តង។

[០៩:១២:២៥]

**ឆ៖** លោកប្រើពាក្យថា "*មេបី*" – ប្រហែលជា, ដែលមានន័យថា អាចចង្អុលបង្ហាញថាលោកក៏ស្មានៗអំពីចំណុចនេះដែរ។ លោកសួរមកឲ្យខ្ញុំស្មាន លោកសួរស្មានដោយខ្លួនឯង។ ខ្ញុំអាចនិយាយឲ្យបានច្បាស់លាស់បានដែរថាកម្មាភិបាលខ្មែរក្រហមថ្នាក់ទាបនេះមិនស្តាប់វិទ្យុរណសិរ្សរួបរួមជាតិកម្ពុជាទេ។ មេបញ្ជាការគេប្រហែលជាអាចមិនស្តាប់ដែរ ប៉ុន្តែគេមានប្រព័ន្ធទំនាក់ទំនង វិទ្យុទំនាក់ទំនងរបស់កងទ័ព។ គេស្តាប់ពីមេគេផ្ទាល់តែម្តង។

**ស៖** លោកស្មូត ខ្ញុំសូមបន្តទៅទៀតចំណុចនេះគឺក៏បាននិយាយពីម្សិលមិញ។ សំណួរនោះថាតើ ជាពិសេសភូមិភាគឧត្តរ ភូមិភាគពាយ័ព្យនោះយើងនិយាយអំពីតួនាទីក្នុងការបញ្ជាពាក់ព័ន្ធទៅនឹងខាងក្រៅគោលនយោបាយនោះ គឺម្សិលមិញលោកនិយាយអំពី រស់ ញឹម។ ខ្ញុំក៏បានអានដែរពីយប់មិញនេះគឺ ថាអានសៀវភៅលោកឡើងវិញ។ ខ្ញុំសូមអានសម្រង់ពីរបីពីសៀវភៅរបស់លោកដោយសារតែវានិយាយអំពីប្រធានបទតែមួយ ដូច្នេះខ្ញុំសូមអានមួយម្តងៗ។ ខ្ញុំសូមចាប់ផ្តើមនូវអ្វីដែលលោកសរសេរនៅលើទំព័រ២៨៣, ERNជាភាសាអង់គ្លេស 00396491, បារាំង 0063800 (*ស៊ីក*), បាទ លោកសរសេរដូចតទៅនេះ៖

"កម្មាភិបាលទាហានគ្រប់ថ្នាក់ទាំងអស់ គឺថាប្រុងប្រយ័ត្នចំពោះខ្មាំងនៅក្នុងការតាមដានជនសង្ស័យណាមួយ។ មិនមានការណែនាំណាពីថ្នាក់ដឹកនាំពីភ្នំពេញនោះទេ ឬក៏មកពីទីក្រុងណាមួយដើម្បីឲ្យសម្លាប់ប្រជាជន ឬក៏ជនភៀសខ្លួននោះទេ ដោយសារតែតំបន់ទាំងអស់នោះគឺថា មិនមានការណែនាំដោយផ្ទាល់ពីមជ្ឈិមដែរ ដើម្បីកែប្រែព្រះពុទ្ធសាសនានោះ។ ទោះយ៉ាងណាក៏ដោយវាកើតមានឡើងពាក់ព័ន្ធទៅនឹងការបំផ្លិចបំផ្លាញឯកសារព្រះពុទ្ធសាសនានេះ"។

[០៩:១៥:១៨]

សម្រង់ទី២ គឺទំព័រ២៨២, ERN ជាភាសាអង់គ្លេស 00396490, បារាំង 00639820, "គោលនយោបាយគណៈអចិន្ត្រៃយ៍ គឺបានបញ្ជូនទៅការិយាល័យកម្មាភិបាលថ្នាក់ក្រោមបញ្ជាក់យ៉ាងច្បាស់ -- ដែលបញ្ជាក់អំពីគោលការណ៍ទាំងនោះយ៉ាងច្បាស់។ មធ្យោបាយដែលគោលនយោបាយនេះត្រូវបាន

អនុវត្តគឺអាស្រ័យទៅលើកម្មាភិបាល ហើយនិងអត្តចរិត អកប្បកិរិយារបស់កម្មាភិបាលដែលលោកមានន័យថា គឺបណ្ដាញ ឬក៏ខ្សែបណ្ដាញដែលបានទទួលនូវសារទាំងនេះ" នេះសម្រង់ទី២។

សម្រង់ទី៣ គឺនៅត្រង់ទំព័រ៣២០, ERN ភាសាអង់គ្លេស 00396528, បារាំង 00639876 ត្រង់នេះលោកសរសេរ សូមដកស្រង់ "មេដឹកនាំថ្នាក់មូលដ្ឋានគឺគេពិនិត្យមើលអ្វីកើតឡើងនៅពីភូមិមួយទៅភូមិមួយ ដែល ប៉ុល បានដឹងយ៉ាងច្បាស់ពីបញ្ហានេះ"។ ហើយខាងក្រោមមកទៀតគឺថា "មិនមានគោលនយោបាយណាដែលរៀបចំតាក់តែងឡើងសម្រាប់ប្រទេសទាំងមូលនោះទេ"។

សេចក្ដីដកស្រង់ទី៤ នេះគឺអាចរកបាននៅទំព័រ៣០៤ ERN អង់គ្លេស 00396512, បារាំង 00639848 គេបានសរសេរថា "នៅភ្នំពេញអង្គភាពនៅឈរជើងនៅទីក្រុងភ្នំពេញ គឺថាទទួលការបញ្ជារួមគ្នាតែមួយតែម្ដង ប៉ុន្តែដោយសារមានមេបញ្ជាការភូមិភាគផ្សេងៗ ប៉ុល ពត គឺថាមិនអាចបង្កើតបណ្ដាលបញ្ជាកងទ័ពដោយផ្ទាល់បាននោះទេ"។

[០៩:១៧:៥៤]

សម្រង់ទី៥ លោក ស្សូត គឺថានៅសៀវភៅរបស់លោកត្រង់ទំព័រ២៨២ ដល់ ២៨៣, ERN ភាសាអង់គ្លេស 00396490 ដល់ 91, បារាំង 00639820 នៅត្រង់នេះលោកសរសេរ សូមដកស្រង់ "របបនាសម្ព័ន្ធខ្មែរក្រហម គឺមានលេខាភូមិភាគ និងតួនាទីរបស់មេកន្ទ្រាញនៅតាមបណ្ដាខេត្ត គឺថាគេមានអកប្បកិរិយា និងធ្វើអ្វីតាមចិត្តរបស់គេ"។

ហើយខ្ញុំសូមស្រង់ពីសៀវភៅរបស់លោកផងដែរ នូវទំព័រ១៧៧ ដល់ ១៧៨, ERN គឺ 0039 6378, បារាំង 00639685 ដល់ 686។ ខ្ញុំសូមដកស្រង់ "ចំណុចស្នូលនៃកងកម្លាំងនោះ គឺកម្លាំងខ្មែរវៀតមិញ គឺ ដឹកនាំដោយអតីតខ្មែរឥស្សរៈដូចជា: រស់ ញឹម, សោ ភឹម និង តាម៉ុក ដែលធ្វើសង្គ្រាមប្រឆាំងជាមួយនឹងបារាំង។ ប៉ុន្តែនៅភូមិភាគឦសានវិញគឺ មាន ប៉ុល ពត, អៀង សារី ជាអ្នកដឹកនាំ។ រស់ ញឹម, កែ ពក, សោ ភឹម គឺបាននិយាយថា អ្នកដែលជាបញ្ញវន្ត គឺមានតែទ្រឹស្ដីទេ។ នេះអ្វីដែល សោ ភឹម បាននិយាយ"។ ដូច្នេះលោកអាចមើលឃើញនូវសម្រង់ទាំងអស់នេះនៅក្នុងបរិបទតែមួយហើយ។ កាលណានិយាយអំពីសម្រង់នេះ ដែលថាមានន័យនៅក្នុងបរិបទតែមួយនោះ។ តើវាអាចថា កម្មាភិបាលថ្នាក់ក្រោមនៅភូមិភាគពាយ័ព្យ ឬក៏ រស់ ញឹម ខ្លួនឯងដឹងថា អ្វីដែលត្រូវធ្វើដោយពួកខ្លួន -- ដោយពួកគេផ្ទាល់ខ្លួនឯងនោះ ដោយមិនបាច់មានបញ្ជាពីមជ្ឈិម ពីថ្នាក់លើកទេ?

[០៩:២០:២៦]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ចារីក៖**

ខ្ញុំសូម ខ្ញុំត្រូវតែជំទាស់ជាមួយបញ្ហានេះ អ្វីដែលមេធាវីការពារក្តីលើកឡើងនេះ លើកឡើងពីមូលដ្ឋានដែលធ្វើឲ្យខ្ញុំជំទាស់មានមូលហេតុពីរ។ ទី១ ការដកស្រង់ដែលគាត់លើកឡើង គឺវាមានរយៈពេលខុសគ្នា។ សម្រង់ខ្លះវាពាក់ព័ន្ធទៅនឹងរយៈពេលមុនការដួលរលំទីក្រុងភ្នំពេញ ខ្លះគឺជាមតិយោបល់និយាយអំពីរចនាសម្ព័ន្ធនៅឆ្នាំ១៩៧០ -- ក្រោយឆ្នាំ១៩៧៥ ខ្លះពាក់ព័ន្ធទៅឆ្នាំ១៩៧៨។ វាមិនត្រឹមត្រូវសម្រាប់អ្នកជំនាញ ហើយក៏វាមិនត្រឹមត្រូវសម្រាប់ការផ្ទុះបញ្ចាំងដោយអ្នកជំនាញនៅក្នុងសៀវភៅរបស់គាត់ទេ ប៉ុន្តែជាការស្នើសុំឲ្យធ្វើការសន្និដ្ឋានទាញយកអង្គហេតុណាមួយខាងក្រៅពីសៀវភៅនេះ។ ដូច្នេះខ្ញុំថាសុំឲ្យសួរស្ថិតនៅក្នុងវង្វង់នៃការតាំងសំណួរ ដោយសារចំណុចនេះវាមានខ្លះ១០ឆ្នាំមុនអំឡុងពេលនៃយុត្តាធិការនេះ។ វាជាសំណួរពាក់ព័ន្ធនឹងភស្តុតាងមិនមានជំនួយអ្វី មិនមានប្រយោជន៍អ្វីទេ។ ហើយនេះក៏ជាសំណួរច្រំដដែលៗទាក់ទងចំពោះស្ថានភាពផ្លូវចិត្តរបស់ រស់ ញឹម, បញ្ហាស្មារតីរបស់ រស់ ញឹម ហើយស្នើសួរថាតើ រស់ ញឹម យល់យ៉ាងម៉េចក្នុងចិត្តរបស់គាត់នោះ? ហើយអ្នកជំនាញក៏បានឆ្លើយហើយថា គាត់មិនអាចផ្តល់នូវចម្លើយណាលើសពីនោះទេ។

[០៩:២២:០៩]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានខ្ញុំសូមឆ្លើយតប។ ការដែលសួរឲ្យគាត់ស្មានពេលនេះ ខ្ញុំយល់ថាតំណាងសហព្រះរាជអាជ្ញាដឹងហើយថា ខ្ញុំបានស្តាប់ការតាំងសំណួររបស់គាត់ ក៏បានសួរឲ្យមានការប៉ាន់ស្មាននោះដែរ ហ្នឹងចំណុចមួយ។ មួយទៀតចំណុចជាសារវន្តតែម្តងនោះ អំឡុងពេលនៃទសវត្សរ៍៧០-៧៥, ៧៥-៧៩ បាទ វាពាក់ព័ន្ធទៅនឹងស្របទៅនឹងផ្លូវច្បាប់ទេ និងពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ទាំងអស់នេះក្នុងករណីនេះគឺថាយើងពិនិត្យមើលនៅអ្វីដែលកើត៧៥-៧៩ ប៉ុន្តែជាក់ស្តែងវិវាទជម្លោះរវាង លន់ នល់ និងខ្មែរក្រហមនោះ ជាជម្លោះដែលបន្តហូរហែមក។ ដូច្នេះ ការដែលថាពាក់ព័ន្ធទៅនឹងរយៈពេលផ្សេងៗគ្នាហ្នឹងគឺថាវាមិនជាបញ្ហាអ្វីនោះទេ។

[០៩:២៣:២៦]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៤:០៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះយល់ឃើញថា សេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា មិនសមស្របទេ។ ហើយពេលវេលានេះពិតមែនតែមានឃ្លាតគ្នាមែន ប៉ុន្តែវាមានភាពពាក់ព័ន្ធគ្នាយ៉ាងជិតដិត ហើយអ្នកជំនាញទំនងក៏មានសមត្ថភាពអាចបំភ្លឺបញ្ហានេះបាន។ ដូច្នេះអង្គជំនុំជម្រះបដិសេធនៅសេចក្តីជំទាស់នេះ ហើយសូមលោកអ្នកជំនាញឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយលោកមេធាវីអន្តរជាតិការពារក្តី លោក នួន ជា ចុងក្រោយអម្បាញ់មិញនេះ!

[០៩:២៤:៥១]

**លោក ហ្វីលីព ស្សូត៖**

**ឆ៖** បាទ ខ្ញុំស្វាគមន៍ណាស់ដែលមេធាវីការពារក្តីជ្រើសរើសយកសម្រង់ ដ៏បង្គប់ប៉ិនប្រសប់មែនទេ។ វាជាការពិតហើយដែលថា មានឥរិយាបថគួរឲ្យចាប់អារម្មណ៍មែនទែនចំពោះថ្នាក់ដឹកនាំនៅតាមភូមិភាគផ្សេងៗ។ ប៉ុន្តែឥរិយាបថដែលត្រូវ ថាតើអនុវត្តគោលនយោបាយនេះដោយរបៀបណាដើម្បីឲ្យមានការយល់ព្រមគ្នាក្នុងលក្ខណៈទូទៅមួយ។ ហ្នឹងមួយចំណុច។ ចំណុចមួយទៀត គឺថាកងទ័ពរបស់ រស់ ញឹម នៅភូមិភាគពាយ័ព្យអាច គឺថាបានធ្វើអ្វីៗដែលជាការរំលោភបំពានទៅនឹងគោលនយោបាយថ្នាក់មជ្ឈិមជារឿងមួយទៀត។ យើងបានឃើញចំណុចអស់ហ្នឹង នៅទូទាំងប្រទេសកម្ពុជាមិនអាចជំទាស់បានទេ។ នៅការអនុវត្តជាប្រព័ន្ធ ជាបែបបទបែបហ្នឹង ដោយក្រុមផ្សេងៗគ្នានោះ។ រស់ ញឹម នៅក្នុងការសម្លាប់តាមតំបន់ផ្សេងៗនោះ។ រស់ ញឹម បានធ្វើយ៉ាងដូច្នេះ ដោយសារគេដឹងថាមជ្ឈិមដឹង បើធ្វើអ៊ីចឹង។ ការគ្រប់គ្រងត្រួតត្រា គឺថាត្រួតត្រាគ្រប់គ្រងបានល្អ នៅតាមភូមិភាគ ប៉ុន្តែវាមានការយល់ព្រម និងការយល់ជារួម ជាឯកច្ឆន្ទហើយ។ ឧទាហរណ៍ ការបំផ្លិចបំផ្លាញសៀវភៅ ការដុតសៀវភៅចោល ការបំផ្លិចបំផ្លាញមន្ទីរពិសោធន៍។

[០៩:២៦:៣៨]

បើសិនណាជាលោកមើលទៅ ឃើញថាការបំផ្លិចបំផ្លាញនេះ ជាការបំផ្លិចបំផ្លាញដែលស្ថិតនៅក្នុងរង្វង់គោលនយោបាយ ចំពោះអ្នកដែលប្រឆាំង ដូចជាអ្នកដែលរស់នៅក្នុងទីក្រុង។ ខ្ញុំមិនយល់ឃើញថា មេបញ្ជាការត្រូវធ្វើតាម ប៉ុន្តែអំពើរបស់គេនេះ គឺថាអាចនឹងធ្វើឲ្យថ្នាក់លើនេះដឹងហើយ។

**ស៖** ខ្ញុំសូមសួរសំណួរចុងក្រោយ លោក ហ្វីលីព ស្សូត! លោកបានយល់ស្របដែលថា មិនមាន

បញ្ហា មាននយោបាយដើម្បីកម្ទេចមន្ទីរពិសោធន៍ សៀវភៅនោះទេ។ ប៉ុន្តែដូចលោកបាននិយាយ វាកើតមានឡើង គឺថាមានការបំផ្លាញបែបហ្នឹង។ តើអាចទេដែលថា ទាហាន លន់ នល់ ត្រូវបាន -- ឬក៏មន្ត្រី លន់ នល់ ត្រូវបានគេសម្លាប់ដោយមិនមានគោលនយោបាយបង្គាប់បញ្ជាមកបែបនេះទេ។ អាចនិយាយថា អ៊ីចឹងបានទេ?

**ឆ៖** ខ្ញុំសូមឆ្លើយឲ្យបានវែងឆ្ងាយបន្តិច។ ថាបាទ វាមានបុគ្គលណាមួយចំនួននោះ ឧទាហរណ៍ថាទៅលួចឆក់នៅក្នុងមន្ទីរពិសោធន៍ បំផ្លិចបំផ្លាញ ប៉ុន្តែមិនមានគោលនយោបាយឲ្យអនុវត្តទូទាំងផ្ទៃប្រទេសទេ។ ឧទាហរណ៍ នៅក្នុងបណ្ណសាររបស់កម្ពុជានោះ ឯកសារភាគច្រើន ដែលនៅក្នុងបណ្ណសារនោះ គឺខ្មែរក្រហមទុក អត់កម្ទេច អត់ដុតចោលទេ។ ហើយក្រោយមក ត្រូវបានរបប ហេង សំរិន គឺថាយកមកបោះពុម្ពផ្សាយនៅក្នុងសារព័ត៌មានផ្សេងៗ វាសល់ពីរបបខ្មែរក្រហម ជាការពិតហើយ។ ហើយគម្ពីព្រះពុទ្ធសាសនាខ្លះ ក៏មិនត្រូវបានបំផ្លាញនោះទេ។ ហើយលោកសួរខ្ញុំថា “តើអាចទេដែលថាមេបញ្ជាការនៅតាមដងផ្លូវនោះ ឬក៏មេបញ្ជាការកងទ័ពក្រុមណាមួយ សម្លាប់ប្រជាជនដោយមិនមានទទួលការណែនាំណាមួយ?” ចម្លើយថា “អាច”។ ជាការពិតហើយវាអាច ប៉ុន្តែខ្ញុំជំទាស់យ៉ាងខ្លាំងថា នេះវាជាលទ្ធភាពរបស់បុគ្គលមួយ យើងមិនអាចយកការពន្យល់លក្ខណៈបុគ្គលមួយ ទៅគ្របដណ្តប់ទៅលើបែបបទនៃការអនុវត្តគោលនយោបាយនៅទូទាំងប្រទេស ដែលជាការយល់ឯកច្ឆ័ន្ទក្នុងការកម្ចាត់កម្ទេច មន្ត្រី និងទាហាន លន់ នល់ និងមន្ត្រីជាន់ខ្ពស់ លន់ នល់ នោះទេ។

[០៩:២៩:១៣]

**ស៖** បាទ យល់ស្រប អាចនឹងមិនយល់ស្រប លោក ហ្វីលីព ស្សូត។ វាអាស្រ័យទៅលើមេធាវីការពារក្តីក្នុងការជំទាស់តវ៉ាទៅគោលនយោបាយ ហើយនិងអ្វីដែលកើតមានឡើង វាមានហេតុផលរបស់វា។ ពីម្សិលមិញ លោកបាននិយាយអំពីលទ្ធភាពនៃការសងសឹក។ ប្រហែលលោកចាំហើយ នៅក្នុងឆ្នាំ១៩៦៨។

បាទ នៅក្នុងកម្មវត្ថុនេះផងដែរ ខ្ញុំសូមចូលត្រឡប់មកសៀវភៅរបស់លោកឡើងវិញ។ អ្វីដែលខ្ញុំរកឃើញនៅក្នុងសៀវភៅរបស់លោក គឺមានការគួរឲ្យចាប់អារម្មណ៍ណាស់។ ដោយសារតែយើងខ្ញុំមិនអាចបាដឹងថា កាលពីសប្តាហ៍មុននោះ គេមាននិយាយជាមួយសាក្សីអំពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ។ ហើយតំណាងសហព្រះរាជអាជ្ញាក៏បង្ហាញភាពយន្តឯកសារ ថេត សម្បត្តិ។ ហើយនៅក្នុងភាពយន្តឯកសារយើងឃើញអ្នកភូមិនិយាយអំពីអ្វីដែលគេបានឃើញ។ ហើយចំណុចមួយ

ទៀតដែលអ្នកភូមិរៀបរាប់ហ្នឹង គឺថាមេបញ្ជាការមូលដ្ឋាននៅឯទួលពោធិ៍ជ្រៃហ្នឹង ហើយជាមួយនឹងអនុបញ្ជាការ គឺត្រូវបានកាត់ក ហើយគេបានដោតក្បាលហ្នឹងដាក់នៅសងខាងផ្លូវ។ ខ្ញុំចង់សួរថា តើនេះអាចជាការសងសឹកទេ? ហើយនិយាយពីសៀវភៅរបស់លោកឡើងវិញ កាលពីម្សិលមិញនេះ។ ខ្ញុំឃើញទំព័រមួយដែលលោកដាក់រូបភាពនៅក្នុងសៀវភៅរបស់លោក។

[០៩:៣១:០០]

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតដើម្បីដាក់បញ្ចាំងរូបថតនៅក្នុងសៀវភៅរបស់លោក អ៊ិចស្ពឹតនៅក្នុងអេក្រង់។ គឺនៅទំព័រ៤២៩ និង៤២៨។ ខ្ញុំមិនដឹងថាម្នាក់ៗមានរូបថតនេះ ឬក៏អត់ទេ។ បាទមានរូបថតបី ហើយសរសេរដូចខាងក្រោមនេះ។

តាមបញ្ជារបស់សម្តេច សីហនុ មេបញ្ជាកងទ័ពគឺ លន់ នល់ បានធ្វើការកាប់សម្លាប់ខ្មែរដែលចាប់បាននៅទសវត្សរ៍១៩៦០។ ហើយរូបនៅខាងក្រោមនេះ គឺជាទាហានលន់ នល់ នោះ លោកឃើញទេ គឺម្នាក់ៗយួរក្បាលអ្នកបះបោរនេះ រំឭឲ្យខ្ញុំឃើញអំពីរឿងរ៉ាវព្រឹត្តការណ៍នេះ។ ការពិត គឺថាមានការអនុវត្តនៃការសម្លាប់កាត់ក ដែលជាការសងសឹកបែបនេះ។ ខ្ញុំយល់អ៊ីចឹង។ លោកអាចរៀបរាប់បានទេ?

**ឆ៖** ខ្ញុំប្រាកដថារឿងហ្នឹងពិតជាកើតអ៊ីចឹងមែន។ មានអំពើនៃការសងសឹង អំពើនៃហិង្សាដោយងងឹតងងុលក្នុងករណីទាហានលន់ នល់។ ខ្ញុំគិតថា លោកនៅចាំហើយនៅក្នុងសៀវភៅរបស់ខ្ញុំ ខ្ញុំបញ្ជាក់ថា: បញ្ហាមួយនោះ គឺថានៅពេលដែលកងកម្លាំងលន់ នល់ នៅទៅរតនគិរី គឺបានសម្លាប់អ្នកកសិករ ហើយកាត់ក្បាលយកមក។ នេះហើយគឺជាការបង្កកំហឹងដោយតាមការបញ្ជារបស់លន់ នល់ ហើយយកក្បាលទាហាន -- យោធា -- អ្នកដែលគេសម្លាប់ហ្នឹងផង ហើយយកកាំភ្លើងដែលគេកាន់ផង។ នេះហើយគឺជារឿងគឺថា ដែលមិន -- មិនមែនថាក្រុមយោធាខ្មែរក្រហមមួយក្រុមតូច មួយក្រុមធំធ្វើបែបនេះទេ។ ប៉ុន្តែវាអាចជាកើតមានអ៊ីចឹងមែន។ ខ្ញុំមិននិយាយស្មានទេ ប៉ុន្តែខ្ញុំមានការខុសគ្នាបន្តិចអំពីគំរូទូទាំងប្រទេសដែលជាប្រព័ន្ធនៃអាកប្បកិរិយានោះ នៃអំពើនោះ។

[០៩:៣៣:៣៨]

**ស៖** ខ្ញុំនឹងសួរសំណួរមួយចំនួនទៀត អំពីប្រធានបទនេះ។ ប៉ុន្តែខ្ញុំទៅមុខបន្តិចលោក ស្បត។ ហើយខ្ញុំចង់សួរអំពីការប្រព្រឹត្តទៅលើរដ្ឋាភិបាល លន់ នល់ ហើយនិងសមាជិក ឬក៏មនុស្សរបស់រដ្ឋាភិបាលលន់ នល់។ ឥឡូវនេះយើងទៅដល់ទំព័រ២៨០ នៅក្នុងសៀវភៅរបស់លោក។ អង់គ្លេស ERN 00396408, បារាំង ERN 00639725 នៅខាងក្រោមទំព័រ២០៨ លោកបានសរសេរដូចខាងក្រោមនេះ

"នៅឆ្នាំបន្ទាប់នោះគឺថា ប្រជាជនវៀតណាមប្រហែលជា២.០០០នាក់ជាង គឺត្រូវបានបញ្ជូនចេញទៅដោយទាហានលន់ នល់ បញ្ជូនទៅក្រៅ គេយកទៅដាក់ក្នុងជំរំ ហើយមានអំពើហិង្សាជាបន្តបន្ទាប់លើអ្នកទាំងនោះ"។ នៅខាងក្រោមបន្តិចនោះ គឺថាលោកសរសេរថា៖ ហើយនេះជាអំពើ កំហឹងអំពីនយោបាយរបស់គេត្រូវសងសឹក ហើយគេត្រូវដាក់ពិន័យ ហើយគិតមានការកាប់សម្លាប់ ហើយជាការសងសឹកនៅរហូតទៅដល់ចុងខែមិថុនានៅឆ្នាំនោះ។ ហើយអ៊ីចឹងហើយអ្វីដែលកងទ័ពវៀតណាមខាងត្បូងបានធ្វើនោះ គឺវាមានលក្ខណៈបែបនោះ។ អានេះជាផ្នែកមួយនៃការប្រព្រឹត្តិរបស់ទាហាន លន់ នល់ ទៅលើជនជាតិវៀតណាម ២៥.០០០នាក់នោះ។ ហើយសូមលោកពន្យល់បន្ថែមអំពីការប្រព្រឹត្តិទៅលើពួកវៀតណាមទាំង ២៥.០០០នាក់នេះ ថាតើលោកអ្វី មានអ្វីបន្ថែមទៀតទេ?

[០៩:៣៥:៤៤]

**ឆ៖** នេះជាប្រជាជនវៀតណាមដែលរស់នៅក្នុងកម្ពុជា ដែលរស់នៅជាច្រើនឆ្នាំមកហើយ ប្រហែលជាពាក់កណ្តាលជីវិតរបស់គេនៅកម្ពុជា នៅក្រោម អំ! នៅពេលដែលគេផ្តួលរបប សីហនុ ទៅ លន់ នល់ ក៏បានប្រកាសនយោបាយមួយដែលជាកម្មវិធីប្រកាន់ពូជសាសន៍និយម ស្នេហាជាតិ ដែលសម្រេចពីថ្នាក់ខ្ពស់ ដែលនាំឲ្យមានកាប់សម្លាប់ ហើយមានការបណ្តេញជនជាតិវៀតណាមពីស្រុកខ្មែរហ្នឹងជាទ្រង់ទ្រាយធំ។

**ស៖** តើលោកអាចធ្វើការប្រៀបធៀបរវាងការប្រព្រឹត្តិទៅលើជនជាតិវៀតណាមនៅក្នុងឆ្នាំ ១៩៧៥ ហើយនិងមុន ហើយនិងក្រោយ១៩៧៥ ដល់ ៧៩។ តើវាយ៉ាងដូចម្តេចបាទ?

**ឆ៖** បាទ វាមានការខុសគ្នាឆ្ងាយ។ លន់ នល់ ដើម្បីកំណត់ត្រាតុលាការ ខ្ញុំដឹងថាមិនមានឯកសារអីអំពីការណែនាំចេញពីរបប លន់ នល់ ទៅទាហានដើម្បីឲ្យការកាប់សម្លាប់ទេ ប៉ុន្តែគឺគំនិតហ្នឹងចេញមកពីថ្នាក់លើ ហើយគឺមានការកាប់សម្លាប់នោះឯង។ ប៉ុន្តែត្រឡប់មកសំណួររបស់លោក គឺតើបន្ទាប់ពី ប៉ុល ពត កាន់អំណាច គឺក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ មានចលនាក្នុងការបញ្ជូនប្រជាជនវៀតណាមទៅវៀតណាមវិញ។ ហើយពលរដ្ឋខ្មែរខ្លះ ប្រជាជនខ្មែរខ្លះ គឺបានរៀបការនោះ គឺថាបានរត់ខ្លួនចេញ រត់គេចខ្លួនទៅវៀតណាម ដើម្បីឲ្យរួចខ្លួន គឺមិនទាន់មានការកាប់សម្លាប់ទេនៅចំណុចនេះ។

[០៩:៣៧:៣៣]

ប្រហែលជាក្រោយមកទៀត ដែលមានការហិង្សាប្រឆាំងនឹងជនជាតិវៀតណាមដែលនៅក្នុង

ប្រទេសកម្ពុជានៅឡើយនោះ គឺចាប់ផ្ដើមនៅពេលមានការប៉ះទង្គិចនៅតាមព្រំដែនខាងយោធា នៅពេលដែលសង្គ្រាមកើតឡើងរវាងវៀតណាមនិងកម្ពុជានោះ ទើបបានមានហិង្សា។ យើងឃើញថាមានថាបញ្ហាជាប្រព័ន្ធនៃការធ្វើទុក្ខបុកម្នេញទៅនៅពេលដែល ប៉ុល ពត កាន់អំណាចឆ្នាំដំបូងនោះ។

[០៩:៣៨:០៤]

**ស៖** បន្តអំពីចម្លើយនេះ លោក ស្សូត! លោកបានប្រើពាក្យ “*ជី-- ជេណូសាយ*” – “គឺប្រល័យពូជសាសន៍” កាលពីថ្ងៃចន្ទ ប៉ុន្តែខ្ញុំមិនទាន់បានសួរលម្អិតទេ។ សូមការអនុញ្ញាតពីតុលាការថាតើមានអំពើប្រល័យពូជសាសន៍ ឬក៏មិនមាននោះ អាហ្នឹងគឺជាសមត្ថកិច្ចរបស់តុលាការសម្រេចទេ។ ប៉ុន្តែនៅទំព័រ៤៤៦ នៅក្នុងសៀវភៅរបស់លោកគឺ ERN គឺ 00396662, ហើយបារាំង ERN 0064434។ លោកបាននិយាយថា “ខ្មែរក្រហមមិនបានកំណត់ថាបំបាត់ជនជាតិសាសនា ពូជសាសន៍ ទោះបីជាចាម វៀតណាម ហើយនិងក្រុមជនជាតិពន្ធុក្នុងស្រុកក៏ដោយ”។ ហើយៗនៅកន្លែងផ្សេងទៀតដែលខ្ញុំនឹងពិនិត្យមើល។ ហើយលោកដូចជាប្រាកដថាតាមទស្សនៈរបស់លោក លោកថាមិនមានគោលនយោបាយដើម្បីបំបាត់ពូជសាសន៍ ក្រុមសាសនា ឬក៏ក្រុមជាតិសាសន៍នោះទេ។ តើក្នុងលក្ខណៈដែលលោកថាអាចនឹងប្រើពាក្យថា *“ជី”, ជី* ហ្នឹងគឺ “*ជេណូសាយ”* –“ប្រល័យពូជសាសន៍”។ តើលោកអាចពន្យល់អ្វីបានទេ?

[០៩:៣៩:៣៦]

**ឆ៖** ខ្ញុំមានការលំបាកក្នុងការឆ្លើយនោះ ដោយសារមិនប្រើពាក្យពិសេសមួយនេះនោះ។ ខ្ញុំៗដកស្រង់ ចច អ័រវេល (George Orwell) “គឺនៅពេលដែលថា នៅពេលភារកិច្ចរបស់បុរសដែលស្មោះត្រង់ដែលថាត្រូវតែធ្វើតាមគោលនយោបាយ ឬបញ្ហានោះ”។ និយមន័យនៃពាក្យនេះគឺថាអ្វីដែលគេយល់តាមន័យរបស់ពាក្យនោះ គឺការប្ដូររូបភាពដើម្បីបំពេញទៅតាមនិយមន័យច្បាប់ វាអាចជាដែនមួយដែលគ្រោះថ្នាក់ គឺថាអត្ថន័យពាក្យហ្នឹងមិនដូចន័យដើមទេ។ វាចូលទៅដល់ពិភពមួយដែលវាមិនច្បាស់ដែលវាមានកម្លាំងខ្លាំងនោះ។ ខ្ញុំនិយាយថា ខ្ញុំជឿយ៉ាងប្រាកដថា មិនមានការប៉ុនប៉ងដើម្បីលុបបំបាត់នូវក្រុមជាតិពន្ធុណាមួយទេ។ យើងមានស្ថានភាពខុសគ្នាស្រឡះណាស់ពីរវ៉ាន់ដា ណាហ្ស៊ី ដឺម៉ានី នៅកម្ពុជាយើងគឺវាខុស។ នៅពេលនោះគេមានការប៉ុនប៉ងនៅណាហ្ស៊ី គេចង់លុបបំបាត់ជនជាតិជ្វីប ហើយនៅរវ៉ាន់ដា គេចង់បំបាត់នូវជនជាតិទុតស៊ី។ ប៉ុន្តែនៅកម្ពុជាប្រជាធិបតេយ្យមិនមានបែបនេះទេ។ ចាមគេនិយាយថា -- ខ្មែរក្រហមនិយាយថា ចាម គឺថាគេចង់បញ្ជាក់ថាមានប្រល័យពូជសាសន៍។ ប៉ុន្តែខ្មែរ

ក្រហមមិនមានការប៉ុនប៉ងជានយោបាយនោះទេ។ ថាតើពួកគេជាក្រុមដែលគេអាចកំណត់ ហើយគេអាចចាក់ឫសជាសាសនារបស់គេយូរហើយនោះ។ ប៉ុល ពត បាននិយាយថា នយោបាយរបស់កម្ពុជាប្រជាធិបតេយ្យគឺធ្វើឲ្យមនុស្សគ្រប់គ្នាមានសមភាព។ ដូច្នេះ អ្នកណាដែលប្រឆាំងគឺត្រូវតែកៀបសង្កត់គឺត្រូវតែធ្វើម៉េចឲ្យគោរពតាម។ ដូច្នេះហើយទើបបានគេបំបែកជនជាតិចាមឲ្យនៅដាច់ៗពីគ្នា ហើយមានការបង្ក្រាប។ ប៉ុន្តែយើងមិនឃើញមានការប៉ុនប៉ងជាបន្តបន្ទាប់ដើម្បីបំបាត់ក្រុមពូជសាសន៍នោះទេ។

[០៩:៤១:៤៧]

**ស៖** អរគុណលោក ស្សុត។ ឥឡូវខ្ញុំទៅប្រធានបទថ្មី។ នេះជាប្រធានបទមួយដែលថាយើងពិភាក្សាលើពាក្យដែលលោកប្រើជាបន្តបន្ទាប់ប៉ុន្មានថ្ងៃនេះគឺពាក្យ “*ផារ៉ាណូយ៉ា*” – គឺថាអំពើភ័យខ្លាច។ អំពើភ័យខ្លាចហ្នឹងគឺថា អាចជាកត្តាជំរុញឲ្យមានការបោសសម្អាតធ្វើឲ្យមេដឹកនាំហ្នឹងប្រើជាអាវុធដើម្បីបំពេញឆន្ទៈរបស់ខ្លួន មហិច្ឆតារបស់ខ្លួន។ លោកនិយាយដែរចំណុចមួយនោះថាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាជាមនុស្សដែលមានហេតុមានផលទេ។ ហើយសំណួរចំពោះលោកហ្នឹងគឺខ្ញុំសួរខាងក្រោមនេះ។ ខ្ញុំមិនប្រើសេចក្តីដកស្រង់នោះទេ ប៉ុន្តែផ្អែកលើអ្វីដែលខ្ញុំយល់ពីការអាននោះគឺថាវៀតណាម គេចាត់ទុកវៀតណាមថាជាការគំរាមកំហែងទៅកម្ពុជា។ ប៉ុន្តែតាមពិតវៀតណាមឆ្នាំ១៩៧៩ មិនឈ្លានពានកាន់កាប់ ហើយយកស្រូវអង្ករលួចប្លន់អីនោះទេ។ ក្នុងសៀវភៅរបស់លោកក៏លោកឃើញដូច្នេះ។ លោកបានដកស្រង់អគ្គរដ្ឋទូតរុស្ស៊ីណែនាំទ័ពវៀតណាមថាឲ្យពិចារណាកុំឲ្យសម្តែងអាកប្បកិរិយាជាអ្នកពង្រីកទឹកដីនិយម។ ប្រទេសចិន ដូចដែលលោកដឹងច្បាស់ណាស់គឺមានការមិនសប្បាយចិត្តចំពោះនយោបាយពង្រីកទឹកដីរបស់វៀតណាមនោះ។ តើត្រឹមត្រូវដែរឬទេបើយើងនិយាយថា ការគំរាមកំហែងដែលខ្មែរក្រហមយល់ថាជាការពិតនោះ តើវាពិតដូចដែលគេគិតទេ? តើមេដឹកនាំកម្ពុជាប្រជាធិបតេយ្យគិតអ៊ីចឹងតើវាពិតជាមានដូចអ៊ីចឹងទេ? យើងមើលដល់ឆ្នាំ១៩៧៩ ថាតើវាមានខ្សាំងផ្ទៃក្នុងនៅខាងក្រៅដែរឬទេ? នៅចំណុចចុងក្រោយនោះលោកនិយាយថា សៀវភៅរបស់លោកនេះ គឺមិនមែនជាករណីដែលកងកម្លាំងវៀតណាមមករំដោះកម្ពុជាទេ។ មិនដូច គ្រាន់ថាជាការសង្គ្រោះប្រជាជនទេ គេឈ្លានពានដើម្បីអត្ថប្រយោជន៍របស់គេ ផលប្រយោជន៍របស់គេ។ តើពិតដែរឬទេ? លោកអាចបដិសេធអ្វីៗទាំងអស់អំពីការដែលថាបោសសម្អាត ឬក៏ចំណាត់ការផ្សេងៗនោះវាជាអំពើភ័យខ្លាចរបស់មេដឹកនាំខ្មែរក្រហមទេដែលគេធ្វើបែបនោះ?

[០៩:៤៤:៤០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[០៩:៤៤:៤៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំត្រូវតែជំទាស់។ មេធាវីការពារក្ដីគាត់រៀបឃ្លា គាត់ធ្វើសង្ខេប គាត់ទាញយកខ្លឹមសារ គឺថាអាចនឹងគាត់ដាក់បញ្ចូលនូវខ្លឹមសារនូវគំនិត និងទស្សនទាន ជំនឿដែលគាត់មាន ហើយរៀបឃ្លាឡើងវិញ យោងទៅរកសៀវភៅ ឬក៏សក្ខីកម្ម។ ហើយដាក់បញ្ចូលខ្លឹមសារទាំងនោះឲ្យអ្នកជំនាញគាត់ឆ្លើយ។ នេះជាហើយជាឧទាហរណ៍គាត់និយាយថា "តាមពិតចិនមិនសប្បាយជាមួយវៀតណាមដែលគេមាននយោបាយពង្រីកទឹកដីនិយម"។ យើងមិនបានឮពីគំនិតនេះទេក្នុងរយៈពេល ៣ថ្ងៃនេះ គឺអ្នកជំនាញមិនបាននិយាយពីរឿងហ្នឹងទេនៅក្នុងសៀវភៅ។ តាមពាក្យដែលមេធាវីប្រើអំម្បាញ់មិញនេះគឺ និយាយគឺបញ្ហាត្រឹមត្រូវ ហើយនិងសេចក្ដីលម្អិតនោះ វាចោទជាបញ្ហា។ ខ្ញុំក៏ថាគាត់សួរអាចសួរ ប៉ុន្តែសួរឲ្យជាក់លាក់ យោងទៅរកនយោបាយជាក់លាក់ ហើយគាត់យោងទៅរកសៀវភៅ ឬក៏ឯកសារណាមួយ ឬក៏សក្ខីកម្មរបស់អ្នកជំនាញ បើគាត់លើកពីការសន្និដ្ឋាន ការដឹង ហើយនិងការយល់ដឹងរបស់គាត់ដាក់មកឲ្យសាក្សី -- មកឲ្យលោកជំនាញឆ្លើយនោះគឺមិនសមស្របទេ។

[០៩:៤៦:០៤]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ គឺខ្ញុំមិនដឹងថា មូលដ្ឋានអីដែលគាត់ជំទាស់ទេ ប៉ុន្តែនេះជាភារកិច្ចខ្ញុំ ដែលខ្ញុំត្រូវធ្វើឥឡូវនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ នៅក្នុងទំព័រ៤០៩, ERN អង់គ្លេសគឺ 00396625, បារាំង ERN 00639989 ឥឡូវនេះ ខ្ញុំដកស្រង់អ្វីៗដែលកើតឡើងឆ្នាំ១៩៧៩។ បន្ទាប់មកគឺៗថាកងទ័ពវៀតណាមក្រោយពីឈ្នះ គឺថាបានលួចឆក់ប្លន់ ហើយដឹកទំនិញរបស់ទ្រព្យទៅហូជីមិញ។ នៅមួយទំព័រនៅក្រោយទៀត ទំព័រ៤១០, អង់គ្លេស ERN 00396626, បារាំង ERN 00639989 មានទុរ្ភិក្សក្នុងសម័យកម្ពុជាហ្នឹងគឺថា វាមានដោយសារស្បៀងអាហារដែលក្នុងឃ្លាំងហ្នឹងត្រូវបានដឹកទៅវៀតណាមអស់។ ទំព័រ ២៣៨, ២៣៩ គឺ ERN 00396438 នៅទំព័រនេះ២៣៨ គឺនៅហាណូយ អគ្គរដ្ឋទូតរុស្ស៊ីបានប្រាប់ថា "មេដឹកនាំ -- គេ

និយាយអំពីសុបិនពីដំបូងរបស់គេអំពីការធ្វើសហព័ន្ធឥណ្ឌូចិននោះនៅឡើយទេ"។ នៅទំព័រ៣៧៣, ERN ហ្នឹងគឺ 00396581, បារាំង ERN 00639943, "ការភ័យខ្លាចរបស់កម្ពុជាពីវៀតណាមហ្នឹង គឺជាការពិត" ពីឆ្នាំនោះគឺថាគេជៀសវាងពីការប៉ះទង្គិច កម្ពុជាគេចង់ធ្វើឲ្យរបបរបស់គេរឹងមាំ ប៉ុន្តែវៀតណាមគេចង់បានគោលដៅរបស់គេតាមវិធីនយោបាយ"។ នៅបញ្ចប់នៅក្នុងទំព័រនេះ "អរិភាពកម្ពុជាមិនឃោរឃៅទេ ដូចជាទាក់ទងទៅនឹងថៃ និងវៀត-ណាមនោះ គឺថាមិនមែនមានមូលដ្ឋាននោះទេ"។

[០៩:៤៨:៤៩]

ឥឡូវនេះ ខ្ញុំបាននិយាយអំពីសេចក្តីដកស្រង់ដែលខ្ញុំសង្ខេប។ ឥឡូវត្រឡប់ទៅសំណួរដំបូង គឺនិយាយពីការភ័យខ្លាចគ្មានមូលហេតុ ហើយនិងការភ័យខ្លាចដែលមានមូលហេតុ។ អ៊ីចឹងសូមលោកស្សូត ជាអ្នកជំនាញលោកឆ្លើយពន្យល់តុលាការផង?

**លោក ហ្វីលីព ស្សូត៖**

**ឆ៖** លោកប្រើពាក្យថា "*រ៉ាស្យូណែល* – សនិទានភាព" គឺថាដោយថាមានមូលហេតុ មានហេតុ មានផលនោះ។ ខ្ញុំមិនទៅដល់ឆ្ងាយប៉ុណ្ណឹងទេ ពាក្យណាដែលសមស្របជាងហ្នឹង។ តាមនោះគឺថាគេមានចេតនានឹងប្រើហេតុ ប្រើផល ប៉ុន្តែបើលោកប្រើពាក្យថា "*រ៉ាស្យូណែល*" នេះជាមសហេតុសមផលទុំង គឺវាកត្តាច្រើនណាស់ ដែលត្រូវផ្តួប។ នេះហើយគេមិនជោគជ័យក្នុងការធ្វើបែបនោះទេ ប៉ុន្តែការគួបផ្សំជាមួយគ្នាអំពីគំរាមកំហែងពីក្រៅខាងក្នុងនេះ។ លោកត្រូវហើយ ពួកគេមានមូលហេតុដូចខ្ញុំបានសរសេរ ហើយខ្ញុំមើលឡើងម្តងទៀត។ ក្នុងការភ័យខ្លាចអំពីសម្ពាធពីខាងវៀតណាម។ វៀតណាមគឺបានបណ្តុះគំនិត គឺថាដើម្បីគ្របសង្កត់ទៅលើវៀតណាម និងឡាវ ហើយគឺមានច្រើនទសវត្សរ៍មកហើយ គេមិនចង់ឲ្យកម្ពុជាដើរតាមនយោបាយឯករាជ្យទេ។ នេះហើយមិនដូចគ្នាទេ ដែលយើងនិយាយថា មានការខ្លាចអំពីការគ្របសង្កត់របស់វៀតណាមហ្នឹង។ ឥទ្ធិពលរបស់វៀតណាមហ្នឹង គឺថា -- ប៉ុន្តែក្រោយមក គឺគេបានផ្តាច់ការទំនាក់ទំនងហ្នឹង គឺថាដើម្បីគេនិយាយថា គេប្រកាន់ឯករាជ្យ គេយកគំនិតហ្នឹង។

[០៩:៥០:៤៦]

ឥឡូវ យើងការគំរាមកំហែងពីខាងក្រៅមិនចាំបាច់ថា ត្រូវតែមានភ្នាក់ងារខាងក្នុងដែលធ្វើឲ្យនៅខាងក្រៅ ក្រុមខាងក្រៅវៀតណាមដែលត្រូវតែតាមរក ហើយចាប់បោសសម្អាត។ ប៉ុល ពត ជឿថា -- ប៉ុល ពត ជឿតាំងពីមុនមកថា សេចក្តីដកស្រង់ដែលនិយាយទៅគណៈអចិន្ត្រៃយ៍ហ្នឹង "យើងអាច

ដោះស្រាយការគំរាមកំហែងពីខាងក្រៅ ប៉ុន្តែការគំរាមកំហែងក្នុង គឺថាត្រូវតែពិនិត្យពិច័យដែរ"។ ខ្ញុំគិតថា វាអាចនឹងជាអំពើភ័យខ្លាចដែលជាគំនិត ប៉ុល ពត ទទួលបានពី ស្តាលីន ដែលថា ស្តាលីន គឺថានៅក្នុងសូវៀត បក្សកុម្មុយនីស្តសូវៀតនោះ គឺថាគេត្រូវតែមើលភ្នាក់ងារចារកិច្ចខាងក្នុងដែរ។ បាទ អ៊ីចឹងប្រព័ន្ធទាំងពីរគឺមិនមែនទាំងស្រុងទេ វាមានការគំរាមកំហែងខាងក្រៅមានពិត។ រីឯគំរាមពីខាងក្នុង ប៉ុន្តែអាហ្នឹងជាការគំរាមកំហែងដែលគេស្រមៃគិតទេ វាមិនពិតនោះទេ។

[០៩:៥១:៤៧]

**ស៖** ខ្ញុំដូចតាមលោកមិនទាន់។ លោក ស្បូត តើនេះមិនមែនជាស្ថានភាពដែលវៀតណាមឈ្លានពាន ហើយត្រឡប់ទៅវិញ។ ពួកគេធ្វើសហការយ៉ាងជិតស្និទ្ធជាមួយកម្មាភិបាលខ្មែរក្រហមដូចជាលោក ហេង សំរិន, ហ៊ុន សែន, ប៉ែន សុវណ្ណ ជាដើម។ ហើយតាមពិតគឺមិនមែនគ្រាន់តែ ដូចថា ១សប្តាហ៍កន្លងទៅនេះ ខ្ញុំបានអានអត្ថបទសារព័ត៌មានមកពីរបស់អាល្លឺម៉ង់។ សាស្ត្រាចារ្យមកពីប៉ែរឡាំង និយាយថា "បាទ គឺថាជាក្រុមស្តាហ្ស៊ី នោះ គឺថាជារបស់អាល្លឺម៉ង់ គឺសហការជាមួយវៀតណាម គឺមានកំណត់ត្រាឯកសារអំពីមនុស្សមួយចំនួនដូចជាមនុស្សមួយចំនួន ដូចជាលោក ហេង សំរិន...។ល។ ដូច្នេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងភូមិភាគបូព៌ា ហើយនិងនយោបាយរបស់វៀត-ណាម។ លោកមិនអាចមើលតែរូបភាពមួយ ហើយបំភ្លេចម្ខាងទៀតទេ។

[០៩:៥៣:០០]

**ឆ៖** ហេង សំរិន បានគេចខ្លួនទៅវៀតណាម បន្ទាប់ពីការសម្លាប់ ឬក៏អត្តឃាតខ្លួនរបស់ សោ ភឹម ទេ។ ហើយគឺមានការបោសសម្អាតដ៏ទូលំទូលាយ ដ៏ធំ ទ្រង់ទ្រាយធំហ្នឹងគឺថាមានការបញ្ជូនមនុស្សជាច្រើនមក ស-២១ ។ យើងមិនអាចឆ្លល់ទេ ព្រោះ នួន ជា និយាយថា អ្នកទាំងនេះគឺត្រូវតែកម្ទេច ហើយនេះហើយជាឱកាសដែលធ្វើឱ្យលោក ហេង សំរិន គេចខ្លួនហ្នឹង។ ហើយក្រុមខ្លះបានចាកចេញមុននឹងទៅទៀត មិនមានការសមគំនិតនៅភូមិភាគបូព៌ាជាមួយវៀតណាមទេកាលណោះនោះ គ្រាន់តែជាការភ័យខ្លាចទេ។

**ស៖** ហេតុអីបានជាគាត់រត់គេចខ្លួន ហើយគាត់ត្រឡប់មកវិញ គាត់ក្លាយទៅជាប្រធានប្រមុខរដ្ឋដំបូងរបស់រដ្ឋកម្ពុជានោះ?

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំនឹងផ្តល់ឱកាសទាក់ទងទៅនឹងខ្លឹមសារ ហើយអត្ថបទសារព័ត៌មាន។ ខ្ញុំឃើញថា សំណួរចុងក្រោយហ្នឹងមិនពាក់ព័ន្ធនឹងសំណុំរឿងទេ ដែលនិយាយទ្រឹស្តីនៃការសមគំនិតក្រោយឆ្នាំ១៩៧៩ ។ល។ ហើយនិងមុនហ្នឹង។ ហើយមេធាវីការពារដូចជាឃ្លាឆ្ងាយពីប្រធានបទនៃសំណុំរឿងនេះឆ្ងាយពេក។ សូមជំទាស់។

**លោក វ៉ិចទ័រ កូប៉េ៖**

នេះជាការជំទាស់គួរឲ្យចាប់អារម្មណ៍ណាស់។ យើងនិយាយអំពីអំពើភ័យខ្លាចរបស់ថ្នាក់ដឹកនាំ ហើយនិងការបោសសម្អាត ហើយយើងរកឲ្យឃើញទំនាក់ទំនងថា ខ្មាំងផ្ទៃក្រៅនិងខាងក្នុង ដែលខ្មែរក្រហមសំដៅថាវៀតណាមនោះ ដែលថា -- ដែលធ្វើឲ្យលោក ហេង សំរិន កាលនោះគាត់ភ័យខ្លាចគាត់រត់ទៅ ហើយក្រោយមកគាត់ក្លាយទៅជាប្រមុខរដ្ឋដែលកើតក្រោយមកនោះ។ ហើយខ្ញុំគិតថា នេះវាស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះនេះដែរ ចំពោះព័ត៌មាន និងអ្វីដែលយើងដឹងនោះ។

[០៩:៥៥:១៥]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥៦:០០]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា គឺមានមូលហេតុសមស្រប ដោយសារវាជាសំណួរក្រៅអង្គហេតុ ដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការ ក៏ដូចជាយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។ ដូច្នេះ គឺសំណួរនេះ គឺពិតជាក្រៅអង្គហេតុ។ សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយមេធាវីការពារក្តី សួរចុងក្រោយអំម្បាញ់មិញនេះទេ។ លោកមេធាវីបន្តការតាំងសំណួរថ្មី។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំនឹងធ្វើតាមការសម្រេច និងណែនាំនេះ លោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទឥឡូវនេះ យើងនិយាយអំពីការគំរាមកំហែងពីខាងក្រៅរបស់វៀតណាម ដែលថារបបកម្ពុជាប្រជាធិបតេយ្យគេគិតបែបនេះ។ ហើយខ្ញុំចង់ព្យាយាមសួរលោកអំពីអ្វីដែលលោកនិយាយពីម្សិល

មិញ អំពីមនោគមន៍វិជ្ជា។ ខ្ញុំសូមសួរតទៅនេះ : តើការគំរាមកំហែងមកពីវៀតណាមមកលើកម្ពុជាប្រជាធិបតេយ្យនោះ គឺជាកត្តាសំខាន់ ឬក៏កត្តាសំខាន់បំផុត ដែលថាអ្វីៗជាកំហុសរបស់កម្ពុជាប្រជាធិបតេយ្យ ដែលបន្ទាប់មកដែលលោកបាននិយាយថា ដែលជាមូលហេតុដ៏ចម្បងមួយដែលគេចាត់ការហ្នឹង។ តើការគំរាមកំហែងហ្នឹង ជាកត្តាសំខាន់ដែលនាំឲ្យមានការអន្តរាយជាជាងសង្គ្រាមស៊ីវិល ជាជាងការទម្លាក់គ្រាប់បែកលឿនរបស់អាមេរិកាំង លឿន ហើយខ្លាំង ហើយដោយសារការអប់រំទាបរបស់កម្មា-ភិបាលថ្នាក់ក្រោម ហើយលោកក៏ប្រើពាក្យថា "អសមត្ថភាពរបស់ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ"។ អ៊ីចឹងគឺថាការគំរាមកំហែងរបស់វៀតណាមជាកត្តាសំខាន់។ តើកត្តាទាំងអស់នេះ គឺត្រូវបានធ្វើឲ្យបដិវត្តន៍មានមូលហេតុដ៏ល្អបំផុត ដែលធ្វើឲ្យបដិវត្តន៍ហ្នឹងដួលរំលំដែរឬទេ?

[០៩:៥៨:៣២]

**លោក ហ្វីលីព ស្ហូត៖**

**ឆ៖** ទោះបីជាមិនទាំងអស់ក៏ដោយ គឺថាយ៉ាងហោចណាស់ មួយ ឬពីរនៅក្នុងហ្នឹង ដែលធ្វើឲ្យបដិវត្តន៍ដួលរំលំ គឺថា គឺវា គឺគំនិតតែមួយរបស់ខ្លួន គឺថាការអនុវត្តដោយមិនមានការពិចារណាអំពីការឈឺចាប់ ដែលកើតមាន គឺថាគេគិតតែពីទិសដៅ ពីផែនការរបស់គេ។ ហើយពួកគេបានអនុវត្តដោយមិនប្រើលើសមត្ថភាព ហើយកម្មាភិបាលមិនមានការអប់រំគ្រប់គ្រាន់ខ្ពស់ទេ។ នេះជា -- យើងម្សិលមិញយើងនិយាយយោងបន្តិចអំពីកម្ពុជាប្រជាធិបតេយ្យរៀនពីចិន ដែលខ្ញុំយល់ថាជាចំណុចសំខាន់។ គំនិតចិននោះ គឺថាវាមានសារៈសំខាន់ ដែលថាឆន្ទៈនយោបាយ វាមានសារៈសំខាន់យុទ្ធវិធីខាងនយោបាយនៅក្នុងការប្រើកសិករ ហើយនិងពលករ ឲ្យធ្វើការងារដែលគេមិនសូវយល់ដឹងច្រើនហ្នឹង។ នេះជាគំនិតត្រឹមត្រូវ ប៉ុន្តែគេមិនបានអនុវត្តគ្រប់គ្រងឲ្យត្រឹមត្រូវទេ។ ហើយគេដាក់សម្ពាធទៅលើការគំរាមកំហែងដែលក្នុងចិត្តគំនិតគេថាមានពីវៀតណាមហ្នឹង។ នេះហើយជាចំណុចដែលនាំឲ្យមានការតានតឹង។ មូលដ្ឋានដែលលោកនិយាយហ្នឹង ដែលខ្ញុំហៅថាជាវិធីដែលអមនុស្សធម៌ឃោរឃៅដែលគេប្រើហ្នឹង គឺគេបានដាក់ឲ្យអនុវត្ត ហើយធ្វើឲ្យស្ថានភាពហ្នឹងមិនត្រឹមអាក្រក់ ប៉ុន្តែវាមហាអាក្រក់ទៅទៀតនោះ។

[១០:០០:២៤]

**ស៖** ចុងក្រោយអំពីបញ្ហា អំពីមនោគមន៍វិជ្ជាធៀបទៅនឹងឥទ្ធិពលពីខាងក្រៅ ឬក៏កត្តាខាងក្រៅ។ ម្សិលមិញ ថ្ងៃម្សិលមិញ លោកប្រើពាក្យថា "*ស្តេវស្តេត*" គឺរដ្ឋទាសករ។ ខ្ញុំជឿថា ប្រហែលជាខ្ញុំយល់ខុស ប៉ុន្តែខ្ញុំគិតទៅដល់មនុស្សដែលសរសេរអំពីកម្ពុជាប្រជាធិបតេយ្យហ្នឹង អ្នកទាំងអស់នោះមិន

ដែលប្រើពាក្យដូចលោកប្រើទេថា "រដ្ឋទាសករ" នោះ។ ប៉ុន្តែខ្ញុំចង់ឲ្យលោកបំភ្លឺ តើពាក្យថា "រដ្ឋទាសករ"ហ្នឹង លោកយកមកពីគំនិតរបស់ ឡេនីន ឬយ៉ាងក៏យ៉ាងដូចម្ដេច? ផ្អែកតាមគំនិត ឡេនីន ឬក៏ផ្អែកលើអ្វី?

ឡេនីន នោះនិយាយដូចខាងក្រោមនេះថា សូមដកស្រង់ "សេរីភាព ហើយនិងសង្គមនាយទុនហ្នឹងគឺស្ថិតនៅដូចដដែល។ ហើយចង់ឲ្យមានសេរីភាពពីម្ចាស់នៃទាសករ"។ អាហ្នឹងទស្សនៈរបស់ឡេនីន។ លោក ស្បូត តើលោកយើងអាចជជែកគ្នាបានទេ គឺទិដ្ឋភាពហ្នឹងវាកើតទេនៅក្នុងមុនឆ្នាំ១៩៧៥ ជាពិសេស តើការអនុវត្តទាំងអស់នោះលោកអាចនឹងប្រើថា ខ្មែរក្រហមហ្នឹងបានប្រើរដ្ឋទាសករបែបឡេនីន ដែរឬទេ?

**ឆ៖** ខ្ញុំយល់ស្រប នឹងយល់ស្របដែលថាលក្ខខណ្ឌកសិករក្របំផុតនៅកម្ពុជាមុនឆ្នាំ១៩៧៥ហ្នឹងគឺលំបាកណាស់។ នេះហើយអាចជាយុត្តិកម្ម ជាមូលហេតុដែលនាំឲ្យបដិវត្តន៍ហ្នឹងឈានទៅដល់ការគ្រប់ បើយើងប្រៀបធៀបទៅនឹងរាជរដ្ឋាភិបាលពីមុនៗ មុនឆ្នាំ១៩៧៥ហ្នឹង គេមិនបានធ្វើអ្វីដើម្បីឲ្យកែប្រែស្ថានភាពអ្នកក្រហ្នឹងឲ្យផ្ទាល់ទេ។ ខ្ញុំអាចនឹងហៅថាជារដ្ឋទាសករ គឺវាមិនជារដ្ឋ វាខុសពីរដ្ឋសក្តិភូមិ ទោះបីជារដ្ឋហ្នឹងមានជនក្រីក្រ មានសេរីភាពមួយចំនួន។

ប៉ុន្តែក្រោយឆ្នាំ១៩៧៥ អ្នកក្រទាំងអស់នោះ គឺមិនមានសិទ្ធិទេ ខ្ញុំមិនប្រើនិយមន័យរបស់ឡេនីនថាជារដ្ឋទាសករទេ។ យើងអាចនឹងជជែកគ្នាយូរបាននៅក្នុងប្រធានបទនេះ បើមានពេល។ ប៉ុន្តែខ្ញុំនិយាយថារដ្ឋទាសករនៅក្នុងន័យកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺថាប្រជាជនកសិករហ្នឹងគឺគ្មានសិទ្ធិសេរីភាពអ្វីទាំងអស់។

[១០:០៣:៣៩]

**ស៖** តើមនោគមន៍វិជ្ជាទាំងពីរនេះ វាប៉ះទង្គិចគ្នាទេដែលថាមួយ គឺគេ -- មួយទៀតគេប្រយុទ្ធប្រឆាំងដើម្បីទស្សនរបស់កម្មករកសិករ ហើយមួយទៀតគឺគេប្រយុទ្ធប្រឆាំងដើម្បីបំបាត់សក្តិភូមិនាយទុន។ ឥឡូវនេះខ្ញុំទុកបញ្ហានេះមួយឡែក ឥឡូវចូលទៅដល់ពិភាក្សាបញ្ហាមួយទៀតអំពីកត្តាខាងក្រៅមួយទៀតដែលដើរតួសំខាន់នៅក្នុងកម្ពុជាប្រជាធិបតេយ្យនោះ ដែលលោកហៅថាការអប់រំទាបរបស់កម្មាភិបាលថ្នាក់ក្រោម។ អ្វីៗដែលលោកបានឮគ្រប់ពេលអំពីបទពិសោធន៍ដែលបានដឹង ដែលថាអ្នកផ្សេងហ្នឹងគឺមិនដឹងគិតមិនដល់ គឺយើងគិតថា តែងតែផ្អែកលើឧទាហរណ៍ដែលថាសម័យនោះគេមិនអនុញ្ញាតឲ្យមនុស្សពាក់វ៉ែនតាមីញ៉ូប ឬវ៉ែនតាអីទេ។ បើអ្នកណាពាក់ គេចោទថានាយទុន សក្តិភូមិអីជាដើម។

ប៉ុន្តែលោកបានសរសេរពីរឿងនេះនៅក្នុងសៀវភៅរបស់លោក។ តើលោកយល់ស្របជាមួយខ្ញុំទេ មិនមានអ្វីកើតមានឡើងទេនៅក្នុងកម្ពុជាប្រជាធិបតេយ្យថាជាការបញ្ជាជានយោបាយរបស់គណៈអចិន្ត្រៃយ៍របស់មជ្ឈិមក្តី គឺថា អាចនឹងណែនាំថាបើអ្នកណាពាក់វ៉ែនតាមីញូបអីក៏ដោយ គឺមានការបញ្ជាពីមជ្ឈិមថាត្រូវតែសម្លាប់អ្នកទាំងនោះ ចាប់អ្នកទាំងនោះ ឬក៏ថាឧទាហរណ៍នៅក្នុងឧទាហរណ៍ត្រូវសម្លាប់អ្នកណាក៏ដោយឲ្យតែលួចម្ហូបអាហារចំណីអីហ្នឹង។ តើមានភាពខុសគ្នាឆ្ងាយដែរឬទេរវាងទស្សនវិស័យរបស់ថ្នាក់ដឹកនាំកំពូលរបស់របបកម្ពុជាប្រជាធិបតេយ្យ ហើយនិងផ្នត់គំនិតរបស់កម្មាភិបាលថ្នាក់ក្រោមក្នុងការអនុវត្តការកាប់សម្លាប់នេះ។ តើលោកអាចពន្យល់អ្វីបន្ថែមទេ?

[១០:០៥:៥៥]

**ឆ៖** មិនប្រាកដជាដូច្នេះទេ បើសិនណាជាមានការប្រកាសតែមនោគមន៍វិជ្ជា។ ឧទាហរណ៍ថានៅក្នុងទង់បដិវត្តតាមរយៈមធ្យោបាយណាមួយនោះ ដែលថារបបនេះ គឺថាប្តេជ្ញាដើម្បីបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជនចោល។ ដូច្នេះវាគេយល់ជាលក្ខណៈទូទៅថា បុគ្គលណាក៏ដោយគឺថាត្រូវតែប្រឆាំងឬជំទាស់ទៅនឹងទ្រព្យឯកជន មិនអនុញ្ញាតឲ្យអ្នកណាបេះផ្លែឈើ លួចផ្លែឈើអីនោះទេ។ វាមានភាពស៊ីសង្វាក់គ្នាសម្រាប់លទ្ធភាពទទួលបានអ្វីមួយ។ អ្វីក៏ដោយ គឺថាគេធ្វើទៅតាមគោលការណ៍ណែនាំរបស់ថ្នាក់មជ្ឈិម។ ឧទាហរណ៍ថាគោលការណ៍កម្មេច។ ដូចធ្វើដូច្នេះបុគ្គលម្នាក់ៗគេអាចរស់នៅក្នុងបក្សបាន ដោយមិនមានអត្តចរិតជាលក្ខណៈបុគ្គលនោះទេ។

[១០:០៧:០៤]

**ស៖** ខ្ញុំនៅតែមិនយល់។ ឥឡូវសូមនិយាយអំពីរឿងការពាក់វ៉ែនតាវិញ។ ថាតើថ្នាក់ដឹកនាំបក្សកុម្មុយនីស្តហ្នឹងគិតយ៉ាងម៉េចចំពោះបណ្តាបុគ្គលដែលរស់នៅតាមបណ្តាខេត្តផ្សេង។ តើគេនិយាយថាម៉េចដែរចំពោះអ្នកដែលពាក់វ៉ែនតានោះ?

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវី អ៎! លោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមជំទាស់។ គាត់សួរថាតើមេដឹកនាំត្រូវទទួលខុសត្រូវយ៉ាងម៉េចដែរចំពោះកម្មាភិបាលថ្នាក់ក្រោមនោះ? គឺមិនមែនសួរទៅអ្នកជំនាញបែបនេះទេ។

**លោក វិចទ័រ កូប៉េះ**

គឺថាវាមានការទទួលខុសត្រូវតាមផ្លូវច្បាប់ និងការមិនទទួលខុសត្រូវតាមផ្លូវច្បាប់។

លោកប្រធាន ខ្ញុំកំពុងតែសួរតទល់ជាមួយនឹងអ្នកជំនាញ។

[១០:០៨:០៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:០៨:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាមិនសមស្របទេ មិនមានមូលដ្ឋានគ្រប់គ្រាន់ទេ។ សាក្សី អ្នកជំនាញឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយមេធាវីការពារក្តីលោក នួន ជា ចុងក្រោយអម្បាញ់មិញនេះ!

**លោក ហ្វីលីព ស្សូត៖**

**ឆ៖** ខ្ញុំគិតថាវាមានពីរចំណុចឆ្លើយតបទៅនឹងបញ្ហានេះ។ ដើម្បីឆ្លើយទៅនឹងសំណួរជាក់លាក់របស់លោក គឺថាអត់ទេ មិនមានសេចក្តីណែនាំជាលក្ខណ៍អក្សរទេ។ ខ្ញុំមិនយល់ថាគេអាចនឹងប្រាប់រឿងនេះទៅ នួន ជា ឬក៏មេដឹកនាំផ្សេងទៀត ដែលថាអ្នកដែលពាក់វ៉ែនតាគឺថានឹងមានបញ្ហាហើយប្រជាជនណាពាក់វ៉ែនតានឹងប្រឈមមុខនឹងបញ្ហា អាចត្រូវសម្លាប់ ឬក៏យ៉ាងណានោះ។ យើងដឹងថាមានតែជំនាន់ខ្មែរឥស្សរៈ អ្នកដែលពាក់វ៉ែនតាក៏ត្រូវគេកំណត់ជាមុខព្រួញអ៊ីចឹងដែរ។

[១០:១០:០២]

តាមដែលខ្ញុំយល់ កម្មាភិបាលខ្មែរក្រហមនោះ គឺថាវាកើតចេញពីមកពីកសិករក្រីក្រគេចាត់ទុកថា អ្នកមាន និងអ្នកចេះដឹងគឺដូចគ្នា។ ទី១ គឺពាក់វ៉ែនតា ទាំងអ្នកមានការអប់រំរៀនខ្ពស់ គឺថាមើលងាយពួកគេ។ ហេតុដូច្នេះឯងបានជាគេចាត់ទុកថាអ្នកពាក់វ៉ែនតាហ្នឹងជាខ្មាំងអាចប្រឈមមុខនឹងភាពប្រទូសរ៉ាយនេះហើយ។ វាអាចមានលទ្ធភាពដែលថា នួន ជា ក៏ដូចមេដឹកនាំផ្សេងទៀតដែលគេបានដឹងថារឿងបែបហ្នឹង កើតឡើងដើម្បីដាក់ចេញសេចក្តីណែនាំថា “នេះ! ការធ្វើបែបហ្នឹងមិនគួរឲ្យកើតមានតទៅទៀតទេ” ប៉ុន្តែខ្លួនធ្វេសប្រហែសមិនបានធ្វើអ៊ីចឹងទេ។

**សៈ** ប្រហែលជាពួកគេមិនបានដឹង។ គឺលោកលើកឡើងយោងសំដៅទៅលើខ្មែរឥស្សរៈដែលអនុវត្តរបៀបដូចគ្នាហ្នឹង។ ថាតើការអនុវត្តហ្នឹងអាចកើតឡើងនៅទសវត្សរ៍៤០ ទសវត្សរ៍៥០ ដែរឬទេ?

ដូចជាថាវាមិនមានការស៊ីសង្វាក់គ្នារវាងគោលនយោបាយ និងការកាប់សម្លាប់ដូចជាកាប់ សម្លាប់អ្នកពាក់វ៉ែនតានៅទសវត្សរ៍៥០ ជាដើម។ ហេតុម៉េចបានជាវាកើតនៅក្នុង ៧៥ ដល់ ៧៩? ថាតើវាអាចពាក់ព័ន្ធទៅនឹងគោលនយោបាយខ្មែរក្រហមដែរឬក៏យ៉ាងណា?

[១០:១១:៣៩]

**ឆ៖** ដោយសារវាតួនាទីរបស់រដ្ឋាភិបាលត្រូវហាមឃាត់ការប្រព្រឹត្តិអំពើអាក្រក់ៗដើម្បីធានាថាប្រជាពលរដ្ឋអាចរស់រានមានជីវិតពីបទល្មើសណាមួយនេះ។ ការខកខានជាប្រព័ន្ធដោយរបបខ្មែរក្រហមក្នុងការហាមឃាត់ប្រជាជនក្នុងការអនុវត្តបែបហ្នឹង ឧទាហរណ៍អ្នកដែលពាក់វ៉ែនតានេះជារឿងមួយ។ ប៉ុន្តែនិយាយជារួមតែម្តង ថាតើថ្នាក់ដឹកនាំមានចេតនាធ្វើដូច្នេះទេ បើធ្វើដូច្នេះត្រូវតែដាក់ចេញនូវគោលនយោបាយដើម្បីទប់ស្កាត់រឿងហ្នឹង។ តែគេមិនបានធ្វើដូច្នេះទេ។

**ស៖** ខ្ញុំយល់ចំណុចរបស់លោក លោក ហ្វីលីព ស្បត។ នេះគឺឆ្នាំ១៩៧៥ ហើយប្រទេសកម្ពុជាមិនមានអ៊ីនធឺណេត, មិនមានទូរទស្សន៍, ហើយខ្ញុំយល់ឃើញថាសម័យនោះមិនមានរបស់របរទាំងអស់នេះទេ។ តើលោកអាចពន្យល់បានទេ ថាតើមេដឹកនាំធ្វើម៉េចអាចដឹងថាការអនុវត្តនៅថ្នាក់មូលដ្ឋានហ្នឹងធ្វើដោយរបៀបនេះ ឧទាហរណ៍ថាការអនុវត្តចំពោះអ្នកពាក់វ៉ែនតានោះ?

[១០:១២:៥២]

**ឆ៖** យើងហាក់បីដូចជាស្ថិតនៅក្នុងស្ថានភាពមួយប៉ាន់ស្មានៗហើយ ស្មានៗហើយ។ នួន ជា ក៏ដូចជាមេដឹកនាំភូមិភាគ ឬក៏មេដឹកនាំតំបន់ បានដឹងថាតើកសិករមានបំណងប្រតិកម្មបែបណានេះ។ ក៏ប៉ុន្តែខ្ញុំមិនដែលឃើញតេឡេក្រាមណាមួយនិយាយអំពីរឿងដាក់លាក់ហ្នឹងទេ។ តែយើងឃើញតេឡេក្រាមនៅក្នុងបណ្ណសារកម្ពុជាមានការរាយការណ៍ពីបណ្តាខេត្តផ្សេងៗ រាយការណ៍លម្អិតតែម្តង។ មានការរាយការណ៍ច្រើនណាស់តាមសារទូរលេខអំពីការប្រព្រឹត្តិអំពើអាក្រក់ ឬក៏មានដំណើរការមិនត្រឹមត្រូវ អ្វីដែលធ្វើដំណើរទៅមុខទៅបានជឿនលឿន។ មេដឹកនាំហ្នឹងបានដឹងថាអ្វីដែលកើតឡើងហើយ។ ដូចដែលបានលើកឡើងហើយប្រហែលជាគេគិតឃើញថាចំណុចផ្សេងទៀតវាអាចសំខាន់ជាងរឿងហ្នឹង។ ឧទាហរណ៍ថា ការរក្សាសណ្តាប់ធ្នាប់សាធារណៈ ការរក្សាបរិស្ថានអីជាដើមសម្រាប់ប្រជាពលរដ្ឋ។

**ស៖** ខ្ញុំកំពុងមើលនាឡិកាលោក ហ្វីលីព ស្បត។ ខ្ញុំមានបញ្ហាពីរបីទៀតដើម្បីសាកសួរលោក។ បញ្ហាមួយគឺសំណួរពាក់ព័ន្ធទៅនឹងការសម្លាប់នៅមន្ទីរសន្តិសុខស-២១ ឯកសារយោងនៅក្នុងសៀវភៅរបស់លោកដែលលោកបានហៅថាស-២១ ជាកន្លែងមួយដ៏អាក្រក់បំផុតសម្រាប់ទសវត្សរ៍នោះ។ ហើយ

ថាតើលោកអាចរកឃើញស្ថាប័នណាមួយនៅក្នុងរដ្ឋដែលប្រព្រឹត្តអំពើបែបហ្នឹងដូចជានៅ អាល់ហ្សេរី អីជាដើម។ល។ តើស-២១នេះជាស្ថាប័នមួយដូចនៅបណ្តាប្រទេសទាំងអស់ហ្នឹងដូចជាសហភាពសូវៀត ចិន ជាដើម ។ល។ ម្យ៉ាងវិញទៀត ហេតុអ្វីបានជាថាស-២១ហ្នឹង វាគឺជាកន្លែងដ៏អាក្រក់សម្រាប់ខ្មែរក្រហមនោះ?

[១០:១៥:០៤]

**ឆ៖** ខ្ញុំថាស្ថាប័នស្រដៀងគ្នានេះវាកើតមានឡើងមិនមែននៅប្រទេសចិនទេ មិនមែនពិត គឺមានប្រព័ន្ធផ្សេងនៅចិននោះ។ នៅសហភាពសូវៀតគឺក៏មានខុសគ្នា ប៉ុន្តែនៅអាហ្សង់ទីននេះ គឺមានការប្រៀបធៀប ហើយក៏អ្វីដូចរបបបារាំងបានធ្វើប្រព្រឹត្តឡើងនៅក្នុងប្រទេសអាល់ហ្សេរីផងដែរ ដែលមានស្ថាប័នដូចគ្នាទៅនឹងស-២១ ដែលគេធ្វើទារុណកម្ម ដើម្បីយកចម្លើយ បន្ទាប់មកសម្លាប់ចោល ដើម្បីថាកម្ចាត់ចោលតែម្តងកុំឱ្យរស់នៅតទៅទៀត ហើយកុំបាច់មិនបាច់ដោះសារអីនោះទេ។ ដូច្នេះវាជាលក្ខណៈចម្លែកមួយ ប៉ុន្តែក្នុងប្រព័ន្ធបារាំងនៅក្នុងប្រទេសអាល់ហ្សេរី, នៅអាហ្សង់ទីន ស្ថាប័នទាំងនេះគឺមិនមែនជាស្ថាប័នស្នូលសម្រាប់ប្រព័ន្ធនោះទេ យើងប្រើពាក្យថា "*ភិនណាខល*" គឺថាអាក្រក់បំផុតនោះ វាជាជ្រុងមួយដ៏ងងឹត។ ខ្ញុំគិតថានៅក្នុងកម្ពុជាប្រជាធិបតេយ្យ, ស-២១, ដែល ហើយនិងមន្ទីរសន្តិសុខផ្សេងទៀតដែលដល់អ្នកខ្លះគឺនៅតែជាអ្នកដែលមានតួនាទីខ្ពង់ខ្ពស់ ផ្ញើ បញ្ជូនមនុស្សមក ស-២១។ ប្រព័ន្ធនេះវាជាចំណុចស្នូលតែម្តង។

**ស៖** គឺអាចយ៉ាងដូច្នោះ គឺមិនមែនវាថា ពាក្យថា "អាក្រក់បំផុត" ដែលលោកប្រើពាក្យ "*ភិនណាខល*" នៅក្នុងសៀវភៅរបស់លោកនេះ។ វាជាខ្សែចង្វាក់សន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យនោះ។

[១០:១៦:៥៧]

**ឆ៖** ស-២១ វាជាកន្លែងមួយដែលគេដាក់គុក ដាក់ច្រវាក់ ហើយដាក់ខ្នោះឃ្នាង ធ្វើទារុណកម្មសម្លាប់អ្នកដែលគេរកឃើញថាវាជាអ្នកជំទាស់ គឺជាចំណុចស្នូលហើយ ជាចំណុចសំខាន់ហើយ។ ដោយសារកាលនោះមិនមានតុលាការ មិនមានលទ្ធភាពណាផ្សេងទៀត មធ្យោបាយណាផ្សេង ដោះស្រាយជាមួយអ្នកដែលជំទាស់ជាមួយនឹងខ្លាំង។ សូម្បីនៅអាហ្សង់ទីនក៏ដោយ គឺថាគេមានតុលាការ គេមានជម្រើសមួយផ្សេង។ នៅបារាំងដែលប្រព្រឹត្តនៅអាល់ហ្សេរី គេមានតុលាការ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនមានតុលាការទេ។ ចំណុចសំខាន់នៃរបបនេះ គឺដើម្បីការពារខ្លួនពីពួកប្រឆាំងនោះ គឺ

មានបណ្តាញដែលចុះពីខាងក្រោម ស-២១ បែកខ្ញែកពី ស-២១ គឺខ្ញុំយល់ថាប្រទេសនោះក៏មានស្ថាប័នស្រដៀងនេះដែរ។

[១០:១៨:០១]

**ស៖** ខ្ញុំសូមសួរសំណួរបន្តទៅ និយាយអំពីបច្ច័យដែលកើតចេញពី ស-២១ នេះ កើតចេញពីការធ្វើទារុណកម្ម សួរចម្លើយនេះ។ នៅក្នុងសៀវភៅរបស់លោក លោកប្រើពាក្យ "ជួនកាលយ៉ាងទូលំទូលាយ" គឺថាចម្លើយសារភាពទាំងនោះ ដើម្បីបញ្ជាក់នូវចំណុចណាមួយ។ ប៉ុន្តែចំណុចខ្លះក្នុងសៀវភៅរបស់លោក លោកថា ប៉ុល ពត គឺថាបានសំអាងខ្លាំងពេកទៅលើចម្លើយសារភាពហ្នឹង មិនសំអាងខ្លាំងណាស់ណាទៅលើចម្លើយ -- សូមកែប្រែ -- មិនសំអាងណាស់ណាទៅលើចម្លើយសារភាពទេ។ លោកសរសេរថាអ៊ីចឹង។ អ៊ីចឹងសំណួរទៅលើវិធីសាស្ត្ររបស់លោកនៅពេលណាយកចម្លើយសារភាពហ្នឹងមកនិយាយ តើលោកអាចអះអាងបានទេ លោកប្រើព័ត៌មានហ្នឹងថាវាពិត ឬក៏មិនពិត ឬយ៉ាងណានោះគឺដោយរបៀបណា?

**ឆ៖** ជាសំណួរមួយដ៏ល្អ។ ពិតហើយខ្ញុំបានធ្វើដូច្នេះ ប្រសិនណាជាលោកមើលសម្រង់របស់ខ្ញុំពីចម្លើយសារភាពហ្នឹងមក មានអង្គហេតុលម្អិត ការបញ្ជាក់ គឺថាព្រឹត្តិការណ៍កើតឡើងនៅពេលនេះពេលនោះ កើតមានទៅលើក្រុមមនុស្សនេះ។ ខ្ញុំថាចម្លើយសារភាពនេះ គឺគ្រាន់តែចំណុចមួយដែលខ្ញុំគិតឃើញថាវាមិនមែនពាក់ព័ន្ធទៅនឹងហេតុផលនយោបាយទេ ហើយមិនអាចយកមកប្រើប្រាស់ ដើម្បីបញ្ហានយោបាយនោះបានទេ។

[១០:១៩:៤៩]

**ស៖** បាទ ជាការពិតណាស់ដោយសារលោកមានសៀវភៅ ថាតើលោកដឹងដោយរបៀបណា?

**ឆ៖** នេះគឺជាការងាររបស់អ្នកសរសេរប្រវត្តិរូប ឬក៏អ្នកប្រវត្តិសាស្ត្រ ដែលត្រូវធ្វើអ៊ីចឹង។

**ស៖** បាទ ខ្ញុំសូមបន្តទៅទៀត។ លោក ហ្វីលីព ស្សូត ចំពោះ នួន ជា នេះសក្ខីកម្មខាងដើមរបស់លោកតាមការយល់ឃើញរបស់លោក គាត់មិនមែនជា នួន ជា មិនមែនជាសមាជិកគណៈកម្មការកងទ័ពទេ។ លោកអាចរៀបរាប់លម្អិតបានទេ ហេតុអីបានជាយោបល់របស់លោកយល់ឃើញយ៉ាងដូច្នេះ?

**ឆ៖** ដោយសារខ្ញុំបានរកឃើញឈ្មោះរបស់គាត់អត់មាននៅក្នុងឯកសារណាមួយទាក់ទងទៅនឹងគណៈកម្មាធិការយោធាទេ។ គឺជាទូទៅមិនពាក់ព័ន្ធនឹងបញ្ហានេះ គាត់មានវត្តមាននៅក្នុងកិច្ចប្រជុំ

គាត់និយាយអំពីបញ្ហាសង្គ្រាមជាមួយវៀតណាម ប៉ុន្តែការចូលរួមរបស់គាត់ គឺវាពាក់ព័ន្ធតែទៅនឹងការពាក់ព័ន្ធផ្នែកនយោបាយ ទំនាក់ទំនងផ្នែកនយោបាយទេ។ មិនមានភស្តុតាងណាដែលចងភ្ជាប់គាត់ទៅនឹងគណៈកម្មាធិការហ្នឹង ហើយក៏មិនមានឯកសារបញ្ជាក់ថា គាត់មានពាក់ព័ន្ធនៅក្នុងរចនាសម្ព័ន្ធកងទ័ពនេះ។ ខ្ញុំគិតថា គាត់មិនមានទេ។

[១០:២១:២១]

**ស៖** ដូច្នេះតាមដែលលោកនិយាយ គឺគាត់មិនមានអ្វីពាក់ព័ន្ធទៅនឹងគោលនយោបាយដែលត្រូវដោះស្រាយជាមួយទាហាន លន់ នល់ ឬក៏យ៉ាងណានោះទេ។ លោកគឺចង់និយាយថាអ៊ីចឹង?

**ឆ៖** បញ្ហាកងទ័ព គឺជាបញ្ហាពាក់ព័ន្ធទៅនឹងការពង្រាយទ័ព យកជ័យជម្នះនៅក្នុងសង្គ្រាម ដាក់ចេញនូវយុទ្ធសាស្ត្រប្រយុទ្ធ។ គាត់ពាក់ព័ន្ធទៅនឹងបញ្ហានយោបាយ ហើយបញ្ហានយោបាយនេះក៏វាពាក់ព័ន្ធទៅរឿងហ្នឹងដែរ។

**ស៖** ប៉ុន្តែប្រហែលជាក្រោយឆ្នាំ៧៥ ទេ លោកអ្នកជំនាញ មិនមែនមុន៧៥ ទេ។ គាត់អត់មានអំណាចអីទេ ហើយគាត់និយាយថា មុនឆ្នាំ៧៥ កងទ័ព លន់ នល់ គឺថាត្រូវសម្លាប់ ហើយអង្គាល់នោះគឺថាមិនមានការទុកនៅគេហៅ ឈ្លើយសឹកនោះទេ?

[១០:២២:២៦]

**ឆ៖** បាទ នេះគឺជាបញ្ហានយោបាយមួយហើយ បើមើលទៅប្រទេសចិនវិញ ដែល ម៉ៅ នោះដាក់គោនយោបាយចុះមកក្រោម ជាគោលនយោបាយៗដែលព្យាយាម គឺថាអូសទាញពួកទាហានខាងខ្មាំងពីថ្នាក់ទាបៗមក ហើយនិងគឺជាស្ទីលដែលកុម្មុយនីស្តចិនធ្វើយ៉ាងហ្នឹង។ អ្វីៗដើម្បីយកជ័យជម្នះគឺវាជារឿងនយោបាយ គឺការឈ្នះខាងផ្នែកយោធាក៏ត្រូវចូលរួមនៅក្នុងការអូសទាញផ្នែកនយោបាយដែរ។

**ស៖** ចំណុចមួយទៀតដែលខ្ញុំមានចំណាប់អារម្មណ៍លោកដឹងហើយនៅក្នុងឆ្នាំ១៩៧៩ កងទ័ពវៀតណាម -- វៀតណាម គឺថាបង្កើត គេហៅថា សវនាការថ្កុកល្ខោនមួយ។ តើលោកមានគំនិតយោបល់ហេតុអ្វីបានជាវៀតណាមនោះ លើកឡើងពីឈ្មោះ នួន ជា ហើយនិងនៅក្នុងសវនាការហ្នឹងអត់មាននិយាយពីឈ្មោះ នួន ជា។ សវនាការហ្នឹង គេកាត់ទោសតែ ប៉ុល ពត ហើយនិង អៀង សារី។ ហើយសក្ខីកម្មរបស់លោក គឺថា នួន ជា គឺជាមនុស្សដែលបន្ទាប់ ប៉ុល ពត ជិតដិត ប៉ុល ពត គួរទទួលការចោទប្រកាន់ជាមនុស្សទី២។ ហេតុអ្វីក៏វៀតណាមកម្រិតបែបនេះ កាត់ទោសហ្នឹងកម្រិតបែបហ្នឹង?

[១០:២៣:៥២]

**ឆ៖** បាទ នេះជាប្រធានបទមួយគួរឲ្យចាប់អារម្មណ៍មែនទែន។ គឺថាយើងបានផ្ដល់គេហៅថា ជំនឿទុកចិត្តហ្នឹងទៅលើវៀតណាមមែន បន្ទាប់ពីនៅចុងទសវត្សរ៍៦០ នោះ។ ការពិតទៅ គឺថា ខ្ញុំភ្លេចកាលបរិច្ឆេទជាក់លាក់ហើយ ប៉ុន្តែនៅពេលណាមួយដែល ប៉ុល ពត បានលាលែងពីតំណែងជានាយករដ្ឋមន្ត្រី។ អៀង សារី បាត់មុខមួយរយៈ ហើយ នួន ជា ត្រូវបានចាត់តាំងជានាយករដ្ឋមន្ត្រីស្ដីទី ហើយ ឡេ យន់ បាននិយាយទៅកាន់ឯកអគ្គរដ្ឋទូតសូវៀត គឺថា នួន ជា ជាមនុស្សល្អណាស់។ កងទ័ពគឺថា គិតឃើញថា នួន ជា មនុស្សដែលមានសណ្ដានចិត្តជាមួយវៀតណាម ទទួលបានការបណ្ដុះបណ្ដាលពីបក្សកុម្មុយនីស្តវៀតណាមនៅក្នុងវៀតណាម គឺថាជាមនុស្សមួយដែល -- ដូច្នេះគេមានការយោបយល់ទៅដល់ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យមួយចំនួន មិនបាននិយាយពីឈ្មោះគាត់ទេនៅក្នុងសវនាការកាលនុំង។ ដោយសារគេរំពឹងថាដូច្នេះ នៅក្នុងពេលណាមួយអាចនឹងផ្សះផ្សាជាមួយនឹងខ្មែរក្រហមបានតាមរយៈ នួន ជា តែម្ដង។ ប៉ុន្តែការនេះ ជាការយល់ខុស ហ្នឹងគឺយល់ឃើញអ៊ីចឹង តែខុស។

[១០:២៥:១៨]

**ស៖** ចំណុចរបស់លោក គឺថាអាចវាមានសុពលភាព គឺមុន៧៩ តែក្រោយ៧៩ នៅពេលដែលគេមានបើកសវនាការបែបហ្នឹង។ កម្មាភិបាលភាគច្រើន គឺជាសមាជិក។ គេក្លាយជាសមាជិករបស់រដ្ឋាភិបាលកម្ពុជា ខ្ញុំអត់ចង់និយាយឈ្មោះម្ដងទៀតទេ ប៉ុន្តែយើងដឹងនិយាយពីរឿងណាហើយ។ ហើយជាការពិត មនុស្សដែលខ្ញុំមិនអាចនិយាយឈ្មោះបាននេះ គឺជាអង្គរក្សផ្ទាល់របស់ នួន ជា តែម្ដង។ ហេតុអីបានជានៅក្នុងសវនាការហ្នឹង រដ្ឋាភិបាលវៀតណាមមិននិយាយថា បន ប៉ុល ពត, បន នួន ជា បែបជានិយាយតែ បន ប៉ុល ពត, បន អៀង សារី តែប៉ុណ្ណឹង?

[១០:២៦:១៥]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំស្នាក់ស្ទើរបន្តិចក្នុងការធ្វើអន្តរាគមន៍ចំពោះការចោទសួររបស់នេះ។ ចំណុច គាត់សួរចុងក្រោយមិនពាក់ព័ន្ធ ថាហេតុអ្វីបានជាវៀតណាមបើកសវនាការកាត់ទោសរបបមួយជាក់លាក់ក្រោយឆ្នាំ១៩៧៩។ គឺអត់ពាក់ព័ន្ធទេលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំគិតឃើញថា អ្នកជំនាញមិនយល់ស្របទៅនឹងការជំទាស់របស់តំណាងសហព្រះរាជអាជ្ញានេះទេ។ ខ្ញុំសូមតាំងសំណួរផ្សេងទៅវិញ។ តើតាមការពិតទៅនោះ ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ ប្រហែលជា ប៉ុល ពត, អៀង សារី។ បាទ ជាបនពីរហ្នឹង និយាយតែពីរហ្នឹង ក្រៅពីនិយាយ ប៉ុល ពត និង នួន ជា មិននិយាយ ប៉ុល ពត និង នួន ជា ទៅវិញ។

**លោក ហ្វីលីព ស្សូត៖**

**ឆ៖** ខ្ញុំយល់ពីគោលបំណងនៃសំណួររបស់លោកនេះហើយ។ ខ្ញុំប្រហែលជាមិនអាចយល់ស្របជាមួយនឹងការនិយាយ -- លោកនិយាយនេះទេ។ បុគ្គលដែលថាជានីរសារ និងអង្គរក្ស កងការពារ នួន ជា នៅក្នុងទសវត្សរ៍៦០នោះ។ ថាតើគួរដឹងទេ ខ្ញុំគិតថាលោកកំពុងតែវាយតម្លៃ មើលស្រាលទៅលើបញ្ហានៃលាក់ការណ៍សម្ងាត់ ដែលខ្មែរក្រហមគេយល់ឃើញបែបហ្នឹង។ រដ្ឋាភិបាលវៀតណាម ថាតើគេដឹងថា នួន ជា មិនមែនជាមនុស្សរបស់គេ នៅពេលណា១គឺជារឿងមួយ។ ហើយដែលថា នួន ជា ជាមនុស្សផ្ទាល់ខ្លួនទី២របស់ ប៉ុល ពត។

[១០:២៨:១៩]

**ស៖** សូមអរគុណ។ គឺសំណួរពីរចុងក្រោយ ហើយសំណួរនេះ គឺរំឭកពីអ្វីដែលឆ្លើយពីម្សិលមិញ ចន្លោះពីរយៈពេលពី៧០ ទៅ៧៥។ លោកបានផ្តល់សក្ខីកម្មដែលបានលើកឡើងដូចតទៅថា៖ នេះគឺពីការបាញ់ផ្លោងនៅឧដុង្គ នៅឆ្នាំ១៩៧៤។ តាមសក្ខីកម្មរបស់គាត់គឺថា វាជាសង្គ្រាមចិត្តសាស្ត្រ ហើយនៅពេលហ្នឹង គឺមិន -- ពេលនោះ គឺថាលោកសរសេរថា ខាងកម្ពុជាប្រជា -- ខាងខ្មែរក្រហមនេះ មិនមានចេតនាអី ដើម្បីបញ្ចៀស កុំឲ្យមានការប៉ះពាល់ទៅដល់ជនស៊ីវិលនោះទេ។ តើលោកមានស្អីនិយាយបន្ថែមលើនេះទៀត?

**ឆ៖** ប្រសិនណាជាកងទ័ពពាក់ព័ន្ធទៅនឹងដូចជាប្រធានាធិបតី អាល់-អាសាត នៅស៊ីរីនេះជាដើមនេះ ពាក់ព័ន្ធទៅនឹងតំបន់ដែលមានប្រជាជនស៊ីវិលរស់នៅកកកុញបែបហ្នឹង គេអាចនិយាយបានយ៉ាងត្រឹមត្រូវហើយថា កងទ័ពហ្នឹងគឺព្យាយាមគំរាមកំហែងជនស៊ីវិលហើយ ហើយកងទ័ពហ្នឹង គឺថាមិនគិតអំពីបច្ច័យនៃការបាត់បង់អាយុជីវិតដ៏ច្រើននោះទេ។

[១០:២៩:៣៥]

**ស៖** តើលោកកំពុងតែស្មាន ឬក៏យ៉ាងណាលោកអ្នកជំនាញ? អ្វីដែលកើតឡើងដោយកងទ័ព

លន់ នល់ ធ្វើឡើងដោយកងទ័ព លន់ នល់។ ដោយសារវាជាសេចក្តីថ្លែងការណ៍ពីរដ៏ទូលំទូលាយនេះថាកម្ពុជាប្រជាធិបតេយ្យអត់គិតយោគយល់អំពីការរងរបួសស្នាមដោយជនស៊ីវិលនោះទេ។ លោកអាចបកស្រាយបានទេ រឿងនេះ?

[១០:៣០:០០]

**ឆ៖** ខ្ញុំគិតថាជាសេចក្តីសន្និដ្ឋានមួយស្របច្បាប់។ នៅក្នុងកាលៈទេសៈទាំងនោះ គេមិនត្រឹមបាច់ មិនត្រូវការបាញ់ផ្តោងទៅហ្នឹងទេ កន្លែង -- គេអាចឈ្នះសង្គ្រាមនៅកន្លែងផ្សេងទៀតក៏បានដែរ។ គោលបំណងអីទើបបាញ់ផ្តោងដាក់ទៅតែកន្លែងហ្នឹង ដែលមានជនស៊ីវិលរស់នៅយ៉ាងច្រើនបែបហ្នឹង? បាទ ចំណុចនេះគឺថាជាការងាររបស់អ្នកប្រវត្តិសាស្ត្រ ដែលសួរថាម៉េចក៏បានរឿងអីចឹងកើតឡើង។ ការណ៍ដែលអាចពន្យល់បាន -- រឿងដែលអាចពន្យល់បានគឺថាជាការគំរាមកំហែងនៅក្នុងកម្រិតមួយគឺថាបាញ់ផ្តោងចូលទៅកន្លែងជនស៊ីវិលរស់នៅតែម្តង។

**ស៖** សំណួរមួយចុងក្រោយលោកអ្នកជំនាញ លោកបានលើកឡើងពីខាងដើម ឆ្លើយតបទៅនឹងតំណាងសហព្រះរាជអាជ្ញា។ "ថានៅពេលមួយនោះ នៅឆ្នាំ៧៣ មានអ្នកកាសែតបានបាត់ខ្លួននៅក្នុងប្រទេសកម្ពុជា" ហើយលោកធ្វើសេចក្តីសន្និដ្ឋានថា នេះគឺជាចំណុចចាប់ផ្តើមនៃការកាប់សម្លាប់ជនបរទេស។ តើលោកអាចភ្ជាប់ទៅបញ្ហាហ្នឹងទៅនឹងអ្វីដែលកើតឡើងក្រោយពី១៧ មេសា ៧៥ ទេ នៅពេលដែលបរទេសទាំងអស់ គឺថាគេប្រមូលដាក់ស្ថានទូតបារាំង ហើយគេអនុញ្ញាតបញ្ជូនចេញទៅក្រៅប្រទេស? តើលោកយល់ថាម៉េចហ្នឹង?

[១០:៣១:៣៣]

**ឆ៖** មានបញ្ហាពីរខុសគ្នា។ អ្នកកាសែតបរទេសដែលខ្មែរក្រហមចាប់ដាក់គុក គឺតាមការយល់ឃើញរបស់គេ ថាដោយសារពួកអ្នកកាសែតជាគិញ។ គិញត្រូវតែសម្លាប់ហើយក្នុងពេលសង្គ្រាម។ ហើយវៀតណាមិសមានការយល់ឃើញផ្សេង គេទទួលស្គាល់ថាទោះបី *ស្ប៉ាយ* មិន *ស្ប៉ាយ* ក៏ដោយគឺអ្នកទាំងនោះជាជនជាតិបរទេស ប្រហែលជាវាអាចមានការចរចាគ្នាក្នុងកម្រិតមួយ។ វាជាការវៃឆ្លាតហើយទុកជីវិតគេឲ្យនៅរស់ដើម្បីអាចផ្តោះប្តូរយកអត្ថប្រយោជន៍អ្វីមួយនោះ។

ដូច្នេះចំណុចនេះវាចំណុចពិបាកនិយាយណាស់លោក វាចំណុចខ្មៅសៗ។ កម្ពុជាប្រជាធិបតេយ្យថាគិញសម្លាប់ចោលហើយ។ មានករណីតែបីទេដែលមិនសម្លាប់តាមខ្ញុំដឹង គឺដោយសារថាពួកគេបានទទួលស្គាល់នូវថ្នាក់លើថា អ្នកទាំងបីហ្នឹងមិនត្រូវកាប់សម្លាប់ទេ។

[១០:៣២:៣២]

**ស៖** ប៉ុន្តែវាមានមូលហេតុផ្សេងគ្នារវាងការសម្លាប់គិញ ហើយនិងការសម្លាប់ជនបរទេសដែលមិនមែនជាគិញ។ នៅការសម្លាប់នេះដោយគេយល់ឃើញថាជាគិញនេះតាមដែលលោកនិយាយអ៊ីចឹងទេត្រឹមត្រូវទេ?

**ឆ៖** បាទ គេយល់ឃើញថាជាគិញ។ ឯជនបរទេសធម្មតា គឺថាមិនត្រូវបានគេបង្ខការឈឺចាប់សម្លាប់នៅឆ្នាំ៧៥ ដែលពេលគេប្រមូលយកទៅដាក់នៅក្នុងស្ថានទូតបារាំង ហើយប្រហែលជាជនបរទេសពីរនាក់ដែលចូលរួមពាក់ព័ន្ធក្នុងបញ្ហានេះ។

**ស៖** សូមអរគុណលោក ស្បូត។ តាមការពិតខ្ញុំថាខ្ញុំត្រូវការ១ថ្ងៃកន្លះទៀតណោះ ប៉ុន្តែដោយសារនេះវាពេលវេលាដល់ហើយ។ លោកប្រធាន ខ្ញុំសូមបញ្ចប់ការតាំងសំណួររបស់ខ្ញុំ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះប្រាំនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់មួយខ្វះប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១០:៣៤នាទី ដល់ម៉ោង ១០:៥៥ នាទី)*

[១០:៥៥:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនិងផ្តល់វេទិកាជូនទៅក្រុម

មេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ បាទ សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់។ ជម្រាបសួរលោក ហ្វីលីព សត។ ជាដំបូងខ្ញុំសូមអរគុណដល់អង្គជំនុំជម្រះដែលបានផ្ដល់ពេលវេលាបន្ថែម ៣០នាទីដល់យើងខ្ញុំ។ ដូច្នេះទោះបីជាយ៉ាងណាក៏ដោយក៏ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គជំនុំជម្រះ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជាបឋមលោក ហ្វីលីព សត ខ្ញុំសូមណែនាំខ្លួន។ ខ្ញុំឈ្មោះអង់តា ហ្គីសសេ។ ខ្ញុំជាមេធាវីអន្តរជាតិរួមជាមួយលោក គង់ សំអុន ដើម្បីការពារក្ដីលោក ខៀវ សំផន។ ខ្ញុំសួរលោក ក្នុងឋានៈជាមេធាវីរបស់លោក ខៀវ សំផន។ ខ្ញុំចង់ត្រឡប់មកនិយាយអំពីចំណុចមួយដែលលោកលើកឡើងកាលពីម្សិលមិញលោកបាននិយាយអំពីពាក្យមួយដែលថា "សិល្បៈនៃអ្វីៗដែលអាចកើតឡើងបានដែរ"។ នេះជាពាក្យដ៏ល្អសម្រាប់អ្នកប្រវត្តិវិទូ ប៉ុន្តែនេះជាការកាត់ក្ដីរឿងឧក្រិដ្ឋកម្ម។ ហើយសៀវភៅរបស់លោកត្រូវបានលើកឡើងជាច្រើនដងនៅក្នុងដីកាដំណោះស្រាយដែលមានពាក់ព័ន្ធនឹងលោក ខៀវ សំផន។ ហើយនៅផ្នែកមួយចំនួននៃសក្ខីកម្មរបស់លោកនោះក៏មានយកចេញមកពីសៀវភៅរបស់លោកដែរ គឺលោកបាននិយាយអំពីលម្អិត។ ដូច្នេះយើងត្រូវធ្វើយ៉ាងណាឲ្យមានភាពច្បាស់លាស់ទាំងអស់គ្នា។ នេះជាអ្វីដែលខ្ញុំចង់ជម្រាបជូនលោកនៅពេលបឋមនេះ។

[១០:៥៧:៥១]

ចំណុចដំបូងនោះគឺថា លោកបានពិភាក្សាគ្នាជាមួយ មេធាវីការពារក្ដី នួន ជា រួចមកហើយអំពីបច្ចេកទេសនៃការធ្វើការងាររបស់លោក។ ខ្ញុំគិតថាក្នុងឋានៈជាប្រវត្តិវិទូនោះ ឬក៏ជាអ្នកសរសេរប្រវត្តិរូប លោកមានវិធីសាស្ត្រផ្ទាល់ខ្លួនរបស់លោកជាធម្មតា។ សំណួរទី១របស់ខ្ញុំចង់សួរលោកថា នៅពេលដែលយើងជាអ្នកប្រវត្តិសាស្ត្រសម័យទំនើបនោះវាខុសគ្នាពីសម័យបុរាណ ដែលពឹងផ្អែកទៅលើឯកសារ។ លោកៗសិក្សាអំពីមនុស្ស ពីព្រោះថាលោកបានសំណេះសំណាលជាមួយមនុស្សដែលបានរស់នៅពីសម័យនោះ។ ដូច្នេះពាក់ព័ន្ធនឹងសៀវភៅរបស់លោកនេះគឺសៀវភៅ "ប្រវត្តិនៃសុបិន្តអាក្រក់"។ បើសិនបើខ្ញុំមិនច្រឡំទេ គឺលោកចាប់ផ្ដើមការងារនៅឆ្នាំ៩៩ ឆ្នាំ២០០០ នេះបើតាមសក្ខីកម្មរបស់លោក។ គឺថាច្រើនឆ្នាំ

មកហើយក្រោយអង្គហេតុនោះ។ តើលោកមានឧបសគ្គអ្វីពាក់ព័ន្ធទៅនឹងការចងចាំរបស់អ្នកដែលបានសម្ភាសជាមួយលោកនោះទេ?

[១០:៥៩:00]

**លោក ហ្វីលីព ស្សូត៖**

**ឆ៖** គឺថាមិនមានបញ្ហាត្រឹមតែ បញ្ហានៃការចងចាំ។ ប៉ុន្តែគឺថាយើងមានលិខិតថ្មី -- លិខិតនៅក្នុងសម័យនោះផង ដូចជាឯកសារលាយលក្ខណ៍អក្សរក្នុងសម័យនោះគឺភាគច្រើនមិនមានគឺយើងត្រូវតែផ្អែកទៅលើចម្លើយផ្ទាល់មាត់។ អ្វីដែលខ្ញុំធ្វើនោះគឺខ្ញុំព្យាយាម គឺបារាំងហៅថា *"រើតូប៉េ"* គឺថាប្រមូលអ្វីៗបញ្ចូលគ្នាដើម្បីធានាថាយើងមានប្រភពអ្វីខ្លះដើម្បីកំណត់ថាវាគ្រប់គ្រាន់អាចជឿបានដែរអត់។ ប៉ុន្តែបើយើងនិយាយថា អ្វីដែលអាចទៅបាននោះ ហើយយើងក៏ធ្វើការនូវអ្វីដែលថាអ្វីដែលអាចកើតមាន។ ហើយយើង -- ដូចជាលោកស្រីក៏ព្យាយាមទៅរកពិតឲ្យកៀកបំផុតតាមដែលអាចទៅបានដែរ។ ដូច្នេះអ្នកប្រវត្តិវិទូក៏ដូច្នោះដែរ ដែលខ្ញុំនិយាយថា ប្រវត្តិវិទូជាសិល្បៈនៃអ្វីដែលអាចកើតបាននោះ។

**ស៖** ខ្ញុំមិនអាចពិភាក្សាគ្នាឲ្យបានលម្អិតទេ ពីព្រោះថាពេលវេលាខ្លី ក៏ប៉ុន្តែអ្វីដែលខុសគ្នានោះ គឺថាៗនៅក្នុងសំណុំរឿងព្រហ្មទណ្ឌនោះគឺថា កាលណាមានវិមតិសង្ស័យគឺបានប្រយោជន៍ដល់ជនជាប់ចោទហើយ។ ដោយសារតែពេលវេលាមានកំណត់ ដូច្នេះខ្ញុំមិនសួរបន្តអ្វីវែងឆ្ងាយត្រង់ចំណុចនេះទេ។ លោកបានធ្វើការជាមួយនឹងអ្នកដែលបានស្គាល់របបខ្មែរក្រហម នេះគឺជារៀបនៃការសរសេរប្រវត្តិរូប។ មុននឹងចូលទៅលម្អិតពាក់ព័ន្ធនឹងការសម្ភាសលោក ខៀវ សំផន នោះ ខ្ញុំចង់ដឹងថាតើលោកជាអ្នកជំនាញនេះ លោកជាអ្នកជំនាញខាងប្រវត្តិរូបរបស់ ប៉ុល ពត ក៏ជាអ្នកជំនាញទៅលើការដំណើរការការងារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ? តើលោកអាចពន្យល់អំពីការខុសគ្នាទាំងពីរនេះបានទេ?

[១១:០១:១៩]

**ឆ៖** គោលបំណងរបស់ខ្ញុំ គឺ ខ្ញុំត្រូវសរសេរជីវប្រវត្តិរបស់ ប៉ុល ពត ដើម្បីធ្វើការងារនោះបានជាចាំបាច់ ខ្ញុំត្រូវសិក្សាស្រាវជ្រាវ ដើម្បីឲ្យខ្ញុំដឹងច្រើនតាមដែលអាចធ្វើទៅបាន អំពីការប្រព្រឹត្តិទៅរបស់កម្ពុជាប្រជាធិបតេយ្យ។ ហើយចំណុចពីរនេះ វាបំពេញបន្ថែមគ្នាទៅវិញទៅមកនោះឯង។

**ស៖** លោកបានរកឃើញនូវទិដ្ឋភាពជាច្រើននៃកម្ពុជាប្រជាធិបតេយ្យ តើត្រឹមត្រូវដែរទេក្នុងការសរសេររបស់លោកនោះ លោកបានធ្វើការជ្រើសរើសពាក់ព័ន្ធទៅនឹងចំណុចដែលត្រូវសរសេរឲ្យបានលម្អិត គឺប្រធានបទដែលលោកត្រូវសិក្សាឲ្យបានស៊ីជម្រៅ ពីព្រោះថាដោយសារតែចំណុចមួយ

ចំនួននោះ វាពាក់ព័ន្ធទៅនឹងបុគ្គល ឬក៏អាកប្បកិរិយារបស់ ប៉ុល ពត?

**ឆ៖** នៅសៀវភៅណាក៏ដោយយើងត្រូវជ្រើសរើស។ មានចំណុចខ្លះយើងមិនដាក់ចូល ហើយមានផ្នែកខ្លះដែលយើងត្រូវដាក់ចូល។ ខ្ញុំ -- ពិតហើយបើយើងសរសេរជីវប្រវត្តិ យើងផ្តោតទៅលើធាតុផ្សំទាំងឡាយដែលទាក់ទងទៅនឹងអាកប្បកិរិយា ឬបុគ្គលិកលក្ខណៈរបស់តួអង្គនោះ។ បើយើងសរសេរប្រវត្តិរូបមេដឹកនាំនយោបាយ នយោបាយដែលគេគោរពតាម ប្រព័ន្ធដែលគេដឹកនាំ យើងត្រូវសង្កត់ធ្ងន់។ នេះហើយជាចំណុចសំខាន់ៗដែលយើងត្រូវផ្តោតលើ នៅលើបុគ្គលិកលក្ខណៈ។ ភាពខុសគ្នានោះគឺថា វាមានលក្ខណៈតិចជាងអ្វីដែលវាទំនងនឹងអាចមាន។

[១១:០២:៥៩]

**ស៖** ដើម្បីត្រឡប់មកវិញ ពាក់ព័ន្ធទៅនឹងការសម្ភាសជាមួយនឹងឥស្សរជនសម័យនោះ លោកបានផ្តល់សក្ខីកម្មថា "លោកបានសម្ភាសជាមួយអ្នកខ្លះនោះ គឺថាមានលក្ខណៈងាយស្រួលជាងអ្នកខ្លះ" គឺពាក់ព័ន្ធទៅនឹងសម័យកាលប្រវត្តិសាស្ត្រនៃកម្ពុជាប្រជាធិបតេយ្យ? នេះគឺជាបញ្ហាដែលពាក់ព័ន្ធទៅនឹងការងារទៅលើប្រវត្តិសម័យទំនើប។ តើនៅពេលដែលលោកសម្ភាសអ្នកណាមួយនោះ លោកមិនគិតថាគាត់លម្អៀង ឬក៏គាត់កាន់ជើងអ្នកនេះ កាន់ជើងអ្នកនោះឬទេ? លោកមិនគិតថា អ្នកដែលសម្ភាសហ្នឹងគាត់មានភាពលម្អៀង ព្រោះអ្នកខ្លះនោះគាត់អាចមានឆន្ទៈក្នុងការពង្រីក ឬក៏ពន្លើសអំពីតួនាទីរបស់គាត់នោះ ពាក់ព័ន្ធទៅនឹងការស្រាវជ្រាវរបស់លោកនោះ?

**ឆ៖** អានេះជាចំណុចមួយចំនួនដែលលោកស្រីអាចនឹងគិត ប៉ុន្តែការសិក្សារបស់ខ្ញុំ ដើម្បីការវាយតម្លៃនៃបទសម្ភាសន៍នោះ នៅក្នុងបទសម្ភាសន៍ចំណុចមួយដែលមេធាវីការពារក្តីម្នាក់ខាងដើមលើកឡើងហើយ គឺយើងជាទូទៅ យើងមិនធ្វើនឹងរហូតឱ្យគេប្រាប់ការពិត ទាំងស្រុងទាំងអស់ទេ។ គឺយើងគ្រាន់តែស្តាប់អ្វីដែលគេចង់ឱ្យយើងយល់ នេះជាការងាររបស់យើងដើម្បីព្យាយាមបកស្រាយនូវអ្វីដែលគេនិយាយ ដើម្បីឱ្យយើងរកឃើញ តើអ្វីនៅពីខាង -- ពាក្យហ្នឹងវាមានអត្ថន័យដូចម្តេច? តើគេនិយាយដូចម្តេចដើម្បីឆ្លុះបញ្ចាំងអំពីទស្សនៈនោះ វាមិនជាបញ្ហាយកទិន្នន័យ យកពាក្យទាំងស្រុង យកមកដាក់ហើយ យើងសរសេរទាំងស្រុងនោះទេបាទ។

[១១:០៥:០០]

**ស៖** ដូចគ្នាផងដែរ នៅក្នុងប្រភពឯកសាររបស់លោក ឬក៏នៅក្នុងឯកសារដែលលោកពិគ្រោះនោះ ខ្ញុំសន្និដ្ឋានថាលោកព្យាយាមធ្វើការពិនិត្យមើលតើមានចំណុចដូចគ្នាឬទេ? ហើយមានចំណុចខុស

គ្នាយ៉ាងម៉េច? អីយ៉ាងម៉េច? នេះគឺជាការងារពិនិត្យមើលភាពស៊ីសង្វាក់គ្នានៃឯកសារផ្សេងៗដែលលោកទទួលបាននោះ។ តើអ៊ីចឹងមែនទេ?

**ឆ៖** កាលណាអាចធ្វើបាន ខ្ញុំធ្វើបែបនោះ។ ប៉ុន្តែមិនតែងតែអាចធ្វើបានបែបនេះនោះទេ។ នេះជាការពិតដែលនៅពេលដែលសម័យពេលថ្មីៗ ដូចសម័យខ្មែរក្រហមនោះ គឺថាការសិក្សាហ្នឹងទសវត្សរ៍ដូចជារកតួលេខក្នុងសតវត្សរ៍ទី១៨,១៩ អ៊ីចឹងដែរ។

**ស៖** ឥឡូវនេះ ខ្ញុំត្រឡប់មកនិយាយអំពីកិច្ចសម្ភាសន៍របស់លោកជាមួយលោក ខៀវ សំផន។ នៅពេលឆ្លើយទៅនឹងសំណួរកាលពីប៉ុន្មានថ្ងៃនោះ លោកប្រាប់ថាលោកបានជួបលោក ខៀវ សំផន ប្រាំ ឬក៏ប្រាំមួយដង។ តើលោកអាចបញ្ជាក់បានទេថា ជួបប្រាំប្រាំមួយដងទំនុំងនៅពេលណា? គឺថារយៈពេលច្រើនខែ ឬក៏រយៈពេលខ្លី? ហើយលោកបានជួបគាត់ហ្នឹងកម្រិតញឹកញាប់ប៉ុនណាដែរនៅក្នុងពេលដែលលោកសម្ភាសគាត់នោះ?

[១១:០៦:៤០]

**ឆ៖** តាមដែលខ្ញុំចាំបានល្អបំផុតនោះ គឺថាយើងបានជួបគ្នាសឹងតែរាល់ថ្ងៃ រាល់ព្រឹកក្នុងរយៈពេល១សប្តាហ៍ ប្រហែលជាជួបគ្នាប្រាំដង។ បន្ទាប់មកខ្ញុំត្រឡប់មកវិញ ខ្ញុំមិនចាំប្រហែលជា ១ខែ ឬ២ខែក្រោយទេ ដែលជាការជួបចុងក្រោយនោះ។ បន្ទាប់ពីនោះមកលោក ខៀវ សំផន និយាយថា គាត់ថាអាចនឹងធ្វើឲ្យគាត់មានការលំបាកក្នុងការពិភាក្សាតទៅទៀត ឬក៏មិនមែនជាភាពវៃឆ្លាតហ្នឹងបន្តទេបាទ។

**ស៖** នៅពេលដែលលោកជួបគ្នានោះ គឺថាលោកមានបានពិភាក្សាគ្នាអំពីការបង្កើតតុលាការជាយថាហេតុដែរឬទេ?

**ឆ៖** ទេ យើងមិនបានគិតបែបនោះទេ។ ប៉ុន្តែខ្ញុំចាំថា លោក ខៀវ សំផន និយាយថា នេះជាការជួបនៅក្នុងការប្រជុំចុងក្រោយនោះ មូលហេតុ -- ខ្ញុំសម្រួលឃ្លា, គាត់មិនចង់បន្តទេ ខ្ញុំត្រូវតែដឹងថាស្ថានភាពរបស់គឺថា គាត់មានការលំបាក គឺផុយស្រួយ ហើយគាត់និយាយថា ជីវិតរបស់ខ្ញុំអាចនឹងគ្រោះថ្នាក់។ គាត់ប្រាប់ខ្ញុំអ៊ីចឹង។

[១១:០៨:០០]

**ស៖** បើតាមលោកនោះ តើបរិបទនោះពន្យល់ពីអ្វីដែលលោកបានប្រាប់តាំងពីដំបូងនោះថា គឺថាវាមានទំនោរទៅនិយាយអំពីរយៈពេលមុនឆ្នាំ៧៥-៧៩ ជាជាងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ផ៖** បាទ គឺប្រាកដជាអ៊ីចឹង។

**ស៖** នៅពេលដែលលោកជួបលោក ខៀវ សំផន តើលោកមានបានស្រាវជ្រាវជាមុនអំពីខ្សែជីវិតរបស់គាត់ ហើយបាន មានបានជួបអ្នកណាផ្សេងដែលបានស្គាល់គាត់ ហើយដែលមានព័ត៌មានអំពីប្រវត្តិរូបរបស់គាត់រួចហើយ គឺបានន័យថា លោកទទួលបានព័ត៌មានមុនហើយទើបលោកទៅសម្ភាសគាត់នោះ តើអ៊ីចឹងមែនទេ?

**ផ៖** បាទ ខ្ញុំធ្វើបែបនោះ។ ខ្ញុំត្រូវគប្បីតែអាចធ្វើបានការងារនោះ ពីព្រោះខ្ញុំប្រើពេល១៨ខែមុននឹងជួបជាទី១។ ខ្ញុំបានអានជាច្រើន អានឯកសារជាច្រើនមកពីឯកសារ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយឯកសារដែលសល់ពីរបបកម្ពុជាប្រជាធិបតេយ្យ ហើយខ្ញុំក៏បានអានសៀវភៅដែលបានសរសេរពីមុននិយាយអំពីកម្ពុជា ដែលសរសេរអំពីតួនាទីរបស់ ខៀវ សំផន។ ខ្ញុំបានពិនិត្យមើលនិក្ខេបបទរបស់គាត់នៅប៉ារីស ហើយខ្ញុំបានសិក្សាស្រាវជ្រាវមួយចំនួនច្រើន ហើយខ្ញុំបានជួបមនុស្សពីរនាក់ដែលស្ថិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលបានស្គាល់គាត់គ្រាន់បើ គួរសមដែរនៅក្នុងសម័យនោះ។

[១១:០៩:៥៩]

**ស៖** តើខ្ញុំអាចសួរលោកថាតើអ្នកណាខ្លះដែលលោកបានជួបនោះ? អ្នកទាំងពីរហ្នឹងជាអ្នកណាខ្លះ?

**ផ៖** ខ្ញុំគិតថា ជាពិសេស ស្អួង ស៊ីគឿន ដែលបានមកធ្វើសក្ខីកម្មមកសាលាក្តីនេះ ហើយនិងមួយទៀត ពឹង សយ។

**ស៖** លោកទើបតែនិយាយអំពីនិក្ខេបបទរបស់លោក ខៀវ សំផន ដូច្នេះខ្ញុំនឹងត្រឡប់មកនិយាយអំពីចំណុចនៃនិក្ខេបបទនេះ។ លោកបាននិយាយជាមួយលោកស្រីចៅក្រម ខាតវ៉ាយថ៍ កាលពីថ្ងៃចន្ទ។ អ្វីដែលលោកបានពន្យល់នៅក្នុងសវនាការ គឺថាមិនសូវច្បាស់ដូចនៅក្នុងសៀវភៅរបស់លោកទេ។ ដូច្នេះខ្ញុំចង់ត្រឡប់មកចំណុចមួយនៅក្នុងសៀវភៅរបស់លោក។ សម្រង់ដែលខ្ញុំលើកឡើងនោះ គឺនៅឯកសារ E3/9, ERN ជាភាសាបារាំង 00639828, ERN ជាភាសាអង់គ្លេស 00396497។ លោកបានបញ្ជាក់ថាលោក ខៀវ សំផន បានលើកឡើងអំពីរបបស្វ័យឧបត្ថម្ភ នៅក្នុងពេលដែលគាត់ធ្វើនិក្ខេបបទនៅស៊កប៊ន, “សមូហកម្មនៃអន្តរជាតិនោះគឺជាឫសគល់នៃសេដ្ឋកិច្ចខ្មែរ។ ជំនួយបរទេសនោះ គឺពឹងផ្អែកទៅលើទីផ្សារបរទេស ដែលប្រទេសកម្ពុជាមិនអាចក្តោបក្តាប់ មិនអាចគ្រប់គ្រងបាន ពីព្រោះថាវាត្រូវ

បានត្រួតត្រាដោយផលប្រយោជន៍បរទេស។ ពាណិជ្ជកម្មបរទេស ដែលធ្វើឲ្យឧស្សាហកម្មក្នុងស្រុក អត់មានការងារនោះ គឺថាឲ្យមានទំនិញធ្លាក់ចុះ"។ នេះគឺជាការសង្ខេបមួយនៃខ្លឹមសារនៅក្នុងនិក្ខេបបទរបស់គាត់។

[១១:១២:០៩]

នៅទំព័របន្ទាប់មកទៀត នេះជាអ្វីដែលលោកបាននិយាយសរសេរ។ ខ្ញុំត្រឡប់មកនិយាយវិញនេះ ពីព្រោះថា នៅពេលដែលលោកបានលើកឡើងអំពីបញ្ហានេះ ជាមួយលោកស្រី ខាតវ៉ាយថ៍ នោះ លោកនិយាយថាត្រូវប្រុងប្រយ័ត្ន ត្រូវពិនិត្យនិក្ខេបបទរបស់លោក ខៀវ សំផន ដើម្បីឲ្យដឹងថាមានអ្វីកើតឡើងជាបន្តមកទៀតនោះ។ ដូច្នេះ នៅក្នុងសៀវភៅរបស់លោកនោះ លោកនិយាយយ៉ាងច្បាស់ជាងអ្វីដែលលោកឆ្លើយនៅក្នុងសវនាការនេះ។

ERN ជាបន្តមកទៀតនោះ 00639829, ERN ជាភាសាអង់គ្លេស 00396498។ ខៀវ សំផន បានបញ្ជាក់ថា "កម្ពុជាត្រូវការទម្រង់មូលធនជាតិស្វយ័ត"។ ដូច្នេះ នៅត្រង់ចំណុចនេះ យើងឯកភាពថា នៅពេលនោះ គឺយើងឃ្លាតឆ្ងាយអំពីស្វ័យឧបត្ថម្ភកុម្មុយនីស្តនៅក្នុងគំនិតរបស់លោក ខៀវ សំផន។

**ឆ៖** បាទ សូមឲ្យទំព័រខ្ញុំ ក្នុងសៀវភៅមកខ្ញុំ ដោយសារ ERN នេះ ខ្ញុំមិនអាចតាមទាន់ទេ។

**ស៖** សូមអភ័យទោស ខ្ញុំនឹងផ្ដល់ជូនលោក ជាភាសាអង់គ្លេស គឺទំព័រ ២៨៩ និង ២៩០ គឺជាឃ្លាចុងក្រោយ ដែលខ្ញុំអានពាក់ព័ន្ធទៅនឹងមូលធននិយម ឬក៏នាយទុននោះ។

[១១:១៤:០៥]

**ឆ៖** ខ្ញុំមិនឃើញចំណុចផ្ទុយគ្នានោះទេ។ គាត់សរសេរអំពីស្វ័យគ្រប់គ្រង ឬក៏ខ្លួនទីពឹងខ្លួន ដែលជាវិធីដែលអាចទទួលយកបានចំពោះរដ្ឋាភិបាល សីហនុ។ ហើយនិយាយពីរបបដែលហៅថា *អូតាគី* គឺអតាធិបតេយ្យនោះ។ ហើយគេមិន -- ខ្ញុំមិនយល់ថា គេយកគំរូហ្នឹង នៅក្នុងកម្ពុជាប្រជាធិបតេយ្យទេ ប៉ុន្តែវាជា វាមានគំនិតមួយចំនួនដែលស្ថិតនៅក្នុងការពិភាក្សានៅពេលនោះ។ ភាពខុសគ្នាដែលពិសេសនោះ ដែលខ្ញុំកត់សម្គាល់នោះ គឺថាលោក ខៀវ សំផន ហើយនិងនិក្ខេបបទរបស់គាត់ហ្នឹង គឺថាសង្កត់ធ្ងន់ទៅលើបច្ចេកវិទ្យា ប៉ុន្តែនៅក្នុងកម្ពុជាប្រជាធិបតេយ្យ គេមិនយកបច្ចេកវិទ្យាជាមូលដ្ឋានទេ។ អាហ្នឹងហើយជាភាសខុសគ្នា។ ប៉ុន្តែវិធីសាស្ត្រដ៏ទូលំទូលាយនោះ គឺហើយវាទំនងជាស្របទៅនឹងអ្វីដែលកើតឡើងនៅពេលក្រោយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

**ស៖** មូលធននិយម ឬក៏នាយទុននៅក្នុង -- លោកចង់សំដៅទៅដល់ក្នុងកម្ពុជាប្រជាធិបតេយ្យ

ឬក៏យ៉ាងណា?

**ឆៈ** បាទ ខ្ញុំសូមរំឭកលោកស្រី គឺការអនុវត្តនៅសហភាពសូវៀតគេហៅថា មូលធននិយមរបស់រដ្ឋនោះដែរ។ អានោះគេលទ្ធិកុម្មុយនីស្តមួយ។

[១០:១៥:៥០]

**សៈ** អ៊ីចឹងលោកគិតថា វាកើតឡើងមាននៅក្នុងសេដ្ឋកិច្ចរដ្ឋនៅកម្ពុជាប្រជាធិបតេយ្យដែលជាសេដ្ឋកិច្ចមូលធននិយម។ អ៊ីចឹងមែនទេ?

**ឆៈ** អត់ទេ លោក ខៀវ សំផន ប្រើពាក្យថា "មូលធននិយមជាតិ" ដែលអាចបកស្រាយថាជាប្រជាជាតិ សម្ងហភាព កាន់កាប់មូលធនដើមទុននៃរបស់ប្រទេស ដែលថាដើមទុននោះគឺផលិតកម្ម -- សមត្ថភាពផលិតកម្មកសិកម្មរបស់គេនោះឯង។ ជាពិសេស ហើយការវិវត្តដោយផ្អែកទៅលើគោល-ការណ៍ជាតិ ហើយយើងមិនគប្បីតែមើលពាក្យមិនត្រូវផ្តោតលើពាក្យនីមួយៗ ប៉ុន្តែយើងមើលទៅលើនិក្ខេបបទទាំងមូលរបស់គាត់ ដែលថាកម្ពុជាគប្បីតែមានស្វ័យភាព មិនគប្បីតែរណបរដ្ឋបរទេសទេ។ នេះគឺជាការទទួលខុសត្រូវចំពោះការអភិវឌ្ឍរបស់ខ្លួន ហើយគាត់និយាយម្តងហើយម្តងទៀតថា ប្រជាជាតិ ឬក៏ជាតិគឺជាគោល ជាគន្លឹះ។ រីឯបុគ្គលម្នាក់ៗមិនមែនជាសំខាន់ទេ។ ដូច្នេះលោកស្រីអាចឃើញហើយ ទំនាក់ទំនងរវាងគំនិតទាំងអស់នេះដែលត្រូវយកមកពិភាក្សានៅឆ្នាំ១៩៦០ ចំពោះអ្នកកំណែទម្រង់ដូចជាលោក ខៀវ សំផន នោះដែរ។

[១១:១៧:១២]

**សៈ** យើងនឹងត្រឡប់មកនិយាយអំពីបញ្ហាសេដ្ឋកិច្ចនេះនៅពេលក្រោយ។ ខ្ញុំព្យាយាមអនុវត្តទៅតាមកាលប្បវត្តិ។ នៅក្នុងក្របខ័ណ្ឌនៃសក្ខីកម្មរបស់លោក និងនៅក្នុងសៀវភៅរបស់លោក លោកបាននិយាយអំពីការវិលត្រឡប់របស់លោក ខៀវ សំផន មកប្រទេសកម្ពុជា ជាពិសេសគឺការប្រឹងប្រែងរបស់គាត់នៅក្នុងការសរសេរកាសែត ហើយនិងមានមុខតំណែងផ្សេងៗទៀត។

លោកបានលើកឡើងអំពីទំនាក់ទំនងដែលអាចកើតមាននៅសម័យនោះ លោកក៏បាននិយាយអំពី ហ៊ូ យន់, ហ៊ូ នឹម។ ដូច្នេះលោកនិយាយអំពីទំនាក់ទំនងរវាងបក្សដោយលួចលាក់ ហើយនៅពេលដែលសហព្រះរាជអាជ្ញាបានសួរលោក លោកបានឆ្លើយថាពិបាកណាស់ក្នុងការដឹងអំពីទំនាក់ទំនងពិតប្រាកដពីព្រោះថាអ្នកខ្លះអត់មានទំនាក់ទំនងផ្ទាល់ អ្នកខ្លះមានទំនាក់ទំនងដោយប្រយោល។ ដូច្នេះខ្ញុំព្យាយាមបង្ហាញឱ្យឃើញថាតើលោកទទួលបានប្រភពពីណាខ្លះពាក់ព័ន្ធទៅនឹងចំណុចនេះ ដើម្បីសរសេរនៅក្នុង

សៀវភៅរបស់លោកនោះ?

[១១:១៨:៤៧]

**ឆ៖** មុនឆ្នាំ១៩៦៧ នៅពេលដែល ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម បានចូលទៅក្នុង -- ទៅជនបទនោះ យើងមិនឃើញមានទំនាក់ទំនង ឬក៏ប្រភពជាក់លាក់អំពីលក្ខណៈ ឬក៏ទំនាក់ទំនងទាំងនោះទេ។ ខ្ញុំអាចនិយាយបានថា ទាំងអស់នេះពួកគាត់សុទ្ធតែជាបញ្ញាជនដែលមានសមានចិត្តចំពោះគំនិតមួយចំនួនរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលក្នុងករណីលោក ខៀវ សំផន នោះគេបាន -- គាត់បោះពុម្ពផ្សាយនូវកាសែតមួយដែលបានសរសេរិះគន់សង្គម របបសង្គមរាស្ត្រនិយមអឺជាដើម។ ខ្ញុំអាចនិយាយថា គាត់ធ្វើការងារហ្នឹងក្លាហាន ធ្វើឡើងដោយភាពឈ្លាសវៃក្លាហានរបស់គាត់។ ហើយ ហ៊ូ យន់ ស្ថិតនៅក្រោមការដឹកនាំរបស់សម្តេច សីហនុ ដែលកាលនោះសង្គមរាស្ត្រនិយម។ ប៉ុន្តែមិនដឹងថាលោក ខៀវ សំផន មិនបានពន្យល់ខ្ញុំ ហើយមិនមានប្រភពផ្សេងទេ ថាតើអាហ្នឹងគឺជាទំនាក់ទំនងជាក់ស្តែងដែរទេ។ ហើយគាត់និយាយភាសាបារាំង គឺថា *"វើ មូវ៉ង់"* – បាទ គឺចលនាដែលពាក់ព័ន្ធទាក់ទៅនឹង ប៉ុន្តែវាមិនផ្សាភ្ជាប់ទៅនឹងបក្សនយោបាយទេ។ នេះហើយគឺជាការរៀបរាប់ពីតួនាទីរបស់គាត់។ បន្ទាប់ពីឆ្នាំ១៩៧០ គេៗបានអមដំណើរគាត់ដោយការពារគាត់ទៅតំបន់រំដោះខ្មែរក្រហម។ ពេលនោះទើបបានយើងឃើញទំនាក់ទំនងគាត់ទៅនឹងបក្សកុម្មុយនីស្តកម្ពុជាហ្នឹងច្បាស់។

[១១:២០:៤៩]

**ស៖** សូមអរគុណ។ នៅពេលដែលលោកនិយាយអំពីចលនា ឬចរន្តនៃការទាក់ទងនោះ គឺលោកនិយាយអំពីការទាក់ទងជាមួយនឹងក្រុមហ្នឹង។ តើមែនទេ?

**ឆ៖** ក្រុមនៃគំនិតហ្នឹងគឺមែនហើយ ហើយក៏វាចាំបាច់ពាក់ព័ន្ធទៅនឹងទម្រង់នៃការទាក់ទងដោយផ្ទាល់ដែរ។ ប្រសិនបើសួរថាតើទម្រង់អ្វី? ខ្ញុំមិនអាចនិយាយប្រាប់ច្បាស់ថា អ្នកណាម្នាក់ក៏មិនអាចបញ្ជាក់ទេ ទាំងលោក ខៀវ សំផន ក៏អាចបញ្ជាក់ទេ នៅដំណាក់កាលនេះថាវាប្រភេទអ្វីនោះ។ ខ្ញុំបន្ថែមដោយសង្ខេប បើមិនមានទំនាក់ទំនងប្រភេទនោះទេ យើងពិបាកនឹងស្រមៃនឹកឃើញថា តើមានភាពចាំបាច់អ្វីកើតឡើងដែលថានៅក្នុង១៩៦៧ មិនអាចធ្វើឱ្យគាត់ចាកចេញពីក្រុងទៅជនបទទេ។ បើសិនជាវាទំនាក់ទំនងដាច់ដោយឡែកនោះ ខ្ញុំមិនអាចនឹងឃើញថាមានហេតុអ្វីដែលថាក្រុមទាំងពីរនេះ ដែលមិនដែលស្គាល់គ្នាសោះនោះ គឺថាភ្លាមៗគឺថា ១ម៉ោង ២ម៉ោងគឺថាអាចប្រមូលផ្តុំគ្នា ហើយអាចនាំគាត់ពីភ្នំពេញចេញទៅកន្លែងនោះបានទេ លើកលែងតែមានទំនាក់ទំនងអ្វីមួយទើបបានធ្វើបាន។

[១១:២២:១៨]

**សៈ** ក៏ប៉ុន្តែយើងមិនដឹងថា ចាប់ពីពេលដែលលោក ខៀវ សំផន ចូលមកកម្ពុជា ហើយនិងពេលដែលគាត់រត់ចូលព្រៃនោះ យើងមិនដឹងថានៅពេលណាពិតប្រាកដចាប់ផ្តើមការទំនាក់ទំនងគ្នានោះទេ ហើយនិងតាមវិធីណានោះទេ។ នេះជាអ្វីដែលលោកពន្យល់នោះ បើសិនស្តាប់មិនច្រឡំនូវគំនិតរបស់លោកទេ។ តើអ៊ីចឹងមែនទេ?

**ផៈ** ការយល់របស់លោកស្រីនោះគឺត្រូវមួយផ្នែក ប៉ុន្តែខ្ញុំបន្ថែមបន្តិច គឺថាលោក ខៀវ សំផន កាលណោះ គឺគាត់នៅប្រទេសបារាំងនោះ គាត់ជិតស្និទ្ធជាមួយ អៀង សារី ហើយលោក អៀង សារី ជាផ្នែកមួយនៃបក្សកុម្មុយនីស្តកម្ពុជា។ ដូច្នេះ គាត់ចូលរួមនៅក្នុងសមាជឆ្នាំ១៩៦០។ យ៉ាងហោចណាស់ គឺថាមានទំនាក់ទំនងជាមិត្តភាព ដែលផ្សាភ្ជាប់គាត់ទៅនឹងសមាជិកបក្សកុម្មុយនីស្តកម្ពុជាហើយគាត់ក៏ជាសមាជិកនៅក្នុងក្រុមរង់កុម្មុយនីស្តនៅបារាំងដែរ។ ដូច្នេះហើយគេអាចមានការផ្លាស់ប្តូរខាងមនោគមន៍វិជ្ជា។ ខ្ញុំ យើងមិនឃើញបន្ទាត់ខ្មៅលើផែនទីដែលថា គាត់ស្គាល់អ្នកនេះ អ្នកនេះតទៅនេះ គឺថាយើងមិនអាចបញ្ជាក់ច្បាស់។ ហើយខ្ញុំមិនដឹងចំណុចហ្នឹងច្បាស់ ហើយអ្នកផ្សេងទៀតក៏មិនអាចច្បាស់ជាងហ្នឹងដែរ ហើយខ្ញុំសន្និដ្ឋានយកគំនិតត្រឹមហ្នឹង។

[១១:២៣:៣៧]

**សៈ** សូមអរគុណលោក។ សំណួរដែលខ្ញុំសួរនោះ គឺដើម្បីចង់ដឹងថាមានមូលដ្ឋានអ្វីដែលលោកបានសរសេរនៅក្នុងសៀវភៅរបស់លោកនោះ។ គឺថាលោកប៉ាន់ស្មាន ឬក៏លោកសន្និដ្ឋាន។ ដូច្នេះ ខ្ញុំចង់ដឹងណាស់ ថាតើលោកមានមូលដ្ឋានអ្វីដើម្បីសរសេរសៀវភៅរបស់លោកនោះ? ដូច្នេះចំណុចរបស់ខ្ញុំទាំងអស់ដែលសួរលោកនៅថ្ងៃហ្នឹង គឺចង់ដឹងអ៊ីចឹង ថាលោកមានមូលដ្ឋានអ្វីដើម្បីសរសេរសៀវភៅរបស់លោក?

យើងបានឃើញថាលោក ខៀវ សំផន បានចូលក្នុងឆាកនយោបាយជាមួយនឹងអ្នកចម្រើនដូចជា ហ៊ូ នឹម, ហ៊ូ យន់ ដែលព្យាយាមធ្វើឲ្យមានការប្រែប្រួល ការផ្លាស់ប្តូរនៅក្នុងរដ្ឋាភិបាល សីហនុ នៅសម័យនោះ។ ហើយបន្ទាប់មកទៀត មានការគំរាមកំហែងពីតុលាការយោធាដែលរហូតថាត្រូវកាត់ ឬរកកាត់ក្បាលលោក ខៀវ សំផន ទៀតផង។ ដូច្នេះចំពោះ -- នោះគឺថាសាក្សី មាស វឿន នោះគឺនៅក្នុងប្រតិចារឹកសវនាការថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ គឺ E1/132.1 គឺថានៅប្រហែលជាម៉ោងដប់មួយដប់ប្រាំបួនគឺថាពេលនុ៎ងៗ គេចង់ គេស្វែងរកលោក ខៀវ សំផន គឺថាគេចង់កាត់ក្បាលលោក ខៀវ

សំផន។ ដូច្នេះអ្វីដែលខ្ញុំនិយាយនោះ គឺថារបបនោះមានភាពហិង្សាហើយអំបាញ់មិញនេះលោកនិយាយអំពីការបង្ក្រាប ពាក់ព័ន្ធទៅនឹងបញ្ហានយោបាយ។ ហើយលោកបានលើកឡើងជាមួយសហព្រះរាជអាជ្ញាអំពីបញ្ហាដែលថាមានការបះបោរ គឺថាជាមធ្យោបាយតែមួយគត់គឺការបះបោរហ្នឹងដើម្បីបង្ហាញមតិយោបល់នៅក្នុងរបបនោះ។ ដូច្នេះតើលោកឯកភាពពីការវិវត្តទៅនៃស្ថានភាពរបៀបនេះទេ?

[១១:២៥:៤៣]

**ផ៖** គឺត្រឹមត្រូវអ៊ីចឹងហើយ។ គឺមិនមានឱកាសនយោបាយណាមួយទុកឲ្យអ្នកជំទាស់ សីហនុទេ។ កាលណាមានរឿងហ្នឹងកើតឡើងការបះបោរគឺជាសកម្មភាពខុសច្បាប់ ហើយអ្នកទាំងហ្នឹងគឺត្រូវបានគេចាត់ទុកថាជាអ្នកជំទាស់ហើយមិនអាចនៅជាមួយរបបនោះបានទេ។

**ស៖** ឥឡូវនេះខ្ញុំចូលទៅនឹងបញ្ហាបក្សកុម្មុយនីស្តកម្ពុជាសម័យនោះ ហើយនិងទំនាក់ទំនងជាមួយនឹងបញ្ញាជន។ លោកបានពន្យល់អំពីចំណុចនេះហើយ ដូច្នេះខ្ញុំនឹងត្រឡប់មកនិយាយអំពីចំណុច នេះវិញបន្តិច។ លោកបាននិយាយថា មានការប្រែប្រួលនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ហើយអ្នកច្រើនដូចជា ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់ ជាដើមនោះ ទោះបីជាគាត់តស៊ូខាងឆ្វេងនិយមនៅបារាំងក៏ដោយក៏គាត់មិនមែនជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា។ ពីព្រោះថា បក្សកុម្មុយនីស្តកម្ពុជានោះនិងការពារពួកគាត់ក្នុងសម័យគ្រោះថ្នាក់សម្រាប់ពួកគាត់ទាំងអស់នោះ។ ក្នុងទំនាក់ទំនងរវាងបក្សកុម្មុយនីស្តកម្ពុជានិងបញ្ញាជន លោកបាននិយាយអំពីលោក សួង ស៊ីគឿន ដែលមកធ្វើសក្ខីកម្មនៅទីនេះ។ សួង ស៊ីគឿន គាត់បាននិយាយគួរឲ្យចាប់អារម្មណ៍អំពីការបែងចែកគ្នានៅក្នុងបក្សកុម្មុយនីស្តកម្ពុជារវាងកម្លាំងយុទ្ធសាស្ត្រនិងកម្លាំងយុទ្ធវិធី។

[១១:២៧:២២]

ខ្ញុំយោងទៅលើកំណត់ហេតុស្តាប់ចម្លើយលោក សួង ស៊ីគឿន -- សុំទោសសំដៅទៅលើប្រតិចារឹកសវនាការស្តាប់ចម្លើយលោក សួង ស៊ីគឿនគឺនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ -- សុំទោស ២០១២ ដែលមានលេខ E3/107.1។ ERN ជាភាសាបារាំង 00838433, ជាភាសាអង់គ្លេស 00838305 រហូតទៅដល់ 06, ជាភាសាខ្មែរ 00835351 រហូតទៅដល់ 2។ គាត់ពន្យល់អំពីភាពខុសគ្នារវាងកម្លាំងយុទ្ធសាស្ត្រ និងកម្លាំងយុទ្ធវិធី ពាក់ព័ន្ធទៅនឹងបញ្ញាជន។ កម្លាំងយុទ្ធវិធីសំដៅទៅដល់បញ្ញាជនជាទូទៅជាពិសេសអ្នកដែលទៅរៀននៅបារាំង ហើយអ្នកដែលបានចូលក្នុងរង្វង់ម៉ាក្ស-ឡេនីននិយម។ នៅសម័យនោះបក្សកុម្មុយនីស្តកម្ពុជា ត្រូវការបញ្ញាជនទាំងអស់នេះដើម្បីរួបរួមជាមួយនឹង

មហាជនពីព្រោះថា បញ្ហានេះមានប្រសិទ្ធភាពជាងនិស្សិតធម្មតា។ បញ្ញាជនទាំងអស់នេះ គឺមានបញ្ញាជនក្រហមជាបញ្ញាជនកុម្មុយនីស្តជានិស្សិតពូកែ។ ពួកគាត់គោរពអ្នកចាស់។ ពួកគាត់មានសប្បុរសធម៌ជាមួយនឹងនិស្សិតផ្សេងៗទៀត។ ហើយជាមនុស្សចេះជួយយកអាសា។ នេះគឺជាកម្លាំងគាំទ្រដែលខុសពីកម្លាំងយុទ្ធសាស្ត្រ។ ពួកគេអាចក្លាយទៅជាកម្លាំងយុទ្ធសាស្ត្របាននៅពេលដែលពួកគេចូលមកប្រទេសវិញ ហើយអាចផ្លាស់ប្តូរឋានៈ និងផ្លាស់ប្តូរផ្នត់គំនិតរបស់ខ្លួនដើម្បីក្លាយជាអ្នកវណ្ណៈអធន និងក្លាយទៅជាសមាជិកនៃវណ្ណៈពលករ។

[១១:២៩:២៥]

មូលហេតុដែលខ្ញុំលើកឡើងអំពីឃ្លារបស់លោក សួង ស៊ីគឿន នេះគឺថានៅក្នុងសៀវភៅរបស់លោក លោកបានសរសេរអំពីការស្នាក់នៅរបស់ -- អំពីការទៅចូលព្រៃរបស់លោក ខៀវ សំផន ដែលបង្ហាញអំពីជីវិតរបស់គាត់ជាមួយនឹងកុម្មុយនីស្តដែលកើតចេញមកពីកសិករ។ លោកបានឆ្លើយថាលោក ខៀវ សំផន នោះគាត់គោរពវិន័យ។ សំណួររបស់ខ្ញុំគឺដើម្បីទទួលបានការបំភ្លឺពាក់ព័ន្ធទៅនឹងអ្វីដែលលោក សួង ស៊ីគឿន បានឆ្លើយ។ ដូច្នេះ នៅពេលនោះគឺជាការមើលឃើញពិភពផ្សេងមួយទៀត ហើយនិងការព្យាយាមគោរពតាមវិន័យ ហើយគឺក្នុងឋានៈជាបញ្ញវន្តនោះគឺថា គាត់មិនអាចធ្វើអ្វីខុសពីវិន័យបានទេ។ ដូច្នេះនេះគឺជាបញ្ហានៃបញ្ញាជន ដែលថាមិនមែនបានន័យថាគាត់អន់ជាង ធ្វើខ្លួនអន់ជាងមហាជននោះទេ?

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១១:៣០:៤០]

**លោក អាប់ឌុលឡាក់ ថារីក៖**

នេះជាសំណួរវែងណាស់ តាមដែលខ្ញុំយល់នោះគឺថាមេធាវីការពារក្តីបានសួរឲ្យលោក ស្សូត ទៅឲ្យយោបល់ទៅលើគំនិតអ្នកដទៃទៀតដែលទាក់ទងទៅគំនិតរបស់វណ្ណៈកសិករអីជាដើម។ នេះជាសំណួរមិនសមស្របដែលថា សួរឲ្យអ្នកជំនាញគាត់ទៅបញ្ជាក់ថាគំនិតអ្នកផ្សេងយល់បែបណាៗនោះបាទ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំដូចជាភ្ញាក់ផ្អើលចំពោះការជំទាស់របស់សហព្រះរាជអាជ្ញា។ នៅពេលដែលគាត់សួរអ្នកជំនាញនោះ អ្នកជំនាញក៏បានបញ្ជាក់អំពីអ្វីដែលបានកើតឡើង ពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់ ខៀវ សំផន នោះ។ ដូច្នេះយើងកំពុងតែនៅចំពោះមុខអ្នកជំនាញ ដែលសរសេរអំពីមូលហេតុ -- គឺជាគំនិតរបស់គាត់ គាត់ជាអ្នកជំនាញ។ ដូច្នេះខ្ញុំគិតថា យើងគួរតែមានសេរីភាពក្នុងការសួរគាត់ ហើយនៅពេលដែលយើងពិនិត្យប្រតិចារឹកកាលពីប៉ុន្មានថ្ងៃមកនេះ ការបន្ទោសរបស់សហព្រះរាជអាជ្ញានោះគឺមិនមានមូលដ្ឋាននោះទេ។

[១១:៣១:៥៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣២:៥៨]

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាចំពោះសំណួរចុងក្រោយដែលសួរឡើងដោយមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា សេចក្ដីជំទាស់នេះមាននូវមូលដ្ឋានសមស្រប។ បញ្ហាគឺពិតជាចេញចាកឆ្ងាយពីអ្វីដែលភាពជំនាញរបស់អ្នកជំនាញនេះដែលអាចដឹង និងសរសេរនៅក្នុងសៀវភៅរបស់គាត់ ដែលជាមូលដ្ឋាននៃការពិនិត្យ ពិភាក្សាដេញដោលនៅពេលនេះ។ ដូច្នេះ លោកអ្នកជំនាញមិនបាច់ឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយមេធាវីអន្តរជាតិការពារក្ដីឲ្យលោក ខៀវ សំផន ចុងក្រោយអម្បាញ់មិញនេះទេ។ សូមលោកស្រីមេធាវីបន្តសំណួរថ្មីទៀត!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ឥឡូវខ្ញុំសូមបន្តទៅមុខទៀត។ ខ្ញុំសូមនិយាយអំពីចម្លើយរបស់លោកដែលលោកបានឆ្លើយប៉ុន្មានថ្ងៃនេះ។ ខ្ញុំលើកចំណុចមួយទាក់ទងទៅនឹងយុវជននៅបក្សកុម្មុយនីស្តកម្ពុជា ហើយនិងយុវជនជាមួយនឹងបក្សកុម្មុយនីស្តវៀតណាម។ លោកបាននិយាយនៅក្នុងសៀវភៅរបស់លោកអំពីចំណុចនេះ ហើយលោកបានលើកឡើងអំពីរយៈកាលដែល ប៉ុល ពត ទាក់ទងជាមួយនឹងបក្សកុម្មុយនីស្តវៀតណាម ហើយនិងរយៈកាល គឺថាមុនសមាជឆ្នាំ១៩៦០ ដែលមានកាលហ្នឹងមានឆន្ទៈក្នុងការជំទាស់អនុត្តរភាពវៀតណាម ហើយនិងបង្កើតបក្សមួយដែលស្នេហាជាតិខ្មែរ។ លោកក៏បានពន្យល់ថ្ងៃនេះផងដែរ ទៅ

សហភាតារបស់ខ្ញុំអំពីទំនាក់ទំនងដ៏លំបាក និងជាប្រវត្តិសាស្ត្ររវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម។ តើនៅក្នុងយុវជនខ្មែរ ហើយនិងការជំទាស់របស់ខ្មែរទៅនឹងបក្សកុម្មុយនីស្តឥណ្ឌូចិននេះ តើត្រង់ចំណុចនេះលោកមើលឃើញថា វាជាចំណុចកត់សម្គាល់មួយនៃសីមាប្រវត្តិសាស្ត្រនេះនៃជម្រើសរបស់ ប៉ុល ពត ដែរឬទេ?

[១១:៣៥:១២]

**លោក ហ្វីលីព ស្សូត៖**

**ឆ៖** បាទ នេះគឺប្រធានបទដ៏ទូលំទូលាយដែលអាចមានឧទាហរណ៍ច្រើនណាស់ ទាំងក្នុងសតវត្សរ៍ទី១៩ នៅក្នុងសម័យបារាំង ដែលបារាំងសម្រេចចិត្តប្រើវៀតណាម ជា -- បាទ មន្ត្រីរាជការស៊ីវិលក្មេងៗនៅក្នុងរដ្ឋាភិបាលនោះ គឺថាវាមានទិដ្ឋភាពជាច្រើនដែលជាប្រធានបទក្នុងប្រវត្តិសាស្ត្រជាបន្តបន្ទាប់។ វៀតណាមគេយល់ថាខ្លួនឯងមានឧត្តមភាព ហើយខ្លួនជាបងរបស់សមមិត្តកម្ពុជារបស់គេនោះ ហើយគេអាចនឹងព្យាយាមចង់ប្រើអនុត្តរភាព ឬក៏មានឥទ្ធិពលនៅលើកម្ពុជា ដូចគេនិយាយថាចិនមានអនុត្តរភាពលើកកម្ពុជាដូច្នេះ។ អ៊ីចឹងកម្ពុជាប្រជាធិបតេយ្យ គេជាកុម្មុយនីស្តកម្ពុជា បើយើងត្រឡប់ទៅឆ្នាំ១៩៣០ គឺថាវៀតណាមជាអ្នកបង្កើត ហើយជាការបង្កើតដោយវៀតណាម។ ហើយវាមានការវិវត្ត ក្រោយមកគឺវាមានលក្ខណៈកម្ពុជាច្រើនចំពោះចលនារបស់ខ្មែរពេលនោះ។ ហើយវៀតណាមបានដើរតួនាទីសំខាន់រហូតទៅដល់ទសវត្សរ៍ឆ្នាំ១៩៣០-៤០ នៅក្នុងសម័យខ្មែរវៀតមិញ។ វានៅស្ថិតនៅក្រោមវៀតណាម។ ហើយនៅទីបញ្ចប់ ឱកាសនោះក៏បានផុសឡើងដោយសារថាវៀតណាមក៏គេមានការតស៊ូនៅក្នុងវៀតណាមដែរ។ ពួកគេមិនមានផ្តោតអារម្មណ៍ខ្លាំងអ្វីៗនៅកម្ពុជាដែរ។ ហើយជាឱកាសដើម្បីឲ្យចលនាកម្ពុជា ដើម្បីខ្លួនឯងទាមទារយកកុម្មុយនីស្តឯករាជ្យពីឥទ្ធិពលក្នុងឆ្នាំ១៩៥០-៦០ មក។ អាហ្នឹងជាគំរូដែលមានបន្តជានិច្ចកាលមកបែបនេះឯង។

[១១:៣៧:១៤]

**ស៖** ឥឡូវនេះ ខ្ញុំសូមត្រឡប់មកនិយាយអំពីបញ្ហាផ្ទៃក្នុងបក្សកុម្មុយនីស្តកម្ពុជា ហើយនិងនិយាយអំពីផ្នែកទាំងពីរនៃការបះបោរដែលលោកបានពិពណ៌នា។ ជាភាសាបារាំងគឺ ERN 00 -- ឯកសារដដែល គឺថា E3/9, 00639688, ជាភាសាអង់គ្លេស គឺ00396379។ បាទ ជាភាសាអង់គ្លេសគឺ ១៧៩ -- ទំព័រ១៧៩។ លោកនិយាយអំពីសង្គ្រាមប្រជាជននៅឆ្នាំ១៩៦៩ គឺថាមានការប្រមូលផ្តុំចលនាកុម្មុយនីស្ត ហើយលោកបានលើកឡើងថា៖ នេះជាលើកទី១ ហើយដែលចលនាបដិវត្តន៍ជាតិសុទ្ធសាធ

ដែលកំពុងតែកើតមានឡើង ប៉ុន្តែកូដកម្មនេះ មិនទាន់ល្អឥតខ្ចោះនៅឡើយទេ។ ការសម្ព័ន្ធភាពដែលមិនអាចជៀសវាងបានប៉ុន្តែវាមិនជាធម្មជាតិទេ ហើយការពន្យល់ពីមូលហេតុនេះ ត្រូវតែតម្រូវឲ្យមានការគេហៅថា ស្រុះស្រួលគ្នា ឬការប៊ិនប្រសប់ ដើម្បីធ្វើការជាមួយគ្នា។ តើពាក្យដែលលោកនិយាយថាពាក្យថា “សម្ព័ន្ធភាពដែលប្រឆាំងនឹងធម្មជាតិ” នេះ ហើយដែលចាំបាច់។ មានន័យថាយ៉ាងម៉េចដែរ?

[១១:៣៨:៥៦]

**ឆ៖** បាទ វាមិនអាចជៀសវាងបាន ប៉ុន្តែសម្ព័ន្ធភាពដែលខុសធម្មតា។ និស្សិតដែលត្រឡប់ពីបរទេស ដែលមានប្រវត្តិសិក្សាមួយ ជីវិតមួយហ្នឹង ដូចមាន សាឡុត ស, អៀង សារី ហើយនិងអ្នកផ្សេងទៀតនោះ អ្នកទាំងនោះដែលមកពីខ្មែរឥស្សរៈនោះ ប្រវត្តិរបស់គេហ្នឹងគឺខុសគ្នាស្រឡះ។ គេមានការលំបាកក្នុងការ -- នៅក្នុងគំនិតតែមួយ គឺធ្វើឲ្យគំនិតហ្នឹងស្រុះស្រួលគ្នា ហើយយើងមានគំរូបដើមគឺបដិវត្តន៍បារាំង គេមានសម្ព័ន្ធភាពរវាងបញ្ញវន្តហើយនិងពួកកសិករ បាទ វណ្ណៈមួយទៀត។ ដូច្នេះនេះជាមូលដ្ឋាន ជាសម្ព័ន្ធភាពរវាងក្រុមទាំងពីរនេះដែលមានការលំបាកក្នុងការចុះសម្រុងគ្នា។ ហើយនេះហើយជាកត្តាដែលជំរុញឲ្យមានបដិវត្តន៍កម្ពុជានោះ។

**ស៖** បន្ទាប់មកនៅក្រោយ -- នៅពេលដែលធ្វើរដ្ឋប្រហារ គឺថាពេលដែលរបបសីហនុពោរពេញដោយតិរច្ឆាន ហើយនិងថមថយ ហើយក្រោយមកក៏ផ្សាភ្ជាប់សម្ព័ន្ធភាពជាមួយជនចំរើន។ អ៊ីចឹងក្រោយមក ក៏កើតមានជារដ្ឋប្រហារនេះ។ ថ្ងៃនោះលោកឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាថា “សីហនុមិនច្រឡំទេ អំពីអ្វីដែលខ្លួនកំពុងតែរំពឹងរង់ចាំអំពីពួកខ្មែរក្រហមនោះ”។ ប៉ុន្តែសំណួរខ្ញុំនោះថា បើសិនជាគាត់ផ្សាភ្ជាប់សម្ព័ន្ធភាពនោះ ប្រហែលជាគាត់មានគោលបំណងអីមួយ ហើយមានផលប្រយោជន៍អីមួយហើយ ជាមួយខ្មែរក្រហមនេះ។ អ៊ីចឹង តើលោកអាចផ្តល់យោបល់អីបានទេ តើហេតុអីក៏ចងសម្ព័ន្ធភាពហ្នឹង មានប្រយោជន៍អី ក្នុងបំណងអី?

[១១:៤១:០៦]

**ឆ៖** ខ្ញុំជឿថាវាមានកត្តាមួយចំនួន វាមានការពាក់ព័ន្ធ។ ប៉ុន្តែកត្តាពីរដែលនៅក្នុងគំនិតរបស់ខ្ញុំហ្នឹង គឺការក្បត់របស់ លន់ នល់ និង សិរិមតៈ គឺជាចំណងចំណូលចិត្តខាងផ្នែក សីហនុ។ មិនមែនជារឿងនិយាយអំពីរឿងការលេងអុក ក្តាអុកអីនោះទេ។ ដូចដែល ប៉ង់ស្វង់ ដែលនិយាយបែបនេះ គឺក្រោយដោយគាត់យល់អំពីរបបថ្មីនេះ។ គឺនិយាយអំពីកត្តាខាងផ្នែកផ្លូវអារម្មណ៍ទេ ប៉ុន្តែជ្រាលជ្រៅជាជាងនេះទៅទៀតនោះ គឺថាសម្តេច សីហនុ បានសម្រេចព្រះទ័យរក្សាតួនាទីក្នុងនយោបាយកម្ពុជា។ លោកស្រី

អាចនិយាយថា នេះជាការប៉ាន់ប្រមាណ ប៉ុន្តែក្នុងមួយជីវិតរបស់ព្រះអង្គ គឺដើម្បីរក្សាព្រះរាជ្យវង្សសានុវង្សនេះ ហើយដើម្បីរក្សាព្រះរាជ្យវង្សនៅក្នុងប្រទេសកម្ពុជា។ បាទ គឺហេតុផលមួយនេះហើយ ដើម្បីរក្សារាជ្យនិយមនៅក្នុងប្រទេសកម្ពុជានេះ។ ហើយយើងនឹង -- គាត់នឹងបន្តជាអ្នកដើរតួមួយតទៅទៀត។

[១១:៤២:៣៨]

**ស៖** នៅក្នុងសៀវភៅរបស់លោក ERN ជាភាសាបារាំង គឺ 00639712, ជាភាសាអង់គ្លេស 00396398។ លោកបាននិយាយអំពីសុន្ទរកថារបស់សម្តេច សីហនុ ដែលផ្សាយនៅវ៉ាង្ស ដែលចេញពីទីក្រុងប៉េកាំង។ ចំពោះលោក គឺថាទំព័រ១៩៨ ជាភាសាអង់គ្លេស។ លោកបានលើកឡើងដូចតទៅនេះ៖ “បន្ទាប់មក ព្រះអង្គម្ចាស់បានប្រាប់ ហ្ស៊ូ ថាព្រះអង្គបានសម្រេចព្រះទ័យហើយ។ នៅក្នុងសារដែលផ្សាយឲ្យប្រជាជនកម្ពុជាពីទីក្រុងប៉េងកាំងមក គាត់ថ្កោលទោសអ្នកដែលធ្វើរដ្ឋប្រហារ ហើយដើម្បីបង្ហាញថាគាត់នឹងតស៊ូដើម្បីយុត្តិធម៌។ នេះគឺជាស្នារតីសងសឹកហើយ”។ តើលោក -- ហេតុអីលោកលើកឡើងនៅក្នុងសៀវភៅលោកអម្បាញ់មិញនេះ ថាព្រះអង្គម្ចាស់ -- សម្តេច សីហនុ ហ្នឹង គាត់មានបំណងសងសឹក?

**ឆ៖** ខ្ញុំសារភាពថា វាអាចជះឥទ្ធិពលនៃការបកស្រាយរបស់លោកឪពុក ប៉ុងស្វូដ៍។ គឺវាកើតឡើង បញ្ហាដែលកើតឡើងក្នុងបណ្តាសៀវភៅមួយចំនួន ដែលព្រះអង្គបានសរសេរដោយព្រះហស្តព្រះអង្គផ្ទាល់។ អានេះគឺជាការបកស្រាយរបស់ខ្ញុំ។

[១១:៤៤:២១]

**ប្រធានអង្គជំនុំ៖**

ឈប់ៗ អ្នកជំនាញកុំអាល់ទានឆ្លើយតប!

មានបញ្ហា?

សូមលោកអ្នកជំនាញឆ្លើយបំភ្លឺសាជាថ្មីឡើងវិញ ដោយសារហេតុផលនៃបញ្ហាប្រព័ន្ធបកប្រែភាសាហ្នឹង អត់មានភាសាអង់គ្លេសអំមិញហ្នឹង បានជាមានបញ្ហា។ អ៊ីចឹង សូមលោកឆ្លើយសំណួរចុងក្រោយនេះម្តងទៀត។

**លោក ហ្វីលីព ស្បូត៖**

**ឆ៖** តាមដែលខ្ញុំចាំ សំណួរគឺថាតើសំអាងទៅលើមូលដ្ឋានអី ដែលលោកនិយាយដែលថាព្រះ

អង្គមានគំនិតសងសឹក? ហេតុនេះខ្ញុំនិយាយឡើងវិញ។ ខ្ញុំមិនអាចដឹងបានទេថាអ្វីវាមាននៅក្នុងចិត្តគំនិតនៅក្នុងអ្នកដែលដើរតួនៅក្នុងរឿងហ្នឹង ទោះជាសម្តេច សីហនុ ក្តី, ខៀវ សំផន ក្តី, ប៉ុល ពត ក្តី។ ប៉ុន្តែអ្វីដែលខ្ញុំអាចនិយាយបានក្នុងនាមជាប្រវត្តិសាស្ត្រ ឬអ្នកប្រវត្តិ សរសេរជីវប្រវត្តិនោះ គឺខ្ញុំផ្តល់អំពីការបកស្រាយ។ ហើយក្នុងករណីនេះការបកស្រាយរបស់ខ្ញុំ ដូចខ្ញុំបានផ្តល់ជូនហើយ គឺថាព្រះអង្គត្រូវបានគេក្បត់ ព្រះមានការចង់សងសឹក ហើយព្រះអង្គនៅតែមានចិត្តចង់ដើរតួក្នុងឆាកនយោបាយ។ លោកឪពុក ប៉ុងសូដ៏ ក៏គាត់ធ្វើការបកស្រាយ ដែលខ្ញុំរកឃើញថាវាគួរឲ្យយកបាន ជឿជាក់តាមគាត់បាន។ ប៉ុន្តែខ្ញុំមិនអាចដងបានទេថា អ្វីនៅក្នុងព្រះទ័យរបស់ព្រះអង្គនោះ មិនអាចដឹងបានទេ។

[១១:៤៦:៣២]

**ស៖** ឥឡូវនេះខ្ញុំសូមដកស្រង់ចំណុចមួយទៀត ដែលលោកនិយាយអំពីរយៈកាលមុនឆ្នាំ១៩៧៥ នៅក្នុងសេចក្តីផ្តើមនៃសៀវភៅរបស់លោក គឺថា ERN ជាភាសាបារាំង 00639455 ហើយនិងទំព័របន្ទាប់មកទៀត 56, ជាភាសាអង់គ្លេស 00369197 ហើយនិងបន្តមកទៀតគឺ 8។ លោកបានលើកឡើងដូចតទៅនេះ “ក្នុងសង្គ្រាម៥ឆ្នាំ ដែលរវាងរបប លន់ នល់ ហើយនិងពួកកុម្មុយនីស្ត អ្នកសង្កេតការណ៍នៅកម្ពុជា ក៏ដូចជានៅបរទេសដែរ ជឿថាចលនានេះត្រូវដឹកនាំដោយ ខៀវ សំផន ដែលជាបញ្ញាជនឆ្វេងនិយម ដោយគេស្គាល់គាត់គ្រប់គ្នា។ គាត់តែងតែនិយាយដើម្បីយុត្តិធម៌សង្គមកាលសម័យ សីហនុ ហើយគេគាំទ្រគាត់ច្រើនណាស់សម័យ សីហនុ នេះ។ គាត់បានចូលព្រៃម៉ាគី នៅឆ្នាំ១៩៧៧ និង -- អ៎! ៦៧ ហើយនិងបន្ទាប់ពីគឺថាស្ទើ -- ក្រោយពីទម្លាក់សម្តេច សីហនុ ៣ឆ្នាំមក គាត់ក៏ក្លាយជាអ្នកនាំពាក្យរបស់ខ្មែរក្រហម ជារដ្ឋមន្ត្រីក្រសួងការពារជាតិ ហើយនិងអគ្គមេបញ្ជាការនៃកងទ័ពតស៊ូ។ ខៀវ សំផន បានទៅទីក្រុងប៉េកាំងដើម្បីជួប ម៉ៅ សេទុង។ គាត់បានធ្វើចេញសេចក្តីប្រកាសមួយនិយាយអំពីព័ត៌មានលម្អិត និងការរីកដំណើរការទៅមុខនៃសង្គ្រាម ហើយនិងគាត់និយាយអំពីការធ្វើសម្ព័ន្ធមិត្តជាមួយនឹង សីហនុ។ ហើយ ខៀវ សំផន បានទទួលសម្តេច សីហនុ នៅតំបន់រំដោះនេះ។ ក៏ប៉ុន្តែនេះគ្រាន់តែជាផ្សែងបានតែមួយភ្លែតតែប៉ុណ្ណោះ អំណាចទាំងអស់នេះសុទ្ធតែនៅក្នុងកណ្តាប់ដៃអ្នកផ្សេងនោះទេ ហើយអ្នកផ្សេងទៀតមិនដឹងទេ គឺថាតាមពិតទៅអ្នកដឹកនាំខ្ពស់បំផុតនៃបក្សកុម្មុយនីស្តកម្ពុជាទេជាអ្នកកាន់អំណាច”។

អ៊ីចឹងសំណួរទាក់ទងនឹងផ្នែកនេះ ដែលឆ្លើយតបទៅនឹងសំណួរដែលគេសួរទៅលោកប៉ុន្មានថ្ងៃមុននេះ គឺថាទាក់ទងទៅនឹងគេហៅថា ការរក្សាការសម្ងាត់ មិនបង្ហាញការពិតទេ គឺថាផ្តល់តែអាការៈ

ក្រៅតែប៉ុណ្ណោះឲ្យគេឃើញនោះ។ តើនេះពិតជាគោលការណ៍របស់ ប៉ុល ពត នៅសម័យនោះដែលថា ស្ថិតនៅក្រោយឆាកដើម្បីបង្ហាញ -- កុំឲ្យគេដឹងថាអ្នកកាន់អំណាចពិតនោះជាអ្នកណា? តើអ៊ីចឹងមែនទេ?

**ផ៖** ជាការត្រឹមត្រូវហើយ ខ្ញុំមិនដឹងឆ្លើយអ្វីលើសពីនេះទេ។

[១១:៥០:០០]

**ស៖** មានផ្នែកមួយទៀត គឺថាទំព័របន្ទាប់នោះ ដែលលោកបាននិយាយអំពី សាឡុត ស ដែលដូចជាគេហៅថាជាសម្មតិករម្នាក់ ដែលថាតាមពិតទៅនៅក្នុងសាច់រឿង បើយើងនិយាយពីការថតកុនគាត់ជាគ្រាន់តែជាអ្នករាយរងទេ ប៉ុន្តែការពិតគាត់ជាអ្នកដឹកនាំរឿង ជាសម្មតិករ។ យើងឥឡូវនេះ ខ្ញុំសូមនិយាយអំពីបុគ្គលិកលក្ខណៈរបស់ ប៉ុល ពត។ ខ្ញុំសង្ឃឹមថាខាងសហព្រះរាជអាជ្ញាមិនជំទាស់របស់មកខាងខ្ញុំទេ ពីព្រោះថាលោកមកទីនេះ និយាយអំពីប្រវត្តិរូបរបស់ ប៉ុល ពត។

មានការសរសេរ មានអត្ថបទមួយចំនួនអំពីបុគ្គលិកលក្ខណៈរបស់ ប៉ុល ពត នេះ។ ឧទាហរណ៍ដូចជាលោក ដេវីដ ឆេនដ៍ល័រ បានសរសេរ ឬក៏និយាយអំពីបុគ្គលិកលក្ខណៈរបស់ ប៉ុល ពត។ ERN ជាភាសាអង់គ្លេស -- ខ្ញុំសូមទោសដែលមានតែជាភាសាអង់គ្លេស គឺថា 00393065។ គឺស្ថិតនៅក្នុងសៀវភៅ "បងធំទី១"។ ក្នុងនេះ ឆេនល័រ និយាយថាពីការដែលគេស្រលាញ់ ឬក៏ថាគឺថាមុនស្នេហ៍របស់ ប៉ុល ពត គឺថាគាត់ទៅណា គេស្រលាញ់គាត់ ហើយគាត់មានចរិតជាអ្នកដឹកនាំ ដែលធ្វើឲ្យខ្មែរភាគច្រើនគាំទ្រគាត់។ សំណួរខ្ញុំចង់ដឹងថាតើនៅក្នុងក្របខ័ណ្ឌនៃការស្រាវជ្រាវរបស់លោកនេះ តើលោកៗធ្លាប់បានគិតអំពីថាភាពប្រជាប្រិយភាពរបស់ ប៉ុល ពត ឬក៏ថាចរិតម៉ឺងម៉ាត់របស់ ប៉ុល ពត ដែលធ្វើឲ្យគេគ្រប់គ្នាតាមគាត់ទេ? គាំទ្រគាត់ទេ?

[១១:៥២:២២]

**ផ៖** ខ្ញុំថាគ្មានអ្វីគួរឲ្យសង្ស័យនោះទេ ពេលដែលខ្ញុំជួប ប៉ុល ពត ផ្ទាល់នៅទីក្រុងប៉េកាំង -- តើយើងមានបញ្ហាអី ឬក៏យ៉ាងម៉េចដែរលោកប្រធាន។ តើអាចចាប់ផ្តើមបានទេ?

បាទ ខ្ញុំបាននិយាយថាមិនគួរឲ្យសង្ស័យទេ នៅពេលដែលខ្ញុំបានជួប ប៉ុល ពត នៅទីក្រុងប៉េកាំងឆ្នាំ៧៧។ គឺថាភាពសម្រស់របស់គាត់ ប្រជាប្រិយរបស់គាត់ ហើយគាត់តែងតែញញឹមគួរឲ្យចាប់អារម្មណ៍ ហើយមានការរៀបរាប់ជាច្រើនពីខាងភាគីកម្ពុជាបន្ទាប់ពីកិច្ចប្រជុំមួយទៅ គឺថាគេម្នាក់ៗគឺដាក់ខ្លួនធ្វើតាម គឺគាត់ថាប្រជាប្រិយភាព អត្តចរិតផ្ទាល់ខ្លួននេះ គឺជារឿងសំខាន់ណាស់ក្នុងភាពជាអ្នក

ដឹកនាំនេះ។

[១១:៥៣:៣១]

**ស៖** ទាក់ទងនឹងរបៀបធ្វើការរបស់ ប៉ុល ពត នេះ លោកបានធ្លាប់បានសម្ភាសលោក ស្វួង ស៊ីគឿន ហើយលោកបានដកស្រង់នៅក្នុងសៀវភៅរបស់លោក គឺថានៅទំព័រជាភាសាអង់គ្លេសគឺថា ៣៤០, ERN ជាភាសាបារាំងគឺ 00639901, ជាភាសាអង់គ្លេសគឺ 00396548។ លោកសរសេរដូចតទៅនេះ "ស្វួង ស៊ីគឿន យល់ឃើញថា ប៉ុល ពត នោះគិតអំពីព័ត៌មានលម្អិតបំផុតក្នុងការដឹកនាំរបស់គាត់ គឺគាត់កាន់អំណាចផ្តាច់មុខគ្រប់វិស័យទាំងអស់"។ សូមបញ្ចប់ការដកស្រង់។ ហើយលោកបន្ថែមមកទៀត – នេះជាពាក្យសម្តីរបស់លោក មិនមែនជាពាក្យសម្តីរបស់ ស្វួង ស៊ីគឿន ទេ – គឺថា "ទំនោនេះ គឺថាកាន់តែធ្ងន់ធ្ងរទៅៗ។ ទំនោរបស់ ប៉ុល ពត នេះ"។ សំណួររបស់ខ្ញុំនេះ គឺថាក្រៅពីចម្លើយរបស់ ស្វួង ស៊ីគឿន នេះ តើមានអ្វីខ្លះដែលជាធ្វើឲ្យលោកនិយាយលើកឡើងដូចនេះ ថាៗនិយាយថា ប៉ុល ពត ហ្នឹងកាន់អំណាចផ្តាច់ការ ហើយពេលវេលាកាន់តែកន្លងទៅ ការកាន់ចង់អំណាចផ្តាច់មុខតែឯងនេះកាន់តែច្រើនទៅៗ ធ្ងន់ៗទៅ?

[១១:៥៥:១៣]

**ឆ៖** ខ្ញុំកំពុងគិតអំពីឧប្បត្តិហេតុកើតក្រោយមកទៀត។ ខ្ញុំគិតថាប្រហែលជានាយករដ្ឋមន្ត្រីថៃដែលធ្វើទស្សនកិច្ចទៅកាន់សៀមរាប ខ្ញុំអត់ចាំឆ្នាំទេ។ ប៉ុន្តែ ប៉ុល ពត ខ្លួនឯងផ្ទាល់នេះដែលបានស្នើសុំឲ្យនិយាយលម្អិតថាតើគួររៀបចំយ៉ាងម៉េច ថាតើរបបអាហារ បន្ទប់ស្នាក់អាស្រ័យនៅ បង្អែម ហើយទៅគួរផ្តល់អាហារអីឲ្យគាត់ហូបចុកនេះ គឺជារឿងធម្មតាដែលគួរតែឲ្យអ្នកដទៃធ្វើ។ ហើយសម្តេចសីហនុ ក៏ប្រហែលដូចតែគ្នាហ្នឹងក្នុងការគ្រប់គ្រងតែរឿងកំប៉ិកកំប៉ុកដូចគ្នាអ៊ីចឹង។ ប៉ុន្តែវាជាចំណុចមួយនៃការគ្រប់គ្រងរបស់គាត់ នៃការត្រួតត្រារបស់គាត់។

**អ្នកបកប្រែ៖**

លោកប្រធានគាត់អត់បានបើកមីក្រូ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំសូមលើកចំណុចចុងក្រោយមុននឹងសម្រាកអាហារថ្ងៃត្រង់ ពីព្រោះថាជិតម៉ោងដប់ពីរហើយ។ គឺថាយើងបាននិយាយអំពីសង្គ្រាម៥ឆ្នាំនៅក្នុងព្រៃដែល ខៀវ សំផន កាលនោះគ្រាន់តែជាខែលសម្រាប់សាធារណជនទេ។ លោកក៏បានលើកឡើងអំពីរយៈពេលដើមមួយគឺដើមឆ្នាំ៧៥ សម្រាប់លោក

គឺទំព័រ --សូមអភ័យទោសខ្ញុំអត់មានលេខទំព័រទេ។ ខ្ញុំសូមផ្ដល់លេខ ERN ជាភាសាបារាំងសិន។ 00639849, ERNជាភាសាអង់គ្លេសគឺ 00396513។ ចំពោះលោកសាក្សីគឺទំព័រ៣០៥, លោកនិយាយថាកាលនោះ ក្រសួងក្លែងក្លាយនោះកាលនោះ ឆ្នាំ៦៥, "ខៀវសំផន មិនមែនជាអ្នកទទួលខុសត្រូវខាងការពារជាតិទេ គឺថាលេខាភូមិភាគបស្ចិមនោះទទួលខុសត្រូវ។ ហើយនេះគឺជាក្រសួងដែលបង្ហាញមុនឆ្នាំ៧៥ ជាក្រសួងស្រមោល។ អ៊ីចឹងគឺថាក្រោយមកថាអ្នកផ្សេងទេ ជាអ្នកឡើងកាន់អំណាចមិនមែនលោក ខៀវ សំផន ទេ"។ នេះខ្ញុំនិយាយអំពីមុននេះ និយាយពីរយៈពេលជិតឡើងកាន់អំណាចហើយហ្នឹងគឺថាតើក្នុងរយៈកាលនេះបើតាមលោកស្រាវជ្រាវនោះសួរថាតើវាស្ថិតនៅក្នុងក្របខ័ណ្ឌនៃច្បាប់រក្សាការសម្ងាត់ដដែល ឬក៏យ៉ាងណា? ព្រោះថាគ្រាន់តែជាក្រសួងស្រមោលទេ ហើយមិនឡើងកាន់អំណាចទេ។

[១១:៥៨:៤៨]

**ឆ៖** វាសំខាន់ណាស់ដែលត្រូវរក្សាការសម្ងាត់នៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យតែម្ដង។ ក៏ប៉ុន្តែនៅក្នុងពេលនុ៎ង ដូចដែលខ្ញុំបាននិយាយហើយថា ដើម្បីបង្ហាញឬធ្វើឲ្យមានចំណាប់អារម្មណ៍ថាមានរដ្ឋាភិបាលមួយដែលមានដំណើរការប្រព្រឹត្តទៅគ្រប់ផ្នែក សូម្បីជាមួយនឹងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាត្រូវបានបង្កើតឡើងនៅដើមទសវត្សរ៍៧០ គឺនៅឆ្នាំ៧១ ក្ដី គឺប៉ុស្ដិ៍រដ្ឋមន្ត្រីទាំងអស់គឺគ្រាន់តែជាស្រមោលតែប៉ុណ្ណឹង។ ហ្នឹងឯងបានជារដ្ឋកម្ពុជាប្រជាធិបតេយ្យទៅជាអ៊ីចឹង។ រដ្ឋសភា នួន ជា ជាប្រធាន ប៉ុន្តែអត់មានកើតរូបរាងពិតប្រាកដទេ។ ហើយមានគេដឹងឮថាមានការចូលរួមក្នុងកិច្ចប្រជុំលើកទី១គ្រាន់តែចូលរួមតែមួយព្រឹក ស្លៀកពាក់ស្អាតបាតបន្តិចទៅ ហើយក្រោយមកចប់ឈឹងបណ្ដោយហើយមិនដែលមានទៀតទេ។ នេះគឺជាការប្រឌិតឡើងហើយមិនមានអត្ថិភាពពិតប្រាកដដូចរដ្ឋាភិបាលដទៃទៀតដែលគេមានប្រតិបត្តិការត្រឹមត្រូវនោះទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ដោយសារខ្ញុំចូលប្រធានបទផ្សេងទៀត។ អ៊ីចឹងបើសិនជាលោកប្រធានអនុញ្ញាតឲ្យសម្រាកពេលនេះសូមបញ្ឈប់ត្រឹមនេះសិនលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណដល់អ្នកជំនាញ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ ម៉ោងមួយសាមសិបនាទីរសៀលនេះសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និង អ្នកជំនាញ ឬក៏ទីកន្លែងណាមួយសមស្របសម្រាប់អ្នកជំនាញរូបនេះសម្រាកនៅក្នុងអំឡុងពេលថ្ងៃត្រង់នេះ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងមួយសាមសិបនាទីរសៀលនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកនៅខាងក្រោមសាលសវនាការនេះ និងឲ្យអញ្ជើញគាត់ នាំខ្លួនគាត់ចូលមកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០១ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:២៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

សូមអញ្ជើញ!

[១៣:៣០:៥៧]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក ហ្វីលីព ស្សត! យើងខ្ញុំនឹងពិនិត្យមើលជាមួយលោកនូវបញ្ហាផ្សេងៗជាបន្តទៅទៀត។ កាលពីព្រឹកម្សិលមិញប្រហែលជាម៉ោង ១០:១៨ នៅក្នុង និង១០:២០នាទី សហព្រះរាជអាជ្ញាបានសួរលោកពាក់ព័ន្ធទៅនឹងកិច្ចប្រជុំមួយដែល ភី ភួន បាននិយាយ ហើយលោកបានសម្ភាស ភី ភួន នេះហើយលោកក៏បានសរសេរនៅក្នុងសៀវភៅរបស់លោកយ៉ាងវែងពាក់ព័ន្ធទៅនឹង ភី ភួន នេះ។ ហើយសហព្រះរាជអាជ្ញាបានសួរលោកថា "ភី ភួន បាននិយាយប្រាប់លោកអំពីកិច្ចប្រជុំនៅខែមេសា

ឆ្នាំ៧៥?" ហើយលោកក៏បានឆ្លើយជាភាសាបារាំងនោះថា "ខ្ញុំមិនដឹងទេ គាត់មិនបាននិយាយប្រាប់ខ្ញុំទេ ហើយអ្នកផ្សេងទៀតក៏អត់និយាយទេ"។ ចំណុចនេះអាចជឿជាក់បាន។ សំណួរទី១ តើលោកមិនចាំ ឬក៏គេមិននិយាយប្រាប់លោក?

**លោក ហ្វីលីព ស្សូត៖**

**ឆ៖** ខ្ញុំគិតថា ខ្ញុំដូចជានឹកមិនឃើញថាគាត់បាននិយាយពីរឿងនោះទេ ខ្ញុំមិនច្បាស់១០០ភាគរយទេ ប៉ុន្តែខ្ញុំមិននឹកឃើញពីអ្វីនោះទេ។ ខ្ញុំមិនគិតថាគាត់បាននិយាយទេ ហើយវាអាចថា ខ្ញុំភ្លេច ឬក៏ -- តាមពិតទៅ ខ្ញុំរកនឹកមិនឃើញទេពេលនេះ។

[១៣:៣២:៥២]

**ស៖** សូមអរគុណ។ ពីព្រោះថានៅពេលគាត់មកផ្តល់សក្ខីកម្មនោះ គេបានសួរសំណួរគាត់ពាក់ព័ន្ធទៅនឹងចំណុចនេះ គឺប្រតិចារឹកសវនាការ E1/97.1 នៅម៉ោង១១:១៩ គឺមេធាវី វែកគែន បានសួរគាត់ ដើម្បីចង់ដឹងថាតើគាត់មានបាននិយាយកិច្ចប្រជុំដើមខែមេសា ឆ្នាំ១៩៧៥ ពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនដែរឬទេ? ហើយគាត់ពេលនោះឆ្លើយថា "ខ្ញុំបាននិយាយរឿងនេះជាមួយគាត់មែន"។ ឥឡូវនេះ ខ្ញុំស្តាប់ឮចម្លើយរបស់លោកហើយ ខ្ញុំយល់ហើយ។ អ្វីដែលខ្ញុំចាប់អារម្មណ៍គឺចំណុចទី២ គឺកិច្ចប្រជុំដើមខែមេសាហ្នឹង គឺថាលោកមិនដែលឮគេនិយាយទេ ហើយសហព្រះរាជអាជ្ញានិយាយអំពីបញ្ហានេះ ហើយលោកក៏ថាជឿជាក់បាន។

[១៣:៣៣:៤៥]

ប្រសិនបើលោកមិនដែលឮគេនិយាយ ឬក៏មិនមានអ្នកណាម្នាក់បាននិយាយប្រាប់លោកពីមុនអំពីកិច្ចប្រជុំនេះទេ អ៊ីចឹងលោកមានមូលដ្ឋានអីដែលលោកអាចនិយាយថា វាជាការអាចជឿជាក់បាននោះ ប្រសិនបើមិនមានអ្នកណាប្រាប់លោក ហើយលោកក៏មិនបានទទួលព័ត៌មានទុំង ហើយហេតុអ្វីក៏បានជាលោកមានមូលដ្ឋានអីបានជាលោកប៉ាននិយាយថា "ចំណុចនេះគឺថាអាចជឿជាក់បាន" នោះ?

**ឆ៖** ជាសាមញ្ញនោះ ប្រសិនបើលោកស្រីប្រាប់ខ្ញុំ ឬក៏ថាអ្នកណាប្រាប់ខ្ញុំថាមានកិច្ចប្រជុំនៅប-៥ ដែលនិយាយកាលពីម្សិលមិញនោះ គឺនៅដើមខែមេសានោះ ហេតុអីក៏ថាមិនមានកិច្ចប្រជុំបែបនោះ? តើមានហេតុផលអីដែលខ្ញុំឆ្ងល់ពីរឿងហ្នឹង? ខ្ញុំមិននិយាយថា មាន ឬមិនមាននោះទេ ខ្ញុំគ្រាន់តែនិយាយទេ។ ខ្ញុំមិនមានហេតុផលក្នុងការសង្ស័យ គឺថាបើសាក្សី ឬក៏អ្នកណាបញ្ជាក់ថាមានការប្រជុំ គឺវាពិតជាដូចអ្នកនោះថាហើយ។

[១៣:៣៤:៥៨]

**ស៖** ខ្ញុំត្រឡប់មកនិយាយអំពីចំណុចដែលបានលើកឡើងកាលពីព្រឹកមិញពាក់ព័ន្ធទៅនឹងវិធីសាស្ត្រការងាររបស់លោក និងជាពិសេសនោះពាក់ព័ន្ធទៅនឹងបញ្ហាដែលលោកបានសួរប៉ុន្មានឆ្នាំក្រោយពីអង្គហេតុ ហើយប្រហែលជាអាចមានការភ័ន្តច្រឡំ។ ម្សិលមិញនៅពេលដែលយើងនិយាយអំពីគណៈមជ្ឈិមនៅឆ្នាំ៧៤ នោះ លោកបាននិយាយថា កាលបរិច្ឆេទនៅក្នុងសៀវភៅរបស់លោកខែកញ្ញា ឆ្នាំ៧៤ ប្រហែលជាមិនពិតទេ ពីព្រោះថាលោកបានឃើញសៀវភៅទស្សនាវដ្តីទង់បដិវត្តនោះ គឺបញ្ជាក់ថា ខែ៦ នោះទេ ឆ្នាំ៧៤ នោះ។ ពាក់ព័ន្ធនឹងខែកញ្ញា ឆ្នាំ១៩៧៤ នោះ គឺថាលោកបានព័ត៌មានហ្នឹងមកពី ភី ភួន មែនទេ? បានជាលោកប៉ានបញ្ជាក់ថា នៅខែកញ្ញា ឆ្នាំ៧៤នុ៎ង?

**ឆ៖** បាទ ខ្ញុំផ្អែកលើចម្លើយនោះមែន។

[១៣:៣៦:០៤]

**ស៖** ដូច្នេះនេះ គឺជាឧទាហរណ៍ជាក់ស្តែងដែលបង្ហាញអំពីសុច្ឆន្ទៈនៃបុគ្គលម្នាក់ដែលប្រាប់លោកអំពីព័ត៌មានមិនពិត។ នៅពេលដែលខ្ញុំប្រាប់លោកអំពីព័ត៌មានណាមួយនោះ គឺថានៅពេលដែលយើងមិនមានភាពស៊ីសង្វាក់គ្នា ឧទាហរណ៍ថា នៅក្នុងសៀវភៅរបស់លោក លោកសរសេរចំណុចមួយហើយជួនកាលទៅមានគេឲ្យ -- គេប្រាប់ព័ត៌មានលោកមិនពិត។ ដូច្នេះអាចមានកំហុសឆ្គងពាក់ព័ន្ធនឹងចំណុចនេះ។ ដូច្នេះលោកអាចឯកភាពទេថា ប្រសិនជាយើងប្រៀបធៀបទៅជួនកាលវាអាចមានភាពខុសគ្នា គឺនេះហើយជាកិច្ចការងាររបស់ប្រវត្តិសាស្ត្រ ជាអ្នកប្រវត្តិវិទូរបស់លោកនោះ។ ដូច្នេះនៅទីនេះគឺជាតុលាការ ដូច្នេះគេត្រូវការឲ្យលោកធានាបន្ថែម ដូច្នេះលោកឯកភាពជាមួយខ្ញុំទេត្រង់ចំណុចនេះ?

[១៣:៣៦:៥៤]

**ឆ៖** យើងយល់ស្របទាំងស្រុង ប៉ុន្តែអ្វីដែលអាចផ្ទៀងផ្ទាត់គ្នាបាននោះ គឺថាដែលត្រូវតែធ្វើបានសម្រាប់តុលាការ ឬសម្រាប់អ្នកប្រវត្តិសាស្ត្រ នៅក្នុងករណីនោះគឺខ្ញុំមិនដឹងថាមានឯកសារយោងជាឯកសារទង់បដិវត្តទេ។ បញ្ហាដ៏ធ្ងន់នៃការចងចាំនោះ គឺទៅតាមកាលប្បវត្តិ កាលលំដាប់លំដោយកាលប្បវត្តិ ហើយ ភី ភួន គឺចងចាំត្រឹមត្រូវ កន្លែងខ្លះក៏មិនសូវត្រូវ។ អ្វីដែលកើតនោះ ជាញឹកញាប់គាត់ច្រឡំថាកើតឡើងនៅពេលណា ពីកាលបរិច្ឆេទ។ បញ្ហានៃការសរសេរអំពីកម្ពុជាប្រជាធិបតេយ្យ ហើយបញ្ហានៅក្នុងតុលាការដែលត្រូវវិនិច្ឆ័យនោះ គឺថាគឺត្រូវតែពឹងផ្អែកមួយផ្នែកធំទៅលើការចងចាំ។ ឯកសារក៏អាចជាមូលដ្ឋានបង្អែកដែរ ប៉ុន្តែការចងចាំនោះគឺថាវាជាស្ថានភាពមួយ។ ចំណុចដែលលោកស្រីលើក

ឡើងហ្នឹងគឺថាវាទាក់ទងទៅនឹងប្រវត្តិសាស្ត្រ ហើយនិងយើងទាំងអស់គ្នាក៏វាត្រូវផ្អែកលើប្រភពទាំងនោះដែរ។

[១៣:៣៨:០២]

**សៈ** យើងនឹងមានឱកាសត្រឡប់មកនិយាយអំពីបញ្ហាប្រៀបធៀប និងពិនិត្យផ្ទៀងផ្ទាត់ព័ត៌មាននេះវិញនៅពេលក្រោយទៅតាមករណីនីមួយៗ។ ចំណុចមួយដែលខ្ញុំចង់ពិភាក្សាជាមួយលោកនេះ គឺថាលោកបានលើកឡើងអំពីស្ថានភាពកម្ពុជានៅមុនពេលរំដោះ ជាពិសេសគឺឆ្នាំមុនៗពេលរំដោះ។ លោកបានពន្យល់នៅក្នុងសៀវភៅរបស់លោកថា យើងគិត -- លោកគិតយ៉ាងម៉េច ទោះបីជាការទម្លាក់គ្រាប់បែកហ្នឹងក៏វាមានឥទ្ធិពលខ្លាំង ហើយតាមផ្នែក តាមទស្សនៈសេដ្ឋកិច្ចនោះ តើលោកឯកភាពទេថានៅឆ្នាំ១៩៧៥ ស្ថានភាពកម្ពុជាមានការលំបាកខាងផ្នែកសេដ្ឋកិច្ច គឺថាមានប្រព័ន្ធកសិកម្មនុំងវាហួសសម័យ។ តើលោកឯកភាពជាមួយខ្ញុំហ្នឹងទេ?

**ផះ** នៅក្នុងឆ្នាំ១៩៧៥ ស្ថានភាពសេដ្ឋកិច្ច គឺលំបាកខ្លាំង ហើយអាក្រក់ណាស់។ ដោយសារសង្គ្រាមស៊ីវិល តំបន់ខ្លះនៃប្រទេសគឺកាន់កាប់ដោយខ្មែរក្រហម ហើយសំណល់ផ្សេងទៀតនោះ គឺថាលន់ នល់ កាន់កាប់ គឺថាត្រូវបានបំផ្លាញដោយសង្គ្រាម។ ខ្ញុំមិនបញ្ជាក់ថា ជាប្រព័ន្ធកសិកម្មថយក្រោយឱនភាពនោះទេ ប៉ុន្តែវាជាកសិកម្មសម័យនោះត្រូវបានបំផ្លាញដោយសង្គ្រាមស៊ីវិល។

[១៣:៣៩:៤៥]

**សៈ** តើលោកកំណត់អំពីប្រព័ន្ធកសិកម្មនៅសម័យនោះថា យ៉ាងម៉េចដែរ?

**ផះ** គឺជាកសិកម្មដែលដើរថយក្រោយ ដោយមិនឆ្ងល់ទេ។ ប៉ុន្តែការនេះក៏មិនមែនថាអាចនឹងរារាំងដល់ការវិវឌ្ឍសេដ្ឋកិច្ចនោះដែរ។ វាមិនមានលក្ខណៈស្មើ -- វាថាដោយសារកសិកម្មថយក្រោយសេដ្ឋកិច្ចមិនទៅមុននោះទេ ពីព្រោះថាគេធ្វើចំណាត់ថ្នាក់ថា កម្ពុជាកាលនោះក៏ជាប្រទេសក្រីក្រដែរក្នុងលោក។ គឺថាវាមានជំនួយបរទេសដើម្បីឧបត្ថម្ភស្បៀងអាហារ។ គឺថានៅក្នុងតំបន់មួយចំនួន គឺថាវិស័យកសិកម្មនៅថយក្រោយ ប៉ុន្តែតំបន់ខ្លះគេអាចផលិត អាចនឹងផ្គត់ផ្គង់ប្រជាជន។ គឺថាសេដ្ឋកិច្ចគឺដើរទៅមុខ ប៉ុន្តែយឺតមិនដូចគេចង់បានទេកាលនោះ។

[១៣:៤០:៥៣]

**សៈ** ពាក់ព័ន្ធនឹងបញ្ហាសេដ្ឋកិច្ចនេះដដែល នៅក្នុងសៀវភៅរបស់លោក លោកបានពិភាក្សាអំពីនិក្ខេបបទរបស់លោក ខៀវ សំផន ហើយនិងគំនិតដែលមាននៅសម័យនោះ។ នៅចំពោះលោកនោះ

គឺទំព័រ២៩០, ERN ជាភាសាបារាំង 00639829, ជាភាសាអង់គ្លេស 00396498។ នៅទំព័រនេះ លោកសរសេរថា "នៅពាក់កណ្ដាលឆ្នាំ៧០ (លោកនិយាយអំពីនិក្ខេបបទរបស់លោក ខៀវ សំផន) អភិវឌ្ឍនោះ គឺថាមិនសំខាន់ដូចកាលពីប៉ុន្មានឆ្នាំមុននោះទេ គឺវាមានលក្ខណៈស្មុគស្មាញ។ ក្រុមអ្នកសង្គមវិទូបស្ចិមប្រទេសដែលគេសុំនៅឆ្នាំ៧៦ ឲ្យបង្កើតគម្រោងមួយសម្រាប់អនាគតនៅថៃនោះ បានស្នើកម្មវិធីមួយដែលមានភាពស្រដៀងគ្នាទៅនឹងវិធីសាស្ត្រដែលបានធ្វើឡើងនៅប្រទេសជិតខាង។ បើយើងពិនិត្យមើលទៅលើភាពលើសនៃប្រជាជននៅទីក្រុង នៅជនបទនោះ យើងឃើញមានការរឹបអូសទ្រព្យសម្បត្តិដែលគ្មានប្រយោជន៍។ របបខ្លួនទីពឹងខ្លួននោះគឺថាមានភាពសមហេតុផល"។ នេះជាការសរសេរនៅឆ្នាំដដែលនោះ ដោយ ដេវីដ ឆេនដ័ល័រ។

[១៣:៤២:៥០]

នៅទំព័របន្ទាប់មកទៀត នៅកថាខណ្ឌទី២ ជាភាសាបារាំង "អ្នកនិពន្ធទាំងអស់នេះ មិនមានអ្នកណាជាអ្នកឆ្វេងនិយមនោះទេ។ ពួកគាត់ដឹងច្បាស់អំពីបរាជ័យនៃយុទ្ធសាស្ត្រអភិវឌ្ឍដែលបានបង្កើតឡើងនៅកម្ពុជា នៅក្នុងចន្លោះទសវត្សរ៍ឆ្នាំ៥០-៦០។ សីហនុ ចំពោះគម្រោងដើម្បីលើកកម្ពស់កិត្យានុភាព ហើយនិងរោងចក្រជាគន្លឹះនោះ គឺថាមានបង្ហាញអំពីរបៀបមួយដែលលេចធ្លោឡើង ហើយនិងមានបង្ហាញអំពីរបៀបផ្សេងៗ"។ ពាក់ព័ន្ធទៅនឹងការបង្ហាញអំពីគំនិតដែលពាក់ព័ន្ធទៅនឹងសេដ្ឋកិច្ចដើម្បីអភិវឌ្ឍនេះ ខ្ញុំត្រឡប់មកការពិចារណា ដែលលោកបានឃើញ ពិនិត្យឃើញកាលពីម្សិលមិញនោះ គឺថាមិនមែនជាគោលបំណងរបស់ខ្មែរក្រហមនោះទេដែលអាក្រក់នោះ គឺថាមធ្យោបាយដែលអនុវត្តទេដែលបង្កនូវគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរបែបនេះនោះ។ តើការស្រាវជ្រាវរបស់អ្នកសង្គមវិទូនៅសម័យនោះ បានធ្វើឲ្យលោកគិតពិចារណាពាក់ព័ន្ធទៅ នឹងគោលបំណងរបស់ខ្មែរក្រហម ដែលថាពួកគេមានគំនិតល្អ ក៏ប៉ុន្តែការអនុវត្តរបស់ពួកគេ ឬក៏ មធ្យោបាយទេដែលមានបញ្ហានោះ?

[១៣:៤៤:២០]

**ផ៖** ខ្ញុំគិតថា នៅក្នុង -- ខ្ញុំនិយាយស៊ីសង្វាក់គ្នានៅក្នុងសៀវភៅ។ បាទ គោលបំណង គឺមានមូលដ្ឋានត្រឹមត្រូវគឺបែបនោះមែន។ បញ្ហាដែលកើតឡើង គឺក្នុងការអនុវត្តគំនិតនោះទេ។

**សៈ** ឥឡូវនេះ ខ្ញុំត្រឡប់មកចំណុចមួយ ដែលលោកបានពិភាក្សាជាមួយសហព្រះរាជអាជ្ញាកាលពីម្សិលមិញ ពាក់ព័ន្ធទៅនឹងការជម្លៀស និងចំណុចជាក់លាក់មួយដែលលោកបានលើកឡើង។ ចំពោះលោកនោះគឺទំព័រ២៨៦, ERN ជាភាសាបារាំង 00369825, ERN ជាភាសាអង់គ្លេស 0039

6494។ លោកបានសរសេរពាក់ព័ន្ធទៅនឹងការជម្លៀស គឺខ្ញុំសូមលើកឡើងនូវកថាខណ្ឌកាលម្សិលមិញ។

**អ្នកបកប្រែ៖**

លោកប្រធានសូមឲ្យមេធាវីបន្ថយល្បឿនបន្តិច គាត់អានលឿនណាស់អ្នកបកប្រែតាមអត់ទាន់។

[១៣:៤៥:៥២]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ចាស ខ្ញុំសូមចាប់ផ្តើមម្តងទៀត "នួន ជា និង ខៀវ សំផន ទទួលបន្ទុកក្នុងការពិនិត្យតាមប៉ុស្តិ៍ត្រួតពិនិត្យមួយៗនៅក្នុងភូមិភាគឧត្តរ នៅព្រែកក្តាម នៅផ្លូវជាតិលេខ៥។ ម៉ុក គឺគាត់ទៅមកៗនៅតំបន់តាកែវ"។ កាលម្សិលមិញនោះ នៅពេលដែលគេសួរលោកនោះលោកបានបញ្ជាក់ជូនលោកស្រីខាតវ៉ាយថ៍ ថាមិនមែន ខៀវ សំផន ជាអ្នកប្រាប់លោកទេ។ លោកនៅក្នុងជើងទំព័ររបស់លោកនោះលោកបានបញ្ជាក់ថា -- ដូច្នេះខ្ញុំចង់ដឹងថាតើលោកបានប្រភពមកពីណាពាក់ព័ន្ធទៅនឹងចំណុចនេះ ដែលថា នួន ជា ហើយនិង ខៀវ សំផន នោះគាត់មានវត្តមាននៅតាមប៉ុស្តិ៍ត្រួតពិនិត្យនោះ?

**លោក ហ្វីលីព ស្ហតៈ**

**ឆ៖** ប្រភពរបស់ខ្ញុំគឺ ភី ភួន គាត់ធ្លាប់បានវត្តមាននៅក្នុងក្រុមមនុស្សដែលមកចូលក្នុងភ្នំពេញដំបូងនៃអ្នកដឹកនាំនោះ ហើយនៅថ្ងៃទី១ គាត់ -- ក្រោយមកត្រឡប់ទៅ ប៉ុល ពត ហើយថ្ងៃទី២ គាត់ក៏មកម្តងទៀត។ ហេតុនេះហើយគឺជាមូលហេតុដែលយើងអាចយល់បាន ដែលថាពាក្យដែលថាកុហកនោះ គឺថាជាពាក្យមួយ គឺថាអាចនឹងមានករណីថាមនុស្សនិយាយការមិនពិត គឺចង់លាក់ការពិត ដូចថាយើងនិយាយអំពីជំនួយវិញ គឺថាតាមសម្តីរបស់លោក ខៀវ សំផន គឺមិនស្មោះត្រង់ទេ គឺយើងអាចយល់បាន។ គឺថាទាក់ទងនឹងចំណុចផ្សេងទៀត ដែលខ្ញុំយល់ថាគាត់មិនស្មោះត្រង់ទេ គាត់មិនចង់បង្ហាញពីបញ្ហាមួយចំនួនទេ។ អាហ្នឹងជារឿងធម្មតាទេ ពីព្រោះកាលណាយើងនិយាយ ពីព្រោះប្រវត្តិសាស្ត្រជាមួយនឹងតួអង្គដែលជាអ្នកដើរក្នុង ជាអ្នកអនុវត្តហេតុការណ៍ក្នុងប្រវត្តិសាស្ត្រហ្នឹង អ្នកហ្នឹងតែងតែអ៊ីចឹងឯង។

[១៣:៤៨:០៤]

**ស៖** នៅចំណុចនេះទៀត គឺប្រភពលោកបានមកពី ភី ភួន។ តើលោកទទួលបានព័ត៌មានពីអ្នកផ្សេងទៀតទេបញ្ហាពាក់ព័ន្ធទៅនឹងបញ្ហាដែលថាលោក នួន ជា និង ខៀវ សំផន មានវត្តមាននៅកន្លែងត្រួតពិនិត្យនៅភូមិភាគឧត្តរនោះ?

**ឆ៖** នៅក្នុងពិភពមួយដែលល្អឥតខ្ចោះនោះ គឺថាគេត្រូវពិនិត្យផ្ទៀងផ្ទាត់ទៅវិញទៅមក។ ប៉ុន្តែ ការពិតការពិនិត្យផ្ទៀងផ្ទាត់ទៅវិញទៅមក គឺថាវាមានប្រភពណាផ្សេងទៀតដែលខ្ញុំរកមកផ្ទៀងផ្ទាត់ទេ ប៉ុន្តែជាប្រភពផ្ទាល់មាត់ ដែលអាចនឹងស៊ីសង្វាក់ជាមួយដំណើររឿងដែល ភី ភួន បាននិយាយតាមការស្តាប់អ្នកដទៃ។ ហើយអ្វីដែលខ្ញុំបានឮពី ខៀវ សំផន ផ្ទាល់ហ្នឹងគឺថាគាត់បានប្តូរនូវដំណើររឿងដែលគាត់ប្រាប់ គឺថាក្រោយមកគាត់ថា១ខែក្រោយមកទេដែលគាត់មកទីក្រុងភ្នំពេញនោះ ក្រោយពីរំដោះ។

[១៣:៤៩:០៨]

**ស៖** ពាក់ព័ន្ធទៅនឹងបញ្ហាដែលថាមក១ខែក្រោយមក បើតាម ខៀវ សំផន នោះតើលោកទទួលបានព័ត៌មាននេះមកពីណាដែលថា គាត់មកមួយក្រោយ -- ១ខែក្រោយមកទេមកភ្នំពេញនោះ?

**ឆ៖** ក្នុងការសម្ភាសដែលគាត់ជួបជាមួយខ្ញុំ នោះហើយជាអ្វីដែលគាត់និយាយ។ ខ្ញុំដាក់ក្នុងលេខយោងសៀវភៅខ្ញុំនោះឯង ហើយគាត់បាននិយាយពីដំណើររឿងនោះផង ហើយយើងខ្ញុំត្រូវ -- ខ្ញុំត្រូវមើលអត្ថបទរបស់ខ្ញុំ។ ហើយយើងបានពិភាក្សាបញ្ហានេះជាមួយ អ៊ិន សុភាព គឺថាផ្អែកទៅលើការដែលខ្ញុំពិភាក្សាជាមួយលោក ខៀវ សំផន។

**ស៖** ខ្ញុំត្រឡប់មកចំណុចដើមវិញ នៅពេលដែលលោកនិយាយថា ពេលនេះ ពេលនោះ បន្ទាប់ពីកើតអង្គហេតុហើយនោះ គឺថាខ្ញុំចង់ឱ្យលោកមានភាពច្បាស់លាស់។ ដូច្នេះ វាមិនច្បាស់ទេ នៅពេលដែលនិយាយថាពេលនេះ ពេលនោះនោះ។ ខ្ញុំឱ្យឧទាហរណ៍មួយទៀត។ នៅក្នុងសៀវភៅរបស់លោក លោកបានកំណត់កាលបរិច្ឆេទនៃការចូលភ្នំពេញមករបស់ ប៉ុល ពត គឺថ្ងៃ២០ ខែមេសា។ សំណួរទី១ តើលោកបានប្រភពមកពីណាដើម្បីកំណត់កាលបរិច្ឆេទថា ប៉ុល ពត ចូលភ្នំពេញនៅថ្ងៃ២០ មេសា នោះ?

[១៣:៥០:៤២]

**ឆ៖** គឺថាលោក ភី ភួន ដដែលហ្នឹងហើយដែលនិយាយ។ គាត់នៅធ្វើដំណើរ ធ្វើការជាប់ជិតស្និទ្ធជាមួយគាត់។ មិនអាចចៀសរួចទេ គឺភី ភួន ហ្នឹងឯងអ្នកនិយាយ។

**ស៖** តើលោកមានប្រភពផ្សេងទៀតទេ ដើម្បីកំណត់កាលបរិច្ឆេទថាប៉ុល ពត ពិតជាចូលមកភ្នំពេញនៅថ្ងៃ២០ មេសានោះ?

**ឆ៖** ខ្ញុំដូចជាស្ទាក់ស្ទើរក្នុងការបញ្ជាក់ ពីព្រោះថា ខ្ញុំអាចនឹងមិនបង្ហាញពីភាពស្មោះត្រង់ទេ បើសិនជាខ្ញុំនិយាយថាខ្ញុំមិនមានប្រភពផ្សេងទៀត។ ហើយនិយាយទៀតនេះ និយាយពីការចងចាំរបស់អ្នកផ្តងកាត់ អ្នកដែលខ្ញុំបានជួប។ ហើយបើលោកស្រីមេធាវីចុចខ្ញុំ ឱ្យខ្ញុំឆ្លើយអីចឹង វាអាចនឹងធ្វើឱ្យគេយល់

ថាខ្ញុំវាមិនមានភាពស្មោះត្រង់។ ហើយខ្ញុំមិនបានដឹងថាមានអ្វីខ្លះកើតឡើងជុំវិញពេលនោះទេ។

[១៣:៥១:៣៨]

**សៈ** អ្វីដែលធ្វើខ្ញុំសង្កត់ធ្ងន់ទៅលើបញ្ហាកាលបរិច្ឆេទនេះ ពីព្រោះនៅក្នុងសៀវភៅរបស់លោក ដេវីដ ឆេនដ៍ល័រ គាត់ថាគាត់និយាយពីថ្ងៃ២៣ មេសា គឺសៀវភៅ "ប្រាឌ័រណាំប៊ឺរវ័ន" – បងធំលេខ១។ គឺលេខ ERN 00397018 ជាភាសាអង់គ្លេស គឺគាត់បបញ្ជាក់ថ្ងៃ២៣ មេសា។ ខ្ញុំយល់ថាមានតែ ភី ភួន ទេជាប្រភពព័ត៌មានរបស់លោក។ នៅជើងទំព័រ២៨៦ លោកបាននិយាយថានៅក្នុងកិច្ចសម្ភាសន៍នៅក្នុងឆ្នាំ៧៨ ជាមួយនឹងអ្នកសារព័ត៌មានយូហ្គោស្លាវីនោះ គាត់បានបញ្ជាក់ថា គាត់ចូលភ្នំពេញថ្ងៃ២៤ មេសា។ ហើយការអត្ថាធិប្បាយរបស់លោកក្នុងជើងទំព័រ គឺថាលោកថាមិនពិតទេ។ មិនមែនថាដោយសារគាត់ភូតកុហក់ទេ គឺដោយសារតែគាត់ចង់ឲ្យបានច្បាស់ពេក។ ដូច្នេះក្នុងឋានៈជាអ្នកស្រាវជ្រាវនោះ លោកបានឃើញ ភី ភួន ប៉ុន្មានឆ្នាំក្រោយពីអង្គហេតុ? គឺប៉ុល ពត ខ្លួនឯងហ្នឹងនៅឆ្នាំ៧៨ គាត់និយាយថាគាត់ចូលមកភ្នំពេញហ្នឹងគឺនៅថ្ងៃ២៤ មេសាហើយមានអ្នកនិពន្ធផ្សេងនោះបញ្ជាក់ថា ២៣ មេសា។ ដូច្នេះហេតុអីបានជាលោកច្បាស់ម្ល៉េះ លោកហ៊ានថា ប៉ុល ពត និយាយហ្នឹងមិនត្រូវទេ មិនមែន២៤ ទេ គឺលោកគិតថា ២៣ បើតាមភី ភួន ទៅវិញនោះ។ ដូច្នេះហេតុអ្វីបានជាលោកហ៊ាននិយាយថា ថ្ងៃ២៣ មេសា តាមព័ត៌មានរបស់ភី ភួន នោះ?

[១៣:៥៣:៣៣]

**ឆៈ** ខ្ញុំមិនអាចឆ្លើយជំនួសលោក ដេវីដ ឆេនដ៍ល័របានទេ។ ខ្ញុំប្រាកដថា ផ្អែកជាមួយការសន្ទនាជាមួយគាត់ដែលគាត់សរសេរសៀវភៅ "បងទី១" ហ្នឹងគាត់មិនបាននិយាយជាមួយអ្នកណាម្នាក់ដែលបានធ្វើការ ឬក៏មានការងារអ្វីជាប់ជាមួយ ប៉ុល ពត នៅពេលនោះទេ។ ហើយអ្វីនេះគឺថាមិនមែនចេញពីប្រភពដែលចេញពីក្រុមខ្មែរក្រហមដែលនៅក្រៅភ្នំពេញទេ។ ថ្ងៃទី២៤នេះ។ ខ្ញុំអាចយល់បានដែលថា ២៤ មេសានេះ។ គាត់និយាយចាត់ទុកជារឿងសាមញ្ញអំពីការពិត។ ប្រហែលជាគាត់ចង់ដកខ្លួនឲ្យឆ្ងាយចេញអំពីការនិយាយទាយស្មាន អំពី -- ជាពិសេសរឿងហេតុការណ៍ជម្លៀសភ្លាមៗនោះឯង។

ស្ថានភាពប្រវត្តិសាស្ត្របែបនេះកាលណាមិនមានឯកសារជាភស្តុតាងទេ។ លោកស្រីនិយាយហើយថា ការចងចាំហ្នឹងគឺវាមិនជាក់លាក់ទេ។ អ៊ីចឹងយើងត្រូវធ្វើការវិនិច្ឆ័យពិចារណាថា តើថ្ងៃទី២០ ថ្ងៃ២៣ ឬក៏ថ្ងៃទី២៤។ ដូច្នេះអាហ្នឹងការចងចាំវាមានគន្លាតអ៊ីចឹង។ ដូច្នេះយើង ប្រភពមួយយើងបាន ប្រភពមួយដែលនៅជាមួយ ប៉ុល ពត ហ្នឹងដែលថាជូនអ្នកនោះមកភ្នំពេញ ហើយជូនដំណើរការគាត់

ប៉ុល ពត ហ្នឹងទៅវិញ ចេញពីភ្នំពេញ។ ហើយនៅថ្ងៃបន្ទាប់ ហើយមកម្តងទៀត ហើយប្តូរផ្លូវតាមផ្លូវម្ខាងទៀតជាមួយ ប៉ុល ពត។ នេះគឺជាសក្ខីកម្មជាភស្តុតាងកាលៈទេសៈមួយដែលថា ដំណើររឿងហ្នឹងគួរឲ្យជឿបាន គឺថាមិនៗបានឲ្យយើងឆ្ងល់ទេ។ អ៊ីចឹងហើយបើមិនមានអ្នកណាឆ្ងល់ពីរឿងហ្នឹង ខ្ញុំក៏ត្រូវតែជឿរឿងហ្នឹងអ៊ីចឹងដែរ។

[១៣:៥៥:២៨]

**ស៖** អម្បាញ់មិញនេះ យើងលើកឡើងអំពីបញ្ហាកាលបរិច្ឆេទ និងដំណើរការនៃអង្គហេតុ។ អ្វីដែលលោក ឆេនដ័ល័រ បាននិយាយនោះ គឺថាវាមិនមានភាពខុសគ្នាខ្លាំងពី ភី ភួន ទេ គឺថាដំបូងឡើងពួកយោធាបានមកដល់ចូលមកដល់ភ្នំពេញ ហើយបន្ទាប់ពីនុំងមក ប៉ុល ពត ហើយនិងគ្នាគាត់នោះបានមកតាមក្រោយ។ ដូច្នេះមកនេះ គឺថាដើម្បីវាមានសន្តិសុខស្រួលបានពួកគាត់ចូលមក។ ពាក់ព័ន្ធទៅនឹងដំណើរការនៃអង្គហេតុនោះ យើងឯកភាពគ្នា ក៏ប៉ុន្តែនៅក្នុងចម្លើយរបស់លោកនោះ ខ្ញុំមិនយល់ថាហេតុអីបានជានៅក្នុងកំណត់សម្គាល់ជើងទំព័ររបស់លោកនោះ លោកថាលោក ប៉ុល ពត -- អ្វីដែល ប៉ុល ពត ប្រាប់នោះគឺមិនត្រូវទេនោះ។ ហេតុអីបានជាលោកនៅពេលដែលលោកប្រៀបធៀបព័ត៌មាននោះលោកយកខាង ភី ភួន ទៅវិញនោះ?

**ឆ៖** លោកស្រីប្រហែលជាត្រូវហើយ ខ្ញុំគួរតែមិនប្រកាន់យកសម្តីរបស់ ភី ភួន ឲ្យប្រាកដ។ ប៉ុន្តែ ប៉ុល ពត និយាយពីឆ្នាំ១៩៧៥ ដល់៧៩ ដល់ក្រោយមក គឺថាយើងមានគេចាត់ទុកថាពេលខ្លះពួកគាត់និយាយការណ៍ដែលមិនពិត និយាយកុហកបាទ។ កាលណានៅក្នុងការប្រកាស ហើយបទសម្ភាសន៍ជាផ្លូវការជាប្រព័ន្ធអ៊ីចឹងគឺថា ហើយគាត់មិនសូវបាននិយាយទូលាយទេ។ អ៊ីចឹងហើយគឺអាចនឹង ភី ភួន ទេ គាត់ដែលមនុស្សមួយដាច់ស្រយាលពីអំណាច គាត់អាចនឹងនិយាយការពិតច្រើនជាង។ ហើយបើយើងនិយាយមើលដំណើររឿងទាំងមូលនៅក្នុងកាលៈទេសៈនីមួយៗនោះ កត្តានេះឯងដែលធ្វើឲ្យខ្ញុំជឿបែបនេះ។

[១៣:៥៧:២៨]

**ស៖** ខ្ញុំរំឭកអំពីអ្វីដែលខ្ញុំនិយាយអម្បាញ់មិញនេះ គឺថាក្រៅពី -- ខ្ញុំមិនគិតពីបញ្ហាភរភូតភរ ឬមិនភូតភរទេ ក៏ប៉ុន្តែខ្ញុំគិតថាប្រហែលជា ប៉ុល ពត ច្រឡំ។ ដូច្នេះ ភី ភួន ក៏អាចច្រឡំដែរពាក់ព័ន្ធនឹងកិច្ចប្រជុំរបស់គណៈមជ្ឈិមនៅខែកញ្ញា ឆ្នាំ៧៤។ ក៏ប៉ុន្តែតាមពិតទៅ គឺនៅខែមិថុនា ៧៤ ទេ។ នេះមិនមែនជាការភូតភរ ឬក៏កុហកនោះទេ ក៏ប៉ុន្តែខ្ញុំគិតថាប្រហែលជាអាចមានការចងចាំច្រឡំ។ ដូច្នេះក្នុងការងារលោកជាអ្នកស្រាវជ្រាវនោះ ខ្ញុំសួរលោកអំពីបញ្ហាដែលថាមានការអះអាងជាច្រើន ដែល

ឧទាហរណ៍ដូចជាថា ខៀវ សំផន, នួន ជា នៅខាង -- នៅកន្លែងកុងត្រូល នៅតំបន់ឧត្តរនោះ នៅពេលដែលលោកផ្ទៀង -- មុនពេលដែលលោកផ្ទៀងផ្ទាត់ទៅ លោកអត់មានប្រើថា "ប្រហែលជា" -- ប្រើពាក្យ "ប្រហែល"ទេ គឺលោកសរសេរច្បាស់តែម្តង។ ដូច្នេះយើងទីនេះនៅតុលាការ ដូច្នេះខ្ញុំចង់ឲ្យដឹងព័ត៌មានច្បាស់ ថាតើលោកបានប្រភពមកពីណា? ហើយប្រភពហ្នឹងវាស៊ីសង្វាក់គ្នាឬអត់? ហើយលោកលោកនិយាយថាមិនមានការលំបាកទេ គឺថាលោកមានមូលហេតុក្នុងការជឿជាក់បែបហ្នឹង។ ក៏ប៉ុន្តែនៅពេលដែលខ្ញុំឲ្យឧទាហរណ៍អំពីកាលបរិច្ឆេទនៃការចូលភ្នំពេញរបស់ ប៉ុល ពត នោះ គឺថាមិនមានមូល-ហេតុថាកុហកទេ លោកគឺឮថាលោកនិយាយដាច់ណាត់តែម្តង។

[១៣:៥៨:៤៦]

ដូច្នេះហើយអ្វីដែលខ្ញុំចង់បង្ហាញលោកនៅថ្ងៃនេះនោះ គឺថាទោះបីជា ភី ភួន មិនមានចេតនាក្នុងការកុហកក៏ដោយ ក៏ប៉ុន្តែវាអាចដែលថាគាត់ភ័ន្តច្រឡំ។ ហើយដោយសារតែលោកអត់បានពិនិត្យផ្ទៀងផ្ទាត់ដោយសារតែមានចម្លើយតែពីមនុស្សម្នាក់នោះ វាមានការភ័ន្តច្រឡំ។ តើលោកឯកភាពជាមួយខ្ញុំទេត្រង់ចំណុចនេះនោះ?

**ឆ៖** យើងយល់ស្របទាំងស្រុង។ ខ្ញុំនិយាយហើយថា កាលប្បវត្តិ កាលបរិច្ឆេទនោះគឺថាវាអាស្រ័យទៅលើការចងចាំរបស់សាក្សីរបស់ ដូចលោក ភី ភួន អ៊ីចឹង គឺថាហើយបញ្ហាចម្បងរបស់អ្នកប្រវត្តិសាស្ត្រនេះអ៊ីចឹងឯង។ ហើយលោកនិយាយថា អ្នកឯងអះអាងរឿងនេះជាអង្គហេតុ មិនផ្ទៀងផ្ទាត់ជាមួយអ្នកដទៃ។ ឥឡូវសូមពិនិត្យមើល លោកស្រីមើលទៅ គឺថាស្ថានភាពហ្នឹងមិនអាចឲ្យខ្ញុំពិនិត្យផ្ទៀងផ្ទាត់ផ្សេងទៀតទេ មិនមានប្រភពផ្សេងទៀតទេ។ ហើយកាលណាមានប្រភពតែមួយ អ្នកត្រូវជឿប្រភពនេះ ឬក៏លោកអ្នកជឿនិយាយថាអាចនៅថ្ងៃនេះ ថ្ងៃនោះ ឬក៏ថ្ងៃមួយផ្សេងទៀត អាហ្នឹង។ ប៉ុន្តែក្នុងការសម្រេចរបស់ខ្ញុំ គឺថាដោយសារប្រភពហ្នឹងគឺថាជឿជាក់ គាត់ថា គាត់ជឿថាអាចថ្ងៃនេះ។ អ៊ីចឹងខ្ញុំជឿថាមិនជាចាំបាច់ក្នុងសៀវភៅខ្ញុំសរសេរ ខ្ញុំថាខ្ញុំគួរសរសេរថាគាត់អាច គាត់អាចមកថ្ងៃទី២០, ២៣, ២៤ ទេ។ អ៊ីចឹងខ្ញុំត្រូវផ្អែកលើប្រភពនេះហើយដើម្បីសរសេរ។ គឺថាអាចនឹងមកនៅថ្ងៃទី២០។ ដូចដែលខ្ញុំជម្រាបតុលាការរហូតមកដល់ថ្ងៃនេះ គឺថាកាលបរិច្ឆេទគឺជាទំនាក់ទំនងដ៏ខ្សោយណាស់និយាយពីការចងចាំអង្គហេតុដែលកើតឡើងយូរដូចដែលយើង ពិភាក្សានេះ។

[១៤:០០:៤៥]

**ស៖** ខ្ញុំសូមលើកចំណុចមកបំភ្លឺមួយ គឺថាយើងបានស្តាប់ ភី ភួន ហើយនៅក្នុងបន្ទប់សវនាការ

នេះ។ តើលោកអាចបញ្ជាក់បានទេ ថាគឺពិតជាអង្គរក្សហើយនិងនីរសាររបស់ ប៉ុល ពត។ តើលោកអាចបញ្ជាក់បានទេ?

**ផះ** គាត់ចាប់ផ្តើមបំពេញការងារជានីរសារក្រោយមកជាអង្គរក្សរបស់ ប៉ុល ពត។ ក្រោយឆ្នាំ ៧៥ គាត់បានក្លាយជាប្រធានសន្តិសុខនៅក្រសួងការបរទេស។

**សះ** ឥឡូវនេះយើងកំពុងនិយាយឆ្នាំ៧៥-៧៩ ព្រោះថានេះជាអ្វីដែលយើងនិយាយនៅតុលាការនេះ។ នៅឆ្នាំ១៩៧៥ នៅពេលគាត់មកដល់ទីក្រុងភ្នំពេញ តើ ភី ភួន នេះមានឋានៈអី បុណ្យស័ក្តិអីដើម្បីឲ្យបានដឹងពីកាលប្បវត្តិច្បាស់លាស់ បើតាមលោកចាំនោះ គាត់មានឋានៈអី ហើយតំណែងអីដែរ?

[១៤:០២:០១]

**ផះ** នៅពេលនោះគឺគាត់ជាអង្គរក្ស ឬក៏ជាជំនួយការរបស់ ប៉ុល ពត។

**សះ** តើក្នុងលក្ខណៈណាមួយនោះគាត់ជាសមាជិកគណៈកម្មធិការមជ្ឈិម ឬក៏ស្ថិតនៅក្នុងការិយាល័យថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាអីដែរទេ?

**ផះ** អត់ទេ គាត់មិនមែនទេ។

**សះ** សូមអរគុណដែលបានបំភ្លឺ។ ចាស ឥឡូវនេះខ្ញុំសូមលើកចំណុចទីពីរ ដែលលោកបាននិយាយរួចហើយជាមួយសហព្រះរាជអាជ្ញា។ ជាពិសេសគឺ ផ្នែកមួយនៃសៀវភៅយើងសម្រាប់លោក ទំព័រជាភាសាអង់គ្លេសគឺ ទំព័រ៣១៣, ERNជាភាសាបារាំងគឺ 00939867, 00396521 ជាភាសាអង់គ្លេស។ ចាស គឺថាសម្រង់មួយដែលខ្ញុំបានអានជូនលោកហើយៗ គឺដោយសហព្រះរាជអាជ្ញា។ លោកបានលើកឡើងថា៖ “ខៀវ សំផន ទទួលបន្ទុកក្នុងបេសកកម្មមួយដែល ប៉ុល ពត ថា ទាំងនេះជាចំណុចរសើបត្រូវតែឲ្យ ខៀវ សំផន អ្នកធ្វើវិញ”។

[១៤:០៣:៤៣]

ឥឡូវនេះ ខ្ញុំសូមពិគ្រោះកំណត់ហេតុជើងទំព័ររបស់លោកដើម្បីកុំឲ្យនិយាយផ្តេសផ្តាស។ ហើយនៅក្នុងហ្នឹងមាន ភី ភួន ផងដែរហើយមានកំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ គឺថាកំណត់ហេតុដែលយើងបានលើកឡើងប៉ុន្មានថ្ងៃមុនមកនេះហើយៗ។ គឺឯកសារ E3/182 -- លោកប្រធានខ្ញុំសូមអនុញ្ញាតបញ្ចាំងទំព័រទី១នៃឯកសារនេះលោកប្រធាន! ជាភាសាខ្មែរដើម្បីសាធារណជន។

អ្នកជំនាញ ខ្ញុំមិនដឹងថាលោកមានឯកសារនេះហើយឬនៅទេ ឬក៏លោកចង់ឲ្យយើងជូនឯកសារនេះមួយច្បាប់ទៅដល់លោក? បាស E3/182។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១៤:០៥:០៧]

**កញ្ញា អង់តា ហ្គីសសេ៖**

*(គ្មានការបកប្រែ)* ERN គឺថា 00292--

**អ្នកបកប្រែ៖**

លោកប្រធានសូមទោស សូមឲ្យលោកមេធាវីជូនលេខ ERN មួយសាទៀតលោកប្រធាន។

**កញ្ញា អង់តា ហ្គីសសេ៖**

ជាភាសាបារាំងគឺ 00292868។ គឺឯកសារ E3/182, ERN ជាភាសាខ្មែរគឺ 00019108, ERN ជាភាសាអង់គ្លេសខ្ញុំអត់មានទេ ប៉ុន្តែខ្ញុំដឹងថាជាទំព័រទី១ នៃឯកសារហ្នឹង។ លោក ហ្វីលីព ស្មូត ខ្ញុំជូនឯកសារនេះនៅទំព័រទៅលោកជាភាសាអង់គ្លេស។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវីការពារក្តីយកជូនអ្នកជំនាញពិនិត្យ!

**កញ្ញា អង់តា ហ្គីសសេ៖**

*(គ្មានការបកប្រែ)*

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ឯកសារនេះគឺលោកធ្លាប់បានពិនិត្យពិគ្រោះជាមួយសហព្រះរាជអាជ្ញា ហើយនិងលោកស្រី ចៅក្រម ខាតវ៉ាយថ៍ ផងដែរ។ គឺតាមរយៈឯកសារនេះៗគឺថា គេបែងចែកការងារនិងដំណើរ -- និងកិច្ចដំណើរការជាដើម។ នៅទំព័រទី១ នោះ នៅលេខរៀងទី៤ គឺថាមានសមមិត្តហែម ទទួលបន្ទុករណសិរ្សនិងរាជរដ្ឋាភិបាល ហើយនិងពាណិជ្ជកម្ម ខាងបញ្ជីនិងតម្លៃ។ តើលោកអាចជម្រាបជូនបាន ពន្យល់បានទេ អំពីពាក្យដែលលោកនិយាយថា "ជាបេសកកម្មរសើប ឬក៏សំខាន់ខ្លាំង" ដែលត្រូវប្រគល់ជូនទៅលោក ខៀវ សំផន ហ្នឹងនៅក្នុងកំណត់ហេតុ -- កំណត់សម្គាល់ជើងទំព័ររបស់លោកនេះ។ លោកពន្យល់បានទេ ពាក្យ "បេសកកម្មសំខាន់ ឬក៏ថាររសើប" អីនេះ?

[១៤:០៧:២៣]

E1/192.1

**លោក ហ្វីលីព ស្មុត៖**

**ឆ៖** គឺថាយើងបានពិភាក្សារួចទៅហើយ គឺថា ខៀវ សំផន គាត់មានតួនាទីពីរ។ គឺទី១ដូចដែលមានពណ៌នានៅក្នុងឯកសារនេះ គឺទទួលខុសត្រូវខាងរដ្ឋបាលពាណិជ្ជកម្ម ខាងរណសិរ្ស ហើយខ្លួនគាត់ផ្ទាល់ក៏បានបញ្ជាក់ផងដែរថា គាត់គឺជាសមាជិករបស់សេនាធិការ។ ហើយគាត់បន្តធ្វើការងារនៅខាងសេនាធិការ គឺក្នុងនោះមានសមមិត្ត យ៉ែម ដែលគេហៅថាជាមន្ទីរ៨៧០ ហើយនៅក្នុងសមត្ថភាព នៅក្នុងតួនាទីនោះ គឺថាគាត់ត្រូវបានគេបញ្ជូនទៅតាមខេត្ត។ គឺ ប៉ុល ពត ជាអ្នកបញ្ជូនគាត់ទៅតាមខេត្ត ឬក៏យើងអាចថាបញ្ជូនទៅតាមភូមិភាគ។ ជាពិសេសនៅពេលទាក់ទងទៅនឹងបញ្ហាដែលមានលក្ខណៈផុយស្រួយ ឬក៏មានលក្ខណៈសំខាន់ណាមួយអ៊ីចឹង។ គឺថា ប៉ុន្តែ ខៀវ សំផន មិនមានតួនាទីអ្វី ប៉ុន្តែគាត់មិនមានសិទ្ធិសម្រេចទេ គាត់គ្រាន់តែមានតួនាទីរាយការណ៍ត្រឡប់មក ប៉ុល ពត វិញ ដើម្បីឲ្យទទួលបានយោបល់ផ្សេងៗ។

[១៤:០៨:៤៥]

**ស៖** អ៊ីចឹងសំណួរជាក់លាក់របស់ខ្ញុំនោះ ដែលខ្ញុំចង់ដឹងច្បាស់នោះ ថាតើពាក្យថា "បញ្ហាស្មុគស្មាញខ្លាំង" ហើយនិង "បេសកកម្មសំខាន់ខ្លាំង" នោះ អ៊ីចឹងថាតើរឿងថាបញ្ជូនលោក ខៀវ សំផន ទៅខេត្ត ទៅអីនោះ អ្នកណាគេអ្នកប្រាប់លោក លោកបានប្រភពដំណឹងនេះមកពីណាដែរ?

**ឆ៖** ខ្ញុំបានបញ្ជាក់រួចហើយថា ប្រភពគឺលោក ស្ទួង ស៊ីគឿន ខ្ញុំបានសម្ភាសជាមួយគាត់ ហើយយើងបានពិភាក្សាអំពីប្រធានបទនេះ។ ហើយខ្ញុំក៏បាននិយាយជាមួយ ភី ភួន ផងដែរ ប៉ុន្តែខ្ញុំសូមទោសប្រហែលជាខ្ញុំចាំមិនច្បាស់ ខ្ញុំប្រហែលជាបានពិភាក្សាអំពីបញ្ហាបេសកកម្មនេះដែរជាមួយគាត់។ ហើយតួនាទីរបស់ -- តួនាទីរបស់ ខៀវ សំផន ក៏ត្រូវបានបញ្ជាក់នៅក្នុងកិច្ចប្រជុំមជ្ឈិមនេះផងដែរ ប៉ុន្តែខ្ញុំមិនដឹងច្បាស់បន្ថែមពីលើនេះទេទាក់ទងទៅនឹងការកំណត់ប្រភេទ។ ប្រសិនបើខ្ញុំត្រូវបញ្ជាក់ថា តើអ្នកណាដែលជាជនសង្ស័យ ឬក៏អ្នកណាត្រូវសង្ស័យ ហើយគេឲ្យ ខៀវ សំផន ចុះទៅធ្វើការវាយតម្លៃ ហើយរាយការណ៍អំពីស្ថានភាពត្រឡប់មកវិញនោះ។ គឺវាអាចបែបនេះមែន ប៉ុន្តែខ្ញុំមិនមានមូលដ្ឋានជាក់លាក់ណាមួយដើម្បីនិយាយ ដើម្បីបញ្ជាក់អំពីបញ្ហាទាំងអស់នេះទេ។ ដូច្នេះ ខ្ញុំសូមនៅប្រើប្រាស់ពាក្យថា "បញ្ហាសំខាន់ៗ ឬក៏ចម្បង"។

[១៤:១០:២០]

**ស៖** អ៊ីចឹងបើខ្ញុំមិនច្រឡំទេ គឺថាប្រភពសំខាន់បំផុតរបស់លោកនោះ ដែលថា ខៀវ សំផន

ទទួលបន្ទុកបេសកម្មសំខាន់ៗហ្នឹង គឺថាមានតែលោក សួង ស៊ីគឿន ហ្នឹងទេនៅក្នុង -- ដែលលោកទទួលបានពីការសម្ភាសជាមួយ សួង ស៊ីគឿន ហ្នឹង។ អ៊ីចឹងខ្ញុំអាចនិយាយអ៊ីចឹងបានទេ? ប្រភពសំខាន់ហ្នឹងថា មានតែលោក សួង ស៊ីគឿន ហ្នឹងទេ?

**ផ៖** ទោះបីសួរថាតើគាត់ជាប្រភពសំខាន់ ឬក៏ប្រភពតែមួយនោះទេ ខ្ញុំមិនអាចនិយាយបានទេ ប៉ុន្តែខ្ញុំបានធ្វើការសម្ភាស ហើយ សួង ស៊ីគឿន ក៏ជាអ្នកដែលខ្ញុំត្រូវបានសម្ភាស។ ប៉ុន្តែចំពោះព័ត៌មានដទៃទៀត គឺអាចមាននៅក្នុងបណ្ណសាររបស់វៀតណាម ហើយបាននិយាយថា ខៀវ សំផន គាត់នៅមន្ទីរ៨៧០ ដែរ។ ឯកសារដែលលោកស្រីបានបញ្ជាក់អ៊ីចឹង ខៀវ សំផន គាត់នៅតែទទូចម្ដងហើយម្ដងទៀតថា គាត់នៅតែទទូចថា គាត់មិនមានតួនាទីណាមួយនៅក្នុងមន្ទីរ៨៧០ នោះទេ។ នៅពេលអ្នកណាម្នាក់ចង់ចូលរួមនៅក្នុងសកម្មភាពណាមួយនោះ គឺថាវាមានហេតុផលដែលគាត់ធ្វើដូច្នេះ។ ប៉ុន្តែវាមានមូលដ្ឋាននៅក្នុងការវាយតម្លៃទៅលើសក្ខីកម្មរបស់អ្នកដទៃ។

[១៤:១២:០០]

**ស៖** ដើម្បីឲ្យច្បាស់ជាងនេះទៅទៀត អំពីតំណែងរបស់លោក ខៀវ សំផន ហើយយ៉ាងហោចណាស់ក៏ច្បាស់ពីអ្វីដែលយើងច្បាស់នៅក្នុងការជម្រះសេចក្ដីយើងនេះ។ ខ្ញុំសូមដកស្រង់នូវសម្រង់មួយនៃចម្លើយរបស់គាត់នៅចំពោះមុខចៅក្រមស៊ើបអង្កេត ដែលគាត់និយាយអំពីការងាររបស់គាត់នៅក្នុងមន្ទីរ៨៧០ គឺឯកសារ E3/37។ ជាភាសាបារាំងគឺថាលេខ ERN គឺ 00156681។ កាលពីម្សិលមិញនោះសហព្រះរាជអាជ្ញាក៏បានដកស្រង់ឯកសារនេះដោយផ្នែកដែរ ជាផ្នែកដែរទាក់ទងនឹងអ្វីដែលលោក ខៀវ សំផន បាននិយាយ។ ប៉ុន្តែឥឡូវនេះ ខ្ញុំផ្ដល់សំណៅទាំងស្រុងតែម្ដង។ គាត់និយាយពីមន្ទីរ៨៧០។ "គឺជាការិយាល័យមួយនៃគណៈអចិន្ត្រៃយ៍ ហើយនៅក្នុងនោះមានសមាជិកពីរនាក់ទេ គឺ ឌឿន ហើយនិងខ្ញុំ ។ ឌឿន គឺជាប្រធាន គាត់មានកូនចៅគាត់ ប៉ង់ ដែលទទួលបន្ទុកខាងកិច្ចការនយោបាយ ហើយចំណែកខ្ញុំវិញដូចដែលខ្ញុំបានលើកឡើងរួចមកហើយ គឺថាខ្ញុំទទួលបន្ទុករៀបចំបញ្ជីតម្លៃសម្រាប់សហ-ករណ៍ ការបែងចែកសម្ភារៈសម្រាប់ភូមិភាគតាមការណែនាំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ហើយនិងទំនាក់ទំនងជាមួយសម្ដេចសីហនុ"។

[១៤:១៣:៤៧]

ដូច្នេះ គឺថាច្បាស់ណាស់ ហើយហោចណាស់ក៏នៅចំពោះមុខចៅក្រមស៊ើបអង្កេតគាត់និយាយអំពីសកម្មភាពគាត់ នៅក្នុងការ -- មន្ទីរ៨៧០ គាត់និយាយអំពីទំនាក់ទំនងរបស់គាត់ជាមួយនឹងសម្ដេច

សីហនុ។ ERN ជាភាសាអង់គ្លេស គឺ 00156754។ ដូច្នេះ គឺថាគាត់និយាយអំពីសកម្មភាពរបស់គាត់នៅក្នុងមន្ទីរ៨៧០ ហើយគាត់បានបញ្ជាក់ឡើងវិញផងដែរ ហើយគួរតែសរសេរនៅក្នុងកំណត់ហេតុនៃគណៈអចិន្ត្រៃយ៍ដែលខ្ញុំបានអាចជូនលោកអម្បាញ់មិញនេះហើយ។ អ៊ីចឹងទាក់ទងទៅនឹងមន្ទីរ៨៧០ នេះកាលពីម្សិលមិញ នៅពេលដែលសហព្រះរាជអាជ្ញាសួរលោក សូមឲ្យលោកធ្វើការអត្ថាធិប្បាយលើការដែល ខឿន បានបាត់ខ្លួន ហើយព្រះរាជអាជ្ញាក៏សួរផងដែរថា "តើលោកដឹងថាមានការដូរ ខឿន នេះទេ? ជំនួស ខឿន ទេ"។ កាលណោះ ពេលនោះលោក ឆ្លើយថា លោកនិយាយថា កាលណោះមិនមានឯកសារណាដែលនិយាយពីការជំនួស ខឿន នេះទេ។ អ៊ីចឹងយើងយល់ស្របត្រង់ចំណុចនេះ។ ក៏ប៉ុន្តែលោកក៏បានលើកឡើងផងដែរថាប្រហែលជាអាច ខ្ញុំសូមដកស្រង់ពីសម្ដីលោកទាំងស្រុងតែម្ដងដើម្បីកុំឲ្យដកស្រង់ពាក្យសម្ដីលោកខុស។ សូមអភ័យទោស ខ្ញុំមើលបន្តិចសិន។

[១៤:១៥:៣៨]

កាលពីម្សិលមិញ គឺនៅម៉ោង១០:០២ សម្រាប់អង្គជំនុំជម្រះ គឺថាក្នុងប្រតិចារឹកជាភាសាបារាំងនេះ។ "-- ជាប្រធានផ្ទាល់ ឬក៏ថាមានតែឈ្មោះ បន្ទាប់ពីការដក ខឿន ចេញទៅ មិនដែលមាននិយាយពីអ្នកទទួលបន្ទុកជំនួស ខឿន ទេ។ ខ្ញុំគិតថាប្រហែលជា ខៀវ សំផន សំខាន់ ហើយនេះវាស៊ីគ្នាទៅនឹងបេសកកម្មរបស់គាត់ទៅតាមខេត្តនានា។ អ៊ីចឹង គាត់ទៅនេះក្រោយពី ខឿន ត្រូវបានដកខ្លួន"។ អ៊ីចឹងឥឡូវ ខ្ញុំសូមត្រឡប់មកនិយាយពីបេសសកម្មសំខាន់ៗរបស់ ខៀវ សំផន នេះ។ តើលោកមានប្រភពមកពីណា ដែលទាក់ទងនឹងបេសសកម្មសំខាន់ៗរបស់ ខៀវ សំផន ទៅតាមខេត្តនេះ? តើមានតែ សួង ស៊ីគឿន ដដែលហ្នឹងទេ ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១៤:១៧:៥៤]

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំងើបឈរឡើងដើម្បីជំទាស់។ ខ្ញុំចង់ឲ្យមានការបញ្ជាក់ឲ្យបានច្បាស់នៅពេលដែលគាត់អាននូវផ្នែកណាមួយដែលដកស្រង់ចេញពីការសម្ភាសរបស់ ខៀវ សំផន ជាមួយនឹងសហចៅក្រមស៊ើបអង្កេត គឺថាត្រូវតែបញ្ជាក់ឲ្យច្បាស់នៅក្នុងកំណត់ត្រា។ គឺថាវាមានបញ្ហាពីរដែល

ត្រូវបញ្ជាក់ គឺថាវាជាមន្ទីររបស់គណៈអចិន្ត្រៃយ៍ ហើយមានសមាជិកតែពីរ គឺ ឌឿន ហើយនិងខ្ញុំ។ គឺថាដោយសារតែមិនមានពាក្យច្បាស់ គឺពាក្យ “ខ្ញុំ”។ ហេតុដូច្នេះ ខ្ញុំចង់ឲ្យមានការបញ្ជាក់នៅក្នុងកំណត់ត្រាប្រតិចារឹក។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជាភាសាបារាំងអំមិញខ្ញុំអានទាំងស្រុងហើយ គឺថានៅពាក្យសម្ដីដែលលោកបានអានទាំងស្រុង ហើយបើថាបើផ្នែកមួយចំនួននោះ ដូចជាពាក្យថាគាត់ធ្វើការជាមួយនឹងសហការី ដូចជា ប៉ង់ អីជាដើម។ ចាស ឥឡូវនេះ ខ្ញុំសូមត្រឡប់មកនិយាយអំពីប្រភពរបស់លោក ទាក់ទងបេសសកម្មតាមខេត្តរបស់លោក ខៀវ សំផន នេះ។ លោកបាននិយាយថា “នេះជាបេសសកម្មសំខាន់ណាស់ ឬក៏មានភាពស្រួចស្រាល់”។ ខ្ញុំមិនយល់ ថាតើលោកមានព័ត៌មានលម្អិតដែរឬទេ ទាក់ទងនឹងបេសសកម្មទាំងអស់នេះ? តែគ្រាន់តែយ៉ាងណាក៏ចង់ដឹងថា តើមានតែ សួង ស៊ីគឿន ឬ ជាប្រភពរបស់លោកនោះប្រភពព័ត៌មានរបស់លោកនោះ?

[១៤:១៨:៣២]

**លោក ហ្វីលីព ស្សូត៖**

**ឆ៖** ខ្ញុំបានបញ្ជាក់រួចទៅហើយថា សួង ស៊ីគឿន ជាប្រភពមួយ។ ហើយជាប្រភពជចម្បង។ ហើយខ្ញុំបញ្ជាក់ដដែលៗឡើងវិញ ថាគាត់គឺជាប្រភពដែលប្រាប់ព័ត៌មាននេះមកខ្ញុំ។ ខ្ញុំមិនចង់និយាយលម្អិតបន្ថែមអំពីបញ្ហាស្រួចស្រាល់ ឬក៏បេសសកម្មស្រួចស្រាល់នោះទេ។ ប៉ុន្តែខ្ញុំគិតថាវាជាការត្រឹមត្រូវដែលថាខ្ញុំមានហេតុផលដែលជឿជាក់ថា វាជាការត្រឹមត្រូវ។ ប៉ុន្តែចំពោះការនិយាយថាជាសន្និដ្ឋានឬក៏ស្មាននោះ វាជាការនិយាយខុសទេ។

**ស៖** ដូចដែលលោកបានលើកឡើងខ្លួនឯង ស្រាប់ហើយថា សួង ស៊ីគឿន បានមកផ្ដល់សក្ខីកម្មនៅទីនេះ ហើយគាត់មិនបាននិយាយអំពីបេសសកម្មសំខាន់ៗរបស់លោក ខៀវ សំផន តាមខេត្តនោះទេ ឬក៏និយាយពីការងារស្មុគស្មាញខ្លាំង ឬក៏សម្ងាត់ខ្លាំងនោះទេ។ អ៊ីចឹងហើយបានខ្ញុំចោទសំណួរនេះទៅកាន់លោកនោះ។ តើលោកមានមិនមានព័ត៌មានលម្អិតអីលើសហ្នឹងទេឬ ទាក់ទងនឹងប្រភពព័ត៌មានដែលលោកទទួលបាននេះ? អ៊ីចឹងលោកអាចបញ្ជាក់ថា លោក ស៊ីគឿន នេះ បានផ្ដល់ -- ព័ត៌មានដែលលោកទទួលបាននេះ គឺមានតែ ភី ភួន ហើយនិង សួង ស៊ីគឿន នោះទេ។ អ៊ីចឹងលោកអាចបញ្ជាក់បានទេ?

[១៤:២០:០២]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថាវីក៖**

ខ្ញុំសូមអភ័យទោសដែលខ្ញុំត្រូវតែងើបឡើងមកជាថ្មីម្តងទៀត ប៉ុន្តែចម្លើយដែលបានធ្វើឡើងនេះ គឺធ្វើឡើងដោយមានលក្ខណៈធ្វើឱ្យយល់ខុស។ ដោយសារតែ ស្វង ស៊ីគឿន មិនបាននិយាយអំពីបេសកកម្មស្រួចស្រាល់ ឬក៏បេសកកម្មសំខាន់នោះ មិនមែនបានន័យថាគាត់មិនដឹងនោះទេ។ ដូច្នេះខ្ញុំសូមអភ័យទោសទុកជាមុន ប៉ុន្តែខ្ញុំជឿជាក់ថា នៅពេលដែល ស្វង ស៊ីគឿន ផ្តល់ព័ត៌មានទៅដល់លោក ហ្វីលីព ស្សូត នោះប្រហែលជាគាត់មិនបាននិយាយអំពីបេសកកម្មនុំង។ ដូច្នេះ ខ្ញុំចង់ប្រាប់លោក ស្សូត នៅនេះថា ថាតើគាត់មិនបានផ្តល់សក្ខីកម្មឬយ៉ាងណានោះ មិនមែននោះទេ។

[១៤:២០:៥៨]

**កញ្ញា អង់តា ហ្គីសសេ៖**

លើកលែងតែថាព្រះរាជអាជ្ញាបង្ហាញថាខ្ញុំយល់ច្រឡំ។ តាម ស្វង ស៊ីគឿន បានឆ្លើយនៅទីនេះ អំពីបេសកកម្មសំខាន់នោះទេ បើសិនជាគាត់មាននិយាយអ៊ីចឹង មិននិយាយអ៊ីចឹងទេគឺថាខ្ញុំមិនច្រឡំទេ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំសូមបន្តទៅមុខក្នុងរយៈពេល -- ក្រោយពេលចូលភ្នំពេញ ហើយលោកបាននិយាយផ្តល់ប្រភពព័ត៌មានរបស់លោក យើងបាននិយាយអំពីបេសកកម្មសំខាន់ៗ ហើយនិងពីប្រភពព័ត៌មានដែលលោកទទួលបាន។ ឥឡូវនេះខ្ញុំសូមចូលមកនិយាយបានលម្អិតបន្តិច អំពីមន្ទីរ៨៧០ ដែលលោកបានលើកឡើងអម្បាញ់មិញនេះ ហើយនិងអវត្តមាន ឬក៏ការពុំមានឯកសារទាក់ទងទៅនឹងការបន្តតំណែងពី ខឿន នៅមន្ទីរ៨៧០នេះ។ ទាក់ទងចំណុចនេះ សំណួរទី១របស់ខ្ញុំ ពាក់ព័ន្ធទៅនឹងសៀវភៅរបស់នោះ។ អ៊ីចឹងខ្ញុំសួរថាតើលោកមានស្រាវជ្រាវលើមន្ទីរ៨៧០នេះ ឱ្យស៊ីជម្រៅដែរឬទេ?

[១៤:២២:២៧]

**លោក ហ្វីលីព ស្សូត៖**

**ឆ៖** ខ្ញុំមិនបានធ្វើឱ្យសិក្សាលម្អិតជាងប្រធានបទដទៃទៀតនោះទេ ព្រោះថាវាជាអង្គការមួយដែលមានលក្ខណៈសម្ងាត់បំផុត ឬក៏សម្ងាត់ខ្លាំងនោះ។ វាហាក់ដូចជាចំណុចកណ្តាលដែលធ្វើការបញ្ជូន

គណៈមជ្ឈិម។ ខ្ញុំធ្វើការសិក្សាតាមដែលខ្ញុំអាចធ្វើទៅបាន ហើយខ្ញុំធ្វើទៅតាមអ្វីដែលខ្ញុំអាច។ ឧទាហរណ៍ ដូចជាខ្ញុំបានឃើញឯកសារវៀតណាមនិយាយអំពី ភោគ ឆាយ, អំពី យឹម ហើយនិង ប៉ង់ ហើយខ្ញុំ ប្រសិនបើខ្ញុំយល់មិនខុសទេ ប៉ង់ ហ្នឹងឈ្មោះពេញគាត់គឺ ឈឹម សំអោក។ ហើយខ្ញុំព្យាយាមស្វែងរក តាមដែលខ្ញុំអាចធ្វើទៅបាន។ ប៉ុន្តែដោយសារតែវាជាអង្គការដ៏សម្ងាត់មួយ ដូច្នេះវាមិនបានទុកជាឯកសារ អ្វីជាភស្តុតាងច្បាស់លាស់នោះទេ។

**ស៖** នៅក្នុងការដេញដោលនៅក្នុងសវនាការយើងនេះ មានសាក្សីជាច្រើនបានមកទីនេះ ហើយ អ្នកខ្លះនោះនិយាយថា និយាយអំពីមន្ទីរ៨៧០នេះ។ យើងមានសាក្សីបីនាក់ គឺថាមាន ម៉ាដាម សែម ដែលបានផ្តល់សក្ខីកម្មនៅថ្ងៃទី២៥ កញ្ញា ឆ្នាំ២០១២, ប្រតិចារឹក E1/126.1 ជាប្រតិចារឹកតុលាការ យើងនេះ។

[១៤:២៤:០៣]

ហើយយើងក៏មានសាក្សីមួយទៀតដែលឈ្មោះ អឿន តាន សវនាការថ្ងៃទី១៣ ខែ៦ ឆ្នាំ២០១២ E1/886.1។ ហើយយើងក៏មានសាក្សីមួយទៀតដែរ ដែលបានមកទីនេះគឺឈ្មោះ ស វី ដែលមកផ្តល់ សក្ខីកម្មថ្ងៃទី០៨ ខែ០១ ឆ្នាំ២០១៣, ឯកសារ E1/156.1។ ហើយមានម្នាក់ទៀតឈ្មោះ នង សុផង់ ឯកសារ E1/201.1។ ហើយក្នុងការស្តាប់ចម្លើយរបស់ពួកគាត់ទាំងអស់នេះ មានគេចោទសំណួរមួយ ចំនួនទៅកាន់ពួកគាត់ ឧទាហរណ៍ដូចជា អ្នកណាជាទទួលបន្ទុក៨៧០? ហើយកាលណោះចម្លើយដែល ចេញពីពួកគាត់មកនោះ គឺថាមាន ប៉ង់, មានកែន ហៅ លីន, ហើយច្បាស់ជាងហ្នឹងទៅទៀត គឺម៉ាដាម នឹម សែម ដែលជាប្រពន្ធរបស់ លីន ហ្នឹងបានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយគាត់នៅថ្ងៃទី២៥ ខែ៩ ឆ្នាំ២០១២, ឯកសារ E1/126.1 ERN ជាភាសាបារាំងគឺ 0049695, ERN ជាភាសាអង់គ្លេសគឺ 00849586, ERN ជាភាសាខ្មែរគឺ 00850477។ គាត់បានស្គាល់ ប៉ង់ នៅមន្ទីរ៨៧០ គេសួរគាត់ថា "អ្នកណាជំនួស ប៉ង់ បន្ទាប់ពី ប៉ង់ បាត់ខ្លួននៅឆ្នាំ៧៩នោះ? ចម្លើយ៖ គាត់ហ្នឹងថាអ្នកបន្តពី ប៉ង់ គឺប្តីខ្ញុំ។ សំណួរ៖ អម្បាញ់មិញនេះលោកនិយាយថា មានមន្ទីរ(ក)មួយចំនួនដាក់នៅក្រោមឱវាទមន្ទីរ៨៧០ បន្ទាប់ ពីលីន ជំនួសប៉ង់ ទៅតើមន្ទីរកទាំងអស់នេះស្ថិតនៅក្រោមបញ្ជាគ្រប់គ្រងរបស់ប្តីលោក ឬក៏អ្នកផ្សេង ទៀត? ចម្លើយ៖ ប្តីខ្ញុំហ្នឹងគ្រប់គ្រងរួមនៅមន្ទីរ៨៧០។ ឯគ្រប់គ្រងតាមមន្ទីរផ្សេងៗមានផ្សេងៗគ្នា។ ខ្ញុំអត់ចាំទេ"។

[១៤:២៦:៤៩]

បន្ទាប់មកទៀត ចាស អ៊ីចឹងសូមចោទសំណួរទី១សិន។ តើលោកធ្លាប់បានឮថា លីន នេះបានជំនួស ប៉ង់ បន្តពី ប៉ង់ ហើយដែលប៉ង់នេះប្រហែលជាបានធ្វើការនៅមន្ទីរ៨៧០ហ្នឹង បន្ទាប់ពីគេដកខឿន ចេញទៅ។ លោកធ្លាប់បានឮយ៉ាងដូច្នេះទេ?

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។ ខ្ញុំគិតថា ខ្ញុំមានបញ្ហាមួយទៀតដែលគាត់បានធ្វើការជ្រើសព័ត៌មានមួយដុំៗ ប៉ុន្តែគាត់គួរតែដកស្រង់នូវសាក្សីទាំងអស់ដែលបានឆ្លើយទាក់ទងទៅនឹងមន្ទីរ៨៧០ ហើយមានសាក្សីពីរបាននិយាយថាគាត់ – ខៀវ សំផន ធ្វើការនៅមន្ទីរ៨៧០។ ដូច្នេះគ្រាន់តែចង់ឲ្យមានការបញ្ជាក់ច្បាស់នៅក្នុងកំណត់ត្រាប្រតិចារឹក និងដើម្បីកុំឲ្យអ្នកជំនាញគាត់មានការយល់ច្រឡំ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំគ្រាន់តែចង់ប្រាប់ថា មានសាក្សីដែលមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ គឺខ្ញុំនិយាយពីប្រពន្ធលីន ដែលគាត់ឆ្លើយថាប្តីគាត់ទទួលបន្ទុកមន្ទីរ៨៧០នេះ។ ហើយខ្ញុំបានរំឭកទៅព្រះរាជអាជ្ញាម្តងទៀតថា គាត់អាចប្រាប់ទៅសាក្សីនេះព័ត៌មានអីក៏បានដែរ។ ហើយខ្ញុំសុំ គ្រាន់តែសួរលោក ហ្វីលីព ស្សូត ថាតើគាត់ហ្នឹងធ្លាប់ឮនិយាយពី លីន ដែលប្រពន្ធលីននេះនិយាយថា លីន នេះជាអ្នកគ្រប់គ្រងរួមមន្ទីរ៨៧០។ ខ្ញុំគ្រាន់តែសួរប៉ុណ្ណឹងទេតើ! លោក ភី ភួន ក៏ប្រាប់អ៊ីចឹងដែរ។

[១៤:២៨:៥០]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** សូមអភ័យទោសលោក ហ្វីលីព ស្សូត អ៊ីចឹងខ្ញុំនៅប្រកាន់សំណួរខ្ញុំដដែល។ ខ្ញុំចោទសំណួរហ្នឹងដដែល។

**ឆ៖** ខ្ញុំធ្លាប់ឮពី កែន គឺមនុស្សម្នាក់ដែលឈ្មោះ កែន តែខ្ញុំមិនដឹងថាតើគេហៅគាត់ថាលីន ឬក៏អត់នោះទេ។ ប៉ុន្តែតាមដែលខ្ញុំដឹង គឺថាគាត់គឺជាប្រធានផ្នែកនីរសារ។ ខ្ញុំមិនចាំឈ្មោះមន្ទីរ លេខកូដនោះទេ ប៉ុន្តែដឹងថាវានៅក្នុង៨៧០។ ខ្ញុំមិនធ្លាប់ឮថាគាត់ជាប្រធានមន្ទីរ៨៧០ទេ។ ហើយខ្ញុំក៏មិនដែលឮថាលោក ខៀវ សំផន គឺជាប្រធានមានតែឈ្មោះរបស់៨៧០នោះដែរ។ ប៉ុន្តែខ្ញុំហេតុផលដែលជឿថាគាត់

មានតួនាទីសំខាន់មួយ។ នេះគឺផ្អែកទៅលើឯកសារ ក៏ដូចជាព័ត៌មានដែលខ្ញុំទទួលបានពីបណ្ណសារវៀត-ណាមដែល គឺពាក់ព័ន្ធទៅនឹងព័ត៌មាននេះ។

[១៤:២៩:៥៩]

**ស៖** ឥឡូវនិយាយអំពី ភី ភួន ពីព្រោះលោកធ្លាប់បានសម្ភាសគាត់។ លោកឮខ្ញុំនិយាយទេ? ឥឡូវ តើ ភី ភួន ធ្លាប់បាននិយាយជាមួយលោក អំពីការដែល ខៀវ សំផន ប្រហែលជាប្រធានមន្ទីរ ៨៧០។ តើលោកធ្លាប់បាននិយាយជាមួយគាត់អំពីការដែលថាលោក ខៀវ សំផន នេះប្រហែលជាប្រធានមន្ទីរ៨៧០ ទេ?

**ឆ៖** តាមអ្វីដែលខ្ញុំចាំបាននោះ គឺអត់ទេ។ នៅទីក្រុងប៉ារីស ខ្ញុំមានអត្ថបទនៃបទសម្ភាសន៍ ហើយបើសិនខ្ញុំទៅមើល ខ្ញុំអាចនឹងមានលទ្ធភាពផ្តល់ចម្លើយត្រឹមត្រូវទៅលោកស្រី។ ប៉ុន្តែតាមអ្វីដែលខ្ញុំចាំល្អបំផុតនោះ គឺចម្លើយទេ តើខ្ញុំបានសួរជាក់លាក់ តើលោក ខៀវ សំផន ជាប្រធានមន្ទីរ៨៧០? ខ្ញុំមិនច្បាស់ដូចតែគ្នាទេ។ អ៊ីចឹងខ្ញុំមិនចង់ធ្វើឲ្យលោកស្រីភ័ន្តច្រឡំទេ។ ខ្ញុំមិនអាចឆ្លើយអ្វីលើសបានពីហ្នឹងទេ។

[១៤:៣០:៥៨]

**ស៖** អត់បញ្ហាអីទេ លោក ស្បូត ខ្ញុំមិនសុំឲ្យលោកនិយាយនូវអ្វីដែលលោកមិនដឹងនោះទេ។ ឥឡូវនេះខ្ញុំចូលទៅដល់ចំណុចមួយទៀត កាលពីម្សិលមិញលោកបានពិភាក្សាជាមួយសហព្រះរាជអាជ្ញារួចមកហើយ លោកបានឆ្លើយថា -- គេបានបង្ហាញនូវសម្រង់មួយដែលខ្ញុំនឹងអាននៅក្នុងសៀវភៅរបស់លោក គឺទំព័រ៣៦៦។ សម្រាប់លោកជាភាសាអង់គ្លេសនៅជួរបន្ទាត់ទី១, ERN ជាភាសាបារាំង 00639935, ជាភាសាអង់គ្លេស 00396574។ ឃ្លានេះគឺគេអានប្រាប់លោកហើយ "ចម្លើយសារភាពនោះគឺមានសារៈសំខាន់ណាស់ដើម្បីឲ្យ អៀង សារី និង ខៀវ សំផន អាននូវក្នុងកិច្ចប្រជុំសម្ងាត់របស់បក្ស"។ សំណួររបស់ខ្ញុំ គឺខ្ញុំចង់ដឹងថា តើលោកបានប្រភពមកពីណាដែលបញ្ជាក់ថាមានការអានចម្លើយសារភាពជាសម្ងាត់នោះ ហើយលោកនិយាយថាអាននៅក្នុងកិច្ចប្រជុំនុ៎ង ក្នុងកិច្ចប្រជុំបែបណាដែរ?

**ឆ៖** ទាំងនោះគឺជាការប្រជុំ។ ជាឧទាហរណ៍ គឺមន្ត្រីពីក្រសួងគឺថាសៀវភៅរបស់ រ៉ូឡង់ ពិច គាត់បានសរសេរមួយចំនួនពីការប្រជុំនោះ ហើយគាត់បានរៀបរាប់ពីការប្រជុំរបស់កម្មាភិបាលថ្នាក់ខ្ពស់ ដូចជាថាលោក អៀង សារី បានអានចម្លើយសារភាពនៅក្នុងអង្គប្រជុំ។ ហើយខ្ញុំមិនមានអ្វីជាក់លាក់នោះទេ ប៉ុន្តែប្រហែលជាមន្ត្រីថ្នាក់កណ្តាលរបស់ខ្មែរក្រហម ជាកម្មាភិបាលថ្នាក់កណ្តាលអាចនឹងនិយាយពីបញ្ហានេះ អ្នកដែលបានរស់នៅក្បែរប៉ៃលិន។ បន្ទាប់ពីសម្រាក ប្រហែលខ្ញុំអាចនឹងប្រាប់ឈ្មោះ

លោកស្រីមេធាវីបាន។

**ស៖** អត់អីទេលោកសាក្សី។ យើងនឹងត្រឡប់មកនិយាយពីចំណុចនេះវិញ។ លោកបាននិយាយអំពី រ៉ូឡង់ ពិច ហើយនិងកិច្ចប្រជុំនៅក្រសួងការបរទេស។ ចំណុចនេះពាក់ព័ន្ធនឹង អៀង សារី។ ក្នុងឃ្លារបស់លោកនេះ លោកថា អៀង សារី និង ខៀវ សំផន អានចម្លើយសារភាព។ ដូច្នេះខ្ញុំចង់តើលោកមានឧទាហរណ៍ណាមួយទេ ដែលបង្ហាញថា ខៀវ សំផន ទំនងជាអានចម្លើយសារភាពនៅក្នុងកិច្ចប្រជុំនោះ? ហើយបើសិនមានឧទាហរណ៍ តើអ្នកណាជាអ្នកប្រាប់លោកអំពីព័ត៌មានហ្នឹង?

[១៤:៣៣:៥៦]

**ឆ៖** ទេ អត់មានប្រភពណាដែលប្រាប់ខ្ញុំថា អ្នកទាំងពីរហ្នឹងបានអានចម្លើយសារភាពនៅអង្គប្រជុំទេ ហើយពីព្រោះថាកិច្ចប្រជុំសម្ងាត់របស់គណៈអចិន្ត្រៃយ៍ របស់មជ្ឈិម ឬក៏កម្មាភិបាលខ្មែរក្រហមនោះ គឺវាមានលក្ខណៈសំខាន់។ ហើយ ខៀវ សំផន ពិតជាបានធ្វើជាអធិបតីភាពនៅក្នុងអង្គប្រជុំ ហើយ អៀង សារី ក៏បានធ្វើបែបនោះដែរ។ ប្រភពរបស់ខ្ញុំនិយាយថា នៅឱកាសមួយនោះ ដើម្បីបំភ្លឺដល់របៀបវារៈអង្គជំនុំនោះ គឺគេបានអានចម្លើយសារភាពឲ្យអង្គប្រជុំស្តាប់។

**ស៖** ប្រសិនបើខ្ញុំមិនច្រឡំទេ អ្វីដែលលោកសរសេរនោះគឺជាលក្ខណៈទូទៅនៃការសង្ខេបនូវអ្វីដែលកើតឡើងនៅក្នុងកិច្ចប្រជុំ គឺថាមិនមានអ្នកណាគេប្រាប់លោកទេ។ ហើយលោកសន្និដ្ឋានថា ខៀវ សំផន ទំនងជាអានចម្លើយសារភាពនៅក្នុងកិច្ចប្រជុំ។ នេះជាអ្វីដែលលោកបានឆ្លើយមែនទេ អម្បាញ់មិញនេះ?

[១៤:៣៤:៥៨]

**ឆ៖** គឺថាកម្មាភិបាលថ្នាក់កណ្តាលនៅក្រសួងការបទេស ដែលខ្ញុំបាននិយាយជាមួយមិនមែន សួង ស៊ីគឿន ទេ។ ពិតជាបាននិយាយទៅរកអង្គប្រជុំដែលគាត់បានចូលរួម ដែលគាត់ថាលោក ខៀវ សំផន ពិតជាបានអានចម្លើយសារភាពនៅក្នុងអង្គប្រជុំនោះ។

**ស៖** ពាក់ព័ន្ធទៅនឹងចំណុចនេះគឺថា សួង ស៊ីគឿន មែនទេ ជាប្រភពព័ត៌មានរបស់លោកនោះ?

**ឆ៖** ទេ ខ្ញុំមិនថា សួង ស៊ីគឿន ទេ គឺម្នាក់ទៀតជាកម្មាភិបាលថ្នាក់កណ្តាលមួយដែលឈ្មោះរបស់គាត់ហ្នឹងខ្ញុំមិនទាន់នឹកឃើញទេ នៅហ្នឹងចុងមាត់នេះឯង។

**ស៖** មិនអីទេអ៊ីចឹងពេលឈប់សម្រាក បន្ទាប់ពីសម្រាកមកវិញយើងនឹងនិយាយចំណុចនេះវិញ។ លោកប្រធានដោយសារតែយើងបញ្ឈប់នៅម៉ោងបួនកន្លះ ដូច្នេះខ្ញុំមិនដឹងថាតើលោកប្រធានចង់

សម្រាក ឬក៏ចង់ឲ្យខ្ញុំបន្តដល់ម៉ោងបី ដូចដែលលោកប្រធានបានអនុវត្តកាលពីម្សិលមិញនោះ? សូមលោកប្រធានសម្រេច។

**ប្រធានអង្គជំនុំ៖**

សូមអនុវត្តរហូតដល់ម៉ោងបី ទើបសម្រាក។

[១៤:៣៦:១៤]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណច្រើនលោកប្រធាន។

**ស៖** ឥឡូវនេះខ្ញុំត្រឡប់មកចំណុចមួយដែលលោកបានពិភាក្សាកាលពីម្សិលមិញ។ ហើយចំណុចនេះលោកបាននិយាយថា មានលក្ខណៈខុសគ្នាបន្តិចនៅក្នុងសៀវភៅរបស់លោក។ ដូច្នេះ ដើម្បីឲ្យច្បាស់នោះខ្ញុំនឹងអានឃ្លានេះឡើងវិញ។ ខ្ញុំកំពុងតែរកមើលលេខយោងហើយ។ ជាភាសាបារាំង 00639941 រហូតដល់ទំព័របន្ទាប់, ERNជាភាសាអង់គ្លេស 00396579។ ខ្ញុំសូមជំនួយពីក្រុមរបស់ខ្ញុំ ដើម្បីរកមើលទំព័រកន្លែងហ្នឹងបន្តិចសិន។

ចាស ចំពោះលោកហ្នឹងគឺទំព័រ៣៧១ គឺភាសាអង់គ្លេស។ លោក បានសរសេរនៅក្នុងសៀវភៅរបស់លោកថា ប៉ុល ជាអ្នកសម្រេចអំពីការចាប់ខ្លួនបន្ទាប់ពីពិគ្រោះយោបល់ជាមួយនឹង ខៀវ សំផន។ ម្សិលមិញនៅពេលដែលគេសួរលោកអំពីផ្នែកមួយនៃសៀវភៅរបស់លោកនេះ លោកបានឆ្លើយបញ្ជាក់ថា -- ខ្ញុំនឹងស្វែងរកពាក្យពេចន៍របស់លោកដោយផ្ទាល់តែម្តងដើម្បីកុំឲ្យថាខ្ញុំបំប្លែងសម្តីរបស់លោក។ សូមទុកពេលឲ្យខ្ញុំបន្តិចសិនលោក ស្បត។

[១៤:៣៨:៤៣]

សូមអភ័យទោសលោក ស្បត ដែលខ្ញុំធ្វើឲ្យខាតពេលដល់ម៉ោងរបស់តុលាការ។ សូមទោសផងខ្ញុំកំពុងតែញាប់ដៃញាប់ជើងពិនិត្យមើលហើយ។ ខ្ញុំនឹងរកឃើញនូវពាក្យពេចន៍របស់លោកនៅពេលក្រោយ។ ក៏ប៉ុន្តែជាទូទៅ បើតាមការយល់នូវចម្លើយរបស់លោកនោះគឺថា លោកមិនគិតថា ខៀវ សំផន សម្រេចជាមួយ ប៉ុលពត ក្នុងការចាប់ខ្លួនទេ។ ក៏ប៉ុន្តែនេះជា ឡូស៊ិក ដែលលោកគិតនោះគឺ ថាគាត់ទទួលបេសកកម្មសំខាន់។ ដូច្នេះហើយបានជាលោកទាញការសន្និដ្ឋាន តែលោកអត់មានព័ត៌មាន អីច្បាស់លាស់ទេ លោកគ្រាន់តែគិតថា ខៀវ សំផន ទំនងជាងឬក៏ប្រហែលជាបានពិគ្រោះយោបល់ ឬពិភាក្សាជាមួយ ប៉ុល ពត មុនពេលចាប់ខ្លួនអ្នកណាម្នាក់នោះ។ ទោះបីជាខ្ញុំរកឃើញឃ្លារបស់លោកនៅពេលក្រោយក៏

បាន តែសូមឲ្យលោកពន្យល់នូវអ្វីដែលលោកបានឆ្លើយកាលពីម្សិលមិញនោះ។

**ធ៖** បាទខ្ញុំចាំការពិភាក្សានេះ ដែលយើងបាននិយាយអំពីរបៀបដែលការពិគ្រោះយោបល់ដែលនិយាយពីបញ្ហាផ្សេងៗនោះ។ តាមដែលខ្ញុំយល់ គឺនេះអាចផ្អែកលើមូលដ្ឋាននៃថា ខៀវ សំផន បានរកឃើញបន្ទាប់ពីដែលយើង -- គាត់ធ្វើបេសកម្មសំខាន់ទៅខេត្តនោះឯង។ ប្រភពផ្សេងទៀត គឺបទសម្ភាសន៍ជាមួយនឹង ឌឿក -- ប៉ុន្មានឆ្នាំមុននេះ គឺថាមុនពេល -- ជាមួយ ឌុច ដែលថា មុនពេលគាត់ចាប់ខ្លួននោះ គឺថាដែលខ្ញុំព្យាយាមនឹងរកប្រតិចារឹកនៃបទសម្ភាសន៍នោះ ដែលនិយាយអំពីបញ្ហានេះនោះ។

**ស៖** តើ ឌុច មានប្រាប់លោកថា គាត់បានឃើញ ខៀវ សំផន នៅក្នុងរយៈពេលនោះទេ ហើយគាត់បានការសន្និដ្ឋានបែបហ្នឹងមកពីណាដែរ?

[១៤:៤១:០៣]

**ធ៖** អត់ទេ ដូចដែលខ្ញុំនិយាយហ្នឹង។ ខ្ញុំមិនបានសម្ភាស ឌុច ទេ គឺអ្នកផ្សេងសម្ភាសគាត់ គឺដោយអ្នកកាសែតជនជាតិបរទេស ដូចជា និក ប៉ុន្តែខ្ញុំបានប្រតិចារឹកនៃបទសម្ភាសន៍ហ្នឹងទាំងស្រុង។ ខ្ញុំបានមើលឃើញ។

**ស៖** លោក ហ្វីលីព ស្សត! ឥឡូវនេះ ខ្ញុំរកឃើញឯកសារយោងដែលខ្ញុំនិយាយអម្បាញ់មិញនេះហើយ។ លោកបានបញ្ជាក់យ៉ាងច្បាស់ថា គឺពាក់ព័ន្ធទៅនឹងការចាប់ខ្លួននោះ លោកថាសេចក្តីសន្និ -- គឺថានៅក្រោយមកម៉ោង ០៩:៤៦, "ការសន្និដ្ឋាននៅក្នុងសៀវភៅរបស់ខ្ញុំ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំផ្អែកទៅលើប្រភពមួយដែលខ្ញុំអាចជឿជាក់បាន គឺថាពិតជាអាចជឿជាក់បាន។ គឺថាជឿជាក់រហូតដល់អង្គជំនុំជម្រះយកមកធ្វើជាភស្តុតាងបាន"។ នេះជាចម្លើយរបស់លោកកាលម្សិលមិញ។ ប៉ុល ពត បានប្រើ ខៀវ សំផន ឲ្យទៅបំពេញបេសកម្មនៅតាមខេត្ត។ ខៀវ សំផន ត្រូវបានបញ្ជូនទៅខេត្តដើម្បីវាយតម្លៃពីស្ថានភាពនៅតាមខេត្ត ហើយបន្ទាប់មកគាត់ត្រឡប់មកវិញ រាយការណ៍។ នៅពេលដែលលោកនិយាយបែបនេះនោះ គឺលោកនិយាយអំពីកម្មាភិបាលមធ្យម ថ្នាក់កណ្តាលដែលលោកកំពុងតែរកឈ្មោះ។ តើមែនទេអ្នកដែលនិយាយរឿងនេះប្រាប់លោកនោះ?

[១៤:៤២:៤៥]

**ធ៖** បាទ ខ្ញុំដូចនឹកឃើញឈ្មោះ ឡុង នរិន្ទ -- នរិទ្ធ ដែលខ្ញុំចាំថា គាត់និយាយប្រាប់រឿងហ្នឹងដល់ខ្ញុំ។

**ស៖** ចុះ ឡុង នរិន្ទ ហ្នឹងគាត់មានតួនាទីអ្វីដែរ?

**ឆ៖** គាត់ធ្វើការនៅក្រសួងការបរទេសកាលណោះ។ សូមអភ័យទោស គឺថាគាត់ឈ្មោះ ឡុង នរិន្ទ មិនមែន នរិទ្ធ ទេបាទ។

**ស៖** តើគាត់មានប្រាប់លោកទេថា នៅពេលណាដែលគាត់បានពិភាក្សាជាមួយនឹងលោក ខៀវ សំផន នោះនៅពេលដែលគាត់ប្រាប់លោកនោះ?

[១៤:៤៣:៣១]

**ឆ៖** គឺថាពាក្យថាការប្រាស្រ័យទាក់ទងជាមួយនឹងលោក ខៀវ សំផន ហ្នឹង គឺពាក្យធ្ងន់ពេក។ ប៉ុន្តែគាត់ហ្នឹងបានចូលរួមនៅក្នុងអង្គប្រជុំដែលលោក ខៀវ សំផន ជាអធិបតីអង្គប្រជុំនោះ។

**ស៖** លោកនិយាយនេះ គឺលោកនិយាយអំពីកិច្ចប្រជុំដែលនៅក្នុងនោះមានការអានចម្លើយសារភាពមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** បាទ សូមអភ័យទោសដែលខ្ញុំជជីកសួរលម្អិតលោក។ តើគាត់មានប្រាប់លោកថា ប្រជុំនោះប្រជុំនៅឯណា? ហើយប្រជុំក្នុងក្របខ័ណ្ឌអីទេ?

**ឆ៖** តាមការខ្ញុំចាំគឺគាត់មិនបានបញ្ជាក់ទេ។ ប្រហែលជាខ្ញុំមិនបានគិតថា សួររកប្រជុំនៅកន្លែងណា? ព្រោះខ្ញុំមិនទាន់ចាប់អារម្មណ៍ពីរឿងហ្នឹងទេពេលនោះ។ ដូចជា រ៉ូឡង់ ពិច គឺថាបាន គឺថាមានរឿងហ្នឹងអ៊ីចឹង ហើយ ឡុង នរិន្ទ ហ្នឹងក៏ថាកើតមានអ៊ីចឹងដែរ។ គឺថា គឺព័ត៌មាននេះវាស៊ីសង្វាក់គ្នា បើសិនជាលោកស្រីចង់បានថា ឲ្យពិនិត្យផ្ទៀងផ្ទាត់អាហ្នឹងហើយប្រភពពីរប្រាប់រឿងតែមួយ។ ហើយខ្ញុំមិនបានកត់ត្រាថាតើអាការប្រជុំទាំងពីរ ឬក៏ប៉ុន្មាននៅកន្លែងណា? ខ្ញុំមិនចាប់អារម្មណ៍សួរទេកាលណោះ។

[១៤:៤៤:៥០]

**ស៖** ខ្ញុំសួរសំណួរនេះ គឺដោយសារតែ រ៉ូឡង់ ពិច ជាប្រពន្ធរបស់ សួង ស៊ីគឿន ដែលធ្វើការនៅក្រសួងបរទេសនេះ បានប្រាប់ថា ឡុង នរិន្ទ ក៏ធ្វើការក្រសួងការបរទេសដែរ។ ហើយលោកអម្បាញ់មិញនេះនិយាយអំពីកិច្ចប្រជុំសម្ងាត់។ ដូច្នេះ ខ្ញុំចង់ដឹងថាប្រជុំសម្ងាត់ហ្នឹង នៅការក្រសួងការបរទេសដែរឬទេ ក៏ប៉ុន្តែលោកខ្ញុំយល់ហើយ លោកអត់មានព័ត៌មាននឹងចំណុចនេះទេ។ ដូច្នេះ លោកមិនអាចឆ្លើយបានទេ។

ឥឡូវនេះ ខ្ញុំចូលទៅប្រធានបទមួយផ្សេងទៀតទេ ពីព្រោះថាពេលវេលាកាន់តែខើចទៅហើយ។

ខ្ញុំមិនដឹងថា ពីម្សិលមិញ ឬក៏ថ្ងៃពីចន្ទទេ -- ត្រូវហើយ ម្សិលមិញ គឺជាមួយនឹងសហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញាបានសួរលោកថា តើលោកដឹងអំពីជំនួយមនុស្សធម៌ផ្សេងដែលបក្សកុម្មុយនីស្តកម្ពុជាទទួលពីក្រៅដែរឬទេ? ហើយលោកបានឆ្លើយថា លោកអត់ដឹងពីជំនួយមនុស្សធម៌នេះទេ។ នៅក្នុងសំណុំឯកសារដែលយើងខ្ញុំបានប្រគល់ជូនលោកកាលពីម្សិលមិញនោះ គឺមានឯកសារមួយចំនួន ហើយនិងកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍។ តើលោកអាចមានបានមើលទេ ឯកសារដែលខ្ញុំជូនលោកនោះ?

[១៤:៤៦:១៦]

ឥឡូវនេះ ខ្ញុំសូមពិនិត្យមើលឯកសារនេះទាំងអស់គ្នា។ ឯកសារដំបូងនោះ គឺលេខ E3/230, ERN ជាភាសាបារាំង 00301330, ERN ជាភាសាខ្មែរ 00000711, ERN ជាភាសាអង់គ្លេស 00182546។

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបញ្ចាំងទំព័រទី១ ជាភាសាខ្មែរនៅលើអេក្រង់។ ហើយលោក ហ្វីលីព ស្សុត លោកមានឯកសារនេះ នៅនឹងដៃលោកហើយ។

នេះគឺជាកំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ នៅយប់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦។ អ្នកចូលរួមនោះ មានដូចជា : សមមិត្តលេខា សមមិត្តអនុលេខា, សមមិត្ត វ៉ាន់, សមមិត្ត វន, សមមិត្តខៀវ, សមមិត្ត ធុច, សមមិត្ត ហែម, សមមិត្ត ឌឿន, សមមិត្ត ទូច។ សូមអភ័យទោសផង បើសិនជាខ្ញុំអានទៅមិនច្បាស់នោះ ព្រោះថាឈ្មោះនោះ ខ្ញុំមើលទៅស្រដៀងៗតែគ្នា។ នៅចំណុចទី៤នៃឯកសារនេះ មានដាក់ថា “ជំនួយ យូហ្គោស្លាវី ៣លានដុល្លារ”។ នៅខាងក្រោម គឺជាផ្នែកអនុសាសន៍៖ “ស្នើទិញថ្នាំពេទ្យចំនួន១លានដុល្លារ ជាពិសេសថ្នាំគ្រុន ថ្នាំប្រឆាំងមេរោគគ្រប់យ៉ាងដូចជាអង់ទីប៊ីយ៉ូទិច ថ្នាំកម្លាំង សេរ៉ូម...។ល។”

[១៤:៤៨:៣៦]

នៅឯកសារដដែលនេះ នៅទំព័របន្ទាប់មកទៀត។ ចំណុចទី៧ ដែលមានចំណងជើងថា “ការចែកចាយអង្ករបានមកពីជំនួយចិន : ស្នើចែកអង្ករមួយចំនួនទៅឲ្យខាងសមមិត្តមុត ៥.០០០បាវ។ ខាងកោះកុង ៣.០០០បាវ។ តំបន់២៥ ១០.០០០បាវ ឯចំនួនដែលនៅសល់ ទុកបម្រុង និងទុកប្រើប្រាស់នៅភ្នំពេញ”។ សំណួរទីមួយរបស់ខ្ញុំ ប្រហែលជាអាចមិនចាំបាច់ ពីព្រោះថាលោកឆ្លើយកាលពីម្សិលមិញ ក៏ប៉ុន្តែ ខ្ញុំនៅតែសួរលោកទៀត។ ថាតើលោកដឹង ឬក៏ស្គាល់ឯកសារនេះទេ? ឬក៏លោកស្គាល់តែលោកភ្លេច?

**ឆ៖** បាទ ខ្ញុំដឹង បានឃើញឯកសារនេះ។ ខ្ញុំបាននិយាយ។ គឺថាអាចតុលាការយល់ថា ខ្ញុំមិនប្រាកដ ឬក៏ខ្ញុំអាចយល់សំណួរមិនច្បាស់ ប៉ុន្តែខ្ញុំមិននិយាយថា -- អ្នកសួរនោះ សួរខ្ញុំអំពីកង្វះស្បៀងអាហារនៅឆ្នាំ១៩៧៥។ ខ្ញុំឆ្លើយថាអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យបានគឺថាបានបដិសេធមិនឱ្យបញ្ជូនជំនួយសង្គ្រោះបន្ទាន់ទេក្នុងរយៈពេល១សប្តាហ៍បន្ទាប់រំដោះ។ ប៉ុន្តែស្បៀងអាហាជំនួយមួយចំនួនគឺបានបញ្ជូនមកពីប្រទេសចិន ទាក់ទងទៅនឹងសំណើសុំរបស់កម្ពុជាប្រជាធិបតេយ្យនោះ គឺថាមានជំនួយមួយចំនួនចូលមក។ ប៉ុន្តែគេដឹងទូទៅហើយដូចជា កូរ៉េខាងជើង យូហ្គោស្លាវី ក៏បានផ្តល់ជំនួយបច្ចេកទេសខ្លះមកពីប្រទេសស្វីស។ បាទ គឺថាគេទទួលជំនួយបរទេសមាន ប៉ុន្តែក្នុងបរិមាណមានកម្រិតណាស់តិចតួច។

[១៤:៥០:៥៨]

**សៈ** ចំណុចនេះគឺនាំឱ្យខ្ញុំចូលទៅឯកសារទី២ ដែលខ្ញុំចង់ពិនិត្យមើលជាមួយលោក គឺឯកសារ E3/238 គឺលោកមានហើយ ខ្ញុំឱ្យលោកហើយ។

ដូច្នេះខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីបញ្ចាំងឯកសារ E3/238, ERN ជាភាសាបារាំង 00446630, ជាភាសាខ្មែរគឺ 00072458, ERN ជាភាសាអង់គ្លេស 00424112។ ឯកសារនេះគឺជាកំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ថ្ងៃ២៨ កុម្ភៈ ឆ្នាំ១៩៧៦។ មានអ្នកចូលរួមបីនាក់ ហើយក្នុងការបកប្រែជាភាសាបារាំងនោះ មើលឃើញបានតែសមមិត្ត ទូច មួយទេក្រៅពីហ្នឹងមើលអត់ដាច់ទេ។ គឺក្នុងប្រជុំនោះគឺនិយាយអំពីបញ្ហាជំនួយរបស់ស៊ុយអែត និងយូហ្គោស្លាវី។

នៅកថាខណ្ឌទី១ និយាយអំពីជំនួសស៊ុយអែត។ "រដ្ឋាភិបាលស៊ុយអែតគ្រោងជួយប្រទេសអង់ហ្គោឡា សូម៉ាលី និងកម្ពុជាក្នុងឆ្នាំ១៩៧៦, ៧៧ ចំនួនជាទឹកប្រាក់១៨០លានគូរុន ត្រូវជា៤០លានដុល្លារ"។

[១៤:៥២:៤១]

ខ្ញុំចូលដល់កថាខណ្ឌទី២ ជំនួយយូហ្គោស្លាវី "រដ្ឋាភិបាលយូហ្គោស្លាវីជួយយើង៤លានដុល្លារ តែគេបានចំណាយ១លានដុល្លារហើយសម្រាប់ទិញភួយនិងថ្នាំពេទ្យ។ ភួយចំនួន១.៥០០ ផ្ញើមកតាមប៉េកាំង។ គេសួរយើងថាតើយើងបានទទួលឬទេ?"។ នេះជាឯកសារមួយដែលបញ្ជាក់ថា មានជំនួយពីស៊ុយអែត និងយូហ្គោស្លាវី។ ដូច្នេះជាថ្មីម្តង ទៀតតើនៅក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យនោះលោកដឹងថាមានជំនួយរបស់ស៊ុយអែត និងយូហ្គោស្លាវីដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានធ្វើដូច្នេះ ខ្ញុំបានដឹងហើយនៅកាលណោះ នៅពេលដែលខ្ញុំនៅទីក្រុងប៉េកាំង នោះ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គឺខ្ញុំបានដឹងថាអគ្គរដ្ឋទូតយូហ្គោស្លាវីបានមកភ្នំពេញ។ គេមិនរក្សាជាការសម្ងាត់ទេកាលណោះនោះ។

[១៤:៥៣:៥៥]

**សៈ** ខ្ញុំបន្តចំពោះឯកសារដែល ពីព្រោះគេនិយាយអំពីគោលជំហរនយោបាយពាក់ព័ន្ធទៅនឹងជំនួយបរទេស។ ជាភាសាបារាំងគឺនៅលេខ ERN ដដែល ហើយអង់គ្លេសនិងខ្មែរគឺទំព័របន្ទាប់។ ជាភាសាខ្មែរនោះគឺ 00072459, ជាភាសាអង់គ្លេស 00424113។ “លក្ខណៈជំនួយរបស់ស៊ុយអែត និងយូហ្គោស្លាវី : ក) ខាងនយោបាយ ដើម្បីទទួលជំនួយ យើងត្រូវជ្រើសរើសសមាសភាពប្រទេសដែលឯករាជ្យដោយប្រៀបធៀបមិនរណបអាមេរិកនិងសូវៀត”។ ហើយបន្តទៅទៀតជាភាសាបារាំងនៅទំព័របន្ទាប់ “មានប្រទេសទាំងអស់នេះយើងមានកម្លាំងនៅឆាកអន្តរជាតិ អាមេរិកចង់សង្កត់យើង សូវៀតក៏ចង់សង្កត់យើងតាមរយៈវៀតណាម។ ដូច្នេះយើងត្រូវមានមិត្តក្នុងសកលលោក គឺមិត្តដែលគ្មានស្លាកជាបក្សពួក។”

ចុះមកក្រោមបន្តិចមក នៅទំព័រដដែល គឺនៅចំណុចទី២ ហើយយើងខ្ញុំសូមបញ្ឈប់ការអានដ៏គួរឲ្យធុញទ្រាន់នេះ។ ចំណុចទី២ ឈរលើ -- ជាភាសាខ្មែរគឺចូលលេខERN ថ្មីហើយគឺលេខ 00072460, ERN ជាភាសាអង់គ្លេស 00424114។ នេះគឺជាការសន្និដ្ឋាន។ “គេថាជំនួយគេគ្មានលក្ខខណ្ឌ តែជំនួយដែលមាននេះដូចជាមានឥទ្ធិពល ឬចង់បានឥទ្ធិពល ឬការឧបត្ថម្ភពីយើង។ តែបញ្ហានេះមិនអីទេ។ ដូច្នេះអ្វីដែលបម្រើបដិវត្តន៍ ចំណេញបដិវត្តន៍យើងយកបាន។ហើយយើងអរគុណគេទៅ”។

[១៤:៥៦:១១]

បន្ទាប់មកទៀតមានការពិពណ៌នាគឺនៅERN ដដែល ហើយភាសាបារាំងបញ្ចប់នៅទំព័រខាងមុខមួយទៀត។ គេពន្យល់ថាជំនួយពីស៊ុយអ៊ែត គឺសម្រាប់ទិញសម្ភារៈ ហើយជំនួយខាងយូហ្គោស្លាវីនោះគឺសម្រាប់ទិញថ្នាំពេទ្យ។ ឯកសារនេះជាឯកសារដែលលោកធ្លាប់ឃើញទេ? ហើយជំហរដែលបានបង្ហាញនៅក្នុងកំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ដែលថាយើងយកជំនួយបានហ្នឹង គឺថាទៅតាមប្រទេស ដូចថាប្រទេសណាដែលថាឯករាជ្យ ហើយមិនគាបសង្កត់នោះយើងយកជំនួយ។ ដូច្នេះវាពាក់ព័ន្ធទៅនឹងអ្វីដែលលោកបានសិក្សានៅសម័យនោះទេ។

**ឆ៖** និយាយជាទូទៅបាទ។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំឃើញថាម៉ោងជិតបីហើយ។ ហើយខ្ញុំចូលទៅប្រធានបទផ្សេងទៀត។ ដូច្នេះតើលោកប្រធានសម្រេចសម្រាកសិន ឬក៏ឲ្យខ្ញុំបន្ត។

**ប្រធានអង្គជំនុំ៖**

បាទអរគុណៗលោកស្រីមេធាវី។ អរគុណអ្នកជំនាញ។ បាទ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទីចាប់ពីពេលនេះទៅ រហូតដល់ម៉ោងបី ម្ភៃនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រងចាំសម្រាបសាក្សី និងអ្នកជំនាញដល់អ្នកជំនាញរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក។ និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី និងម្ភៃនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៥៨ នាទី ដល់ម៉ោង ១៥:២៣ នាទី)*

[១៥:២៣:៤៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធិសវនាការ និងផ្តល់វេទីកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ នេះជាប្រធានចុងក្រោយហើយ។

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** បន្ទាប់មុននឹងនិយាយអំណុចមួយទៀតលើឯកសារដែលខ្ញុំបានដាក់ជូនតុលាការម្សិលមិញនេះ ខ្ញុំសូមត្រឡប់មកនិយាយពេលក្រោយដែរ។ លោកសាក្សី -- លោកអ្នកជំនាញនេះ លោកបានអម្បាញ់មិញ លោកថាគឺ ឡុង នរិន្ទ ដែលបាននិយាយអំពីកិច្ចប្រជុំជាមួយ ខៀវ សំផន ហើយថានៅក្នុងឱកាសនោះ គឺថា ខៀវ សំផន បានអានចម្លើយសារភាព។

[១៥:២៤:៤៨]

នៅពេលសម្រាកអម្បាញ់មិញនេះ យើងបានផ្ទៀងផ្ទាត់ហើយ គឺថា ឡុង នរិន្ទ បានមកផ្ដល់សក្ខីកម្មនៅទីនេះមែន ហើយដើម្បីៗជាកំណត់ហេតុប្រតិចារឹកហ្នឹង ខ្ញុំសូមឲ្យលោកអត្ថាធិប្បាយមួយចំនួន។ សូមអានសម្រង់របស់គាត់មួយគឺថា នៅចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១១, ឯកសារ E1/191, ERN ជាភាសា 00761 --, ERN ជាភាសាខ្មែរគឺ 00519197, ERN ជាភាសាអង់គ្លេសគឺថា 00761264។ នៅក្នុងកំណត់ហេតុនេះមានសួរសំណួរមួយចំនួនទៅលោក ឡុង នរិន្ទ ជាភាសាអង់គ្លេស ទំព័រទី២២ “តើលោកធ្លាប់ចូលកិច្ចប្រជុំដែរមានវត្តមាន នួន ជា និង ខៀវ សំផន ដែរឬទេ? ចម្លើយ៖ អត់មាន នួន ជា ទេ។ គាត់អត់មានមកទេ ប៉ុន្តែមាន ខៀវ សំផន ទំនងជាគាត់មក”។ តើលោកច្បាស់ទេ ថាលោក ឡុង នរិន្ទ នេះនិយាយអំពីកិច្ចប្រជុំហ្នឹង ឬក៏យ៉ាងម៉េច ឬក៏លោកមិនចាំទេ ឬក៏អាចជាអ្នកផ្សេងក្រៅពី ឡុង នរិន្ទ ឬក៏ប្រភពរបស់លោកនោះមិនច្បាស់លាស់ទេ?

[១៥:២៦:៣៣]

**លោក ហ្វីលីព ស្សូត៖**

**ឆ៖** ឡុង នរិន្ទ គឺខ្ញុំចាត់ទុកថាជាប្រភពព័ត៌មានដែលអាចទុកចិត្តបាន ហើយតាមរយៈខ្ញុំចាំ គឺ ឡុង នរិន្ទ បាននិយាយដូច្នេះមែន។ ខ្ញុំឆ្ងល់ថាអាចនឹងមានការយល់ខុស ឬមួយក៏យ៉ាងដូចម្ដេច។ ខ្ញុំគិតថាប្រហែលជាមានការយល់ខុសទៅលើបញ្ហាទាំងអស់នេះ ថាតើលោកសួរអំពីប្រភពព័ត៌មាន ឡុង នរិន្ទ ទាក់ទងទៅនឹងការប្រជុំផ្លូវការ និយាយអំពីបញ្ហាផ្លូវការ ប៉ុន្តែខ្ញុំគិតថាគាត់មិនមានវត្តមានជាមួយ នឹង នួន ជា នៅក្នុងការប្រជុំ ឬក៏មានវត្តមានជាមួយ ខៀវ សំផន ហើយប្រជុំជាមួយគ្នាដើម្បីកំណត់នូវគោលនយោបាយឡើយ។ គាត់មិនបានចូលរួមនៅក្នុងកិច្ចប្រជុំណាមួយ ដែល ខៀវ សំផន បានបើកវគ្គរៀនសូត្រ ឬក៏បើកជាសិក្ខាសាលានោះទេ។ តាមដែលខ្ញុំចាំ គឺថាគាត់និយាយថាគាត់ធ្លាប់ ប៉ុន្តែខ្ញុំមិនអាចបញ្ជាក់បានទៅលើបញ្ហាទាំងអស់នេះទេ។

ទាក់ទងទៅនឹងប្រធានបទនេះ គឺថានៅពេលដែលយើងបានពិភាក្សាពីមុនកន្លងមកហើយ។ នៅពេលដែលយើងនិយាយថាតើខ្ញុំប្រាកដអត់ ថាមានកិច្ចប្រជុំបែបនេះ? ខ្ញុំមិនបានសួរគាត់អំពីកិច្ចប្រជុំជាក់លាក់នោះទេ។ ប៉ុន្តែជាអ្វីដែលខ្ញុំដឹង គឺថាកិច្ចប្រជុំគឺបានធ្វើឡើងនៅក្រសួងការបរទេស។ ហើយនិយាយអំពីបុគ្គលិកដែលចង់ចេញទៅណាមកណាត្រូវមានការអនុញ្ញាតជាផ្លូវការ។ នេះគឺជាកិច្ចប្រជុំដែលបានកើតឡើង ដែលបានធ្វើឡើងនៅក្រសួងការបរទេស គឺមានមែន។

[១៥:២៨:២១]

**ស៖** ខ្ញុំយល់ស្រប គឺថានេះជាការចងចាំរបស់លោក។ អ៊ីចឹងខ្ញុំនិយាយសួរអំឡុញមិញនេះដើម្បីឲ្យច្បាស់ទាំងអស់គ្នា។ ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយអំពីឯកសារមួយទៀតដែលលោកបាន --ធម្មតាពិគ្រោះហើយៗ ក៏ប៉ុន្តែមុនហ្នឹងខ្ញុំ មុននឹងហ្នឹងខ្ញុំសូមដកស្រង់ផ្នែកមួយនៃសៀវភៅរបស់លោក។ ទំព័រជាភាសាអង់គ្លេសសម្រាប់លោកនោះគឺថា ទំព័រ៥៥៦, ERN ជាភាសាបារាំងគឺ 00639922, ហើយជាភាសាអង់គ្លេសគឺ 00396546។ នៅចំកណ្តាលទំព័រសម្រង់នេះ គឺជាផ្នែកមួយដែលលោកនិយាយអំពីបញ្ហាព្រំប្រទល់រវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម។ លោកបានលើកឡើងដូចតទៅនេះ៖ "ឧសភា ឆ្នាំ១៩៧៦ អ្នកចរចាខ្មែរនិងវៀតណាមបានជួបគ្នានៅទីក្រុងភ្នំពេញ ដើម្បីព្យាយាមរកកិច្ចព្រមព្រៀងមួយលើបន្ទាត់ព្រំប្រទល់រួមរវាងប្រទេសទាំងពីរ។ ការជួបគ្នានេះ ថាកើតមុនការជំនួបកំពូលនៅទីក្រុងហាណូយ ហើយដែលត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងទាក់ទងព្រំប្រទល់នេះ"។ នេះគ្រាន់តែជាផ្តល់ការផ្តល់បរិបទឲ្យលោកទេ។

[១៥:៣០:០២]

លោកនិយាយពីកិច្ចប្រជុំខែឧសភាឆ្នាំ១៩៧៦ អ៊ីចឹងខ្ញុំសូមឲ្យលោកទៅពិគ្រោះឯកសារ E3/221, ERNជាភាសាបារាំងគឺ 00386175, ERN ជាភាសា អង់គ្លេសគឺ 00182693, ERN ជាភាសាខ្មែរគឺ 00000810 ហើយឯកសារនេះមានចំណងជើងថា: ពិនិត្យអំពីប្រតិកម្មវៀតណាមនៅក្នុងអង្គប្រជុំលើកទី៥ ព្រឹកថ្ងៃ១៤ ឧសភា ៧៦។ មានសរសេរផង ដែរ គឺថា : អង្គប្រជុំគណៈអចិន្ត្រៃយ៍នៅពេលរសៀល និងពេលយប់ថ្ងៃទី១៤ ឧសភា ឆ្នាំ១៩៧៦ សមសភាព សមមិត្តលេខា សមមិត្តអនុលេខា សមមិត្តវ៉ាន់ សមមិត្តវន, សមមិត្តខៀវ, សមមិត្តហែម, សមមិត្តយ៉ា, សមមិត្តចាន់, សមមិត្តសែ, សមមិត្តទូច ហើយកំណត់ហេតុ។

កថាខណ្ឌទី១ និយាយថាសេចក្តីរាយការណ៍ជូនអង្គប្រជុំ គណៈអង្គប្រជុំលើកទី៤ ហើយគេបញ្ជាក់ពីអ្នកណាអ្នកនិយាយ។ អ៊ីចឹងនៅក្នុងនេះមានមិត្ត យ៉ា ដែលរាយការណ៍ ជូនអង្គប្រជុំ។ "ផាន់ ហ៊ាន មានមតិដោយអានអត្ថបទវាយម៉ាស៊ីនច្រើនសន្លឹក។ គេអរគុណយើងពីទស្សនកិច្ចនៅអង្គរ ហើយរំភើបចំពោះអង្គការយើងដែលបានយកចិត្តទុកដាក់ចំពោះគេ។ គេថាគេបានពិចារណាអំពីមតិយើង អំពីទស្សនកិច្ចនិងអំពីគោលជំហរនៃការចរាចរ។ គាត់ថាមតិខ្លះដូចគ្នា ហើយមតិខ្លះមិនដូចគ្នា។ ហើយមានពេលខ្លះភាគីទាំងពីរមិនយល់គ្នាទេ"។

[១៥:៣២:៤១]

កថាខណ្ឌពីរ នៅក្រោមទៀត អានេះនៅក្នុងកំណត់ហេតុដដែល។ អ៊ីចឹង មិត្តយ៉ា បន្ត “ទាក់ទងនឹងព្រំដែនសមុទ្រគេថា គេបានពិនិត្យមតិយើងថ្ងៃទី៥ ដល់ថ្ងៃទី៨ ហើយមានប្រកាន់ជំហរម៉ឺងម៉ាត់ ថាយើងបានយល់ព្រមលាក់ការណ៍របស់វា (ហើយគាត់បន្តទៀត) ប៉ុន្តែយើងយកបន្ទាត់ ប្រេវីយ៉េជាកំណត់ព្រំដែនវិញ។ ហើយយើងបានស្រែកថាបន្ទាត់នេះមិនអាចប្រកែកបានទេ”។

ទំព័រមួយទៀតជាភាសាបារាំង ERN 00386176, ជាភាសាអង់គ្លេស គឺ00182694, ជាភាសាខ្មែរគឺ 00000811។ ចាស ខ្ញុំអានសេចក្តីសន្និដ្ឋាន “គេមិនទទួលស្គាល់ខ្សែបន្ទាត់ប្រេវីយ៉េទេ ដែលថាតាមផ្លូវការខ្សែបន្ទាត់ប្រេវីយ៉េនេះមិនមានសំអាងលើអ្វីឡើយ។ បើយើងយកខ្សែបន្ទាត់ប្រេវីយ៉េហ្នឹងគឺថាវាប៉ះពាល់ដល់អធិបតេយ្យភាពរបស់ប្រទេសវា។ វាពុំអាចទទួលយកបានទេ”។ នេះគឺជាសេចក្តីសន្និដ្ឋាននៃឯកសារនេះ។ ខ្ញុំចង់ដឹងថាតើនៅក្នុងកំណត់ហេតុនេះ គេនិយាយពីកិច្ចប្រជុំដែលលោកបានលើកឡើងនៅក្នុងសៀវភៅរបស់លោកដែរឬទេ? ហើយប្រសិនពិតជាកំណត់ហេតុហ្នឹងមែននោះ តើពាក់ព័ន្ធនឹងបន្ទាត់ប្រេវីយ៉េ នេះមានបញ្ហាអ្វីខ្លះដែរ?

[១៥:៣៤:៣០]

**ផ៖** បន្ទាត់ប្រេវីយ៉េ គឺជាបន្ទាត់បែងចែងព្រំដែនសមុទ្ររវាងវៀតណាម ដែលជាអតីតអាណានិគមបារាំង គឺនៅក្នុងតំបន់កូសាំងស៊ីនហ្នឹងជាមួយនឹងប្រទេសកម្ពុជា។ ហើយនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យគឺថា ពួកគាត់ចង់បែងចែកព្រំដែនសមុទ្រដោយប្រើបន្ទាត់នេះ ព្រោះថាដូចដែលបានបង្ហាញនៅក្នុងឯកសារហ្នឹងខ្សែបន្ទាត់ហ្នឹងត្រូវបានគូសដោយបារាំង។ ហើយវៀតណាមគាត់ចង់ធ្វើការរំកិលព្រំដែលឲ្យបានច្រើនដើម្បីទទួលបានសមុទ្រ ព្រំដែនសមុទ្រច្រើនទៅខាងវៀតណាម។

ប្រសិនបើយើងមើលឯកសារហ្នឹងអ្វីដែលខ្ញុំចាប់អារម្មណ៍ គឺថា គឺខាងកម្ពុជាប្រជាធិបតេយ្យមានចេតនាយ៉ាងខ្លាំងក្នុងការរារាំងមិនចង់ឲ្យមានការទាស់ទែង។ បានន័យថាប្រសិនមានការមិនយល់ស្រប គឺយើងធ្វើការចរចា ហើយបន្ទាប់មកគឺយើងទុកឲ្យវានៅស្ងៀមស្ងាត់ទៅកុំធ្វើការអ្វីទាំងអស់។ ហើយដូចដែល ប៉ុល ពត ធ្លាប់និយាយអ៊ីចឹង។ ប្រសិនបើយើងមានបញ្ហា គឺយើងរក្សាទុកសិន។ ដូច្នេះអ្វីដែលខាងកម្ពុជាធ្វើគឺបានន័យថា គូសទៅតាមនេះទៅ។

[១៥:៣៦:០០]

**សៈ** តាមពិតអម្បាញ់មិញនេះ ខ្ញុំគួរតែសួរសំណួរដែលថា តើលោកស្គាល់ឯកសារហ្នឹងទេ?

E1/192.1

ធ្លាប់ពិគ្រោះឯកសារហ្នឹងទេ មុននឹងសួរសំណួរ ខ្ញុំទើបតែបានសួរអម្បាញ់មិញនេះ?

**ឆ៖** ខ្ញុំគិតថា ខ្ញុំធ្លាប់ឃើញសេចក្ដីសង្ខេបជាភាសាវៀតណាម ប៉ុន្តែខ្ញុំមិនដែលឃើញឯកសារជាផ្លូវការ ជាភាសាខ្មែរ ឯកសារដើមជាភាសាខ្មែរនេះទេ។

**ស៖** និយាយអំពីឆន្ទៈក្នុងការសម្របសម្រួលគ្នានេះ ខ្ញុំសូមបន្តទៅទំព័រចុងក្រោយនៃឯកសារហ្នឹង គឺថាគ្រប់ភាសាទាំងអស់នៅទំព័រចុងក្រោយ គឺERN 00386179 នេះជាបារាំង ហើយអង់គ្លេសគឺ 00182705, ERN ជាភាសាខ្មែរគឺ 00000826។ នេះសេចក្ដីសន្និដ្ឋាន "មិត្តនួន បើតាមមើលទៅលើឡេ យន់ សរសេរខ្លួនឯង ហើយថាចង់ជួបយើងដល់ទៅពីរដង ទូរលេខគាត់ទាំងពីរនិយាយពីរឿងនេះ ហើយគាត់ត្រូវការយើងមែនទែន។ សមមិត្តលេខា ដូច្នេះយើងត្រូវធ្វើស្ងួត យើងទៅមើលកុនវាទៅ។ គាត់មិនទាន់មានហេតុផលអ្វីវាយផ្ដាច់យើងទេ ព្រោះយើងនៅតែញញឹមស្រស់មិនដែលជេរគាត់អីណា បើគាត់វាយផ្ដាច់ គាត់អត់មានអីចំណេញទេ មានតែខាត"។ អ៊ីចឹងខ្ញុំចង់ដឹងថា តើនេះបញ្ជាក់ពីឆន្ទៈចង់សម្របសម្រួលចរចាគ្នាពីសំណាក់ភាគីខ្មែរដែរឬទេ?

[១៥:៣៨:០៩]

**ឆ៖** មិនត្រឹមតែប៉ុណ្ណោះទេ គឺថានៅក្នុងឯកសារទាំងមូលនេះ តែម្ដងហ្នឹង។ ហើយក៏ដូចដែលខ្ញុំបានបង្ហាញនៅក្នុងឯកសារ នៅក្នុងសៀវភៅរបស់ខ្ញុំ គឺបានបញ្ជាក់រួចមកហើយថា គឺថាខាងខ្មែរគឺយើងមិនចង់ឲ្យមានភាពតានតឹងនឹងវាកើនឡើងតទៅទៀតទេ។

**ស៖** យើងមានសាក្សីមួយដែលបានពន្យល់ឈ្មោះ ឈូក រិន គាត់បានចូលនៅក្នុងការប្រយុទ្ធនៅតាមព្រំប្រទល់នេះ។ អ៊ីចឹងជម្លោះព្រំប្រទល់នេះ គឺជាបញ្ហាដែលញឹកញាប់នៅក្នុងរបបខ្មែរក្រហមនេះ។ អ៊ីចឹងយើងត្រូវយល់អ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ គឺថាមានការ -- មានសម្ពាធទាំងសងខាង ទាំងខាងខ្មែរនិងខាងវៀតណាម ហើយមានទាហានខាងកម្ពុជាប្រជាធិបតេយ្យប៉ះពាល់ទៅខាងវៀតណាម ហើយក៏មានការឈ្លានពានពីខាងវៀតណាមមកខាងខ្មែរវិញផងដែរ។ ហើយខ្ញុំចង់បន្ថែមនៅមតិមួយទៀត ខ្ញុំគិតថាមានឯកសារមួយដែលសំខាន់ផងដែរ។ លោក ខៀវ សំផន បានចូលរួមនៅក្នុងកិច្ចប្រជុំនោះ ប៉ុន្តែគាត់មិនបាននិយាយអ្វីទេអាស្រ័យទៅលើកំណត់ហេតុនៃការប្រជុំ។ ចំណែកអ្នកដទៃទៀត លើកលែងអ្នកធ្វើកំណត់ត្រា គឺគេបានបញ្ចេញមតិយោបល់។ ហើយកំណត់ហេតុហ្នឹងគឺវាត្រូវជាមួយនឹងកំណត់ហេតុគណៈអចិន្ត្រៃយ៍ដទៃទៀត។

[១៥:៤០:០០]

លើកលែងតែប្រធានបទដែលគេលើកយកមកនិយាយហ្នឹង ជាជំនាញរបស់គាត់ លោក ខៀវ សំផន គាត់មិននិយាយទេ ប៉ុន្តែចំពោះ នួន ជា គាត់តែមានមតិយោបល់។ ដូច្នេះ ខ្ញុំចង់បញ្ជាក់នៅក្នុងសវនាការនេះថា លោក ខៀវ សំផន គឺមិនមែនជាក្រុមស្នូលនៃការធ្វើការសម្រេចចិត្តនោះទេ។ ប៉ុន្តែតួនាទីរបស់គាត់ មិនដូច នួន ជា ក៏អ្នកចូលរួមសំខាន់ៗដទៃទៀតនោះទេ។

**ស៖** ចាស តាមពិតទៅ លោកឆ្លើយតបនៅនឹងសំណួរដែលខ្ញុំត្រៀមសួរហើយបាត់ទៅហើយ។ អ៊ីចឹងខ្ញុំសូមបន្តទៅនិយាយចំណុចមួយទៀត។ នៅក្នុងក្របខ័ណ្ឌនៃការពិភាក្សាប៉ុន្មានថ្ងៃនេះ គឺថាលោកបាននិយាយអំពី -- ជាមួយនឹងក្រុមមេធាវីលោក នួន ជា អំពីបញ្ហាភូមិភាគ ហើយនិងគឺថាការប្រព្រឹត្តិមិនដូចគ្នារវាងភូមិភាគទាំងអស់នោះ ហើយលោកក៏បាននិយាយផងដែរ អំពី *ប៉េកក្រោន* – និយាយពីប្រវត្តិរបស់មេភូមិភាគ។ កាលពីសភាតារបស់ខ្ញុំ បានប្រើពាក្យថា "ស្តេចត្រាញ់" ហើយលោកបានប្រើពាក្យនេះ។ ប្រើពាក្យនេះដោយសារបញ្ហាភាគច្រើន មកពីគឺថាពាក្យ ស្តេចត្រាញ់ នេះហើយ។ ហើយគាត់ថាគោលជំហរ តំណែង -- ខ្ញុំមិនដឹងថាខ្ញុំយល់ច្បាស់ ឬមិនច្បាស់ទេ ក៏ប៉ុន្តែដើម្បីបំភ្លឺត្រង់ចំណុចនេះ ខ្ញុំសូមអានផ្នែកមួយនៃសៀវភៅរបស់លោក។

[១៥:៤២:០០]

ចំពោះលោកហ្នឹង គឺទំព័រ២៨១, ERN ជាភាសាបារាំងគឺ00639817, ហើយជាភាសាអង់គ្លេសនោះគឺថា 00396489។ ខ្ញុំសូមអានយឺតៗ ព្រោះថាខ្ញុំចង់អានសម្រង់នេះតែម្តង។ ជាភាសាបារាំង គឺនៅក្រោមទំព័រមុនកថាខណ្ឌចុងក្រោយនៃទំព័រហ្នឹង គឺថាលោកសរសេរដូចតទៅនេះ៖ "បើសិនជាមេភូមិភាគសំខាន់ៗ ដូចជា រស់ ញឹម, គង់ សុផល ដែលនៅភូមិភាគពាយ័ព្យ, ពក នៅភូមិភាគឧត្តរ, ណើ សារ៉ាន់ នៅពាយ័ព្យ, សោម ភីម នៅបូព៌ា ហើយតាម៉ុក នៅនិរតី។ នេះពុំមានអ្វីគួរឲ្យឆ្ងល់នោះទេ ដែលពួកគាត់ចាប់ផ្តើមការងារជាបដិវត្តន៍នេះ តាំងពីសម័យឥស្សរៈមកម្ល៉េះ។ នៅក្នុងសម័យប្រឆាំងនឹងបារាំង ហើយពួកគេនោះ ថាគេប្តេជ្ញាចិត្ត ហើយនិងគេសាមញ្ញ ហើយនិងពួកគេមានលក្ខណៈឃោរឃៅ ហើយនិងមើលងាយដល់ជីវិតមនុស្ស ហើយគេ តាំងពី៣០ឆ្នាំមុនមកម្ល៉េះ"។ អ៊ីចឹងខុសពីរដ្ឋកុម្មុយនីស្តអ័រតូដុក ដែលសេចក្តីសម្រេចចិត្តនេះធ្វើនៅមជ្ឈិម ហើយការអនុវត្តសេចក្តីសម្រេចផ្សេងៗនោះ មានតែមនុស្សតែម្នាក់ទេ។ ហើយនៅប្រទេសកម្ពុជានៃរបបខ្មែរក្រហមនេះ គឺមិនមានវិន័យអីទេ។ ដូច្នេះការដែលមានក្រុមច្រើនៗនេះ ផ្សេងគ្នានេះ គឺជាមូលហេតុសំខាន់ណាស់ ដែលធ្វើឲ្យរបបនេះ ដួលរលំ

ដោយសារមានក្រុមច្រើនពេក ខុសគ្នា”។

[១៥:៤៤:១៣]

ទាក់ទងទៅនឹងចំណុចនេះ នៅពេលដែលលោកពន្យល់នោះ ខ្ញុំយល់ -- ដូចជាយល់ថា មានការប្រព្រឹត្តខុសគ្នាអំពីវិន័យ ការខ្វះខាត មិនគោរពវិន័យ នៅពេលដែលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ខ្ញុំហាក់ដូចជាយល់ថា លោកនិយាយតែអំពីរយៈពេលជម្លៀសចេញពីភ្នំពេញនេះទេ។ ហើយគឺថាដែលនិយាយសរុបទៅ គឺថាក្រោយមកមានការធ្វើឯកភាពគ្នា ធ្វើឱ្យមានថាច្បាប់ទម្លាប់មួយច្បាស់លាស់។ ហើយកាលពីព្រឹកមិញ នៅពេលដែលលោកនិយាយជាមួយសភាតារបស់ខ្ញុំ លោកបានពន្យល់ថា ពុំមាន -- គឺថាមិនអាចមិនគោរពវិន័យបានទេ។ ក៏ប៉ុន្តែអ្វីដែលខ្ញុំទើបនឹងអានអម្បាញ់មិញនេះ សម្រង់អំមិញនេះ ធ្វើឱ្យខ្ញុំយល់ថាប្រហែលជាមាន -- ថាមានបញ្ហាវិន័យដែលកើតមាននៅពេលជម្លៀស ហើយក្រោយមកទៀតត្រូវកែប្រែវិញ។ ហើយលោកបានលើកឡើងផងដែរថា ដោយសារតែមានការមិនគោរពវិន័យនេះហើយបានធ្វើឱ្យរបបហ្នឹងដួលរលំ។ អ៊ីចឹងលោកអាចពន្យល់ឡើងវិញបានទេ ព្រោះលោកហាក់ដូចជានិយាយថា អង្កាល់ជម្លៀសមិនគោរពវិន័យ ក្រោយមកមានគោរពវិន័យវិញ។ ហើយហេតុអីក៏និយាយថាការដែលមិនគោរពវិន័យពេលដែលជម្លៀសនេះ វាជាមូលហេតុនៃការធ្វើឱ្យរបបខ្មែរក្រហមនោះដួលរលំ?

[១៥:៤៥:៥៤]

**ឆៈ** នៅពេលដែលយើងនិយាយពីដើម គឺវាមិនស្ថិតនៅក្នុងបរិបទនៃការជោគជ័យ ទទួលជោគជ័យនៅទីក្រុងភ្នំពេញ និងនៅពេលក្រោយៗបន្ទាប់ភ្លាមនោះទេ។ គឺវានិយាយអំពីស្ថានភាពដែលកើតឡើងមុន គឺនៅពេលដើមដំបូងនៃការធ្វើសង្គ្រាមខទ្ទាមនៅក្នុងឆ្នាំ១៩៦៨។ នៅពេលនុ៎ងគឺវាពិបាកក្នុងការធ្វើឱ្យមានការស៊ីសង្វាក់ ការរួបរួមគ្នាល្អណាស់។ ប៉ុន្តែនៅក្នុងឆ្នាំ៧៣, ៧៤ ការធ្វើទំនាក់ទំនងវាប្រសើរជាងមុន ហើយវាងាយស្រួលជាងដើម្បីឱ្យមជ្ឈិមក្នុងការដាក់ចេញនូវបញ្ហានានា។

ដូច្នេះហើយមាគ៌ាមជ្ឈិមគឺត្រូវបានបញ្ជា ឬត្រូវបានបញ្ជូនទៅខាងមេដឹកនាំភូមិភាគ ហើយនិងមេដឹកនាំភូមិភាគធ្វើទៅតាមរបៀបរបស់ខ្លួន។ ហើយបញ្ហានេះវានៅបន្តរហូតទៅដល់ក្រោយឆ្នាំ៧៥ គឺក្រោយថ្ងៃមេសា ឆ្នាំ៧៥ ហើយនិងបន្តរហូតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អាចមានការលំបាកខ្លះៗនៅក្នុងការធ្វើឱ្យមានភាពស៊ីសង្វាក់គ្នានៅក្នុងការបែងចែកគោលនយោបាយនៅក្នុងទូទាំងប្រទេស។ ប្រសិនបើយើងមើលទៅលើគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ គឺថានៅតាមតំបន់ផ្សេងៗគ្នា

នោះ វាមានលក្ខណៈរួមជាទូទៅ ដែលមនុស្សទាំងអស់ត្រូវគោរពទៅតាម។ ប៉ុន្តែក្រៅពីលក្ខណៈជាមូលដ្ឋានហ្នឹងវាមានការប្រែប្រួល វាមានការខុសប្លែកគ្នាខ្លះ។

[១៥:៤៧:២៧]

បញ្ហានេះគឺវាកើតឡើងសឹងតែគ្រប់ប្រទេសកុម្មុយនីស្តទាំងអស់ ហើយវាមានកើតឡើងនៅក្នុងប្រទេសចិនផងដែរ ទោះបីជាថានៅចិនវាមានតិចតួច ចំណែកសូវៀតវាហាក់ដូចជាមិនមាន។ ប៉ុន្តែយ៉ាងណាក្តីវាមានគ្រប់ទីកន្លែងទាំងអស់នៅក្នុងប្រទេសកុម្មុយនីស្ត។

**ស៖** ក៏ប៉ុន្តែអ្វីដែលខ្ញុំបានជូនលោកអម្បាញ់មិញនេះ ខ្ញុំមានអារម្មណ៍ថា គឺថាខុសពីរបបកុម្មុយនីស្តផ្សេងៗទៀត ដែលការសម្រេចចិត្តនោះមានធ្វើនៅមជ្ឈិមទេ ហើយការអនុវត្តសេចក្តីសម្រេចចិត្តទាំងអស់ សម្រេចទាំងអស់នោះថាប្រទេសកម្ពុជាគឺថាមិនមានវិន័យទេ។ ខ្ញុំគិតថា លោកនិយាយហ្នឹងដូចថាចង់និយាយថា ប្រទេសកម្ពុជាជាករណីលើកលែងមួយដែលខុសពីរបបកុម្មុយនីស្តផ្សេងៗ ដែលលោកបានស្គាល់ពីមុនមក។ អ៊ីចឹងដល់ឥឡូវនេះខ្ញុំស្តាប់ទៅហាក់ដូចជាលោកថា ដូចគ្នាទៅវិញ។ ក៏ប៉ុន្តែយ៉ាងណាក្នុងផ្នែកដែលខ្ញុំអានជូនអម្បាញ់មិញនេះ មើលទៅឃើញថាហាក់ដូចនៅក្រោមរបបកុម្មុយនីស្តខ្មែរហ្នឹងគឺថាមើលទៅអត់មានគោរពវិន័យ វាខុសពីកន្លែងផ្សេង។ អ៊ីចឹងខ្ញុំយល់នេះខុស ឬក៏ត្រូវសូមលោកបញ្ជាក់?

[១៥:៤៨:៤៤]

**ឆ៖** ខ្ញុំគិតថា យើងអាចនិយាយថាកម្ពុជាប្រជាធិបតេយ្យគឺមានលក្ខណៈ លក្ខណៈប្លែកពីគេនៅក្នុងករណីជាច្រើន។ វាអាចមានកម្រិតនៃការមិនគោរពច្បាប់ទម្លាប់ ដូចដែលខ្ញុំនិយាយគឺវាអាចថាប្លែកពីប្រទេសដែលកាន់បែបម៉ាក្ស-ឡេនីន ឬក៏បែបម៉ៅនិយមនោះដែរ។

**ស៖** កាលពីម្សិលមិញនៅពេលដែលបញ្ហាដែលថា បង្អត់អាហារដើម្បីគ្រប់គ្រងអំណាច កាន់អំណាចនេះ លោកបាននិយាយថា -- លោកពន្យល់ថា ប៉ុល ពត នោះមិនចង់ឲ្យបង្អត់អាហារប្រជាជនទេ ព្រោះថាដើម្បីដើម្បីអភិវឌ្ឍនោះត្រូវឲ្យប្រជាជនមានសុខភាពល្អ មានអាហារហូបចុកគ្រប់គ្រាន់។ ក៏ប៉ុន្តែថ្នាក់មូលដ្ឋានវិញ គឺជាមធ្យោបាយក្នុងការគំនាបទៅលើប្រជាជន។ អ៊ីចឹងបើសិន -- តើខ្ញុំអាចសង្ខេបបានដែរឬទេថា ឬទាញការសន្និដ្ឋានបានដែរឬទេថាវាជាការលំបាកណាស់ក្នុងការថា និយាយថាមានគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាចង់បង្អត់អាហារប្រជាជនឯងនោះ?

[១៥:៥០:១៤]

**ឆ៖** ខ្ញុំនឹងនិយាយដដែលៗ គឺថាមិនមានគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដើម្បីបង្អត់អាហារប្រជាជនកម្ពុជាទេ។ គឺពិតជាមិនមានគោលនយោបាយបែបនេះមែន។ គោលនយោបាយគឺថាកម្ពុជាចង់ឲ្យមានប្រជាជនកាន់តែច្រើន ហើយតាមពិតទៅការរៀបការដោយបង្ខំ ហើយគេធ្វើឡើងនៅមូលដ្ឋាន គឺថាប្តីប្រពន្ធដែលរៀបការត្រូវមានកូន។ គឺធ្វើដូច្នេះដើម្បីឲ្យប្រជាជនកម្ពុជាកាន់តែកើនឡើង ហើយធ្វើឲ្យកម្ពុជាកាន់តែមានប្រជាជនឡើងច្រើនជាងមុន ហើយមានផលិតភាពកាន់តែខ្ពស់។ ប៉ុន្តែបញ្ហាវាកើតឡើង គឺកើតឡើងនៅពេលដែលមន្ត្រី ឬក៏កម្មាភិបាលថ្នាក់ក្រោមដែលអត់មានការចេះដឹង ដែលល្ងង់ខ្លៅហ្នឹង គឺបង្ខំឲ្យប្រជាជនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកគេហ្នឹងឲ្យចេញទៅធ្វើការរយៈពេលយូរនៅតាមវាល។ ហើយនៅពេលហ្នឹងហើយ ទើបធ្វើឲ្យមានបញ្ហាកើតឡើង។ ហេតុដូច្នេះហើយនៅពេលចុងក្រោយហ្នឹង គឺគេបានប្រើប្រាស់ការអត់ឃ្លានហ្នឹងធ្វើជាមធ្យោបាយមួយដើម្បីគ្រប់គ្រងទៅលើប្រជាជននៅមូលដ្ឋានតែម្តង។ ដូច្នេះវាផ្ទុយ។

[១៥:៥១:៤៥]

**ស៖** ចាស និយាយអំពីភាពផ្ទុយគ្នារវាងសេចក្តីណែនាំពីមជ្ឈិម និងការអនុវត្តនូវមូលដ្ឋាន។ ខ្ញុំសូមអានសម្រង់មួយជូនលោក។ គឺជាចម្លើយរបស់សាក្សីមួយដែលបានមកផ្តល់សក្ខីកម្មនៅទីនេះ។ គាត់ឈ្មោះ មាស វឿន។ ខ្ញុំសូមរយៈពេលបន្តិចដើម្បីរកឯកសារនេះឲ្យឃើញ។ គឺជាឯកសារចុះថ្ងៃទី០៤ តុលា ឆ្នាំ២០១២, ឯកសារ E1/130.1, ERN ជាភាសាបារាំងគឺ 00533455, ERN ជាភាសាអង់គ្លេសគឺ 0085343, ERN ជាភាសាខ្មែរគឺ 00851151។ ខ្ញុំសូមពន្យល់បរិបទលោក គឺជាសាក្សីដែលជាទាហានដែលបានឆ្លើយថា គាត់ត្រូវបានកោះហៅដោយប៉ុល ពត ដើម្បីចូលរួមប្រជុំនៅវត្តឧណ្ណាលោម។ ហើយដែលនៅទីនោះ គាត់ត្រូវបានទទួលសេចក្តីណែនាំមួយចំនួន។ គាត់បាននិយាយអំពី រៀបរាប់ពី ប៉ុល ពត ប្រាប់គាត់។

"សំណួរគឺថានៅពេលកិច្ចប្រជុំនោះ តើលោកធ្លាប់បានទទួលបទបញ្ជាទាក់ទងទៅនឹងការជម្លៀសបញ្ជូនលោកទៅព្រះវិហារដែរឬទេ? ឆ្លើយវិញ៖ បាទមុននឹងខ្ញុំទៅព្រះវិហារហ្នឹង គាត់បានបញ្ជាក់អំពីទី១ ពីសភាពការណ៍ព្រំដែនខាងកើត ហើយទី២ គាត់បញ្ជាក់អំពីសកម្មភាពប្រជាជននៅខេត្តព្រះវិហារដែលមានការចាប់ចង ហើយនិងអ្នកដែលអត់បាយ។ ទី៣ គឺប្រជាជននៅសៀមរាបនោះមានការចាប់ដាក់គុកដែរ។ សំណួរ៖ តើគេដាក់ភារកិច្ចអ្វីឲ្យលោកធ្វើនៅពេលដែលលោកទៅព្រះវិហារនោះ? ចម្លើយ៖ ជាដំបូងគឺគេឲ្យ បងសឿង ទៅសៀមរាបដើម្បីរៀបចំស្រាវជ្រាវមើលការចាប់ប្រជាជនដាក់គុកនៅ

កន្លែងនោះ។ ការងារខ្ញុំនៅព្រះវិហារ គឺថាស៊ើបមើល តើគេចាប់ប្រជាជនមែនឬក៏អត់ ហើយៗលើសពីហ្នឹងទៀត ខ្ញុំក៏ទទួលបន្ទុកក្នុងការផ្ញើ ឬក៏បញ្ជូនរបស់របរទៅព្រះវិហារផងដែរ ហើយនិងយកប្រជាជននៅកន្លែងនោះ។ តើបានរបស់ទាំងអស់នោះ ដល់ដៃប្រជាជនដែរឬក៏អត់?" -- បើតាមចម្លើយរបស់សាក្សីនេះ គឺថាលោក មាស វឿន នេះ : ប៉ុល ពត សុំទៅ -- សូមឲ្យទៅមើលកន្លែងនោះ ព្រោះថាគាត់ប្រហែលជាឮថានៅទីនោះមានរឿងអីកើតឡើង។ អ៊ីចឹងគាត់ចង់ដឹងថារឿងហ្នឹងវាយ៉ាងម៉េច។

តើឧទាហរណ៍នេះ ដែលខ្ញុំលើកឲ្យអម្បាញ់មិញនេះ មិនឆ្លុះបញ្ចាំងអំពីភាពខុសគ្នានៅរវាងភូមិភាគដែរឬទេ? ព្រោះថាចំពោះមជ្ឈិមនោះមិនជាការងាយស្រួលទេក្នុងការដឹងថាតើនៅភូមិភាគណាមានរឿងអីកើតឡើងនោះ?

[១៥:៥៦:៣០]

**ឆះ** ខ្ញុំមិនគិតថាវាមានអ្វីប្លែកនោះទេ។ ខ្ញុំគិតថាវាគ្រាន់តែបង្ហាញនូវចេតនារបស់ខាងមជ្ឈិមដែលចង់ថាមានអ្វីកើតឡើងនៅតាមភូមិភាគប៉ុណ្ណោះ។ ការពិតទៅ ការបង្ហាញនេះវាហាក់ដូចជាការខ្វះនូវការទំនាក់ទំនងនៅក្នុងកុម្មុយនីស្ត អ័រតូដុក គឺថាមិនមានការរាយការណ៍ទៅដល់ពួកគាត់ប៉ុណ្ណោះ។ ប៉ុន្តែខ្ញុំគិតថាវាមិនមែនជារឿងចម្លែកនោះទេដែលថាមេដឹកនាំបញ្ជូននូវបេសកជនម្នាក់ឲ្យចុះធ្វើការស៊ើបអង្កេត ដូចដែលខ្ញុំបាននិយាយពីដើមអ៊ីចឹង គឺគេបញ្ជូន ខៀវ សំផន ឲ្យចុះបំពេញបេសកកម្មសំខាន់ៗនៅតាមខេត្ត។ ខ្ញុំគិតថានេះជាការដែល ប៉ុល ពត តែងតែអនុវត្តជាក់ស្តែង។

**សះ** បើសិនជាខ្ញុំមិននិយាយទៅដូចជ្រុលទេ គឺថានៅពេលដែលយើងនិយាយអំពីថាបេសកកម្មសំខាន់ៗ ហើយនិងការផ្លាស់ទីទៅ ខៀវ សំផន នៅតាមខេត្តរបស់ ខៀវ សំផន នោះ លោកមិនមានឧទាហរណ៍ជាក់លាក់ទេ។ បើអ៊ីចឹងបានន័យថាលោកធ្វើការសន្មតទេ។ តើអ៊ីចឹងមែនទេ?

[១៥:៥៧:៤៧]

**ឆះ** មិនមែនទេ វាមិនមែនជាការស្មានសន្មតនោះទេ។ ខ្ញុំព្យាយាមបង្ហាញតាមដែលខ្ញុំអាចធ្វើទៅបានក្នុងការកំណត់លក្ខណៈទាំងអស់នេះ។ នៅពេលដែល ប៉ុល ពត នៅរតនគិរី គាត់បញ្ជូនប្រពន្ធរបស់គាត់គឺ ខៀវ ប៉ុណ្ណារី – នៅពេលហ្នឹង ខៀវ ប៉ុណ្ណារី នៅមានសុខភាពល្អទេ ឲ្យចុះធ្វើការស៊ើបអង្កេតនៅតាមខេត្ត។ នេះគឺជាវិធីដែលគេតែងតែប្រតិបត្តិនៅពេលកន្លងមកនោះ។

**សះ** តើលោកដឹងទេថា ខៀវ សំផន ទំនងជាបានទៅខេត្តណាខ្លះ តាមបញ្ជារបស់លោក ប៉ុល ពត នេះ? ហើយលោកបានទទួលព័ត៌មានដែលថាលោក ខៀវ សំផន ចុះទៅតាមខេត្តនេះពីអ្នកណាដែរ?

**ឆ៖** ខ្ញុំគិតថាយើងបានពិភាក្សាបញ្ហានេះពីព្រឹករួចមកហើយ ហើយខ្ញុំបានប្រាប់ពីប្រភពព័ត៌មានរបស់ខ្ញុំ គឺលោក ស្វង ស៊ីគឿន ហើយខ្ញុំបានពិភាក្សាថាជាមួយ ភី ភួន ប៉ុន្តែខ្ញុំអាចថាមិនចាំ។ ដូច្នេះខ្ញុំបញ្ជាក់ឡើងវិញ ខ្ញុំមិនថាច្បាស់ថាគាត់និយាយអ្វីនោះទេ។ ហើយចំពោះបញ្ហាថាតើ ខៀវ សំផន រាយការណ៍មកវិញនោះ គឺ ឌុច ជាអ្នកប្រាប់។ នេះជាប្រភពព័ត៌មានរបស់ខ្ញុំ។

**ស៖** លោកបានស្តាប់សក្ខីកម្ម ឌុច ដែលលោកបាន គឺថាស្តាប់ជាខ្សែអាត់សំឡេង មែនទេ សក្ខីកម្មហ្នឹងលោកបានស្តាប់ជាខ្សែអាត់សំឡេង ឬមួយក៏យ៉ាងម៉េច?

[១៥:៥៩:២៣]

**ឆ៖** ខ្ញុំប្រើប្រាស់ពាក្យខុស ដែលថាសក្ខីកម្ម ប៉ុន្តែខ្ញុំចង់និយាយថា ឌុច បានផ្តល់ការសម្ភាសជាច្រើនមុនពេលគេចាប់ខ្លួន។ គឺថានៅពេលដែលគេពុម្ពសៀវភៅនិយាយអំពីគាត់នោះ។ ហើយខ្ញុំទទួលបាននូវប្រតិចារឹកទាំងស្រុងដែលជាប្រតិចារឹកកិច្ចការសម្ភាសទាំងស្រុងជាមួយនឹង ឌុច។ ហើយដោយសារតែប្រតិចារឹកហ្នឹង ដែលខ្ញុំទទួលបានជាប្រភពព័ត៌មានសម្រាប់ខ្ញុំដែលថា ឌុច និយាយពីបញ្ហានេះ។

**ស៖** ខ្ញុំយល់ព្រមអាចទទួលយកបាន។ ឥឡូវខ្ញុំសូមបន្តទៅមុខទៀត ខ្ញុំសួរលោកជិតចប់ហើយ ព្រោះ ថាបន្ទាប់មកទៀត គឺថាសហភាតារបស់ខ្ញុំលោក គង់ សំអុន នឹងមានសំណួរខ្លះដែរ។ ក្នុងការប្រកាន់ជំហរជាសាធារណៈដែលលោកបានប្រកាន់យកនៅក្នុងក្របខ័ណ្ឌកម្ពុជាប្រជាធិបតេយ្យ។ យើងបានដាក់ជូនលោកនូវឯកសារពីរដុំ។ ឯកសារនោះរបស់ឯកសារភ្នំពេញប៉ុស្តិ៍ អត្ថបទភ្នំពេញប៉ុស្តិ៍លេខ 9/23 ចុះថ្ងៃទី១០ ដល់២៣ វិច្ឆិកាឆ្នាំ២០០០។ ឯកសារ ERN គឺថា 00842099, E226/1.1.1។ នៅក្នុងអត្ថបទកាសែតនេះជាវេទិកាបញ្ចេញមតិថា "មេធាវីបិសាចមិនត្រូវមានការជម្រះសេចក្តីខ្មែរក្រហមទេ"។

[១៦:០១:៥៣]

ខ្ញុំសូមលើកយកសម្រង់មួយ ERN ជាភាសាអង់គ្លេស ខ្ញុំមិនជឿថាមានការបកប្រែជាភាសាខ្មែរទេ។ ប៉ុន្តែ ERN ជាភាសាអង់គ្លេសគឺ 00839943 លោកបាននិយាយដូចតទៅនេះ, សម្រង់នេះវែងណាស់ខ្ញុំសូមឲ្យលោកធ្វើការអត្ថាធិប្បាយ : កុំឲ្យតុលាការអន្តរជាតិនេះកើតឡើងដើម្បីកាត់ទោសខ្មែរក្រហម។ អ្នកមេដឹកនាំខ្មែរក្រហម ហើយក៏មិនមែនជាយុត្តិធម៌នោះទេ គ្រាន់តែជាការសងសឹកតែប៉ុណ្ណោះ ហើយដើម្បីបំពេញចិត្តរដ្ឋបាលយូអិនតែប៉ុណ្ណោះ ហើយក៏គ្រាន់តែជានយោបាយរបស់សហរដ្ឋអាមេរិកតែប៉ុណ្ណោះឯង។ សំណួរទី១ នេះជាគោលជំហររបស់លោកដែលថារឹងប៉ឹងណាស់។ អ៊ីចឹងខ្ញុំ

សួរថាតើលោកសរសេរអត្ថបទបញ្ចេញមតិនេះនៅក្នុងបរិបទអ្វីដែរ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

តំណាងសហព្រះរាជអាជ្ញាសូមជម្រាបថាសំណើដែលមេធាវីការពារនោះសុំពេលច្រើន។ ប៉ុន្តែគាត់សួរក្រៅបរិបទវិសាលភាពហួសពីជំនាញរបស់លោក ហ្វីលីព ស្សូត ទាក់ទងនឹងប្រធានបទដែលត្រូវសួរដេញដោលនៅពេលនេះ។ ជាពិសេសមិនមែនជាបញ្ហា ដែលថាគាត់ជាអ្នកជំនាញទៅលើបញ្ហាអ្វីដែលមេធាវីសួរនោះទេ។ ហើយតុលាការបង្គាប់ឲ្យអនុញ្ញាតឲ្យសួរ -- ឲ្យគាត់ឆ្លើយនោះទេ ហើយសុំឲ្យមេធាវីមេត្តាបង្គាប់ឲ្យមេធាវីហ្នឹងសួរសំណួរផ្សេង។

[១៦:០៣:៤០]

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំសូមឆ្លើយតបដោយសង្ខេបលោកប្រធាន។ ខ្ញុំសូមប្រាប់ថា គឺជាឯកសារដែលយើងបានសុំដាក់បញ្ចូលជាភស្តុតាងនៅក្នុងក្របខ័ណ្ឌនៃការផ្តល់សក្ខីកម្មរបស់លោក ហ្វីលីព ស្សូត ហើយៗ។ ខ្ញុំមិនមានលេខស្នើសុំទេ គ្រាន់តែខ្ញុំអាចផ្តល់លេខនេះបាន។ ហើយតុលាការបានអនុញ្ញាតហើយ។ ជាការសំខាន់ណាស់ដែលរំឭកថាសាក្សីលោក ហ្វីលីព ស្សូត មិនមែនជាសាក្សីសាមញ្ញទេ។ អ៊ីចឹងយើងអាចសួរគាត់ពីយោបល់របស់គាត់ក្នុងរយៈពេលបីបួនថ្ងៃនេះគឺជាចំណុចសំខាន់មែនទែន ចង់បង្ហាញ-- អានេះអាចបង្ហាញពីឯករាជ្យភាពរបស់គាត់ ហើយនិងសិទ្ធិបញ្ចេញមតិរបស់គាត់។

អ៊ីចឹងនៅក្នុងសេចក្តី សម្រេចរបស់តុលាការ អ៊ីចឹងលោកចៅក្រមអាចពិចារណាអំពីគោលជំហររបស់គាត់ទាក់ទងនឹងការជម្រះសេចក្តីនេះដែលគាត់មកធ្វើជាសាក្សីនេះ។ អ៊ីចឹងខ្ញុំគិតថាមិនមែនជាបញ្ហាអ្វីនោះទេ។ ផ្ទុយទៅវិញ វាថាអត្ថបទនេះវាថែមទាំងបានទទួលយកដោយចៅក្រមផងដែរ។ ហើយយើងបានដាក់សំណើរួចទៅហើយ។

[១៦:០៥:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៥:២៧]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ សំអាងហេតុនៃសេចក្តីរបស់តំណាងសហព្រះរាជអាជ្ញាក្នុងការតាំងសំណួរចុងក្រោយរបស់មេធាវីការពារក្តី ខៀវ សំផន ចំពោះអ្នកជំនាញ ជាសេចក្តីជំទាស់មានមូលហេតុសមស្រប ដោយសារសំណួរនេះមិនពាក់ព័ន្ធជាមួយនឹងភាពជំនាញរបស់អ្នកជំនាញរូបនេះទេ។ ដូច្នេះសាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយមេធាវីការពារក្តីលោក ខៀវ សំផន ដែលបានសួរលោកចុងក្រោយនេះទេ។ លោកស្រីមេធាវីអាចបន្តសំណួរថ្មីទៀត។

**កញ្ញា អង់តា ហ្គីសសេ៖**

ចាស គួរឲ្យសោកស្តាយណាស់លោកប្រធាន។ អ៊ីចឹងខ្ញុំសូមបន្តទៅមុខទៀត។

[១៦:០៦:១៥]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** នៅក្នុងឯកសារមួយដែលតុលាការបានទទួលយកជាភស្តុតាងដែរ គឺឯកសារ E271.2 គឺជាកិច្ចសម្ភាសន៍ដែលលោក ហ្វីលីព ស្សូត បានផ្តល់ជូន -- ធ្វើជាមួយនឹងភ្នំពេញប៉ុស្តិ៍ ថ្ងៃទី០៧ មីនា ឆ្នាំ២០១៣ ដែលលោកអង្កាល់ណោះលោកបានមកភ្នំពេញនេះ គ្រោងថាមកផ្តល់សក្ខីកម្មលើកទី១ទាក់ទងទៅនឹងស្ថានភាពសុខភាពសុខភាពរបស់ អៀង សារី -- ដោយសារ អៀង សារី មានបញ្ហាសុខភាពក៏លោកខកខានមិនបានផ្តល់សក្ខីកម្មទៅ។ លោកបានឆ្លើយថា កាលណោះ -- សូមឲ្យលេខ ERN សិន, ERN ជាភាសាបារាំងគឺ 00894870 និង 00894302។ ខ្ញុំសូមដកស្រង់កថាខណ្ឌមួយដែលលោកអ្នកជំនាញបាននិយាយអំពីករណីប្រទេសរវ៉ាន់ដា ហើយលោកបានប្រៀបធៀបនឹងករណីប្រទេសខ្មែរយើងនេះ ឬក៏ជាមួយនឹងគេហៅថា “យន្តការផ្សះផ្សាជាតិ”។

[១៦:០៧:៥៣]

ខ្ញុំភ្លេចលេខ ERN ជាភាសាអង់គ្លេសបាត់ហើយ។ ខ្ញុំអានម្តងទៀត 00894302 លោកបាននិយាយថា “នៅប្រទេសរវ៉ាន់ដា ដែលប្រទេស ដែលថាមានការស្អប់គ្នាយ៉ាងជ្រាលជ្រៅក្នុងរយៈពេលយូរជាង បញ្ហាខ្មែរក្រហម ហើយដោយសារការស្អប់ខ្ពើបគ្នាជាជាតិពន្ធុជាមូលដ្ឋាន ពួកគេមានដំណើរការនៃការផ្សះផ្សាគ្នា ហើយដំណើរការនេះទទួលបានជោគជ័យ។ មានទម្រង់នៃការជម្រះតាមបែបសហគមន៍ តាមភូមិ ក៏ប៉ុន្តែគ្រប់គ្នាមិនគ្រាន់តែបុគ្គលពីរបីនាក់ជានិមិត្តរូបប៉ុណ្ណោះទេ។ តែគ្រប់ៗគ្នាត្រូវបង្ខំចិត្តទទួលដំណើរការនេះ ហើយលទ្ធផលគឺមិនបានទទួលអ្វីដែលមាននៅក្នុងប្រទេសកម្ពុជានោះ

ទេ គឺជាកន្លែងដែល ខៀវ សំផន, អៀង សារី, នួន ជា ជាអ្នកជាប់នៅតុលាការ និងអ្នកផ្សេងទៀតដែលបានធ្វើការកាប់សម្លាប់ក្នុងរបបខ្មែរក្រហម"។ ជាមួយ -- លោកបាននិយាយទៅកាន់សហព្រះរាជអាជ្ញានៅក្នុងខ្សែវីដេអូមួយ ខ្ញុំភ្លេចហើយប្រតិចារឹក។ លោកបាននិយាយថា លោកថា " ត្រូវនិយាយអំពីទំនួលខុសត្រូវបញ្ញវន្ត ហើយនិងលោកនិយាយពីកម្មាភិបាលមូលដ្ឋាន តាមភូមិភាគ តាមតំបន់"។ អ៊ីចឹងលោកចង់និយាយថា យើងត្រូវតែនិយាយអំពីទំនួលខុសត្រូវ តើខ្ញុំ -- ម្សិលមិញនេះ លោកនិយាយនៅក្នុងខ្សែអាត់វីដេអូ ដែលលោកបាននិយាយក្នុងក្របខ័ណ្ឌសន្និសីទមួយនៅសាកលវិទ្យាល័យមួយ តើខ្លឹមសារនៅក្នុងនុ៎ង ហើយនិងអ្វីដែលខ្ញុំអាននេះមានទិសដៅដូចគ្នា ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

លោកអ្នកជំនាញកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១៦:១០:០០]

**លោក អាប់ឌុលឡាក់ ថារីក៖**

តុលាការជាទីគោរព! សំណួរនេះ គឺមិនទាក់ទងអ្វីទាល់តែសោះ ទៅនឹងបញ្ហាដែលយើងកំពុងដេញដោល និយាយអំពីយន្តការនៃយុត្តិធម៌អន្តរកាលប្រទេសរវ៉ាន់ដា និងប្រទេសផ្សេងនោះ គឺថាគឺមិនពាក់ព័ន្ធនឹងគោលបំណងនៃវិសាលភាព និងអង្គជំនុំ -- និងសវនាការសម្រាប់ពេលនេះទេ។ ខ្ញុំសូមជំទាស់។

**កញ្ញា អង់តា ហ្គីសសេ៖**

ឥឡូវនេះ ខ្ញុំចូលដល់ចប់ហើយ។ ខ្ញុំនិយាយដូចសហព្រះរាជអាជ្ញានិយាយម្សិលមិញអ៊ីចឹង ថាបើសិនជាសហព្រះរាជអាជ្ញាអាចនិយាយបានពីសន្និសីទហ្នឹង ហើយឥឡូវនេះ ខ្ញុំក៏ដកស្រង់ខ្លឹមសារនៅក្នុងសន្និសីទ ហើយនិងទៅតាមចម្លើយរបស់គាត់នៅភ្នំពេញប៉ុស្តិ៍នេះ ហើយឃើញលោកអ្នកជំនាញនេះគាត់ងក់ក្បាលទៀតផង។ ដល់អ៊ីចឹងហើយ ខ្ញុំមិនយល់ថាហេតុអីបានខ្ញុំសួរទាក់ទងទៅនឹងការសន្និដ្ឋានរបស់គាត់ទូទៅ ដែលគាត់និយាយទាក់ទងថាត្រូវកាត់ទោសអ្នកណា? ហើយអ្នកណាទទួលខុសត្រូវ នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យនោះ? ខ្ញុំមិនយល់ថា ហេតុអីក៏ខ្ញុំពុំមានសិទ្ធិចោទសំណួរនេះ។ ពីព្រោះថានេះមានសារៈសំខាន់ណាស់សម្រាប់តុលាការក្នុងការវាយតម្លៃការងាររបស់អ្នកជំនាញនេះ ហើយក៏សំខាន់ដែរព្រោះថាវាចោទបញ្ហា គេហៅថា យើងនិយាយអំពីទំនួលខុសត្រូវនៅក្នុងការកាត់ក្តី យើងត្រូវគិតអំពីការទទួលខុសត្រូវ។ អ៊ីចឹងអង្គជំនុំជម្រះគួរតែអនុញ្ញាតឲ្យអ្នកជំនាញនេះ ឆ្លើយតបនឹងសំណួរខ្ញុំ

ហើយខ្ញុំសូមបញ្ចប់ពេលដែលគាត់ឆ្លើយហើយ។

[១៦:១១:៤២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:១១:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់សហព្រះរាជអាជ្ញា សមស្រប ពីព្រោះជាសំណួរមិនពាក់ព័ន្ធ។ អ្នកជំនាញមិនបាច់ឆ្លើយតបទៅនឹងសំណួរចុងក្រោយ ដែលសួរឡើង ដោយមេធាវីការពារក្តីលោក ខៀវ សំផន ទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

ដោយសារបញ្ចប់ទៅ យើងស្ថិតនៅក្នុង គេហៅថាលទ្ធផលមួយដែលអវត្តមាន។ អ៊ីចឹងខ្ញុំសូម បញ្ចប់ត្រង់ចំណុចអវត្តមាននេះ ហើយសូមអរគុណដល់លោកអ្នកជំនាញផងដែរ។

[១៦:១២:២៩]

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមជម្រាបសួរលោក ហ្វីលីព ស្ប៊ត។ ខ្ញុំ គង់ សំអុន ជាមេធាវីជាតិការពារលោក ខៀវ សំផន។ ហើយតទៅនេះ ខ្ញុំមានសំណួរបន្តិចបន្តួចសម្រាប់សួរបញ្ជាក់បន្ថែម ទៅលើការផ្តល់ សក្ខីកម្មរបស់លោកនៅពេលនេះ។ ចំណុចទីមួយ ខ្ញុំសូមសួរបញ្ជាក់លោកចំពោះចម្លើយរបស់លោក ដែលបានឆ្លើយកាលពីថ្ងៃទី០៦ ខែឧសភា កន្លងទៅនេះ ត្រង់ក្រោមម៉ោង ០៩:៥១:៥៨ បន្តិច នៅពេល ដែលលោកស្រីចៅក្រម ខាតវ៉ាយថ៍ សួរទាក់ទងទៅនឹងលោក ភី ភួន។ នៅក្នុង -- ខ្ញុំសូមអានជូននូវ ចំណុចនេះ ដែលក្នុងចម្លើយរបស់លោក លោកបានឆ្លើយថា “មានឯកសារយោង គឺចម្លើយសារភាព ដែលមជ្ឈមណ្ឌលមាននៅបណ្ណាល័យមជ្ឈមណ្ឌលឯកសារកម្ពុជា -- បណ្ណសារមជ្ឈមណ្ឌលឯកសារ កម្ពុជា។ ការចងចាំរបស់ខ្ញុំ គឺថាមានឯកសារយោងបី ឬបួន ទៅលើកិច្ចប្រជុំរបស់គណៈមជ្ឈិម ដែល -- (សូមទោស នៅឆ្នាំ១៩៧៣) ហើយខ្ញុំក៏បានទទួលបានព័ត៌មានពីការសម្ភាសជាមួយ ភី ភួន ដែលមាន វត្តមានស្ទើតែនៅគ្រប់កិច្ចប្រជុំរបស់គណៈមជ្ឈិម គឺនៅអំឡុងឆ្នាំ៧៣, ៧៤ និង៧៥ នៅក្នុងរយៈពេល ៣ឆ្នាំនេះ”។

[១៦:១៤:២០]

សំណួររបស់ខ្ញុំ នៅទីនេះ ខ្ញុំចង់សួរថា តើការប្រជុំដែលលោក ភី ភួន លើកថាជាការប្រជុំរបស់គណៈមជ្ឈិម ហើយដែលលោកយកមកបង្ហាញកាលពីថ្ងៃទី០៦នេះ។ វាជាការប្រជុំរបស់មជ្ឈិម ឬមួយក៏ជាការប្រជុំរបស់គណៈអចិន្ត្រៃយ៍? សូមលោកជួយបញ្ជាក់។

**លោក ហ្វីលីព ស្មូត៖**

**ឆ៖** គឺថាមានការច្រឡំខ្លះតាមដែលខ្ញុំនឹកឃើញអំពីការឆ្លើយឆ្លងនិយាយគ្នានោះ ពីព្រោះថាមានការពិភាក្សា អាចនឹងឆ្នាំ១៩៧៤ គឺប្រជុំគណៈមជ្ឈិមនោះ ខ្ញុំនិយាយថា នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៤ ហើយតែតាមពិតមេធាវីម្នាក់បានបង្ហាញទង់បដិវត្តមួយដែលបង្ហាញថានៅក្នុងខែទី៦ ឆ្នាំ១៩៧៤ គឺមិនមែន៧៣ទេ -- ឆ្នាំ១៩៧៣ទេ។ ដូច្នេះតាមអ្វីដែលខ្ញុំដឹង ខ្ញុំមិននឹកឃើញឲ្យច្បាស់ថាមានកិច្ចប្រជុំរបស់គណៈមជ្ឈិមនៅឆ្នាំ១៩៧៣ គឺថាអាចមានឆ្នាំ១៩៧២ និង៧៤។ ប៉ុន្តែ៧៣ ដូចជាខ្ញុំនឹកមិនឃើញច្បាស់ថាមិនមានទេ។

**ស៖** សំណួររបស់ខ្ញុំវិញ ថាតើមានការច្រឡំគ្នាជាមួយនឹងពាក្យថា "ប្រជុំមជ្ឈិម" ឬក៏ជាមួយនឹងពាក្យថា "ប្រជុំគណៈអចិន្ត្រៃយ៍" ដែរឬទេ? លោកអាចបញ្ជាក់។

[១៦:១៦:០៣]

**ឆ៖** គឺជាកិច្ចប្រជុំរបស់គណៈមជ្ឈិម។

**ស៖** បាទ សូមអរគុណ។ លោកមានសួរលោក ភី ភួន ទេថានៅពេលដែលគណៈមជ្ឈិមប្រជុំនៅពេលនោះ លោក ភី ភួន ស្ថិតនៅទីកន្លែងណា?

**ឆ៖** គាត់មានវត្តមាននៅភូមិមួយឈ្មោះថា មាឃ គាត់នៅទីនោះ។ គាត់មិនមែនជាសមាជិកនៃការពិភាក្សាទេ ដោយសារគាត់មិនមែនសមាជិកគណៈមជ្ឈិម គាត់ជាជំនួយការ ហើយនិងជាអង្គរក្សអ្នកការពារឲ្យ ប៉ុល ពត ហើយគាត់នៅទីនោះ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំជឿថាលោកយល់អំពីកិច្ចការសម្ងាត់ក្នុងការប្រជុំមជ្ឈិមរបស់ពួកខ្មែរក្រហមនៅពេលនោះ។ អ៊ីចឹងខ្ញុំសូមសួរលោកបន្ថែមថា តើ ភី ភួន បានទទួលព័ត៌មានហ្នឹងដោយរបៀបណា? ហើយសួរថាតើវាមានគម្លាតនៃការយាមកាមរបស់លោក ភី ភួន ក្នុងឋានៈដែលជាអ្នករក្សាសន្តិសុខនៅពេលនោះ ថាត្រូវឃ្លាតពីកន្លែងប្រជុំប៉ុនណា? ឬមួយក៏លោក ភី ភួន ហ្នឹងអាចមកចូលរួមស្តាប់ លបស្តាប់នៅក្នុងអង្គប្រជុំនោះបាន?

[១៦:១៧:៤១]

**ឆ៖** ជានីរសារ ឬក៏អង្គរក្សចារ៉ាយហ្នឹង គឺជាមនុស្សដែលគេទុកចិត្តខ្លាំងណាស់ពីថ្នាក់ដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ។ ពួកគេអាចចូលទៅដល់កន្លែងកៀកអ្នកដែលថ្នាក់ខ្ពស់ផ្សេងទៀតមិនអាចទៅជិតអ្នកដឹកនាំនោះបាន។ ខ្ញុំគិតថា ភី ភួន គឺមិនប្រជុំនៅជាមួយគ្នានឹងសមាជិកគណៈមជ្ឈិមក៏ដោយ ប៉ុន្តែគាត់អាចទទួលបានព័ត៌មានដែលបានពិភាក្សាហ្នឹង គាត់អាចបានដឹង។ គឺថាក្រុមជនជាតិចារ៉ាយដូច ភី ភួន នេះគឺគេមានបុព្វសិទ្ធិណាស់ក្នុងសម័យនោះ ដោយសារគេមានឋានៈបែបនោះ។

**ស៖** លោកអាចបញ្ជាក់ពីឋានៈរបស់លោក ភី ភួន នៅឆ្នាំ១៩៧៤ នោះបានទេ?

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១៦:១៨:៤៨]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំគប្បីតែជំទាស់ពីមុន គឺថាខ្ញុំជំទាស់ពេលនេះ គឺថាសំណួររបស់លោកមេធាវីការពារហ្នឹងគឺថា ច្រំដែល ហើយគាត់ស្នើពេលបន្ថែម ប៉ុន្តែគាត់សួរសំណួរច្រំដែល។ ហើយគាត់បានពន្យល់ពីបញ្ហាមួយចំនួនច្រើនហើយ។ ឥឡូវនេះគាត់ត្រឡប់មកសួរសំណួរដដែល ហើយសួរសំណួរដដែលៗ ម្តងហើយម្តងទៀតនោះ។

**លោក គង់ សំអុន៖**

សូមឆ្លើយតបទៅនឹងតំណាងសហព្រះរាជអាជ្ញា។ សំណួរនេះមិនមែនជាសំណួរច្រំដែលទេ ហើយម្យ៉ាងដោយសារចម្លើយរបស់អ្នកជំនាញនៅពេលមុននោះ គាត់បាននិយាយសរុបថា ភី ភួន គាត់មានតួនាទីពីអ្នកយាម ពីនីរសាររបស់ ប៉ុល ពត រហូតមកដល់ជាមេកងសន្តិសុខនៅក្រសួងការបរទេស។ ដូច្នេះវាមានការសរុបមួយ មិនមានការភាពច្បាស់លាស់ទេ ហើយខ្ញុំសួរបញ្ជាក់ទៅលើពេលវេលាជាក់លាក់ គឺឆ្នាំ១៩៧៤។ សូមឲ្យលោកអ្នកជំនាញឆ្លើយបាទ។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់មិនមានប្រសិទ្ធភាព។ អ្នកជំនាញឆ្លើយតបទៅនឹងសំណួរជាក់លាក់របស់មេធាវីការពារក្តី!

[១៦:២០:១០]

**លោក ហ្វីលីព ស្សូត៖**

**ឆ៖** នៅពេលនោះ គាត់គឺជាអង្គរក្ស។ "ជាអ្នកការពារ" ខ្ញុំគិតថាក្នុងករណី ភី ភួន នេះ ប្រហែលមិនមែនជាការអធិប្បាយគ្រប់គ្រាន់ទេ។ ប៉ុន្តែគាត់ជាឋានៈមួយទៀត ហៅថា "*អែត ដឺ ក័រ*" គឺជាជំនួយការផ្ទាល់ដែលក្នុងឋានៈជាតួនាទីជាទូទៅដូចថាជាអ្នកជួយ ដូចជាលេខា ដូចជាស្មៀនរបស់លោក ប៉ុល ពត អ៊ីចឹងដែរបាទ។

**ស៖** បាទសូមអរគុណ។ ខ្ញុំសូមសួរបន្ថែមថាលោកបានបញ្ជាក់អំពីចំនួនអ្នកចូលរួមប្រជុំនៅពេលនោះទេ?

**ឆ៖** បាទ ខ្ញុំគិតថាខ្ញុំបានការចង្អុលបង្ហាញថា មានអ្នកណាចូលរួមនៅក្នុងសៀវភៅរបស់ខ្ញុំនោះរួចហើយបាទ។

**ស៖** បាទសូមអរគុណ។ ខ្ញុំសូមសួរទៅលើចំណុចថ្មីមួយទៀត ទាក់ទងទៅនឹងចម្លើយរបស់លោកដែលបញ្ជាក់អំពីស្ថាប័នរបស់រដ្ឋាភិបាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានក្រសួងនានាហ្នឹងលោកបញ្ជាក់ថា ជាស្ថាប័នដែលបង្កើតឡើងគ្មានអំណាចពិតប្រាកដ។ ខ្ញុំចង់សួរលោកថា តើមានក្រសួងទាំងអស់ដែលមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងមិនមានអំណាចទាល់តែសោះ ឬមួយក៏មានក្រសួងណាមានអំណាច ហើយក្រសួងណាមិនមានអំណាចពិតប្រាកដ?

[១៦:២២:១៦]

**ឆ៖** គឺមានក្រសួងមួយចំនួនដែលមានអំណាច។ យើងត្រូវបែងចែករវាងសម័យកាលមុនឆ្នាំ ១៩៧៥ នៅពេលដែលថាមិនទាន់មានក្រសួង គឺគេគ្រាន់តែដាក់ឈ្មោះទេដែលទាក់ទងទៅនឹង គឺថាមិនមានស្ថាប័នអ្វីពិតប្រាកដ។ ប៉ុន្តែក្រោយឆ្នាំ១៩៧៥ ជាពិសេសឆ្នាំ១៩៧៦នេះ នៅពេលដែលគេបង្កើតក្រសួងនានាជាអង្គការធ្វើការត្រឹមត្រូវហ្នឹង គឺក្រសួងការពារជាតិ ក្រសួងការបរទេស ដែលជាក្រសួងសំខាន់ជាងគេ។ ក្រសួងសង្គមកិច្ច ដែលគេមើលឃើញច្បាស់ គឺតាមប្រភពដែលខ្ញុំពិភាក្សាដែល អៀង ធីរិទ្ធ គាត់គ្រប់គ្រងនោះ គឺថាមានបុគ្គលិកមួយចំនួនច្រើន។ ប៉ុន្តែក្រសួងទាំងអស់នេះ គឺមិនជាអ្នកធ្វើគោលនយោបាយទេ គោលនយោបាយត្រូវអនុម័តដោយបក្ស។ វាខុសពីប្រព័ន្ធផ្សេងទៀតដែលក្រសួងតែងតែចូលរួមកិច្ចប្រជុំគណៈរដ្ឋមន្ត្រី។ ការងារនោះមិនកើតឡើងទេនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺថាមិនមានប្រព័ន្ធនៃការប្រជុំគណៈរដ្ឋមន្ត្រីទៀងទាត់ ដែលរដ្ឋមន្ត្រីទាំងនោះទៅចូលរួមទេ។

[១៦:២៣:៣៤]

**ស៖** បាទសូមអរគុណ។ មុននេះលោកបានមានប្រសាសន៍អំពីតួនាទីរបស់លោក ខៀវ សំផន ថាជាប្រធានគណៈប្រធានរដ្ឋ។ ខ្ញុំចង់សួរថា តើការិយាល័យរបស់លោក ខៀវ សំផន នេះជាស្ថាប័នដែលមានអំណាចប្រតិបត្តិការយ៉ាងដូចម្ដេចដែរក្នុងសម័យនោះ?

**ឆ៖** លោកយោងទៅរកជារដ្ឋមួយ ឬក៏ក្នុងលក្ខណៈអ្វី?

**ស៖** ខ្ញុំចង់សួរលោកពីភាពជាក់ស្ដែងនៃតំណែងរបស់លោក ខៀវ សំផន ក្នុងនាមជាប្រធានគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ដើម្បីប្រើពាក្យថាជាតួអង្គមួយ ក្នុងគំនិតនេះគឺថាអាចថាដូចខ្ចីពេក ប៉ុន្តែដែលហៅថាប្រមុខរដ្ឋ ឬក៏ប្រធានគណៈប្រធានរដ្ឋ ថាមិនមានអំណាចអ្វីសោះ ប៉ុន្តែលេខាបក្សបានចាត់តាំងឲ្យធ្វើការងារនោះ ប៉ុន្តែដូចរដ្ឋាភិបាលដែលថាគេមានប្រមុខរដ្ឋ មិនមានអំណាចស្វ័យភាពដោយខ្លួនឯងទេគឺថាអំណាចទាំងអស់គឺកាន់កាប់ដោយបក្ស។ សួរថាតើក្នុងឋានៈជាប្រមុខរដ្ឋនោះ មានៗអំណាចធ្វើសេចក្ដីសម្រេចដែរអត់? ចម្លើយនោះច្បាស់ហើយ ក្នុងកម្ពុជាប្រជាធិបតេយ្យ គាត់មិនមានអំណាចនោះទេ ធ្វើសេចក្ដីសម្រេចនោះ។

[១៦:២៥:៣១]

**ស៖** បាទ សូមអរគុណ។ កាលពីថ្ងៃទី០៧ ខែឧសភា នៅវេលាម៉ោង១៥:០៧:៥៦ លោកបាននៅពេលដែលតំណាងសហព្រះរាជអាជ្ញាសួរអំពីការដកខ្លួនចេញរបស់លោក ខៀវ សំផន អំពីសេចក្ដីការធ្វើសេចក្ដីនានា ហើយលោកបានឆ្លើយថា "លោក ខៀវ សំផន មិនដែលបានដកខ្លួនចេញពីការធ្វើសេចក្ដីសម្រេចណាមួយទេ"។ លោកចាំចំណុចនេះទេ?

**ឆ៖** សូមអភ័យទោស ខ្ញុំដូចជាស្ដាប់សំណួររបស់លោក ថាតើគាត់មិនបានដកខ្លួនចេញអំពីការដែលធ្វើសេចក្ដីសម្រេចដោយខ្លួនគាត់ ឬក៏ដូចម្ដេច។ សូមសួរ -- លោកសួរម្ដងទៀតឲ្យច្បាស់ជាងនេះ។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមបញ្ជាក់នូវសំណួរបន្ថែម ខ្ញុំសូមអានទាំងស្រុងម្ដង។ នៅក្រោមម៉ោង១៥:០៧:៥៦, សំណួរសួរថា៖ "ខ្ញុំមានសំណួរមួយទាក់ទងទៅនឹងលោក ខៀវ សំផន ដោយផ្ទាល់។ នៅក្នុងការស្រាវជ្រាវរបស់លោក តើលោកធ្លាប់ជួបប្រទះនូវភស្តុតាងណាមួយដែលបង្ហាញថាគាត់ធ្លាប់មានការខ្វែងយោបល់ ឬធ្លាប់មានការមិនឯកភាព ការដកខ្លួនចេញពីការសម្រេចណាមួយដែរទេ? នៅពេលនោះ លោកឆ្លើយថា៖ អត់ទេ។ អត់មានទេ អត់ដែលមានទេ។ ហើយខ្ញុំប្រាកដថា គាត់មិនដែលដកខ្លួនចេញ ឬក៏មិនដែលខ្វែងយោបល់ជាមួយនឹងអ្នកណាម្នាក់ដែរ -- ម្នាក់ទេ ម្នាក់នោះទេ។

នៅក្នុងការធ្វើសេចក្ដីសម្រេច ក៏ដូចជាការទាក់ទងគ្នា"។ លោកចាំសម្ដីនេះទេ?

[១៦:២៧:៣៨]

បាទ សូមអរគុណ។ ខ្ញុំសូមសួរទាក់ទនងនឹងចំណុចនេះថា តើលោកបានដឹងពីបញ្ហាអ្វីខ្លះដែល លោក ខៀវ សំផន ចូលរួមធ្វើសេចក្ដីសម្រេចជាមួយនឹងស្ថាប័នណាមួយ ឬមួយក៏ធ្វើសេចក្ដីសម្រេច និងដោយរូបលោកផ្ទាល់នោះ? សូមលោកជួយបញ្ជាក់។

**ឆ៖** នោះវាអាស្រ័យទៅលើការប្រើពាក្យរបស់លោកថា ដែលថាពាក្យនោះវាវិវត្តន៍។ ដូចខ្ញុំ និយាយហើយថា គាត់វត្តមាននៅកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ គាត់ជាសមាជិក អ្នកខ្លះនិយាយថា តំណែង សំខាន់ ហើយអ្នកខ្លះគេថាគណៈនេះគ្រាន់តែបញ្ជូននូវសេចក្ដីសម្រេចទេ។ ហើយគាត់ជាភាគីមួយនៃ សេចក្ដីសម្រេច ទោះបីជាគាត់មិនបានជាអ្នកធ្វើទេ គឺដែលថាគាត់មិនដែលជំទាស់ទេ ដែលខ្ញុំយល់ហើយ ថាគាត់ពិបាកនឹងជំទាស់ណាស់ បើជំទាស់អាចប្រឈមនឹងគ្រោះថ្នាក់។ ហើយៗគេគ្របដណ្ដប់ថាសេចក្ដី សម្រេចទាំងអស់នោះធ្វើឡើងដោយបក្សកុម្មុយនីស្តកម្ពុជា។ នៅតាមន័យនោះ គាត់ជាភាគ ជាសមាជិក មួយនៅក្នុងនោះ ហើយគាត់មិនដែលបានខ្វែងមតិជាមួយសេចក្ដីសម្រេចនោះទាំងអស់នោះទេ។

[១៦:២៩:១២]

**ស៖** បាទ ខ្ញុំអាចបញ្ជាក់សាឡើងវិញបានទេថា អ្វីដែលលោកមានប្រសាសន៍អម្បាញ់មិញនេះ គឺលោកពុំមានឯកសារណាជាក់លាក់ដែលបង្ហាញថាលោក ខៀវ សំផន បានចូលរួមធ្វើសេចក្ដីសម្រេច ឧទាហរណ៍ដូចជាមានហត្ថលេខារបស់លោក ខៀវ សំផន សម្រេចទៅលើគោលនយោបាយណាមួយ របស់កម្ពុជាប្រជាធិបតេយ្យនោះទេ។ តើខ្ញុំនិយាយអ៊ីចឹងបានទេ?

**ឆ៖** មានឯកសារជាច្រើនដែលបង្ហាញថាគាត់ជាសមាជិក ឬក៏ភាគីដែលធ្វើចូលរួមក្នុងការធ្វើ សេចក្ដីសម្រេចនោះ។ ខ្ញុំមិនឃើញមានឯកសារណាថា គាត់ដើរតួជាសេចក្ដីសម្រេចដាច់ខាតក្នុងការ ពិភាក្សាពីគោលនយោបាយក្នុងសេចក្ដីសម្រេចនោះទេ។ ប៉ុន្តែខ្ញុំគិតថា នេះគឺជាបញ្ហាបច្ចេកទេសមួយ ប្រសិនបើលោកជាផ្នែកមួយនៅក្នុងសេចក្ដីសម្រេចនោះ មានន័យថា លោកយល់ស្របជាមួយសេចក្ដី សម្រេចនោះដែលលោកទទួលស្គាល់ថា មាគ៌ាបក្សថាមានអ៊ីចឹង ទោះបីជាថាលោកខ្លួនឯងមិនបានចូល រួមក្នុងការជាមតិក្នុងការធ្វើសេចក្ដីសម្រេចនោះក៏ដោយ។

[១៦:៣០:២៨]

**ស៖** បាទ សូមអរគុណ។ ដោយសារពេលវេលាខ្ញុំសូមចូលទៅប្រធានបទចុងក្រោយរបស់ខ្ញុំ

មួយទាក់ទងនឹងឯកសារ E3/232។ លោកប្រធានខ្ញុំសូមអនុញ្ញាតជូនឯកសារនេះទៅអ្នកជំនាញ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលសូមយកឯកសារពីមេធាវីយកជូនអ្នកជំនាញពិនិត្យ!

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំសូមជម្រាបលោកថា ឯកសារនេះបានពិភាក្សាជាច្រើនរួចមកហើយ។ ហើយខ្ញុំនឹងមានសំណួរមួយចំនួនទៀតទាក់ទងនឹងឯកសារនេះ។ ប្រធានបទនៃឯកសារនេះគឺជាកំណត់ហេតុនៃអង្គប្រជុំការងារមូលដ្ឋានថ្ងៃ០៨ មីនា ១៩៧៦ ដែលមានពីរចំណុចក្នុងរបៀបវារៈគឺបញ្ហាបោះឆ្នោតថ្ងៃទី២០ ខែ៣, ៧៦ និងសភាពការណ៍នៅឧត្តរ ១០៦ និង១០៣។ ខ្ញុំសូមឲ្យលោកពិនិត្យទៅលើឯកសារនេះជាមួយខ្ញុំទៅលើចំណុចទី១ ដែលនិយាយអំពីសេចក្តីរាយការណ៍របស់សមមិត្តហែម។ លោកបានឆ្លើយហើយថា លោក ហែមគឺ លោក ខៀវ សំផន។ នៅក្នុងនេះយើងឃើញមានគ្រែចំនួនប្រាំ ដែលនិយាយអំពីគោលការណ៍នៃការបោះឆ្នោតថ្ងៃទី២០ ខែ៣, ៧៦ និងគ្រែមួយទៀត សំណូមពរនៃការបោះឆ្នោតនិងបន្តមកទៀត វិធីបោះឆ្នោត។ បន្ទាប់ទៀតលក្ខណៈផ្សេងៗដើម្បីឈរឈ្មោះជាតំណាង និងគ្រែចុងក្រោយវិធីអប់រំនិងឃោសនា។ ក្នុងប្រាំចំណុចនេះតើលោកបានពិភាក្សា ឬក៏ស្រាវជ្រាវលម្អិតទៅលើខ្លឹមសារដែលនៅក្នុងកំណត់ហេតុនេះថាជាសេចក្តីរាយការណ៍របស់លោក ខៀវ សំផន ទេ។ ឧទាហរណ៍គោលការណ៍នេះការបោះឆ្នោតថ្ងៃទី២០ ខែ៣, ៧៦ នេះសួរថាតើគោលការណ៍អ្វីដែលលោកខៀវ សំផនបានស្នើ ឬក៏បានរាយការណ៍ជូននៅពេលនោះដែរទេ?

[១៦:៣២:៥០]

**លោក ហ្វីលីព ស្សត៖**

**ឆ៖** តើលោកសួរថាតើខ្ញុំច្បាស់ថាសមមិត្តហែម – ជា ខៀវ សំផន? តើសួរខ្ញុំថាតើ ខ្ញុំប្រាកដថាអ្វីៗទាំងអស់នេះពិតជាបានគេផ្ទុះបញ្ចាំងលើកឡើងនៅក្នុងអង្គប្រជុំឬ លោកចង់សួរខ្ញុំអ៊ីចឹងឬក៏ដូចម្តេច?

**ស៖** សុំទោសខ្ញុំអត់បានសួរលោកអ៊ីចឹងទេ ខ្ញុំទទួលស្គាល់ហើយ ទៅតាមចម្លើយរបស់លោកកន្លងមកនេះថា ឈ្មោះហែម ហ្នឹងគឺជា ខៀវ សំផន។ ប៉ុន្តែអ្វីដែលខ្ញុំចង់សួរបញ្ជាក់លោកនោះគឺថា ចង់បញ្ជាក់អំពីខ្លឹមសារដែលជាសេចក្តីរាយការណ៍របស់ មិត្តហែម នេះមានក្នុងគ្រែទាំងប្រាំ។ ក៏ប៉ុន្តែខ្ញុំសូមលើកឧទាហរណ៍តែចំណុចមួយទេ ឧទាហរណ៍គោលការណ៍នៃការបោះឆ្នោតថ្ងៃទី២០ ខែ៣ ឆ្នាំ៧៦ នេះ។ សួរថាតើគោលការណ៍អ្វីដែលលោក ហែម ហ្នឹងបានរាយការណ៍? តើលោកមានបានធ្វើការ

ស្រាវជ្រាវឬក៏ពិភាក្សាលម្អិតអំពីបញ្ហានេះទេ?

[១៦:៣៣:៥៩]

**ឆ៖** ខ្ញុំពិនិត្យផ្ទៀងផ្ទាត់ដូចដែលយើងពិភាក្សាពីដើមហ្នឹង។ ចំណុចសំខាន់ណាស់ដែរថាវាអាចទៅរួចបើមិនមានប្រភពណាមួយដើម្បីផ្ទៀងផ្ទាត់ យើងត្រូវតែទុកចិត្តលើប្រភពដែលយើងមានតែមួយ។ យើងដឹងផងដែរថា ខៀវ សំផន ជាការទទួលខុសត្រូវចំពោះការបោះឆ្នោតមានឯកសារផ្សេងទៀតដែលនិយាយពីរឿងហ្នឹង។ យើងដឹងហើយថា ការបោះឆ្នោតដែលបានកើតឡើង គឺមានការប្រកាសតាមវិទ្យុភ្នំពេញខ្មែរក្រហម ហើយនិងវាអាចជារឿងធម្មតាដែលថា ខៀវ សំផន ជាអ្នកទទួលខុសត្រូវ ចំពោះដោយសារតែគាត់ទទួលខុសត្រូវទំនាក់ទំនងជាមួយសម្តេច សីហនុ អំពីការងាររណសិរ្ស។ ហើយការបោះឆ្នោតនោះគឺជាផ្នែក ដែលខ្ញុំអាចនិយាយបានថាជាផ្នែកមួយនៃជាមុខមាត់ឱ្យគេទទួលស្គាល់អំពីការបង្កើតកម្ពុជាប្រជាធិបតេយ្យដើម្បីឱ្យអ្នកខាងក្រៅយល់ថា នេះជាស្ថាប័នធម្មតាដែលជាទូទៅកើតមាននៅក្នុងគ្រប់រដ្ឋៗ ដែលថាៗមានសភាតំណាងប្រជាជននោះបានប្រជុំ ហើយតែម្តងតែប៉ុណ្ណោះក៏ជាមុខមាត់ដែលបង្ហាញថាឱ្យគេឃើញថាមានរដ្ឋសភានោះ។

[១៦:៣៥:៣៣]

**ស៖** បាទ សូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ សូមលោកពិនិត្យតទៅទៀតទាក់ទងទៅនឹងចំណុចទី២, “មតិបញ្ជាក់បន្ថែមរបស់អង្គការ”។ ខ្ញុំសូមឱ្យលោកជួយពន្យល់ចំពោះពាក្យថា “អង្គការនៅទីនេះ” សំដៅទៅលើអ្នកណា?

**ឆ៖** គឺបក្សកុម្មុនីស្តកម្ពុជា។ អង្គការ គឺជាពាក្យមួយមួយទៀតដែលគេហៅនិយាយសំដៅដល់បក្សកុម្មុយនីស្តកម្ពុជានោះឯង។

**ស៖** បាទ សូមអរគុណ។ លោកបញ្ជាក់អម្បាញ់មិញថាបក្សកុម្មុយនីស្តកម្ពុជា។ តើនៅក្នុងទីនេះបក្សកុម្មុយនីស្តកម្ពុជាអ្នកនិយាយ ឬក៏បុគ្គលអ្នកនិយាយ?

**លោក អាប់ឌុលឡាក់ ថារីក៖**

សំណួរនាំមុខ ហើយសំណួរច្រំដែល គាត់សួរសំណួរ។ អ្នកជំនាញឆ្លើយហើយគាត់មិនចូលចិត្តគាត់សួរសំណួរមួយទៀត ហើយគាត់ធ្វើសេចក្តីសន្និដ្ឋានដាក់ទៅឱ្យអ្នកជំនាញឆ្លើយ។ ដូច្នេះយើងខ្ញុំសូមជំទាស់លោកប្រធាន។

**លោក គង់ សំអុន៖**

ចំណុចនេះមិនមែនជាសំណួរនាំមុខទេ ដោយសារខ្ញុំដកស្រង់ចេញពីឯកសារ។ ឯកសារបញ្ជាក់នៅចំណុចទី២ នេះថា "មតិបន្ថែមរបស់អង្គការ"។ អ៊ីចឹងចំណុចនេះវាច្បាស់ណាស់ការដែលអ្នកជំនាញឆ្លើយ ហើយខ្ញុំសួរបន្ថែមនេះ គឺដើម្បីបញ្ជាក់ឲ្យច្បាស់បាទ។ អ៊ីចឹងសូមអនុញ្ញាតឲ្យអ្នកជំនាញឆ្លើយលោកប្រធាន។

[១៦:៣៧:២៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:៣៧:៤៤]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់ សំអាងហេតុនៃសេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញានៅសំណួរចុងក្រោយរបស់មេធាវីការពារក្ដី គឺត្រឹមត្រូវ។ ដូច្នេះសេចក្ដីជំទាស់មានប្រសិទ្ធភាព អ្នកជំនាញមិនបាច់ឆ្លើយតបទៅនឹងសំណួរចុងក្រោយនេះទេ។

លោកមេធាវីទំនងជាអស់ម៉ោងហើយ លើសម៉ោងរហូតដល់១០នាទីហើយ។

**លោក គង់ សំអុន៖**

លោកប្រធានអាចសុំពីរបីនាទីទៀតបានទេ?

**ប្រធានអង្គជំនុំ៖**

ត្រូវការប៉ុន្មានសំណួរទៀត ព្រោះ ឌីវីឌី ជិតអស់ផងដែរ។ អញ្ជើញ បីនាទីណា៎! ទំនងជាមួយសំណួរទេណា៎!

**សួរដោយលោក គង់ សំអុន៖**

បាទ សូមអរគុណ។

**ស៖** សូមលោក ស្បូត ពិនិត្យទៅលើខ្លឹមសារនៅក្នុងមតិបញ្ជាក់បន្ថែមរបស់អង្គការក្នុងចំណុចទី២ នេះ។ នៅក្នុងខ្លឹមសារនេះមានចំណុច (ក), (ខ), (គ) រហូតទៅដល់ចំណុច (ឃ) ទៀត។ ខ្ញុំចង់សួរថាតើលោកបានពិនិត្យទៅលើខ្លឹមសារនេះពីមុនមកទេ?

**លោក ហ្វីលីព ស្បូត៖**

**ឆ៖** បាទ ខ្ញុំមាន។

**សៈ** ខ្ញុំចង់សួរបន្តទៀតថា តើខ្លឹមសារដែលមាននៅក្នុងទាំងបួនចំណុច (ក), (ខ), (គ), (ឃ) នេះជាខ្លឹមសារប្រភេទដូចម្ដេច?

**ឆៈ** និយាយដោយសង្ខេបនេះ គឺថាគាត់និយាយថា “គាត់ (នៅក្នុងករណីនេះ គឺ ប៉ុល ពត) ជាអ្នកនិយាយអំពីអង្គការហ្នឹង”។ ប៉ុន្តែគឺថាពិភពលោកកំពុងមើល ហើយនិងរង់ចាំយើងដែលគេនិយាយថា គេចង់ឲ្យពិភពលោកដឹងថា យើងមិនមែនជាមនុស្សមកពីព្រៃ ហើយគ្មានរបៀបរបបអីទេ កុំឲ្យយើងមើលឃើញថា យើងបោកបញ្ឆោត ហើយកុំឲ្យគេយល់ថាសភារបស់យើងគ្មានប្រយោជន៍។ អាហ្នឹងគឺជាការពិតដែលគាត់និយាយបែបនោះឯង។ ហើយសួរថា តើគោលបំណងនៃសភាតំណាងប្រជាជននោះគឺថាធ្វើឲ្យពិភពលោកចាប់អារម្មណ៍ ដែលថារដ្ឋកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺគេមានបំណងអីចឹងច្បាស់អីចឹងមែន គេចង់បានអីចឹង។

[១៦:៤០:៥៥]

**សៈ** បាទ សូមអរគុណ។ ខ្ញុំចង់ឲ្យលោកពិនិត្យដោយប្រៀបធៀបទៅលើខ្លឹមសារនៃ “សេចក្ដីរាយការណ៍ជូនមូលដ្ឋានពីសមមិត្ត ហែម” ហើយនិងចំណុចទីពីរ “មតិបញ្ជាក់បន្ថែមរបស់អង្គការ” នេះ។ ថាតើវាមានភាពខុសគ្នាយ៉ាងដូចម្ដេចទៅលើខ្លឹមសារជាសារធាតុនៃការបោះឆ្នោតសម្រាប់ថ្ងៃទី២០ ខែ៣ ឆ្នាំ៧៦ -- ១៩៧៦ នោះ?

**ឆៈ** យើងបាននិយាយអំពីការមានគិញ ឬក៏ថារកិច្ចនៅតាមព្រំដែនថៃ។ ខ្ញុំមិនទាញសេចក្ដីមួយជាក់លាក់នោះទេ គឺរបាយការណ៍នេះនិយាយអំពីសមមិត្ត ហែម ហ្នឹង ធ្វើរបាយការណ៍ទាក់ទងទៅនឹងស្ថានភាពកសិកម្មនៅក្នុងតំបន់ ហើយបន្ទាប់មកទំនាក់ទំនងជាមួយប្រទេសថៃ។

**សៈ** ប្រៀបធៀបចំពោះខ្លឹមសារនៃសេចក្ដីរាយការណ៍របស់សមមិត្ត ហែម ដែលមានប្រាំចំណុច អម្បាញ់មិញនេះ ជាមួយនឹងខ្លឹមសារដែលជាមតិបន្ថែមរបស់អង្គការ ដែលពីចំណុច(ក) ដល់ចំណុច(ឃ)។

[១៦:៤២:៥៥]

**ឆៈ** ផ្នែកពីរនៃរបាយការណ៍នេះ គឺផ្នែកទីមួយ បាទ និយាយទាំងស្រុងទៅការបោះឆ្នោត។ ហើយបន្ទាប់ -- ផ្នែកមួយទៀត គឺនិយាយអំពីបញ្ហាផ្សេងៗនៅតាមខេត្តនានា ហើយនៅតាមតំបន់។ ហើយខ្ញុំគិតថា ធម្មតានោះគឺជាកិច្ចប្រជុំរបស់គាត់គណៈអចិន្ត្រៃយ៍ គេពិភាក្សាបញ្ហាបែបនេះឯង។ គឺពិតជាមានបែបនេះ។ គេបន្តទាក់ទង -- និយាយអំពីនយោបាយបរទេស។ ខ្ញុំមិនយល់សំណួររបស់លោកឲ្យច្បាស់ ដែលលោកចង់បានមតិខ្ញុំ ចម្លើយខ្ញុំអីទេ ខ្ញុំមិនទាន់ច្បាស់។

**ស៖** សូមអរគុណ។ អ៊ីចឹង ខ្ញុំសូមបញ្ជាក់បន្ថែម ដោយសារប្រហែលជាមានបញ្ហាបកប្រែ។ ព្រោះក្នុងពីរចំណុចអម្បាញ់មិញនេះ ខ្ញុំបានសួរលោកខ្លះៗហើយ ទាក់ទងទៅនឹងចំណុចទី១ជាសេចក្តីរាយការណ៍របស់សមមិត្ត ហែម ដែលមានប្រាំចំណុចតូចៗទៀត។ ហើយចំណុចទី២ ទាក់ទងទៅនឹងមតិបញ្ជាក់បន្ថែមរបស់អង្គការ ព្រោះនៅក្នុងនេះយើងឃើញថា សេចក្តីរាយការណ៍របស់សមមិត្ត ហែម ហ្នឹង មានប្រាំចំណុច ហើយខ្លី ជាត្រួខ្លីៗ។ ក៏ប៉ុន្តែបើយើងក្រឡេកមើលទៅមតិបញ្ជាក់បន្ថែមរបស់អង្គការ គឺមានវែងក្នុងកំណត់ហេតុនេះ គឺមានច្រើន។ ហើយខ្លឹមសារទៀតសោត នៅក្នុងមតិបញ្ជាក់បន្ថែមរបស់អង្គការនេះវាមានលក្ខណៈជាសារធាតុ វាជាក់លាក់។ ក៏ប៉ុន្តែអ្វីដែលជាសេចក្តីរាយការណ៍របស់សមមិត្ត ហែម នោះ វាលក្ខណៈជាទូទៅ គ្រាន់តែជាគោលការណ៍។ ដូចជាគ្រាន់តែជាចំណងជើងនៃបញ្ហាដែលត្រូវយកមកនិយាយចំពោះការបោះឆ្នោត ឥតមានភាពលម្អិតទេ។ អ៊ីចឹងខ្ញុំចង់ឲ្យលោកធ្វើការបញ្ជាក់ពីភាពខុសគ្នារវាងពីរចំណុចនេះ?

[១៦:៤៥:១៣]

**ឆ៖** ឥឡូវខ្ញុំយល់ហើយ ខ្ញុំសូមអភ័យទោសដែលខ្ញុំមិនបានឆ្លើយត្រង់ទៅតាមដែលលោកចង់បាន។ ខ្ញុំគិតថានេះជាលក្ខណៈបែបដែលគេកត់ត្រានៅក្នុងកិច្ចប្រជុំអចិន្ត្រៃយ៍ គឺថាមានរបៀបវារៈចំនួនប្រាំដែលសមមិត្តហែម ត្រូវរាយការណ៍ ប្រហែលគាត់ប្រើពេល២០នាទី ឬក៏កន្លះម៉ោង ខ្ញុំមិនដឹងច្បាស់ទេ។ ប៉ុន្តែគាត់ពិតជាបាន -- បាទ និយាយពីចំណុចប្រាំនេះលម្អិតទៅអង្គប្រជុំ។ ប៉ុន្តែអ្នកកត់ត្រា គឺអ្វីជា -- គេកត់ហ្នឹងគឺកត់មតិយោបល់របស់ ប៉ុល ពត។ អ៊ីចឹងហើយគេបញ្ជាក់ច្បាស់ដោយលម្អិត ពីព្រោះថាមតិរបស់ ប៉ុល ពត ជាការណែនាំ ហើយនិងជាគោលការណ៍ដែលថាត្រូវធ្វើអ្វីដូចជារបៀប បាទរបៀបដែលគេបោះឆ្នោត។ អ៊ីចឹងហើយមតិរបស់ ប៉ុល ពត សំខាន់ជាងមតិរបស់សមមិត្ត ហែម។

[១៦:៤៦:១២]

**ប្រធានអង្គជំនុំ៖**

បានហើយ!

បាទ សូមអរគុណលោកអ្នកជំនាញ ហ្វីលីព ស្សូត។ ការស្តាប់សក្ខីកម្មរបស់លោកអ្នកជំនាញរហូតដល់ពេលនេះបានចប់ហើយ។ ហើយវត្តមានរបស់លោកអ្នកជំនាញនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ លោកអ្នកជំនាញអាចវិលត្រឡប់ទៅគោលដៅណាដែលលោកមានបំណងចង់ទៅវិញបានហើយ។ អង្គជំនុំជម្រះសូមថ្លែងអំណរគុណចំពោះលោកដែលបានចំណាយពេលដ៏មាន

តម្លៃមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះសាលាដំបូងរយៈពេល៤ថ្ងៃកន្លងមកនេះ ដោយអំណត់អត់ធ្មត់ និងខិតខំប្រឹងប្រែងព្យាយាមឆ្លើយតបទៅនឹងរាល់សំណួរដែលសួរយ៉ាងច្រើនសន្ធឹកសន្ធាប់។

សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានដល់អង្គជំនុំជម្រះក្នុងការពិនិត្យពិចារណាក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ហើយអង្គជំនុំជម្រះក៏សូមថ្លែងអំណរគុណសាជាថ្មីម្តងទៀត និងសូមជូនពរលោកឲ្យមានជួបតែសំណាងល្អ មានសុខភាពល្អ មានសេចក្តីសុខសេចក្តីចម្រើន និងធ្វើដំណើរវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

[១៦:៤៧:១២]

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនអ្នកជំនាញរូបនេះវិលត្រឡប់ទៅកាន់ទីកន្លែងជាគោលដៅ ដែលគាត់មានបំណងទៅ ឬកន្លែងស្នាក់នៅរបស់គាត់វិញចុះ។

សវនាការនៅថ្ងៃនេះដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី២០ ខែឧសភា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃចន្ទ ទី២០ ខែឧសភា ឆ្នាំ២០១៣ ខាងមុខនេះអង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-253 ដែលនឹងសួរដេញដោលសហព្រះរាជអាជ្ញាមុនភាគីដទៃទៀតនៃរឿងក្តី។ សហព្រះរាជអាជ្ញា រួមនឹងសហមេធាវីនាំមុខមានរយៈពេលកន្លះថ្ងៃក្នុងការសួរសាក្សី។ សហមេធាវីការពារក្តីទាំងពីរក្រុមក៏មានរយៈពេលសរុបកន្លះថ្ងៃដែរ ក្នុងការសួរសាក្សីនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងឲ្យនាំខ្លួនពួកគាត់មកចូលរួមនៅក្នុងសវនាការនេះវិញនៅព្រឹកថ្ងៃចន្ទ ទី២០ ខែឧសភា ឆ្នាំ២០១៣ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដោយឡែកលោក នួន ជា ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់រៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់មួយនៅខាងក្រោមសាលសវនាការនេះ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:៤៨ នាទី)*